**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្ដារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | **អង់គ្លេស** |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 15-Jun-2012, 14:03
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ កោសលុប**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ: **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**សេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ស្របតាមវិធាន ៩២ ទាក់ទិននឹងសូចនាអំពីការជឿទុកចិត្ត ចំពោះឯកសារចំនួន៩៧៨ ដែលជាប់ពាក់ព័ន្ធនឹងសាក្សី និងអ្នកជំនាញដែលអាចកោះហៅ សម្រាប់សវនាការបីសប្ដាហ៍ដំបូង**
**ឯកសារសាធារណៈ កោសលុប**

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**
**អង្គជំនុំជម្រះសាលាដំបូង:**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម យូ ឧត្ដារា

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:**

**ចម្លងជូន:**
**ជនជាប់ចោទ:**
នួន ជា
អៀង សារី
ខៀវ សំផន

**មេធាវីការពារក្ដីជនជាប់ចោទ:**
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe

| | |
|---|---|
| ពេជ អង្គ | លោក អាង ឧត្តម |
| Elisabeth SIMONNEAU FORT | លោក Michael G.KARNAVAS |
| | លោក គង់ សំអុន |
| | លោក ArthurVERCKEN |
| | លោក Jacques VERGÈS |

# I. សេចក្តីផ្តើម

១. នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១១ សហព្រះរាជអាជ្ញាបានដាក់*ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងការជំទាស់នឹងបញ្ជីឯកសារសម្រាប់សវនាការវគ្គដំបូង* ("ចម្លើយតបរួម")[1]។ នៅក្នុងចម្លើយតបរួមនេះ សហព្រះរាជអាជ្ញាបានជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូង និងភាគីថា សហព្រះរាជអាជ្ញានឹងដាក់ជូនក្នុងពេលឆាប់ៗខាងមុខនូវសេចក្តីសន្និដ្ឋាននេះ ដោយកំណត់អំពីសូចនានូវភាពជឿទុកចិត្តចំពោះឯកសារផ្សេងៗ ដែលមាននៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាជាប់ពាក់ព័ន្ធទៅនឹងសាក្សី និងអ្នកជំនាញទាំងឡាយដែលនឹងត្រូវកោះហៅ នៅក្នុងអម្លុងពេលបីសប្តាហ៍ដំបូងនៃសវនាការ ("បញ្ជីឯកសារ")[2]។

២. ក្រុមមេធាវីការពារក្តី អៀង សារី និង នួន ជា ទាំងពីក្រុម បានឲ្យដឹងនៅមុនពេលការទទួលយកឯកសារមួយ ដើម្បីបញ្ចូលទៅក្នុងសំណុំរឿង ភាគីដែលសុំផ្តល់ជូនឯកសារគួរបង្ហាញអំពីសូចនានៃភាពជឿទុកចិត្តបាន ឬយថាភូតនៃឯកសារនោះ[3]។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា លក្ខខណ្ឌតម្រូវទូទៅដូច្នេះ នឹងជាការដាក់កម្រិតមួយហួសហេតុ និងលើសពីលក្ខខណ្ឌតម្រូវដែលបានដាក់ចំពោះភាគីក្នុងសំណុំរឿង០០១ ឬក្នុងសាលាក្តីព្រហ្មទណ្ឌអន្តរជាតិនានាយ៉ាងច្រើន។ សហព្រះរាជអាជ្ញារួមបញ្ចូលតាមរយៈសេចក្តីយោងនូវសេចក្តីសន្និដ្ឋាននានាពីមុនរបស់ខ្លួន ចំពោះបទដ្ឋានផ្លូវច្បាប់សម្រាប់ការទទួលយកឯកសារនៅ អ.វ.ត.ក និងក្នុងសាលាក្តីព្រហ្មទណ្ឌអន្តរជាតិដទៃទៀត[4]។ ថ្វីបើមានគោលជំហរយ៉ាងនេះក្តី ដើម្បីជាផលប្រយោជន៍ក្នុងការជំរុញឲ្យមានប្រសិទ្ធភាពចំពោះកិច្ចដំណើរការនីតិវិធី និងដើម្បីជួយដល់អង្គជំនុំជម្រះសាលាដំបូង សហព្រះរាជអាជ្ញាធ្វើ

---

[1] **E131/19** ចម្លើយតបរួម, ១ ធ្នូ ២០១១ (បានជូនដំណឹងនៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១១។ ច្បាប់ចម្លងគ្រាន់ជាការគួរសមមួយច្បាប់ត្រូវបានបញ្ជូនជាភាសាអង់គ្លេស ជូនអង្គជំនុំជម្រះសាលាដំបូង និងភាគីនៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១១)។

[2] **E131/1/4** និង **E131/1/4.1** បញ្ជីឯកសារ, ១ វិច្ឆិកា ២០១១។

[3] សូមអាន **E136/1** ចម្លើយតបរបស់ អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យបង្កើតប្រព័ន្ធមួយមានប្រសិទ្ធិភាពសម្រាប់ទទួលយកភ័ស្តុតាងនៅសវនាការ, ១៨ វិច្ឆិកា ២០១១ ត្រង់កថាខ័ណ្ឌទី៣ក (ដែលសុំឲ្យមាន "គោលការណ៍ណែនាំផ្សេងៗតម្រូវឲ្យគូភាគីចុះបញ្ជីប្រភពឯកសារនិមួយៗ និងរៀបរាប់អំពីសញ្ញាសំគាល់នៃភាពជឿទុកចិត្ត") ។ **E131/1/9** *ការជំទាស់, ការសង្កេត និងការជូនដំណឹង* [*របស់* Nuon Chea's] *ទាក់ទិននឹងឯកសារផ្សេងៗដែលត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង,* ១៤ វិច្ឆិកា ២០១១ ត្រង់កថាខ័ណ្ឌទី១៩ (ដែលជំទាស់នឹង "ឯកសារណាមួយដែលយថាភូតរបស់ឯកសារនោះ មិនត្រូវបានកំណត់ឲ្យបានច្បាស់លាស់ដោយគូភាគីដែលស្វែងរកឲ្យមានការទទួលយកឯកសារនោះ (ឬដោយអង្គជំនុំជម្រះប្រសិនបើភាគីនោះជ្រើសរើសយកការពឹងផ្អែកទៅសម្ភារៈជាឯកសារ *តាមការស្ម័គ្រចិត្តដោយខ្លួនឯង*")។

[4] សូមអានជាទូទៅ **E114/1** "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងការជំទាស់របស់ អៀង សារី ទៅនឹងភាពអាចទទួលយកបាននូវប្រភេទឯកសារមួយចំនួន", ១៦ កញ្ញា ២០១១ ត្រង់កថាខ័ណ្ឌទី៨-១២។ **E131/19** ចម្លើយតបរួម, កំណត់សំគាល់ខាងដើមលេខ១ ត្រង់កថាខ័ណ្ឌទី៥៧-៥៩។

សេចក្តីសន្និដ្ឋាននេះឡើងតាមចិត្តរបស់ខ្លួនផ្ទាល់ ដែលក្នុងនោះសហព្រះរាជអាជ្ញាបានកំណត់នូវសញ្ញាសំគាល់អំពីភាពជឿទុកចិត្តបានចំពោះឯកសារ៩៧៨ ដែលមាននៅក្នុងបញ្ជីឯកសារ។ សហព្រះរាជអាជ្ញាស្នើដល់អង្គជំនុំជម្រះសាលាដំបូង សូមជឿទុកចិត្តចំពោះសញ្ញាសំគាល់ស្តីពីភាពអាចជឿទុកចិត្តបាននេះ នៅពេលពិចារណាលើការជំទាស់របស់មេធាវីការពារក្តីចំពោះឯកសារទាំងនេះ និងបន្ទាប់ពីនេះទៅ សូមឲ្យទទួលយកឯកសារទាំងនេះ។។

៣. គេគ្មានសំណុំនៃ "ស្តូចនា" ដែលបានទទួលស្គាល់ជាទូទៅ សម្រាប់ការកំណត់អំពីភាពជឿទុកចិត្តទៅលើឯកសារណាមួយនោះទេ។ ភាពជឿទុកចិត្តចំពោះឯកសារ ជាទូទៅអាចត្រូវបានគេទាញចេញពីលក្ខណៈខាងក្នុង និង/ឬ ទ្រង់ទ្រាយខាងក្រៅរបស់ឯកសារ។ ផ្អែកតាមទម្លាប់នៃការអនុវត្តនានានៅថ្នាក់ជាតិ និងអន្តរជាតិ សហព្រះរាជអាជ្ញាសូមដាក់ជូនបញ្ជីស្តីពីលក្ខណៈខាងក្នុង និងទ្រង់ទ្រាយខាងក្រៅដែលមានលក្ខណៈមិនទាន់រៀបរាប់អស់នៅឡើយ និងដែលមិនត្រួតគ្នាដែលអាចពាក់ព័ន្ធទៅនឹងការវាយតម្លៃអំពីភាពជឿទុកចិត្តបាន។

*i.* *<u>លក្ខណៈខាងក្នុង</u>*

(ក) ***ចំណុចសម្គាល់ផ្សេងៗ*** - ឯកសារមានហត្ថលេខា ត្រាបោះ ត្រាសម្គាល់ ស្នាមម្រាមដៃ សេចក្តីយោងឯកសារ ឬលេខ/អក្សរសម្ងាត់ ត្រាវាយលើសំបុត្រ ឬចំណុចសម្គាល់ស្រដៀងគ្នាដទៃទៀត។

(ខ) ***ទម្រង់*** - អក្សរសរសេរដោយដៃ ឬប្រភេទអក្សរនៃឯកសារ ស៊ីសង្វាក់គ្នានឹងឯកសារដទៃទៀតដែលមានប្រភេទ ឬទម្រង់ ឬពីប្រភព ឬអ្នកនិពន្ធនោះ។ ទម្រង់រួម ឬទ្រង់ទ្រាយ មានភាពស៊ីសង្វាក់គ្នានឹងឯកសារដទៃទៀតដែលមានប្រភេទ ឬទម្រង់ ឬពីប្រភព ឬអ្នកនិពន្ធ។

(គ) ***ប្រភព/អ្នកនិពន្ធ*** - ឯកសារត្រូវបានបង្កើតឡើងដោយប្រភពផ្លូវការ ឬសាធារណៈ ឬបើមិនដូច្នេះទេ ប្រភព/អ្នកនិពន្ធនោះអាចឲ្យគេស្គាល់អត្តសញ្ញាណបាន។

(ឃ) ***កាលបរិច្ឆេទនៃការបង្កើតឯកសារ*** -ឯកសារត្រូវបានបង្កើតឡើងក្នុងពេលដំណាលគ្នានឹងព្រឹត្តិការណ៍ដែលឯកសារនោះបញ្ជាក់ពីការធ្វើកំណត់ត្រាទុក។

(ង) ***ខ្លឹមសារ*** - ឯកសារប្រើវាក្យសម្ព័ន្ធ ឬវោហាស័ព្ទដែលបានប្រើជាធម្មតាដោយប្រភព ឬអ្នកនិពន្ធ ឬឯកសារនោះមានព័ត៌មាន (អំពីមនុស្ស ទីកន្លែង ព្រឹត្តិការណ៍) ដែលអាចថា មានការយល់ដឹងត្រឹមតែប្រភព ឬអ្នកនិពន្ធ។

(ច) ***គោលបំណង*** - គោលបំណងរបស់ឯកសារ អាចឲ្យគេកំណត់អត្តសញ្ញាណបានយ៉ាងច្បាស់ និងស៊ីសង្វាក់គ្នានឹងគោលនយោបាយ ឬទិសដៅនៃប្រភព ឬអ្នកនិពន្ធដែលគេស្គាល់។

(ឆ) ***ភាពស៊ីសង្វាក់គ្នាខាងក្នុង*** - ព័ត៌មាននៅក្នុងឯកសារមានភាពស៊ីសង្វាក់គ្នាខាងក្នុង ឬស៊ីសង្វាក់ជាមួយនឹងព័ត៌មាននៅក្នុងឯកសារដែលពាក់ព័ន្ធ។

*ii.* *<u>លក្ខណៈខាងក្រៅ</u>*

(ក) ***យថាភូត*** - ឯកសារ (ឬឯកសារដែលមានលក្ខណៈដូចគ្នាជាតួរយ៉ាង ឬស្រដៀងគ្នា) ត្រូវបានបញ្ជាក់អះអាងថាជាឯកសារដើមដោយអ្នកនិពន្ធ ឬដោយសាក្សីម្នាក់ដែលមានចំណេះដឹង ឬដោយសាក្សីជំនាញ។

(ខ) ***អត្តសញ្ញាណកម្ម*** - ឯកសារ (ឬ ឯកសារដែលមានលក្ខណៈដូចគ្នា ឬស្រដៀងគ្នា) ដែលបានពិនិត្យឡើងវិញដោយអ្នកនិពន្ធ ដោយសាក្សីដែលមានចំណេះដឹង ឬដោយសាក្សីជំនាញ ហើយបុគ្គលនោះមិនបានធ្វើការតវ៉ាណាមួយទៅនឹងយថាភូតរបស់វាទេ ដែលនាំឲ្យមានការសន្មតចំពោះយថាភូត។

(គ) ***បមាណីកម្ម*** - ព័ត៌មាន (អំពីមនុស្ស ទីកន្លែង ព្រឹត្តិការណ៍) នៅក្នុងឯកសារ គឺស៊ីសង្វាក់គ្នា ឬឆ្លើយតបទៅនឹងព័ត៌មាន ដែលបានកត់ត្រាទុកនៅក្នុងឯកសារដទៃទៀត។

(ឃ) ***ការរកឃើញ*** - ទីកន្លែងនៃការរកឃើញឯកសារត្រូវបានគេស្គាល់ ហើយទីកន្លែងនៃការរកឃើញនេះ ត្រៀមរួចជាស្រេចដែលអាចពន្យល់បាន (ឧទាហរណ៍ វាជាទីកន្លែងមួយដែលគេតែងរក្សាទុកឯកសារនោះ ឬជាទីកន្លែងមួយដែលមានទំនាក់ទំនងយ៉ាងច្បាស់ជាក់ស្តែងទៅនឹងប្រភព អ្នកនិពន្ធ អ្នកទទួល)។

(ង) ***ការថែរក្សាទុក*** - កាលៈទេសៈនៃការឧបត្ថម្ភឯកសារ (ឬសំណៅច្បាប់ដើម) ទៅភាគីដែលស្នើសុំឱ្យផ្ដល់ ត្រូវបានគេស្គាល់។

៤. ភាគច្រើននៃឯកសារចំនួន៩៧៨ដែលនៅក្នុងបញ្ជីឯកសារ គឺជាឯកសារផ្លូវការដែលបង្កើតឡើងនៅក្នុងសហសម័យ ដោយមន្ទីរ ឬដោយអង្គភាពណាមួយ ដែលស្ថិតនៅក្រោមការត្រួតត្រារបស់រដ្ឋាភិបាលនៃកម្ពុជាប្រជាធិបតេយ្យ។ ឯកសារទាំងនេះទទួលបានមកដោយការិយាល័យសហព្រះរាជអាជ្ញា (“OCP”) ឬដោយការិយាល័យសហចៅក្រមស៊ើបអង្កេត (“OCIJ”) នៅក្នុងអម្លុងពេលនៃការស៊ើបអង្កេតបឋម ឬនៃកិច្ចស៊ើបសួរ ត្រូវបានដាក់បញ្ចូលនៅក្នុងសំណុំរឿង។ ឯកសារភាគច្រើននៃឯកសារទាំងនេះ ត្រូវបានប្រមូលចងក្រងដោយការិយាល័យ OCP និងដោយ OCIJ ដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា (“DC-Cam”) ក្នុងអំឡុងពេលស៊ើបសួរបឋម និងស៊ើបសួររបស់តុលាការ[5]។ នៅក្នុងការធ្វើសម្ភាសន៍មួយដែលដឹកនាំដោយ OCP នៅក្នុងអម្លុងពេលនៃការស៊ើបអង្កេតបឋម លោក ឆាំង យុ បានបញ្ជាក់ថា គាត់មាន “ការយល់ដឹងលំអិតនឹងយ៉ាងជ្រាលជ្រៅ” អំពីឯកសារនានាដែលស្ថិតនៅក្នុងកម្រងឯកសាររបស់ DC-Cam និងបានចាត់វិធានការដ៏សមស្រប ក្នុងការបញ្ជាក់យថាភូតិរបស់ឯកសារទាំងនេះ[6]។ នៅក្នុងឈុតនៃការធ្វើសម្ភាសន៍មួយចំនួនថែមទៀត ដែលដឹកនាំធ្វើដោយ OCIJ នៅក្នុងអម្លុងនៃកិច្ចស៊ើបសួរ លោកនាយក ឆាំង យុ បានផ្ដល់នូវព័ត៌មានដ៏មានតម្លៃផ្សេងទៀតដូចជា អំពីប្រភពដើម និងការរកឃើញនៃឯកសារទាំងនេះនៅក្នុងកម្រងឯកសាររបស់ DC-Cam[7]។ ព័ត៌មានបន្ថែមទៀតទាក់ទងអំពីការរៀបចំចងក្រងឯកសាររបស់ DC-Cam គឺមានចែងនៅក្នុងអត្ថបទមួយដែលនិពន្ធដោយ

---

[5] មានឯកសារជាក់លាក់មួយចំនួនត្រូវបានប្រមូលពីមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) ដោយ កសពក្នុងអម្លុងពេលនៃកិច្ចស៊ើបសួរ។ ក្នុងករណីទាំងនេះ ឯកសារដែលបានប្រមូលទាំងនោះសុទ្ធតែជាឯកសារដែលគេអាចរកបានជាសាធារណៈ និងថាបើដូច្នេះ ការប្រមូលឯកសារនេះ មិនមានតម្លៃស្មើនឹងកិច្ចស៊ើបសួរណាមួយទេ។ សូមអានបន្ថែម ឯកសារ D313 សំណើរបស់សហព្រះរាជអាជ្ញា សុំដាក់បញ្ចូលឯកសារភ័ស្តុតាងបន្ថែមទៅក្នុងសំណុំរឿង, ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១។

[6] ឯកសារ **D2-2** កំណត់ហេតុនៃការធ្វើសម្ភាសន៍ លោក ឆាំង យុ (Chhang Youk), ចុះថ្ងៃទី១២ កក្កដា ២០០៧ (ដែលដឹកនាំធ្វើដោយ កសព)។

[7] សូមអាន ឯកសារលេខ **D150** កំណត់ហេតុនៃការធ្វើសម្ភាសន៍ លោក ឆាំង យុ (Chhang Youk), *ចុះថ្ងៃទី១៩ មីនា ២០០៩។* ឯកសារលេខ **D204/2** កំណត់ហេតុនៃការធ្វើសម្ភាសន៍ លោក ឆាំង យុ (Chhang Youk), *ចុះថ្ងៃទី២៨ ឧសភា ២០០៩។* ឯកសារលេខ **D204/3** កំណត់ហេតុនៃការធ្វើសម្ភាសន៍ លោក ឆាំង យុ (Chhang Youk), *ចុះថ្ងៃទី២៤ មិថុនា ២០០៩* ។ ឯកសារលេខ **D204/4** កំណត់ហេតុនៃការធ្វើសម្ភាសន៍ លោក ឆាំង យុ (Chhang Youk), *ចុះថ្ងៃទី១៩ សីហា ២០០៩* ។ ឯកសារលេខ **D311/2** កំណត់ហេតុនៃការធ្វើសម្ភាសន៍ លោក ឆាំង យុ (Chhang Youk), *ចុះថ្ងទី៦ តុលា ២០០៩* ។ ឯកសារលេខ **D311/3** កំណត់ហេតុនៃការធ្វើសម្ភាសន៍ លោក ឆាំង យុ (Chhang Youk), *ចុះថ្ងៃទី៧ ធ្នូ ២០០៩។*

លោក ឆាំង យុ និងទីប្រឹក្សាច្បាប់របស់ DC-Cam គឺលោក John D. Ciorciari ដែលមានចំណងជើងថា ការរៀបចំចងក្រងឯកសារអំពីឧក្រិដ្ឋកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ។ អត្ថបទនោះ អាចឲ្យរកបាននៅក្នុងសំណុំរឿង[8]។

៩. ព័ត៌មានដែលបានផ្តល់ជូនដោយលោក ឆាំង យុ ស្តីពីខ្សែសង្វាក់នៃការគ្រប់គ្រងឯកសារ ដែល Dc-Cam បានទទួលមកពីបណ្ណសារដ្ឋានរបស់ក្រសួងមហាផ្ទៃ និងទួលស្លែង ("TSL") គឺមានផលប្រយោជន៍ ជាពិសេស ព្រោះឯកសារភាគច្រើននៅក្នុងបញ្ជីឯកសារ គឺទទួលបានមកពីប្រភពណាមួយក្នុងចំណោមប្រភពទាំងពីរនេះ។ រីឯឯកសារដែលទទួលបានមកពីក្រសួងមហាផ្ទៃ លោក ឆាំង យុ បានផ្តល់សក្ខីកម្មថា ឯកសារទាំងនេះ កាលពីដំបូងបង្អស់ ត្រូវបានវៀតណាមរកឃើញក្នុងឆ្នាំ១៩៧៩ នៅក្នុងផ្ទះមួយនៅតាមបណ្តោយវិថីលេខ២៤០ ក្នុងក្រុងភ្នំពេញដែលគេជឿថា ជាផ្ទះដែលសុន សេន ធ្លាប់បានរស់នៅទីនេះ។ បន្ថែមពីលើនេះ គាត់បានបញ្ជាក់ទៀតថា DC-Cam បានរក្សាទុកនូវច្បាប់ដើមនៃរាល់ឯកសារទាំងអស់នេះ[9]។ ចំណែកឯកម្រងឯកសាររបស់ TSL វិញ ក្នុងអត្ថបទរបស់លោក ឆាំង យុ និងលោក John D. Ciorciari បានបញ្ជាក់ថា ឯកសារទាំងនេះត្រូវបានលោក ប៉ែន អេង (Penn Eng) រកឃើញនៅមន្ទីរស-២១ ក្នុងឆ្នាំ១៩៧៩។ បន្ទាប់ពីការរកឃើញមក ឯកសារទាំងនេះស្ថិតនៅក្នុងការគ្រប់គ្រងថែរក្សារបស់ ប៉ែន អេង រហូតដល់ឆ្នាំ១៩៨០។ នៅចន្លោះឆ្នាំ១៩៨០ និងឆ្នាំ១៩៨៤ ឈ្មោះ អ៊ុំង ប៉ិច (Ien Pech) គឺជាអ្នកទទួលខុសត្រូវលើកម្រងឯកសាររបស់ TSL។ នៅចន្លោះឆ្នាំ១៩៨៤ និងឆ្នាំ១៩៨៦ លី ហ៊ាង (Ly Heang) បានកាន់កាប់ឯកសារទាំងនេះ។ ចាប់តាំងពីឆ្នាំ១៩៨៦មក ឈ្មោះ ជ័យ សុភារ៉ា (Chey Sopheara) បច្ចុប្បន្ន ជានាយកនៃសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង បានគ្រប់គ្រង និងការពារកម្រងឯកសារទាំងនេះ[10]។

## II. សូចនាអំពីភាពជឿទុកចិត្តបាន

[8] ឯកសារលេខ **D155.3** *ការរៀបចំចងក្រងឯកសារអំពីឧក្រិដ្ឋកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ (Documenting the Crimes of Democratic Kampuchea)*, លោក John D. Ciorciari និងលោក ឆាំង យុ, ចុះថ្ងៃទី២៤ មីនា ២០០៩។

[9] ឯកសារលេខ **D204/4** កំណត់ហេតុនៃការធ្វើសម្ភាសន៍ លោក ឆាំង យុ, 19 August 2009 p.3 and D311/2 កំណត់ហេតុនៃការធ្វើសម្ភាសន៍ លោក ឆាំង យុ, ចុះថ្ងៃទី៦ តុលា ២០០៩ ទំព័រ៥ ។ សូមអានផងដែរឯកសារលេខ *D155.3 ការរៀបចំចងក្រងឯកសារអំពីឧក្រិដ្ឋកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ*, លោក John D. Ciorciari និងលោក ឆាំង យុ, ចុះថ្ងៃទី២៤ មីនា ២០០៩ ត្រង់ទំព័រ២២៦។

[10] ឯកសារលេខ **D155.3**, *ការរៀបចំចងក្រងឯកសារអំពីឧក្រិដ្ឋកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ*, លោក John D. Ciorciari និង លោក ឆាំង យុ, ចុះថ្ងៃទី២៤ មីនា ២០០៩ ត្រង់ទំព័រ២៣៩។

៦. ឯកសារទាំងឡាយដែលនៅក្នុងបញ្ជីឯកសារ ត្រូវបានដាក់ជាក្រុមចំនួន២៦ប្រភេទនៃឯកសារខុសៗគ្នា។ ឯកសារដែលស្ថិតនៅក្នុងប្រភេទនៃឯកសារនីមួយៗ មានលក្ខណៈជារួមដូចគ្នាមួយចំនួនទាក់ទងនឹងខ្លឹមសារ គំរោង/ទម្រង់ និងប្រភពដើម។ ហេតុដូចនេះ នៅក្នុងការដាក់ជូនឯកសារនេះ សូចនាអំពីភាពអាចឲ្យជឿទុកចិត្តបានត្រូវបានបង្ហាញជូនដោយឯកសារប្រភេទនៃឯកសារ ប្រសើរជាងការបង្ហាញឯកសារមួយៗ។ ក៏ប៉ុន្តែ ការយោងទៅលើឯកសារមួយៗ ដែលត្រូវបានដាក់បញ្ចូលយ៉ាងត្រឹមត្រូវ ដើម្បីបញ្ជាក់អត្តសញ្ញាណថាតើការពោលអះអាង ជាពិសេសណាមួយនោះ មានការពាក់ព័ន្ធទៅនឹងឯកសារណា។ ជាការបន្ថែម គេបានកត់សំគាល់ថា សញ្ញាសំគាល់ដែលបានចែងសម្រាប់ប្រភេទឯកសារនិមួយៗ គឺមានលក្ខណៈជាការបង្ហាញ ហើយគ្មានចេតនាសម្រាប់ជាការបញ្ជាក់ច្បាស់លាស់គ្មានសេសសល់អំពីទ្រង់ទ្រាយលក្ខណៈនៃភាពជឿទុកចិត្តបាន និងយថាភូតនៃឯកសារទាំងនោះឡើយ។ ដោយសារឯកសារទាំងនោះមានចំនួនច្រើនក្នុងបញ្ជីឯកសារ ការធ្វើដូច្នេះនឹងកាន់តែជាបន្ទុកហួសហេតុ ហើយនៅក្នុងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ការសាកល្បងខាងផ្លូវច្បាប់ដែលពាក់ព័ន្ធមិនមែនជាលក្ខខណ្ឌតម្រូវនោះឡើយ សម្រាប់ភាពអាចទទួលយកបាន។ សហព្រះរាជអាជ្ញាសូមរក្សាសិទ្ធិក្នុងការផ្តល់ព័ត៌មានបន្ថែមទាក់ទងនឹងឯកសារជាក់លាក់ណាមួយ ឬប្រភេទឯកសារណាមួយ បើសិនជាព័ត៌មាននោះជាតម្រូវការរបស់អង្គជំនុំជម្រះសាលាដំបូង។

## ១. ចម្លើយរបស់ជនជាប់ចោទ

៧. បញ្ជីឈ្មោះឯកសាររបស់សហព្រះរាជអាជ្ញាមានឯកសារចំនួន៦៨ឯកសារ ដែលត្រូវបានចែកប្រភេទថាជា "ចម្លើយរបស់ជនជាប់ចោទ"[11]។ ឯកសារក្នុងប្រភេទនេះរួមមានចម្លើយ/សេចក្តីថ្លែងការណ៍ទាំងអស់ ក្នុងនោះអាចជាចម្លើយរបស់ជនជាប់ចោទម្នាក់ៗ។ ឯកសារទាំងនេះភាគច្រើនជាប្រតិចារឹក ឬកំណត់ហេតុស្តាប់ចម្លើយ/សេចក្តីថ្លែងការណ៍មុនៗ ក្នុងទម្រង់ជាកិច្ចសម្ភាសន៍សុន្ទរថា និងសេចក្តីថ្លែងការណ៍សាធារណៈ ធ្វើឡើងក្នុងពេលដំណាលគ្នានឹងព្រឹត្តិការណ៍នានាដែលត្រូវបានយកប្រើ ដើម្បីចោទប្រកាន់ជនជាប់ចោទក្នុងដីកាដំណោះស្រាយ។ ឯកសារក្នុងប្រភេទនេះរួមមានផងដែរនូវកំណត់ហេតុសួរចម្លើយជនជាប់ចោទ ដែលធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេតអំឡុងពេលស៊ើបអង្កេត និងកំណត់ហេតុនៃកិច្ចសម្ភាសន៍ផ្សេងទៀត ជាមួយជនជាប់ចោទដែលធ្វើឡើងដោយបុគ្គលមួយចំនួន។

[11] ឯកសារ ១-៦៨ នៅលើបញ្ជីឈ្មោះឯកសារ។

៨. បើពិនិត្យពីទម្រង់វិញ ឯកសារទាំងនោះត្រូវចាត់ជាផ្នែកតូចៗទៀត ដូចជា៖ "របាយការណ៍ពីប្រព័ន្ធផ្សព្វផ្សាយនៃរបបកម្ពុជាប្រជាធិបតេយ្យ", "សេចក្ដីថ្លែងការណ៍សាធារណៈនៃរបបកម្ពុជាប្រជាធិបតេយ្យ (ក្នុងនោះ មានសេចក្ដីថ្លែងការណ៍របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ និងអត្ថបទបោះពុម្ពរបស់រណសិរ្សរួបរួមជាតិកម្ពុជា(FUNK)/ រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា (GRUNK)", "ការប្រាស្រ័យទាក់ទងជាមួយអន្តរជាតិ", "របាយការណ៍ផ្សេងៗពីប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិ" "សេចក្ដីថ្លែងការណ៍" និង"កំណត់ហេតុជាលាយលក្ខណ៍អក្សរ"។ ឯកសារនៅក្នុងប្រភេទតូចៗទាំងនេះមានឯកសារជាច្រើនទៀត និងត្រូវលើកមកបង្ហាញដោយឡែកៗពីគ្នានៅផ្នែកក្រោម។ ទម្រង់ និងប្រភេទដែលអាចទុកចិត្តបានលើឯកសារទាំងនេះ រួមទាំងប្រភេទឯកសារនៅខាងក្រោយផង អាចយកទៅប្រើប្រាស់ដូចគ្នាៗនឹងឯកសារទាំងអស់នៅក្នុងប្រភេទតូចៗពាក់ព័ន្ធដែរ។

*របាយការណ៍ពីប្រព័ន្ធផ្សព្វផ្សាយនៃរបបកម្ពុជាប្រជាធិបតេយ្យ*

៩. សេចក្ដីថ្លែងការណ៍មួយរបស់ជនជាប់ចោទ ខៀវ សំផន ត្រូវបានធ្វើឡើងវិញ ក្នុងសេវាផ្សព្វផ្សាយព័ត៌មានបរទេស(*FBIS*)[12]។ ឯកសារនេះមានទម្រង់ផ្នែកខាងក្នុងដូចគ្នានឹងរបាយការណ៍ផ្សេងៗទៀតដែលផ្សាយដោយសេវាផ្សព្វផ្សាយព័ត៌មានបរទេស ហើយប្រភេទឯកសារនេះត្រូវយកមកពិភាក្សាបន្ថែមទៀតនៅផ្នែកទី៩ខាងក្រោម។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលឯកសារនេះពីប្រភពមួយដែលមានសញ្ញាសម្គាល់ថា "LS"[13]។ការិយាល័យសហព្រះរាជអាជ្ញាបានយកឯកសារនេះពីមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយឯកសារនេះត្រូវបានដាក់ចូលក្នុងសំណុំរឿង តាមសំណើរបស់ការិយាល័យសហព្រះរាជអាជ្ញា កាលពីខែធ្នូ ឆ្នាំ២០០៩[14]។ ឯកសារនេះមានបង្ហាញសូចនាអំពីប្រភេទឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា[15] ហើយអក្សរសម្គាល់ "LS" ក្នុងរង្វង់ក្រចកនៅជ្រុងខាងលើផ្នែកខាងស្ដាំ។

---

[12] ឯកសារ D313/1.2.310 (ឯកសារ 12)។

[13] សូមមើលទិន្នន័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅ ៖ http://www.d.dccam.org/Database/Lod/details.php?keyword=D42048&numRecords=100&lang=eng&page=1&idnum=D42048។

[14] សូមមើលឯកសារ D313 សំណើរបស់សហព្រះរាជអាជ្ញា សុំដាក់បញ្ចូលឯកសារភ័ស្តុតាងបន្ថែមទៅក្នុងសំណុំរឿង, ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ នៅត្រង់កថាខណ្ឌ ២៥-២៩។

[15] លេខយោងសរសេរដោយដៃនៅខាងលើជ្រុងខាងស្ដាំ និងផ្ដើមដោយអក្សរ "D"។

## *សេចក្តីថ្លែងការណ៍សាធារណៈនៃរបបកម្ពុជាប្រជាធិបតេយ្យ*

១០. ឯកសារក្នុងប្រភេទនេះគឺជាសេចក្តីថ្លែងការណ៍ចំនួនប្រាំពីរ ក្នុងនោះមានសេចក្តីថ្លែងការណ៍ផ្លូវការដែលបានធ្វើឡើង ក្នុងនាមឲ្យរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ក្នុងអំឡុងពេលពីខែមេសា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩ និងជាលក្ខខណៈបុគ្គល នៅមុនខែមេសា ឆ្នាំ១៩៧៥ និងក្រោយខែមករា ឆ្នាំ១៩៧៩។ សេចក្តីថ្លែងការណ៍មួយក្នុងចំណោមសេចក្តីថ្លែងការណ៍ទាំងនេះ គឺជាសារទូរលេខរបស់ អៀង សារី ផ្ញើជូន សុន សេន[16]។ ឯកសារចំនួនបួនទៀត គឺជាសុន្ទរកថាថ្លែងដោយ អៀង សារី និង ខៀវ សំផន នៅក្នុងព្រឹត្តិការណ៍ផ្លូវការផ្សេងៗពីឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៨[17]។ ឯកសារមួយនៃឯកសារទាំងនេះ គឺជាឯកសារបោះពុម្ពផ្សាយដែលនិពន្ធដោយ អៀង សារី ដែលជាតំណាងរបស់រណសិរ្សរួបរួមជាតិកម្ពុជា[18] និងឯកសារមួយទៀត គឺជារបាយការណ៍ដែលសរសេរដោយ ខៀវ សំផន នៅឆ្នាំ ១៩៨៧ ក្នុងឋានៈគាត់ជាអនុប្រធាននៃរបបកម្ពុជាប្រជាធិបតេយ្យ ទទួលបន្ទុកកិច្ចការបរទេស[19]។

១១. ក្នុងចំណោមឯកសារទាំងអស់ មានតែឯកសារមួយ[20] ប៉ុណ្ណោះដែលជាកំណត់ត្រាធ្វើឡើងស្របពេលនឹងព្រឹត្តិការណ៍ដែលត្រូវកត់ត្រា។ សារទូរលេខដែល អៀង សារី បានផ្ញើទៅ សុន សេន[21] ត្រូវបានកំណត់អត្តសញ្ញាណដោយ ឆាំង យុ ប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងអំឡុងពេលនៃការធ្វើសម្ភាសន៍ជាមួយលោកដែលធ្វើឡើង ដោយការិយាល័យសហចៅក្រមស៊ើបអង្កេតដែលបានបញ្ជាក់ថា មជ្ឈមណ្ឌលឯកសារកម្ពុជាមានច្បាប់ដើមនៃឯកសារនេះ[22]។ ឯកសារនេះត្រូវបានទទួលស្គាល់ជាឯកសារភ័ស្តុតាងក្នុងសំណុំរឿង០០១[23]។

---

[16] IS 21.154 (ឯកសារ 22)។

[17] ឯកសារ D56-Doc. 103 (ឯកសារ 18); D313/1.2.307 (ឯកសារ 9); IS20.25 (ឯកសារ 10); D108/28.243 (ឯកសារ 16)។

[18] ឯកសារ D313/1.2.258 (ឯកសារ 1)។

[19] D84-Annex A-02 (ឯកសារ 32)។

[20] D84-Annex A-02 (ឯកសារ 32)។

[21] IS 21.154 (ឯកសារ 22)។

[22] សូមមើលឯកសារ D311/2 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី, ថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០០៩ នៅត្រង់ទំព័រ ៨។

[23] ឯកសារ E3/803។

១២. ការិយាល័យសហព្រះរាជអាជ្ញាបានទទួលឯកសារទាំងអស់នេះ ពីមជ្ឈមណ្ឌលឯកសារកម្ពុជា។ ឯកសារចំនួនពីរទទួលបានក្នុងអំឡុងពេលនៃការស៊ើបសួរបឋម និងបានប្រើប្រាស់ជាឧបសម្ព័ន្ធភ្ជាប់នឹងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ[24]។ ឯកសារមួយទៀតត្រូវបានដាក់ក្នុងបណ្ដុំឯកសារនៃសំណុំរឿង ០០១ ដោយការិយាល័យសហព្រះរាជអាជ្ញា នៅខែមីនា ឆ្នាំ២០០៨ និងក្រោយមកត្រូវផ្ទេរចូលក្នុងសំណុំរឿងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត[25]។ ឯកសារនៅសល់ចំនួនបួនផ្សេងទៀតត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿងក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរតាមសំណើរបស់ការិយាល័យសហព្រះរាជអាជ្ញា[26]។

## *ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានអន្តរជាតិ*

១៣. សេចក្ដីថ្លែងការណ៍ចំនួន៣១[27]របស់ជនជាប់ចោទ ត្រូវបានផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិមួយចំនួន ដូចជា វិទ្យុអាស៊ីសេរី[28], វិទ្យុសំឡេងសហរដ្ឋអាមេរិក[29], Summary of

---

[24] IS21.154 (ឯកសារ 22); IS 20.25 (ឯកសារ 10)។

[25] សូមមើលឯកសារ D108 ដីការសម្រេច, ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៨។

[26] ឯកសារ D313/1.2.258 (ឯកសារ 1); D313/1.2.307 (ឯកសារ 9); D84-Annex A-02 (ឯកសារ 32); D56-Doc. 103 (ឯកសារ 18)។ សូមមើលឯកសារ D313 សំណើរបស់ព្រះរាជអាជ្ញាសុំដាក់បញ្ចូលឯកសារភ័ស្តុតាងបន្ថែមក្នុងសំណុំរឿង, ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩; ឯកសារ D84 សំណើរបស់សហព្រះរាជអាជ្ញា សុំដាក់ឯកសារពាក់ព័ន្ធនឹង ខៀវ សំផន ចំនួនបីបញ្ចូលក្នុងសំណុំរឿង, ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០០៨ នៅត្រង់កថាខណ្ឌ ៧។ ឯកសារ D56 សំណើរបស់សហព្រះរាជអាជ្ញា ស្ដីពីការសុំដាក់បញ្ចូលឯកសារទៅក្នុងសំណុំរឿង, ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ នៅត្រង់កថាខណ្ឌ ១ និង ឯកសារ D56-Annex A ។

[27] ឯកសារ D297.14 (ឯកសារ 46); D366/7.1.634 (ឯកសារ 7); D297.12 (ឯកសារ 44); D297.9, D297.9.1 (ឯកសារ 60); IS 20.24, D313/1.2.328 (ឯកសារ 13); D366/7.1.273 (ឯកសារ 49); D297.8, D297.8.1 (ឯកសារ 59); IS 20.4 (ឯកសារ 4); D56-Doc. 209 (ឯកសារ 28); D56-Doc. 252 (ឯកសារ 30); D366/7.1.640 (ឯកសារ 15); D297.6, D297.6.1 (ឯកសារ 54); D366/7.1.275 (ឯកសារ 56); D365/1.1.39 (ឯកសារ 8); D56-Doc. 207 (ឯកសារ 27); D297.2, D297.2.1 (ឯកសារ 50); D56-Doc.042 (ឯកសារ 3); D297.15 (ឯកសារ 47); D56-Doc. 137 (ឯកសារ 21); D297.7, D297.7.1 (ឯកសារ 57); D297.10, D297.10.1 (ឯកសារ 61); D297.4, D297.4.1 (ឯកសារ 52); D248/5.1.7 (ឯកសារ 24); IS 20.8 (ឯកសារ 34); D297.13 (ឯកសារ 45); D297.11 (ឯកសារ 43); D29-Attachment 89 (ឯកសារ 40); D199/26.2.97 (ឯកសារ 6); D297.3, D297.3.1 (ឯកសារ 51); D297.5, D297.5.1 (ឯកសារ 53); ERN 00177964-84 ថ្មី (ឯកសារ 41)។

[28] D297.14 (ឯកសារ 46); D297.12 (ឯកសារ 44); D297.15 (ឯកសារ 47); D297.13 (ឯកសារ 45); D297.11 (ឯកសារ 43); ERN 00177964-84 ថ្មី (ឯកសារ 41)។

Worldwide Broadcasts (*SWB*)[30] របស់ BBC, Newsweek[31], New York Times[32] និង Washington Post[33] និងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗទៀត។ ទម្រង់ទូទៅនៃឯកសារបោះពុម្ពផ្សាយមួយចំនួនបានលើកមកពិភាក្សានៅក្នុង "របាយការណ៍ស្តីពីប្រព័ន្ធផ្សព្វផ្សាយនៃរបបកម្ពុជាប្រជាធិបតេយ្យ" ហើយសេចក្តីសង្ខេបរបស់ "របាយការណ៍នានាពីប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិ" មានបង្ហាញនៅក្នុងផ្នែកទី៩ និងទី១៦ ខាងក្រោម។ ឯកសារចំនួន១២[34]ក្នុងចំណោមឯកសារទាំងអស់នេះ ត្រូវបានបោះពុម្ពផ្សាយស្របពេលនឹងព្រឹត្តិការណ៍ដែលឯកសារទាំងនោះត្រូវកត់ត្រា។

១៤. ឯកសារចំនួន១៥[35] នៃឯកសារទាំងនេះ ត្រូវបានទទួលពីប្រភពសាធារណៈ និងត្រូវបានដាក់នៅក្នុងសំណុំរឿងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ។ ការិយាល័យសហព្រះរាជអាជ្ញាបានទទួលឯកសារដទៃទៀត ហើយបានប្រើជាឧបសម្ព័ន្ធភ្ជាប់ជាមួយនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ[36] ឬដាក់បញ្ចូលទៅក្នុងសំណុំរឿងក្នុងអំឡុងពេលនៃកិច្ចស៊ើប

---

[29] D297.9, D297.9.1 (ឯកសារ 60); D297.8, D297.8.1 (ឯកសារ 59); D297.6, D297.6.1 (ឯកសារ 54); D366/7.1.275 (ឯកសារ 56); D297.2, D297.2.1 (ឯកសារ 50); D297.7, D297.7.1 (ឯកសារ 57); D297.10, D297.10.1 (ឯកសារ 61); D297.4, D297.4.1 (ឯកសារ 52); D297.3, D297.3.1 (ឯកសារ 51); D297.5, D297.5.1 (ឯកសារ 53)។

[30] IS 20.24, D313/1.2.328 (ឯកសារ 13)។

[31] D366/7.1.273 (ឯកសារ 49); IS 20.4 (ឯកសារ 4)។

[32] D56-Doc. 209 (ឯកសារ 28); D56-Doc. 252 (ឯកសារ 30); D56-Doc. 207 (ឯកសារ 27)។

[33] D366/7.1.640 (ឯកសារ 15); D365/1.1.39 (ឯកសារ 8)។

[34] D366/7.1.634 (ឯកសារ 7); IS 20.4 (ឯកសារ 4); D56-Doc. 209 (ឯកសារ 28); D56-Doc. 252 (ឯកសារ 30); D366/7.1.640 (ឯកសារ 15); D365/1.1.39 (ឯកសារ 8); D56-Doc. 207 (ឯកសារ 27); D56-Doc.042 (ឯកសារ 3); D56-Doc. 137 (ឯកសារ 21); D248/5.1.7 (ឯកសារ 24); D199/26.2.97 (ឯកសារ 6)។

[35] D297.14 (ឯកសារ 46); D297.12 (ឯកសារ 44); D297.9, D297.9.1 (ឯកសារ 60); D297.8, D297.8.1 (ឯកសារ 59); D297.6, D297.6.1 (ឯកសារ 54); D297.2, D297.2.1 (ឯកសារ 50); D297.15 (ឯកសារ 47); D297.7, D297.7.1 (ឯកសារ 57); D297.10, D297.10.1 (ឯកសារ 61); D297.4, D297.4.1 (ឯកសារ 52); D297.13 (ឯកសារ 45); D297.11 (ឯកសារ 43); D297.3, D297.3.1 (ឯកសារ 51); D297.5.1 (ឯកសារ 53)។ សូមមើល D297 ដីកាសម្រេចទៅលើការដាក់ឯកសារភ័ស្តុតាង, ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០១០។ D199/26.2.97។ សូមមើល D199 ដីកាចាត់ឲ្យស៊ើបសួរជំនួសអន្តរជាតិ។

[36] IS 20.4 (ឯកសារ 4), IS 20.8 (ឯកសារ 34) និង IS 20.24, D313/1.2.328 (ឯកសារ 13)។

សួរតាមសំណើរបស់ការិយាល័យសហព្រះរាជអាជ្ញា[37]។ ក្នុងចំណោមឯកសារដែលការិយាល័យសហព្រះរាជអាជ្ញាប្រមូលបាននោះ មានឯកសារចំនួនប្រាំពីរ[38] ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលពីដំបូងពីកម្រងឯកសារឈ្មោះថា កម្រងឯកសារស៊ុយអែត (Swedish Collection) នៅខែកុម្ភៈ ឆ្នាំ២០០៧[39]។ ឯកសារផ្សេងៗទៀត ត្រូវបានប្រមូលបានពីប្រភពមួយចំនួននៃប្រព័ន្ធផ្សព្វផ្សាយសាធារណៈ។

*ការប្រាស្រ័យទាក់ទងអន្តរជាតិ*

១៥. មានឯកសារស្ដីពី "ការប្រាស្រ័យទាក់ទងជាមួយអន្តរជាតិចំនួន៩" ដែលកត់ត្រាពីសេចក្ដីថ្លែងការណ៍ នានារបស់ជនជាប់ចោទ អៀង សារី និង ខៀវ សំផន។ ឯកសារពីរនៃឯកសារទាំងនេះជាសារទូលេខរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិក ដោយមានការចុះកាលបរិច្ឆេទកាលនៅខែ សីហា និងខែកញ្ញា ឆ្នាំ១៩៧៥[40]។ ឯកសារទាំងនេះត្រូវបានដាក់នៅក្នុងសំណុំរឿង តាមសំណើរបស់ការិយាល័យសហព្រះរាជអាជ្ញា បន្ទាប់ពីបានទទួលពីកម្រងកំណត់ហេតុដែលមានចុះកាលបរិច្ឆេទពីថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៧៣ ដល់ថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៧៥ និងបានចេញផ្សព្វផ្សាយជាសាធារណៈដោយរដ្ឋបាលកំណត់ត្រា និងបណ្ណសារជាតិសហរដ្ឋអាមេរិក[41]។ ឯកសារទាំងនេះមាន

---

[37] D366/7.1.273 (ឯកសារ 49); D366/7.1.275 (ឯកសារ 56)។ សូមមើល D366 សំណើរបស់សហព្រះរាជអាជ្ញាសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង, ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១០ ត្រង់កថាខណ្ឌ៣។ ឯកសារ D29-Attachment 89 (ឯកសារ 40)។ សូមមើល D29 សេចក្ដីជូនដំណឹងអំពីការបង្ហាញឯកសារ និងប្រភពច្បាប់បន្ថែម ដើម្បីគាំទ្រទៅលើទឡ្ហីករណ៍ សម្រាប់ការឃុំខ្លួនជនសង្ស័យជាបណ្ដោះអាសន្ន ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៧។ D366/7.1.634 (ឯកសារ 7); D366/7.1.640 (ឯកសារ 15); D56-Doc. 207 (ឯកសារ 27); D56-Doc.042 (ឯកសារ 3); D56-Doc. 137 (ឯកសារ 21); D248/5.1.7 (ឯកសារ 24); D365/1.1.39 (ឯកសារ 8); D56-Doc. 209 (ឯកសារ 28); D56-Doc. 252 (ឯកសារ 30)។

[38] D56-Doc. 207 (ឯកសារ 27); D56-Doc.042 (ឯកសារ 3); D56-Doc. 137 (ឯកសារ 21)។ សូមមើល **D56** សំណើរបស់ការិយាល័យសហព្រះរាជអាជ្ញាស្ដីពីការសុំដាក់បញ្ចូលឯកសារទៅក្នុងសំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩ ត្រង់កថាខណ្ឌ១ និង D56-Annex A. D248/5.1.7 (ឯកសារ 24)។ សូមមើល **D248** ដីកាចាត់ឲ្យស៊ើបសួរជំនួស សម្រាប់ឯកសារនៅ DC-Cam។ IS 20.24, D313/1.2.328 (ឯកសារ 13); D366/7.1.634 (ឯកសារ 7); D366/7.1.640 (ឯកសារ 15)។

[39] សូមមើល មូលដ្ឋានទិន្នន័យ DC-Cam មាននៅ៖ http://www.d.dccam.org/Database/Lod/index.php

[40] D313/1.2.84 (ឯកសារ 5); D313/1.2.78 (ឯកសារ 2)។

[41] សូមមើល D313 សំណើសុំរបស់សហព្រះរាជអាជ្ញាសុំដាក់ឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង, ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩ ត្រង់កថាខណ្ឌ១១។

ទម្រង់ផ្នែកខាងក្នុងដូចគ្នានឹងសារទូរលេខផ្សេងៗទៀតរបស់សហរដ្ឋអាមេរិក ដែលលើកយកមកពិភាក្សាបន្ថែមទៀតនៅក្នុងសេចក្តីសង្ខេបអំពី "*ការប្រាស្រ័យទាក់ទងអន្តរជាតិ*" នៅក្នុងផ្នែកទី១៥ ខាងក្រោម។

១៦. ឯកសារចំនួនប្រាំពីរ[42] គឺជាកំណត់ត្រានៃសេចក្តីថ្លែងការណ៍ផ្លូវការរបស់ជនជាប់ចោទ អៀង សារី ដែលបានថ្លែងនៅតាមស្ថាប័ននានានៃអង្គការសហប្រជាជាតិ ពីថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៧៦ ដល់ ថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៩។ ឯកសារចំនួនបួនក្នុងចំណោមឯកសារទាំងនេះ គឺជាសុន្ទរកថាដែលបានថ្លែងនៅក្នុងកិច្ចប្រជុំនៃមហាសន្និបាតអង្គការសហប្រជាជាតិ[43]។ ឯកសារចំនួនពីរ គឺជាឯកសារទាក់ទងនឹងការប្រាស្រ័យទាក់ទងទៅកាន់គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ (ស្ថាប័នមួយនៃក្រុមប្រឹក្សាសន្តិសុខ និងសេដ្ឋកិច្ចអង្គការសហប្រជាជាតិ)[44]។ ឯកសារមួយផ្សេងទៀត គឺជាការប្រាស្រ័យទាក់ទងជាមួយនឹងក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ[45]។

១៧. សុន្ទរកថាចំនួនពីរក្នុងចំណោមសុន្ទរកថានៅមហាសន្និបាតអង្គការសហប្រជាជាតិ គឺជាកំណត់ត្រាផ្លូវការរបស់អង្គការសហប្រជាជាតិ និងរៀបចំឡើងតាមទម្រង់នៃកំណត់ត្រាផ្លូវការផ្សេងៗទៀតរបស់ស្ថាប័ននេះ[46]។ ឯកសារទាក់ទងនឹងទំនាក់ទំនងជាមួយគណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ត្រូវបានផលិតឡើងវិញដោយមានដាក់ក្បាលទំព័ររបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសន្តិសុខសហប្រជាជាតិ។ ឯកសារទាំងពីរនេះមានរូបសម្គាល់ (Logo) របស់អង្គការសហប្រជាជាតិ និងមានរចនា និងទម្រង់ដូចគ្នា។ ឯកសារនៅសល់មួយផ្សេងទៀត គឺជាឯកសារផលិតឡើងវិញពីសារទូរលេខ ដោយមានក្បាលទំព័ររបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ។ ឯកសារនេះមានបង្ហាញពីរូបសម្គាល់(Logo)របស់អង្គការសហប្រជាជាតិ និងជាឯកសាររចនាបទរបស់អង្គការសហប្រជាជាតិដោយមានសញ្ញាសម្គាល់យោង។

---

[42] IS 20.1, IS 21.155 (ឯកសារ 23); D366/7.1.820 (ឯកសារ 19); D115/2.2 (ឯកសារ 17); D313/1.2.403 (ឯកសារ 25); D313/1.2.309 (ឯកសារ 11); IS 20.10 (ឯកសារ 14); D115/2.1 (ឯកសារ 20)។

[43] D313/1.2.403 (ឯកសារ 25); D313/1.2.309 (ឯកសារ 11); IS 20.10 (ឯកសារ 14); D115/2.1 (ឯកសារ 20)។

[44] D115/2.2 (ឯកសារ 17); D366/7.1.820 (ឯកសារ 19)។

[45] IS 20.1, IS 21.155 (ឯកសារ 23)។

[46] D115/2.1 (ឯកសារ 20); IS 20.10 (ឯកសារ 14)។

១៨. ការិយាល័យសហចៅក្រមស៊ើបអង្កេតបានទទួលឯកសារចំនួនបីពីប្រភពសាធារណៈ ហើយបានដាក់ឯកសារទាំងនោះនៅក្នុងសំណុំរឿងក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ[47]។ ឯកសារពីរផ្សេងទៀតត្រូវបានដាក់ចូលក្នុងសំណុំរឿងតាមសំណើរបស់ការិយាល័យសហព្រះរាជអាជ្ញាក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ។ ឯកសារមួយក្នុងចំណោមឯកសារទាំងពីរនេះបានទទួលមកពីបណ្ណាល័យអង្គការសហប្រជាជាតិនៅទីក្រុងញូយ៉ក[48] ហើយឯកសារមួយទៀតបានទទួលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជាពីប្រភពឯកសារដែលមានសញ្ញាសម្គាល់ថា "LS" នៅឆ្នាំ ២០០៩[49]។ ការិយាល័យសហព្រះរាជអាជ្ញាបានទទួលឯកសារចំនួនពីរផ្សេងទៀត ក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរបឋម និងបានដាក់ឯកសារទាំងនេះជាឧបសម្ព័ន្ធភ្ជាប់នឹងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ[50]។

១៩. ឯកសារអំពីការប្រាស្រ័យទាក់ទងរបស់ អៀង សារី ជាមួយនឹងក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ[51] ត្រូវបានទទួលស្គាល់ជាភ័ស្តុតាងក្នុងសំណុំរឿង០០១[52]។

*កំណត់ហេតុជាលាយលក្ខណ៍អក្សរ*

២០. មានកំណត់ហេតុនៃការសួរចម្លើយផ្លូវការ[53], កំណត់ហេតុស្តីពីការចូលខ្លួនជាលើកដំបូង[54] និងសវនាការដេញដោល[55] ដែលធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ជាមួយនឹងជន

---

[47] D115/2.2 (ឯកសារ 17); D313/1.2.403 (ឯកសារ 25); D115/2.1 (ឯកសារ 20)។ សូមមើល D115 ដីកាចាត់ឲ្យស៊ើបសួរជំនួសអន្តរជាតិ។

[48] D366/7.1.820 (ឯកសារ 19)។ សូមមើល **D366** សំណើរបស់សហព្រះរាជអាជ្ញាសុំដាក់បញ្ចូល ឯកសារភ័ស្តុតាងបន្ថែមទៅ ក្នុង សំណុំរឿង, ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១០ ត្រង់កថាខណ្ឌ៣។

[49] សូមមើល មូលដ្ឋានទិន្នន័យ DC-Cam មាននៅ: http://www.d.dccam.org/Database/Lod/index.php. D313/1.2.309 (ឯកសារ 11), សូមមើល **D313** សំណើរបស់ព្រះរាជអាជ្ញាសុំដាក់បញ្ចូលឯកសារភ័ស្តុតាងបន្ថែមក្នុងសំណុំរឿង, ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩។

[50] IS 20.1, IS 21.155 (ឯកសារ 23); IS 20.10 (ឯកសារ 14)។

[51] IS 20.1, IS 21.155 (ឯកសារ 23)។

[52] ត្រូវបានទទួលយកជាឯកសារ E3/785។

[53] D286 (ឯកសារ 68); D47 (ឯកសារ 64); D49 (ឯកសារ 65); D46, D46/Corr-1 (ឯកសារ 63); D285 (ឯកសារ 67)។ D286 (ឯកសារ 68) គឺជាកំណត់ហេតុនៃការសួរចម្លើយ អៀង ធីរិទ្ធ។ ទោះបីជាការចោទប្រកាន់ប្រឆាំងនឹង អៀង ធីរិទ្ធ បច្ចុប្បន្នត្រូវបានបំបែកចេញពីសំណុំរឿងលេខ០០២ សហព្រះរាជអាជ្ញានៅតែសំអាងលើឯកសារនេះ ជាភ័ស្តុតាងប្រឆាំងនឹងជនជាប់ចោទ។

ជាប់ចោទចំនួន៨ឯកសារ។ ឯកសារទាំងអស់នេះត្រូវបានរៀបចំឡើង ដោយការិយាល័យសហចៅក្រមស៊ើបអង្កេត និងមានទម្រង់ផ្នែកខាងក្នុងសំខាន់ៗ (ដូចជា ការផ្តិតមេដៃ និង/ហត្ថលេខា ដូចមានចែងក្នុងវិធានផ្ទៃក្នុង និងមានបោះត្រាផ្លូវការរបស់តុលាការ)ដូចគ្នានឹងឯកសារនានាដែលបានលើកយកមកពិភាក្សានៅក្នុងសេចក្តីសង្ខេបនៃ "កំណត់ហេតុជាលាយលក្ខណ៍អក្សរ" នៅក្នុងផ្នែកទី២៦ ខាងក្រោម។

*កំណត់ហេតុនៃការសួរចម្លើយ*

២១. មានឯកសារចំនួន១០ ដែលកត់ត្រាចម្លើយផ្សេងៗរបស់ជនជាប់ចោទ ក្នុងអំឡុងពេលនៃកិច្ចសម្ភាសន៍ដែលធ្វើឡើងដោយបុគ្គលផ្សេងៗ ក្រៅពីការិយាល័យសហចៅក្រមស៊ើបអង្កេត។

២២. ការិយាល័យសហព្រះរាជអាជ្ញាបានទទួលឯកសារចំនួន៦ ក្នុងចំណោមឯកសារទាំងនេះ ក្នុងអំឡុងពេលនៃកិច្ចស៊ើបអង្កេតបឋម និងបានប្រើជាឧបសម្ព័ន្ធភ្ជាប់ជាមួយនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ ក្នុងចំណោមឯកសារទាំងប្រាំមួយនេះ មានឯកសារមួយច្បាប់ជាកំណត់ហេតុនៃកិច្ចសម្ភាសន៍ជាមួយ ខៀវ សំផន ដែលធ្វើឡើងដោយសាលា Oriental និងការសិក្សាអាហ្វ្រិក (SOAS)/អង្គការឃ្លាំមើលសិទ្ធិមនុស្ស (HRW)[56], ឯកសារចំនួនពីរគឺជាកំណត់ហេតុនៃកិច្ចសម្ភាសន៍ជាមួយ អៀង សារី ដែលធ្វើឡើងដោយ Stephen Heder ក្នុងខែធ្នូ ឆ្នាំ១៩៩៦ និងខែមករា ឆ្នាំ១៩៩៩[57] ដែលឯកសារមួយក្នុងចំណោមឯកសារទាំងពីរនេះគឺជាប្រតិចារឹកនៃកិច្ចសម្ភាសន៍ទាំងស្រុង[58], ឯកសារមួយគឺជាកំណត់សម្គាល់របស់ Stephen Heder ក្នុងពេលសម្ភាស អៀង សារី ដែលធ្វើឡើងដោយ Elizabeth Becker[59], ឯកសារមួយទៀតគឺជាកំណត់ត្រានៃកិច្ចសម្ភាសន៍ជាមួយ នួន ជា ដែលធ្វើឡើងដោយ ឃឹម ងួន ក្នុងខែឧសភា ឆ្នាំ១៩៩៨[60] និងឯកសារចុងក្រោយ

---

54 D38 (ឯកសារ 55)។

55 C25 (ឯកសារ 62); C19 (ឯកសារ 58)។

56 IS 20.23 (ឯកសារ 42)។

57 IS 20.7 (ឯកសារ 37); IS 20.6, D29/I (ឯកសារ 35)។

58 IS 20.6, D29/I (ឯកសារ 35)។

59 IS 20.12 (ឯកសារ 31)។

60 IS 20.28, D288/5.107 (ឯកសារ 36)។

គឺជាកំណត់ត្រានៃកិច្ចសម្ភាសន៍ជាមួយ នួន ជា និង ខៀវ សំផន ក្នុងខែមិថុនា ឆ្នាំ២០០៦ ដែលធ្វើឡើងដោយ ម៉េង ទ្រី អៀ និង សួភ័ក្ត្រ លឿង[61]។

២៣. កំណត់ហេតុនៃកិច្ចសម្ភាសន៍ចំនួនពីរទៀតត្រូវបានដាក់នៅក្នុងសំណុំរឿងក្នុងអំឡុងពេលនៃដំណាក់កាលនៃកិច្ចស៊ើបសួរ។ កំណត់ត្រាមួយ គឺជាកំណត់ត្រាសរសេរជាទម្រង់សង្ខេបរបស់ Stephen Heder ក្នុងពេលសម្ភាសជាមួយ អៀង សារី ក្នុងខែមករា ឆ្នាំ១៩៩៩ ត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត តាមគំនិតផ្តួចផ្តើមរបស់ខ្លួនផ្ទាល់[62]។ ចំណែក ឯកសារមួយទៀតដែលជាប្រតិចារឹកនៃកិច្ចសម្ភាសន៍ជាមួយ អៀង ធីរិទ្ធ ដែលធ្វើឡើងដោយ Elizabeth Becker ក៏ត្រូវបានបញ្ចូលទៅក្នុងសំណុំរឿងក្នុងអំឡុងពេលនៃកិច្ចការស៊ើបសួរតាមការស្នើសុំរបស់ការិយាល័យសហព្រះរាជអាជ្ញា[63]។

២៤. កិច្ចសម្ភាសន៍របស់ SOAS/HRW ជាមួយនឹង ខៀវ សំផន[64] និងប្រតិចារឹកពីខ្សែអាត់សំឡេងក្នុងពេលសម្ភាស អៀង សារី ដែលបានធ្វើឡើងដោយ Stephen Heder ត្រូវបានទទួលស្គាល់ជាភស្តុតាងក្នុងសំណុំរឿង ០០១[65]។

*ឯកសារផ្សេងៗ*

២៥. ឯកសារក្នុងប្រភេទរងនេះរួមមានលិខិតពីរច្បាប់របស់ ខៀវ សំផន និងរបាយការណ៍មួយពី DNUM ដែលជាក្រុមអ្នកនយោបាយមួយក្រុមបង្កើតឡើងដោយ អៀង សារី បន្ទាប់ពីគាត់បានចុះចូលជាមួយរដ្ឋាភិបាលក្នុងឆ្នាំ១៩៩៦។

---

61 IS 20.34, D29-Attachment 81, 20.34/Corr-1 (ឯកសារ 48)។

62 D210/14/1.2 (ឯកសារ 38)។ សូមមើល **D210** ការជូនដំណឹងស្តីពីការដាក់ឯកសារ, ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៩។ D58 (ឯកសារ 66)។

63 D366/7.1.653, D28 (ឯកសារ 26)។ សូមមើល **D366** សំណើរបស់សហព្រះរាជអាជ្ញាសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង, ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១០ ត្រង់កថាខណ្ឌ៣។ ទោះបីជាការចោទប្រកាន់ប្រឆាំងនឹង អៀង ធីរិទ្ធ បច្ចុប្បន្នត្រូវបានបំបែកចេញពីសំណុំរឿងលេខ០០២ សហព្រះរាជអាជ្ញានៅតែសំអាងលើឯកសារនេះ ជាភស្តុតាងប្រឆាំងនឹងជនជាប់ចោទ។

64 IS 20.23 (ឯកសារ 42) ត្រូវបានទទួលយកជាឯកសារ E3/53។

65 IS 20.6, D29/I (ឯកសារ 35) ត្រូវបានទទួលយកជាឯកសារ E3/106។

២៦. លិខិតមួយច្បាប់ក្នុងចំណោមលិខិតរបស់ ខៀវ សំផន នេះ គឺជាលិខិតសរសេរដៃដែលបាន ផ្ញើជូនសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០០៨ និងបានដាក់ចូលក្នុងសំណុំរឿងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត[66]។ ចំណែកឯកសារមួយទៀតគឺជាលិខិតសាធារណៈផ្ញើជូន"ជនរួមជាតិទាំងអស់"។ការិយាល័យសហព្រះរាជអាជ្ញាបានទទួលលិខិតមួយពីមជ្ឈមណ្ឌលឯកសារកម្ពុជាបន្ទាប់ពីចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងត្រូវបានដាក់ចូលក្នុងសំណុំរឿងតាមសំណើរបស់ការិយាល័យសហព្រះរាជអាជ្ញា[67]។ ការិយាល័យសហព្រះរាជអាជ្ញាបានទទួលរបាយការណ៍របស់ DNUM ក្នុងអំឡុងពេលនៃកិច្ចស៊ើបអង្កេតបឋម និងត្រូវប្រើជាឧបសម្ព័ន្ធ ភ្ជាប់នឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[68]។ នៅផ្នែកចុងក្រោយនៃឯកសារនេះ មានចំណារសរសេរដៃនៃលេខទូរស័ព្ទរបស់ ឡុង នូរិទ្ធ និង "សុក ភាព" ដែលអ្នកទាំងពីរជាអនុប្រធាន DNUM ។

## ២. របាយការណ៍វិភាគ

២៧. មានឯកសារចំនួនប្រាំនៅក្នុងបញ្ជីឯកសារ ដែលគេហៅថាជារបាយការណ៍វិភាគ។ របាយការណ៍ចំនួនបួនត្រូវបានរៀបចំដោយអ្នកស្រាវជ្រាវឯករាជ្យ[69] ហើយឯកសារមួយទៀតត្រូវបានរៀបចំឡើងដោយអង្គការលើកលែងទោសអន្តរជាតិ (Amnesty International)[70]។ របាយការណ៍វិភាគជាប្រភេទឯកសារដែលគេបានដឹងជាទូទៅ និងមានខ្លឹមសារ និងកំណត់សម្គាល់ខាងក្នុងដែលផ្តល់នូវសូចនាបន្ថែមទៀតថាអាចជឿជាក់បាន។

២៨. របាយការណ៍របស់អង្គការលើកលែងទោសអន្តរជាតិស្តីពីរបបកម្ពុជាប្រជាធិបតេយ្យ[71] គឺជាសម្រង់ចេញពី *របាយការណ៍របស់អង្គការលើកលែងទោសអន្តរជាតិឆ្នាំ ១៩៧៥-៧៦*។ អង្គការលើកលែងទោសអន្តរជាតិ គឺជាអង្គការអន្តរជាតិមួយដែលមានភាពល្បីល្បាញ ហេតុនេះប្រភេទ

---

[66] D58 (ឯកសារ 66)។

[67] D29-Attachment 85, D312.2.1, D312.2.4 (ឯកសារ 39), សូមមើល D29 សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអំពីការបង្ហាញឯកសារបន្ថែម ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៧។

[68] IS 20.3 (ឯកសារ 33)។

[69] D29-ឯកសារបន្ថែម 66 (ឯកសារ 70); IS 11.15 (ឯកសារ 71); D2-15 (ឯកសារ 72); and D177/3.1 (ឯកសារ 73)។

[70] D84- ឧបសម្ព័ន្ធ A-1 (ឯកសារ 69)។

[71] D84-ឧបសម្ព័ន្ធ A-1 (ឯកសារ 69)។

ឯកសារនៃរបាយការណ៍នេះទទួលយកបាន ដោយគ្មានការសង្ស័យឡើយ។ ឯកសារនេះត្រូវបាន ប្រមូលចងក្រងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam)[72] និងត្រូវបានផ្ដល់ជូនសហព្រះរាជអាជ្ញា ក្នុងដំណាក់កាលស៊ើបអង្កេតបឋមរបស់ខ្លួន។

២៩. របាយការណ៍វិភាគបានបង្ហាញនូវកំណត់សម្គាល់ខាងក្នុង ដែលបញ្ជាក់ពីភាពដែលអាចជឿជាក់បាន និងយថាភាពនៃរបាយការណ៍ទាំងនេះ។ *ប៉ុល ពត និង ខៀវ សំផន*[73] គឺជាឯកសារចម្លងនៃរបាយការណ៍មួយ ដែលត្រូវបានបោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលសិក្សាពីភូមិភាគអាស៊ីអគ្នេយ៍ (Centre of Southeast Asian Studies) នៅសាកលវិទ្យាល័យ Monash ក្នុងប្រទេសអូស្ត្រាលី។ ចំណុចនេះបានបង្ហាញច្បាស់នៅក្នុងកំណត់សម្គាល់ខាងក្នុងឯកសារនោះ ដូចជាស្លាកសញ្ញារបស់សាកលវិទ្យាល័យ និងលេខ ISBN របស់ឯកសារ។ *ទិដ្ឋភាពទូទៅនៃឋានានុក្រមរបស់របបកម្ពុជាប្រជាធិបតេយ្យ*[74] គឺជាឯកសារដែលត្រូវបានរៀបចំ ជាពិសេសដោយលោក Craig Etcheson សម្រាប់ អ.វ.ត.ក។ ឯកសារនេះត្រូវបានរៀបចំព្រាងឡើងដោយប្រើក្បាលលិខិតរបស់ការិយាល័យសហព្រះរាជអាជ្ញា និងត្រូវបានចុះហត្ថលេខាដោយអ្នកនិពន្ធខ្លួនឯង។ របាយការណ៍នេះត្រូវបានទទួលយកជាភ័ស្តុតាងក្នុងសំណុំរឿង ០០១[75]។ *ការធ្វើដំណើរទៅបរទេសរបស់ អៀង សារី ប្រៀបធៀបទៅនឹងកំណត់ហេតុនៃការចាប់ខ្លួន និងការសម្លាប់បុគ្គលិកក្រសួងការបរទេសនៅមន្ទីរស២១*[76] គឺជាឯកសារមួយទៀតដែលត្រូវបានរៀបចំឡើងសម្រាប់ អ.វ.ត.ក។ ឯកសារនេះត្រូវបានរៀបចំដោយ Richard Moore ជាអ្នកវិភាគនៅ ក.ស.ច.ស។ ឯកសារនេះបង្ហាញពីត្រារបស់ អ.វ.ត.ក[77]។ *ជីវប្រវត្តិរបស់ អៀង សារី*[78] (IS 11.15; ឯកសារ 71) ត្រូវបានរៀបចំឡើងដោយទស្សនាវដ្ដីស្វែងរកការពិត ដែលជាការបោះពុម្ពផ្សាយមួយរបស់ DC-Cam។ ជីវប្រវត្តិនេះត្រូវបានរៀបចំជាភាសាអង់គ្លេសដែលបានបោះពុម្ពផ្សាយនៅខែមេសា ឆ្នាំ២០០៣ ដែលគេអាចរកបានពីគេហទំព័ររបស់ DC-Cam[79]។

---

[72] សូមមើល មូលដ្ឋានទិន្នន័យរបស់ DC-Cam មាននៅ៖ http://www.d.dccam.org/Database/Lod/details.php?keyword=16147&numRecords=100&lang=eng&page=1&idnum=D16147។

[73] D29-ឯកសារបន្ថែម 66 (ឯកសារ 70)។

[74] D2-15 (ឯកសារ 72)។

[75] ត្រូវបានទទួលយកជាឯកសារ E3/32។

[76] D177/3.1 (ឯកសារ 73)។

[77] D177/3.1 (ឯកសារ 73) ត្រង់ទំព័រ៤៧។

[78] IS 11.15 (ឯកសារ 71)។

[79] សូមមើល http://d.dccam.org/Projects/Magazines/Image_Eng/pdf/1st_Quarter_2003.pdf ។

## ៣. សៀវភៅ

៣០. មានឯកសារចំនួន១១ នៅក្នុងបញ្ជីឯកសារដែលបានកំណត់អត្តសញ្ញាណថាជា សៀវភៅ[80] ដែលឯកសារទាំងនោះសុទ្ធសឹងជាសៀវភៅដែលបានបោះពុម្ពផ្សាយដែលមានការទទួលស្គាល់[81]។

៣១. សៀវភៅពីរក្បាលនៅក្នុងបញ្ជីឯកសារ ត្រូវបាននិពន្ធឡើងដោយជនជាប់ចោទ ខៀវ សំផន[82]។ សៀវភៅបីក្បាល ក្នុងចំណោមសៀវភៅដែលនៅក្នុងបញ្ជីឯកសារ ត្រូវបានទទួលយកជាភ័ស្តុតាងដោយអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០១[83] បន្ថែមទៅលើចំនួនសៀវភៅយ៉ាងតិច ១៣ ក្បាលទៀត[84]។

៣២. សៀវភៅទាំងនេះ បង្ហាញពីកំណត់សម្គាល់ខាងក្នុងដែលបញ្ជាក់ពីភាពដែលអាចជឿជាក់បានរបស់វា។ សៀវភៅចំនួនប្រាំបីក្បាលនៅក្នុងបញ្ជីឯកសារបានបង្ហាញច្បាស់នូវលេខ ISBN[85]។ គេពុំ

---

[80] ឯកសារ 74-84 នៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា។

[81] តុលាការ ICTR បានលើកឡើងថា សៀវភៅថតចម្លងដែលគេទទួលស្គាល់មានសញ្ញាណនៃការជឿជាក់គ្រប់គ្រាន់ដើម្បីទទួលយកជាឯកសារភ័ស្តុតាង។ សូមមើល *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* *Casimir Bizimungu* និងអ្នកផ្សេងទៀត, សំណុំរឿងលេខ ICTR-99-50-T, សាលក្រម (អង្គជំនុំជម្រះសាលាដំបូង នៃតុលាការ ICTR), ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ ត្រង់កថាខណ្ឌ៤។

[82] D83-ឧបសម្ព័ន្ធ-00013 (ឯកសារ 83); IS 4.23 (ឯកសារ 81)។

[83] IS 4.15 (ឯកសារ 74) ត្រូវបានទទួលស្គាល់ជាឯកសារ E3/330; IS 4.1 (ឯកសារ 75) ត្រូវបានទទួលស្គាល់ជាឯកសារ E3/510; និង IS 4.2 (ឯកសារ 78) ត្រូវបានទទួលស្គាល់ជាឯកសារ E3/4។

[84] សៀវភៅនិពន្ធដោយ ហ៊ុយ វណ្ណៈ *កងពលខ្មែរក្រហម ៧០៣៖ ពីជ័យជម្នះឆ្ពោះទៅការបំផ្លាញខ្លួនឯង*, ត្រូវបានទទួលស្គាល់ជាឯកសារ E3/391។ សៀវភៅនិពន្ធដោយ អៀ ម៉េងទ្រី, *ខ្មែរយៈនៃការភ័យខ្លាច៖ ប្រព័ន្ធសន្តិសុខភូមិភាគនិរតី*, ត្រូវបានទទួលស្គាល់ជាឯកសារ E3/48។ សៀវភៅនិពន្ធដោយ Henry Kamm, *Cambodia: Report from a Stricken Land*", ត្រូវបានទទួលស្គាល់ជាឯកសារ E3/87; សៀវភៅនិពន្ធដោយ Nayan Chanda *សត្រូវបងប្អូនឯង៖ សង្គ្រាមបន្ទាប់ពីសង្គ្រាម* ត្រូវបានទទួលស្គាល់ជាឯកសារ E3/193, សៀវភៅនិពន្ធដោយ David Chandler, *សំឡេងពីមន្ទីរស-២១៖ ភាពព្រឺខ្លាច និងប្រវត្តិក្នុងគុកសម្ងាត់របស់ ប៉ុល ពត*, ត្រូវបានទទួលស្គាល់ជាឯកសារ E3/427; សៀវភៅនិពន្ធដោយ Ysa Osman, *Oukoubah: Justice for the Cham Muslims under the Democratic Kampuchea Regime*, ត្រូវបានទទួលស្គាល់ជាឯកសារ E3/404; សៀវភៅនិពន្ធដោយ Stephen Morris, *ហេតុអ្វីប្រទេសវៀតណាម ឈ្លានពានប្រទេសកម្ពុជា៖ វប្បធម៌នយោបាយ និងបុព្វហេតុនៃសង្គ្រាម*, ត្រូវបានទទួលស្គាល់ជាឯកសារ E3/523; សៀវភៅនិពន្ធដោយ David Chandler *និងអ្នកនិពន្ធផ្សេងទៀត*, *Pol Pot Plans the Future: Confidential Documents from Democratic Kampuchea*, ត្រូវបានទទួលស្គាល់ជាឯកសារ E3/67; សៀវភៅនិពន្ធដោយ Raoul M. Jennar *Les Clés du Cambodge*, ត្រូវបានទទួលស្គាល់ជាឯកសារ E3/515; សៀវភៅនិពន្ធដោយ Nic Dunlop, *ពេជ្ឈឃាដបាត់ខ្លួន*។

[85] IS 4.15 (ឯកសារ 74); IS 4.25 (ឯកសារ 76); D313/1.2.6 (ឯកសារ 77); IS 4.2 (ឯកសារ 78); D141/1.2 (ឯកសារ 79); IS 4.41 (ឯកសារ 82); D83-ឧសម្ព័ន្ធ-00013 (ឯកសារ 83); ឯកសារថ្មី (ឯកសារ 84)។

ឃើញមានលេខ ISBN នៅលើសៀវភៅដែលមានចំណងជើងថា *"នៅពេលដែលសង្គ្រាមរលត់ទៅ"* និពន្ធដោយ Elizabeth Becker នោះទេ។ ទោះជាយ៉ាងណាក្តី ឯកសារនេះពិតជាបង្ហាញពីកំណត់សម្គាល់របស់ក្រុមហ៊ុនបោះពុម្ពផ្សាយឈ្មោះ Public Affairs New York។ សៀវភៅពីរក្បាលផ្សេងទៀត ត្រូវបានបោះពុម្ពផ្សាយដោយការិយាល័យស្រាវជ្រាវឧក្រិដ្ឋកម្មសង្គ្រាម (War Crimes Research Office) សាកលវិទ្យាល័យ American (ត្រូវបានបោះពុម្ពសាជាថ្មីដោយមានការអនុញ្ញាតពីមជ្ឈមណ្ឌលឯកសារកម្ពុជា)[86] និងរោងពុម្ពពន្លឺខ្មែរ[87]។

## ៤. ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

៣៣. មានឯកសារ ៣ នៅក្នុងបញ្ជីឯកសារដែលត្រូវបានចាត់ទុកជាថា "ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី"[88]។ ពាក្យសុំទាំងនេះជាកំណត់ហេតុផ្លូវការរបស់ អ.វ.ត.ក ដែលបានបំពេញដោយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ឯកសារទាំងនេះមានទម្រង់ និងសណ្ឋានដូចគ្នាសម្រាប់ប្រើប្រាស់ផ្ទៃក្នុង។ ឯកសារទាំងនេះរួមបញ្ចូលទម្រង់បែបបទដែលមានលក្ខណៈជាបទដ្ឋាន ដែលត្រូវបានបំពេញដោយអ្នកដាក់ពាក្យសុំ និងមានចុះកាលបរិច្ឆេទ និងហត្ថលេខាដោយអ្នកដាក់ពាក្យសុំ និងសាក្សី នៅខាងចុង។ នៅទំព័រទី១ មានបោះត្រាផ្លូវការរបស់តុលាការ។

៣៤. ពាក្យសុំមួយក្នុងចំណោមពាក្យសុំទាំងនេះ[89] រួមមានការថតចម្លងផ្នែកខាងមុខ និងខាងខ្នងនៃអត្តសញ្ញាណប័ណ្ណរបស់អ្នកដាក់ពាក្យសុំ។ ពាក្យសុំពីរផ្សេងទៀតមានស្នាមផ្តិតមេដៃនៅចុងទំព័រនីមួយៗ[90]។ ពាក្យសុំទាំងនេះក៏មានឯកសារដោយឡែកដែលភ្ជាប់ជាមួយដែរ ដែលតាមការណែនាំគឺត្រូវបំពេញផ្នែក ខ នៃពាក្យសុំនេះ។ ឯកសារដោយឡែក គឺសម្រាប់អង្គភាពគាំពារជនរងគ្រោះ និងមានចំណងជើងថា "ព័ត៌មានបន្ថែមពីជនរងគ្រោះ"។ នៅតួអត្ថបទ អ្នកដាក់ពាក្យសុំស្នើសុំថាឯកសារនោះគួរតែភ្ជាប់ជាមួយនឹងបណ្តឹង ឬពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលគាត់បានដាក់ពីមុន។ ឯកសារបន្ថែមត្រូវបានផ្តិតមេដៃដោយអ្នកដាក់ពាក្យសុំ និងបោះត្រាដោយតុលាការ។

[86] IS 4.18 (ឯកសារ 80)។

[87] IS 4.23 (ឯកសារ 81)។

[88] ឯកសារ 85-87 នៅក្នុងបញ្ជីឈ្មោះឯកសារ។

[89] D22/3605 (ឯកសារ 87)។

[90] D22/43, D22/43.2 (ឯកសារ85) និង D22/42, D22/42.3 (ឯកសារ 86)។

៣៥. អ្នកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានបំពេញពាក្យសុំរួចហើយ បានផ្តល់សក្ខីកម្មមួយផ្នែក នាពេលបច្ចុប្បន្ននេះ ឬត្រូវបានកំណត់ពេលដើម្បីផ្តល់សក្ខីកម្ម នៅក្នុងសវនាការដំណាក់កាលដំបូង[91]។

## ៥. ឯកសារបោះពុម្ពផ្សាយរបស់បក្សកុម្មុយនីស្តកម្ពុជា

៣៦. មានឯកសារចំនួន៨៣ នៅក្នុងបញ្ជីឯកសារជាប្រភេទ "ឯកសារបោះពុម្ពផ្សាយរបស់ ប.ក.ក"[92]។ ឯកសារប្រភេទនេះភាគច្រើនជាទស្សនាវដ្តីទង់បដិវត្តន៍ និងយុវជនបដិវត្តន៍ និងមួយចំនួនជាសេចក្តីណែនាំរបស់ ប.ក.ក និងសន្ទរកថាផ្សេងៗ សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ ឬឯកសារផ្លូវការបោះពុម្ពផ្សាយដោយ ប.ក.ក។

## ទស្សនាវដ្តីទង់បដិវត្តន៍ និងយុវជនបដិវត្តន៍

៣៧. មានទស្សនាវដ្តីទង់បដិវត្តន៍ចំនួន ២៤ លេខ[93] និងទស្សនាវដ្តីយុវជនបដិវត្តន៍ចំនួន២៨លេខ[94] នៅក្នុងបញ្ជីឯកសារ។ ជាការបន្ថែម មានសេចក្តីសង្ខេបចំនួន ២ នៃទស្សនាវដ្តីទង់បដិវត្តន៍ និងយុវជន

---

[91] សូមមើល **E131/1.1** ឧបសម្ព័ន្ធសម្ងាត់ ក ភ្ជាប់ទៅនឹងអនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១១។ E131/1 អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា ការជូនដំណឹងពីការផ្លាស់ប្តូរការកោះហៅដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១១។ ភាគីទាំងអស់ត្រូវបានជូនដំណឹងនៅថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១១ ថា ដើមបណ្តឹងរដ្ឋប្បវេណី នៃអង្គជំនុំជម្រះសាលាដំបូងចំនួន១២៣ រូប ប្រហែលជាមិនអាចមកផ្តល់សក្ខីកម្មបានទេ ដោយសារមានជំងឺ។

[92] ឯកសារ 88-170 នៅក្នុងបញ្ជីឯកសារ។

[93] ឯកសារ D243/2.1.1 (ឯកសារ 99)។ ឯកសារ D243/2.1.2 (ឯកសារ 106)។ ឯកសារD243/2.1.3 (ឯកសារ 113)។ ឯកសារ D243/2.1.4 (ឯកសារ 116)។ ឯកសារ D243/2.1.5។ ឯកសារ D288/5.36 (ឯកសារ 121)។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ 11.9។ D123/3.1 (ឯកសារ 123)។ D243/2.1.6 (ឯកសារ 126)។ ឯកសារ D243/2.1.7 (ឯកសារ 129)។ D243/2.1.8 (ឯកសារ 132)។ ឯកសារ D243/2.1.9 (ឯកសារ 135)។ ឯកសារ D243/2.1.10 (ឯកសារ 140) ។ ឯកសារ D2-15.4 (ឯកសារ 143)។ ឯកសារ D243/2.1.11 (ឯកសារ 144)។ ឯកសារ D189.2 (ឯកសារ 147)។ ឯកសារ D243/2.1.12 (ឯកសារ 148)។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ 11.10។ ឯកសារ D243/2.1.13 (ឯកសារ 152)។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ 11.11 (ឯកសារ 153)។ ឯកសារ D243/2.1.14 (ឯកសារ 156)។ ឯកសារ D243/2.1.15 (ឯកសារ 158)។ ឯកសារ D243/2.1.16 (ឯកសារ 160)។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ 11.14 (ឯកសារ 161)។ ឯកសារ D243/2.1.17 (163)។ D243/2.1.18 (ឯកសារ 165) និង D243/2.1.19 (ឯកសារ 166)។

[94] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ 11.7 (ឯកសារ 119), ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ 11.12 (ឯកសារ 157)។ ឯកសារ D243/2.1.28; D243/2.1.29; D248/4.11; D248/4.7; IS 11.3; ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ 11.4; ឯកសារ D243/2.1.25; D248/4.3; D248/4.2; ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ 11.12; ឯកសារ D243/2.1.22; D248/4.8; D243/2.1.24; 243/2.1.26; D248/4.4; D243/2.1.27; D248/4.10; IS 11.6; D248/4.5; D248/2.1.23; IS 11.8; D248/4.9; D175/6.2; D248/4.6; D243/2.1.20; D243/2.1.21។

បដិវត្តន៍ចំនួន ២ លេខផ្សេងទៀត[95]។ ទស្សនាវដ្ដីទង់បដិវត្តន៍ និងយុវជនបដិវត្តន៍ ត្រូវបានបោះពុម្ពផ្សាយជាផ្លូវការ និងចែកចាយដោយក្រសួងឃោសនាការ ទៅតាមមន្ទីរនានាដែលក្នុងនោះមានមន្ទីរ ក-២៥ មន្ទីរ ក-២៦ និងមន្ទីរ ក-២៧។ សាក្សីឈ្មោះ [redacted] ដែលជាបុគ្គលិកនៅក្រសួងឃោសនាការ បានបញ្ជាក់ថា "*មន្ទីរ ក-២៥ ជាអ្នកបោះពុម្ពផ្សាយទស្សនាវដ្ដីទង់បដិវត្តន៍ និងយុវជនបដិវត្តន៍។ ប្រធានក្រុមនិពន្ធឈ្មោះ* [redacted]*។ មន្ទីរ ក-២៦ ជាកន្លែងបោះពុម្ពកាសែត ហើយមន្ទីរ ក-២៧ ជាអ្នកបោះពុម្ពរូបភាពទស្សនាវដ្ដី*"[96]។ សាក្សីឈ្មោះ ណាំ ចែ អះអាងថា "*ក្រសួងឃោសនាការជាអ្នកផលិតទស្សនាវដ្ដី និងសៀវភៅទង់បដិវត្តន៍ ហើយឈ្មោះ ទូច ភឿន និងអ្នកចេះដឹងមួយចំនួនទៀត ជាអ្នកសរសេរអត្ថបទដាក់ទស្សនាវដ្ដីទាំងនេះ*"[97]។ ក្នុងពេលថ្មីៗនេះ នួន ជា បានផ្ដល់សក្ខីកម្មថា *ទស្សនាវដ្ដីទង់បដិវត្តន៍* ដែលត្រូវបានបែងចែកទៅឱ្យបណ្ដាភូមិភាគនានា គឺមាន"បច្ចេកទេស"មួយដើម្បីដាក់លេខឱ្យ និងមាន "រោងពុម្ព"មួយសំរាប់បោះពុម្ពផ្សាយទស្សនាវដ្ដីនេះ។ គាត់ក៏បានផ្ដល់សក្ខីមកម្មផងដែរថា រូបគាត់ហើយនិង ប៉ុល ពត ទាំងអស់គ្នាព្រមជាមួយនឹងសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ផ្សេងៗទៀត បានសរសេរអត្ថបទសំរាប់ *ទស្សនាវដ្ដីទង់បដិវត្តន៍* នេះ[98]។

៣៨. អត្ថបទទាំងប៉ុន្មានដែលមាននៅក្នុងព្រឹត្តប័ត្របោះពុម្ពផ្សាយទាំងពីរនេះ និយាយផ្ដោតអំពីគោលនយោបាយ និងសកម្មភាពយោធា យុទ្ធសាស្ត្រ និងសេដ្ឋកិច្ចរបស់ ប.ក.ក ។ ពួកគេក៏បានប្រើ ប្រាស់វោហារស័ព្ទមួយចំនួនដូចជា "កងទ័ពបដិវត្តន៍" "ចក្រពត្តិអាមេរិក" "កម្ទេច" "សមមិត្ត" "បងប្អូន" និង "សម្រុក" ជាដើម។ គោលបំណងជាក់ស្ដែងនៃទស្សនាវដ្ដីទាំងពីរនេះ គឺបំពាក់បំប៉នមនោគមន៍វិទ្យាដល់សមាជិកបក្សអំពីគោលនយោបាយ និងទិសដៅរបស់ ប.ក.ក ឱ្យបានដឹង។

---

[95] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ 11.5 (ឯកសារ 109) មានសេចក្ដីសង្ខេបនៃលេខចុះផ្សាយពិសេសរបស់ទស្សនាវដ្ដីទង់បដិវត្តន៍ចុះខែ ធ្នូ ឆ្នាំ ១៩៧៥ ដល់ខែ មករា ឆ្នាំ ១៩៧៦។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ 11.1 (ឯកសារ 98) មានសេចក្ដីសង្ខេបនៃទស្សនាវដ្ដីយុវជនបដិវត្តន៍ លេខទី ៧ ខែ កក្កដា ឆ្នាំ ១៩៧៥។ សហព្រះរាជអាជ្ញាពុំមានសំណៅចម្លងនៃទស្សនាវដ្ដីទាំងប៉ុន្មានលេខនេះទេ។

[96] ឯកសារ D201/10 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី [redacted], ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០៩ ត្រង់ទំព័រ ៣ (នៅក្នុងបញ្ជីឯកសារដំណាក់កាលដំបូងនៅឧបសម្ពន្ធ ១២; លេខ ៥២៤; និងនៅក្នុងបញ្ជីឯកសាររបស់ ខៀវ សំផន)។ សូមមើលផងដែរ ឯកសារ D201/11 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី [redacted], ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩ ត្រង់ទំព័រ ៣-៤ (បញ្ជីឯកសារដំណាក់កាលដំបូងរបស់សហព្រះរាជអាជ្ញានៅឧបសម្ព័ន្ធ ១២ លេខ ៥២៥)។

[97] ឯកសារ D234/7 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី [redacted], ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៩។

[98] ប្រតិចារិក , ចុះថ្ងៃទី២១ ធ្នូ ២០១១, ត្រង់ទំព័រពី៧៣-៧៤។

៣៩. ទស្សនាវដ្តីទង់បដិវត្តន៍ និងទស្សនាវដ្តីយុវជនបដិវត្តន៍ទាំងប៉ុន្មានលេខដែលមាននៅក្នុងបញ្ជីឯកសារ មានចំណុចសម្គាល់ដូចៗគ្នា និងរចនាបទស្រដៀងគ្នា[99]។ ទំព័រក្របមុខមានរូបទង់ជ័យ២ ឬច្រើន។ នៅខាងដើមជំពូកនីមួយៗ និងនៅក្របខ្នងទស្សនាវដ្តី មានរូបញញួរ និងកណ្តៀវ ជានិម្មិតសញ្ញានៃរបបកុម្មុយនីស្ត។

៤០. ទស្សនាវដ្តីទង់បដិវត្តន៍ និងយុវជនបដិវត្តន៍ទាំងអស់ដែលមាននៅក្នុងបញ្ជីឯកសារ ត្រូវបានមជ្ឈមណ្ឌលឯកសារកម្ពុជាប្រមែប្រមូល និងប្រគល់ឲ្យ ក.ស.ព ក្នុងអំឡុងកិច្ចស៊ើបសួរបឋម ឬប្រគល់ទៅឲ្យ ក.ស.ច.ស ក្នុងអំឡុងកិច្ចស៊ើបសួរតាមផ្លូវតុលាការ[100]។ មានតែទស្សនាវដ្តីចំនួន ៤ លេខប៉ុណ្ណោះ ដែលត្រូវបានកត់ត្រាទុកក្នុងមូលដ្ឋានទិន្នន័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាថា មជ្ឈមណ្ឌលឯកសារកម្ពុជាជាអ្នកបានប្រមែប្រមូលពីបណ្ណសារទួលស្លែង កាលពីឆ្នាំ១៩៩៩[101]។ ទស្សនាវដ្តីដែលនៅសេសសល់ចំនួន ៤ លេខទៀត ត្រូវបានកត់ត្រាថាបានប្រមែប្រមូលពីប្រភពផ្សេងៗ[102]។

៤១. លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បានបង្ហាញអត្តសញ្ញាណទស្សនាវដ្តីទង់បដិវត្តន៍ចំនួន ២ លេខដែលមាននៅក្នុងបញ្ជីឯកសារ នៅក្នុងការស្តាប់ចម្លើយដោយ ក.ស.ច.ស។ គាត់បានពិភាក្សាអំពីកាលៈទេសៈផ្សេងៗនៃការរកឃើញទស្សនាវដ្តីទង់បដិវត្តន៍ទាំងនេះ និងបានបញ្ជាក់អះអាងថា DC-Cam មានច្បាប់ដើមនៃឯកសារទាំងនេះ[103]។ ទស្សនាវដ្តីមួយលេខទៀតបានទទួលការបញ្ជាក់យថាភាពដោយសាក្សីឈ្មោះ [redacted] នៅក្នុងការស្តាប់យកចម្លើយដោយ ក.ស.

---

[99] ដូចសម្គាល់ខាងលើ ឯកសារ IS 11.1 (ឯកសារ 98) និងឯកសារ IS 11.5 (ឯកសារ 109) ជាសេចក្តីសង្ខេបនៃទស្សនាទង់បដិវត្តន៍ និងយុវជនបដិវត្តន៍លេខខុសៗគ្នា ទើបពុំមានចំណុចសម្គាល់។ ជាងនេះ ឯកសារ D243/2.1.20 (ឯកសារ ១០០) បាត់ទំព័រក្របមុខ និងក្របក្រោយ ប៉ុន្តែមានចំណុចសម្គាល់ដូចៗគ្នាផ្សេងៗ។

[100] ទស្សនាវដ្តីទង់បដិវត្តន៍ចំនួន ២៣ លេខ និងទស្សនាវដ្តីយុវជនបដិវត្តន៍ចំនួន ១៧ លេខ និងឯកសារសង្ខេបចំនួន ២ ត្រូវបានមជ្ឈមណ្ឌលឯកសារកម្ពុជាប្រគល់ឲ្យ ក.ស.ព កាលពីអំឡុងកិច្ចស៊ើបសួរបឋម។ ទស្សនាវដ្តីទង់បដិវត្តន៍លេខពិសេសមួយនិងទស្សនាវដ្តីយុវជនបដិវត្តន៍ចំនួន១១លេខ ត្រូវបានមជ្ឈមណ្ឌលឯកសារកម្ពុជាប្រគល់ទៅ ក.ស.ច.ស នៅអំឡុងកិច្ចស៊ើបសួរតាមផ្លូវតុលាការ។

[101] សូមមើលប្រព័ន្ធទិន្នន័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅលើគេហទំព័រ៖ http://www.d.dcam.org/Database/Index.htm។

[102] ទស្សនាវដ្តីយុវជនបដិវត្តន៍ចំនួន ២ លេខ (D243/2.1.20 និង D243/2.1.21 ត្រូវបានកត់ត្រាថាបានទទួលបានពី "ហ៊ុន សែន"។ ទស្សនាវដ្តីទង់បដិវត្តន៍ចំនួន ២ លេខ (D243/2.1.17 និង IS11.1) ត្រូវបានកត់ត្រាថាទទួលបានបានពី "H"។ សូមមើលប្រព័ន្ធទិន្នន័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅលើគេហទំព័រ៖ http://www.d.dccam.org/Database/Index.htm.។

[103] សូមមើលឯកសារ D311/2 **កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆាំង យុ, ថ្ងៃទី១ ខែតុលា ឆ្នាំ២០០៩ ត្រង់ទំព័រ ៩ យោងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ** 11.10។ **ឯកសារ** D243/2.1.13 (**ឯកសារ** 152) **និង** 11.11 (**ឯកសារ** 153)។

ច.ស[104]។ ឯកសារទាំង៣នេះ[105] និងទស្សនាវដ្ដីទង់បដិវត្តន៍ និងទស្សនាវដ្ដីយុវជនបដិវត្តន៍មួយចំនួនផ្សេងទៀត[106] ដែលមាននៅក្នុងបញ្ជីឯកសារ ត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿង០០១។ ដូចកត់សម្គាល់ខាងលើ ទស្សនាវដ្ដីទង់បដិវត្តន៍ និងទស្សនាវដ្ដីយុវជនបដិវត្តន៍គ្រប់លេខទាំងអស់សុទ្ធតែមានសណ្ឋានស្រដៀងគ្នាស្ទើរទាំងស្រុង។ ហេតុដូច្នេះ លក្ខណៈនៃភាពអាចជឿជាក់បាននៃឯកសារទាំងនេះដូចដែលបានកំណត់អត្តសញ្ញាណ ឬដែលមានការបញ្ជាក់យថាភាពដោយសាក្សី និង/ឬដាក់បញ្ចូលជាភ័ស្តុតាងក្នុងសំណុំរឿង០០១ សុទ្ធតែមានភាពដូចគ្នាទៅនឹងទស្សនាវដ្ដីលេខផ្សេងទៀត ដែលមានក្នុងបញ្ជីឯកសារ។

## សេចក្ដីសម្រេចរបស់ ប.ក.ក

៤២. មានឯកសារចំនួន ៨ ជាសេចក្ដីសម្រេចរបស់ ប.ក.ក ដែលមាននៅក្នុងបញ្ជីឯកសារ[107]។ ប៉ុន្តែក្នុងចំណោមឯកសារខុសគ្នាទាំងពីរ ឯកសារនីមួយៗសុទ្ធតែមានសំណៅចំនួនពីរ[108]។ ត្រង់ចំណងជើង និងហត្ថលេខានៃឯកសារទាំងអស់នេះបញ្ជាក់ថាមជ្ឈិមបក្សជាអ្នកចេញសេចក្ដីសម្រេចទាំងនេះ (ឬហៅថា គណៈ៨៧០) ឬ មន្ទីរ ៨៧០[109]។ ក្នុងនោះមានសេចក្ដីសម្រេចមួយដែលចេញដោយ សុន សេន (ហៅ ខៀវ) ក្នុងនាមគណៈ៨៧០[110]។

---

[104] សាក្សីបញ្ជាក់ថា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ 11.9 (ឯកសារ 123) ជាឯកសាររបស់បក្សកុម្មុយនីស្តកម្ពុជា, ពិភាក្សាអំពីគោលនយោបាយដែលមាននៅក្នុងឯកសារនោះ បញ្ជាក់ថាទស្សនាវដ្ដីទង់បដិវត្តន៍ត្រូវបានសរសេរដោយសមាជិកមជ្ឈិមបក្សក្នុងនោះមាន ប៉ុល ពត នួន ជា និង អៀង សារី ហើយឯកសារនោះត្រូវបានចែកចាយទៅឯសមាជបក្សឆ្នាំ១៩៧៦ ហើយសមាជិកបក្សត្រូវរក្សាឯកសារនេះជាសម្ងាត់។ សូមមើល ឯកសារ D123/3 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី [redacted], ថ្ងៃទី២៩ ខែ កក្កដា ឆ្នាំ ២០០៨ នៅត្រង់ទំព័រ ៥-៧។

[105] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ 11.9។ ឯកសារ D123/3.1 (ឯកសារ 123) ត្រូវបានទទួលស្គាល់ជាឯកសារ E3/51; IS 11.10; D243/2.1.13 (ឯកសារ 152) ត្រូវបានទទួលស្គាល់ជាឯកសារ E3/29; IS 11.11 (ឯកសារ 153) ត្រូវបានទទួលស្គាល់ជាឯកសារ E3/70)។

[106] ឯកសារD288/5.36 (ឯកសារ 121; ត្រូវបានទទួលស្គាល់ជាឯកសារ E3/36); D2-15.4 (ឯកសារ 143; ត្រូវបានទទួលស្គាល់ជាឯកសារ E3/82); IS 11.14 (ឯកសារ 161; ត្រូវបានទទួលស្គាល់ជាឯកសារ E3/35)។

[107] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ 6.3 (ឯកសារ 115)។ ឯកសារ D366/7.1.139 (ឯកសារ 131)។ ឯកសារ Dl08/50/1.7 (ឯកសារ 146)។ ឯកសារ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ 6.6 (ឯកសារ 154)។ ឯកសារ D200/2.12 (ឯកសារ 155); D248/3.3; D189.1 (ឯកសារ 162); D366/7.1.142 (ឯកសារ 169) ; ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ 6.5 (ឯកសារ 170)។

[108] ឯកសារ D200/2.12 (ឯកសារ 155) ជាឯកសារពណ៌ធម្មជាតិនៃដីកាបញ្ជូនរឿងឱ្យស៊ើបសួរ IS 6.6 (ឯកសារ 154) និងមានចំណារជាអក្សរសរសេរដៃ។ ឯកសារ D366/7.1.142 (ឯកសារ 169) ត្រង់ទំព័រ ២ ដូចនឹងឯកសារដីកាបញ្ជូនរឿងឱ្យស៊ើបសួរ 6.5 (ឯកសារ ១៧០)។

[109] ប្រភពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ (ឯកសារ ១១៥) ពុំមានបញ្ជាក់ឡើយនៅលើឯកសារនេះ។

[110] ឯកសារ Dl08/50/1.7 (ឯកសារ 146)។

៤៣. គោលបំណងនៃឯកសារទាំងនេះ គឺដើម្បីផ្សព្វផ្សាយគោលនយោបាយរបស់ ប.ក.ក ដូចជាការកំណត់អត្តសញ្ញាណ និងការសម្លាប់ "ពួកក្បត់"[111] ការធ្វើរបាយការណ៍ទៅមជ្ឈិមបក្ស[112] និងការតស៊ូប្រឆាំង "ខ្មាំងយួន"[113]។ ឯកសារទាំងនោះក៏ប្រើប្រាស់វាក្យស័ព្ទងាយសម្គាល់ពាក់ព័ន្ធនឹង ប.ក.ក ដូចជាពាក្យថា "កម្ទេច" "ខ្មាំងបង្កប់" និង "សមាសភាពមិនល្អ"។ ឯកសារចំនួន២ ក្នុងចំណោមឯកសារទាំងនេះបញ្ចប់ដោយពាក្យថា "ដោយភាតរៈបដិវត្តន៍កក់ក្តៅបំផុត"[114]។

៤៤. លោក ឆាំង យុ ប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា បានបង្ហាញអត្តសញ្ញាណឯកសារចំនួន ៤ ក្នុងចំណោមឯកសារទាំងនេះ នៅក្នុងការស្តាប់ចម្លើយមួយដែលបានធ្វើឡើងដោយ កសចស[115]។ សាក្សីឈ្មោះ [redacted] បានបញ្ជាក់យថាភាពសេចក្តីសម្រេចមួយរបស់មន្ទីរ ៨៧០ ចុះថ្ងៃទី ៣ ខែមករា ឆ្នាំ ១៩៧៨ និងបានបញ្ជាក់ថាសេចក្តីសម្រេចនោះមានចំណារសរសេរដោយដៃរបស់ ប៉ុល ពត[116]។ នេះជាឯកសារពណ៌ធម្មជាតិមួយក្នុងចំណោមឯកសារនានាដែលលោក ឆាំង យុ បានបង្ហាញអត្តសញ្ញាណ[117]។ សាក្សីឈ្មោះ សៅ សារុន បានបញ្ជាក់ថាគាត់បានទទួលសេចក្តីណែនាំមួយច្បាប់ពីមជ្ឈិមបក្សចុះថ្ងៃទី២០ ខែ មិថុនា ឆ្នាំ ១៩៧៨ ពាក់ព័ន្ធនឹងពួកក្បត់ក្នុងប្រភេទផ្សេងៗ[118] នៅឯសន្និបាតមជ្ឈិមបក្សនៅចុងឆ្នាំ១៩៧៨។ គាត់បានបញ្ជាក់ថានៅក្នុងសន្និបាតនោះ ប៉ុល ពត ជាអ្នកប្រកាសអំពីគោលការណ៍ណែនាំ ហើយអ្នកចូលរួមត្រូវអានគោលការណ៍ណែនាំនៅក្នុងអង្គប្រជុំតាមមូលដ្ឋាន អង្គភាព និងសហករណ៍[119]។ សាក្សីឈ្មោះ [redacted] បញ្ជាក់ថាគាត់បានឮអំពីការប្រកាសស្រដៀងគ្នា ទៅនឹងការប្រកាសរបស់មន្ទីរ ៨៧០ ចុះថ្ងៃទី ១ ខែមករា ឆ្នាំ១៩៧៩

[111] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ 6.3 (ឯកសារ 115) និង ឯកសារ D248/3.3។ ឯកសារ D189.1 (ឯកសារ 162)។

[112] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ 6.3 (ឯកសារ 115)។

[113] ឯកសារ D200/2.12 (ឯកសារ 155) និង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ 6.6 (ឯកសារ 154)។ ឯកសារ D366/7.1.142 (ឯកសារ 169) និង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ 6.5 (ឯកសារ 170)។

[114] ឯកសារ D366/7.1.139 (ឯកសារ 131) និង ឯកសារ Dl08/50/1.7 (ឯកសារ 146)។

[115] សូមមើល (D311/2) កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆាំង យុ, ថ្ងៃទី ៦ ខែតុលា ឆ្នាំ ២០០៩ ទំព័រ៣ ពាក់ព័ន្ធនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ 6.3 (ឯកសារ 115) និង D248/3.3, D189.1 (ឯកសារ 162), ទំព័រ៤ នៅក្នុង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ 6.5 (ឯកសារ 170) និង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ 6.6 (ឯកសារ 154)។

[116] ឯកសារ D200/2.12 (ឯកសារ 155)(សូមមើលទំព័រ ៧)។ សូមមើលផងដែរ ឯកសារ D200/2 កំណត់ហេតុនៃការស្តាប់ចម្លើយ [redacted], ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៩, ទំព័រ ៩-១០។

[117] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ 6.6 (ឯកសារ 154)។

[118] ឯកសារD248/3.3, D189.1 (ឯកសារ 162)។

[119] សូមមើលផងដែរ ឯកសារD232/30 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី (សៅ សារុន), ថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩ (ត្រង់ទំព័រ៣-៤)។

ពាក់ព័ន្ធនឹងការតស៊ូជាហូរហែរប្រឆាំងវៀតណាម។ គាត់បញ្ជាក់ប្រាប់ថា "ពាក្យពេចន៍ទាំងអស់" ដែលបានកត់ត្រាទុកក្នុងឯកសារនេះ"ត្រូវបានប្រើប្រាស់នៅក្នុងសេចក្តីប្រកាសទៅកាន់យោធា"[120]។

៤៥. លើកលែងតែឯកសារមួយប៉ុណ្ណោះ ឯកសារទាំងអស់សុទ្ធតែ[121] ត្រូវបានប្រមូលដោយមជ្ឈមណ្ឌលឯកសារកម្ពុជាពីប្រភពផ្សេងៗ ក្នុងនោះមានបណ្ណសារទួលស្លែង[122], Ben Kiernan[123], និង David Hawk[124]។ ឯកសារចំនួន៣ ក្នុងចំណោមឯកសារទាំងនោះ ក.ស.ព បានទទួលពី DC-Cam ក្នុងអំឡុងកិច្ចស៊ើបសួរបឋម និងត្រូវបានភ្ជាប់មួយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[125]។ ឯកសារដែល ក.ស.ព បានទទួលពីមជ្ឈមណ្ឌលឯកសារកម្ពុជា មានចំនួន៣ និងបានដាក់បញ្ចូលទៅក្នុងសំណុំរឿង តាមក្រោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[126] និងឯកសារចំនួន២ ត្រូវបាន ក.ស.ច.ស ដាក់បញ្ចូលទៅក្នុងសំណុំរឿងក្នុងអំឡុងកិច្ចស៊ើបសួរ[127]។

៤៦. គួរកត់សម្គាល់ថា ឯកសារទាំង ២ ក្នុងចំណោមឯកសារទាំងអស់នេះ ត្រូវបានដាក់បញ្ចូលទៅក្នុងភ័ស្តុតាងនៃសំណុំរឿង ០០១[128]។

---

[120] សូមមើល ឯកសារ D234/9 **កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ([redacted]), ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៩ ត្រង់ទំព័រ ៦។**

[121] ឯកសារ D200/2.12 (ឯកសារ 155) ពុំមានលេខមជ្ឈមណ្ឌលឯកសារកម្ពុជានៅជ្រុងខាងលើផ្នែកខាងស្តាំឡើយ។

[122] ឯកសារ D366/7.1.139, D108/50/1.7។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ 6.5។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ 6.6. សូមមើល ទិន្នន័យមជ្ឈមណ្ឌលឯកសារកម្ពុជានៅគេហទំព័រ http://www.d.dccam.org/Database/Lod/index.php (អាចស្វែងរកតាមរយៈលេខមជ្ឈមណ្ឌលឯកសារកម្ពុជា)។

[123] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ 6.3 (ឯកសារ 115)។ សូមមើល ទិន្នន័យមជ្ឈមណ្ឌលឯកសារកម្ពុជានៅគេហទំព័រ http://www.d.dccam.org/Database/Lod/details.php?keyword=D00693&numRecords=100&lang=eng&page=1&idnum=D00693។

[124] ឯកសារ D248/3.3, D189.1 (ឯកសារ 162)។ សូមមើល ឯកសារ D311/2 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆាំង យុ, ថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០០៩, ទំព័រ ២-៣។

[125] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ 6.3 (ឯកសារ 115)។ ដីកាសន្និដ្ឋានបញ្ជូរឿងឱ្យស៊ើបសួរ 6.6 (ឯកសារ 154) និង 6.5 (ឯកសារ 170)។

[126] ឯកសារ D366 សំណើរបស់សហព្រះរាជអាជ្ញា សុំដាក់បញ្ចូលឯកសារភ័ស្តុតាងបន្ថែមទៅក្នុងសំណុំរឿង, ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១០ ទាក់ទងទៅនឹងឯកសារ D366/7.1.139 (ឯកសារ 131) និង D366/7.1.142 (ឯកសារ 169) និង D189.1 សំណើសុំទទួលយក សេចក្តីណែនាំរបស់គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា អំពីគោលនយោបាយរបស់បក្សចំពោះការប្រហារជីវិតនៅខែមិថុនា ឆ្នាំ១៩៧៨ និងទស្សនាវដ្តីទង់បដិវត្តន៍ខែសីហា ឆ្នាំ១៩៧៧, ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៩ កថាខណ្ឌ ៣ ពាក់ព័ន្ធនឹងឯកសារ D248/3.3, D189.1 (ឯកសារ 162)។

[127] ឯកសារ D200/2.12 (ឯកសារ 155)។ ឯកសារ D108/50/1.7 (ឯកសារ 146)។

[128] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ 6.6 (ឯកសារ 154) ត្រូវបានទទួលស្គាល់ជាឯកសារ E3/525 និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ IS 6.3 (ឯកសារ 115) ត្រូវបានទទួលស្គាល់ជាឯកសារ E3/13។ ដូចតាមការកត់សម្គាល់ពីខាងដើម ឯកសារ D200/2.12 (ឯកសារ 155)

## ឯកសារបោះពុម្ពផ្សាយផ្សេងទៀតរបស់បក្សកុម្មុយនីស្តកម្ពុជា

៤៧. មានឯកសារបោះពុម្ពផ្សាយរបស់ ប.ក.ក ចំនួន ២២ ទៀតនៅក្នុងបញ្ជីឯកសារ។ ឯកសារទាំងនេះជាច្រើនបង្ហាញពីសញ្ញាសម្គាល់ដែលមានជាទូទៅនៅក្នុងឯកសារ និងការបោះពុម្ពផ្សាយរបស់ ប.ក.ក ដូចដែលបានរៀបរាប់ខាងលើ។ ដោយឡែក ឯកសារចំនួន៩ មានរូបសញ្ញាញញួរ និងកណ្តៀវ នៅក្របខាងមុខ និងខាងខ្នង ឬនៅក្នុងតួនៃឯកសារនោះផង[129]។ សញ្ញាសម្គាល់នោះគេយកមកប្រើប្រាស់នៅក្នុងឯកសារបោះពុម្ពផ្សាយដទៃទៀតរបស់ ប.ក.ក ដែរ ដែលក្នុងនោះរួមមានទស្សនាវដ្តីទង់បដិវត្តន៍ និងទស្សនាវដ្តីយុវជនបដិវត្តន៍។

៤៨. ឯកសារទាំងនេះស្របទៅនឹងគោលបំណងរួមក្នុងការប្រាស្រ័យទាក់ទង និងនិយមន័យដែលគេហៅថាជាគោលនយោបាយ ប.ក.ក។ ឯកសារចំនួនបីបានផ្តោតយ៉ាងច្បាស់ទៅបញ្ហាថ្នាក់ដឹកនាំ[130] ឯកសារចំនួន ៣ ពន្យល់យ៉ាងពិស្តារជាក់លាក់ ឬពិនិត្យពីផែនការបួនឆ្នាំ[131] និងឯកសារចំនួនបី ជាឯកសារចម្លងនៃលក្ខន្តិកៈ ប.ក.ក និងលក្ខន្តិកៈសម្ព័ន្ធយុវជន[132]។ ឯកសារទាំនេះក៏បានប្រើប្រាស់វោហាស័ព្ទដោយឡែក ដែលមានទំនាក់ទំនងរួមជាមួយ ប.ក.ក និងរក្សាមនោគមន៍វិជ្ជា ប.ក.ក ដូចជាពាក្យថា "ចក្រពត្តិអាមេរិក"[133] និង "កម្មេច"[134] ជាដើម។

៤៩. ខ្លឹមសារនៃឯកសារដែលមានចំណងជើងថា *ប្រកាសប្រយុទ្ធជាប្រចាំ និងដាច់ខាតប្រឆាំងនឹងខ្មាំងយួនឈ្លានពានវាតទីលេបទឹកដី*[35] ដែលបានចេញដោយមន្ទីរ ៨៧០ ត្រូវបានសាក្សីឈ្មោះ [redacted] បញ្ជាក់ក្នុងពេលផ្តល់សក្ខីកម្មដែលរៀបចំដោយ ក.ស.ច.ស។ គាត់បានអះអាងថា គាត់

គឺជាសំណៅមួយទៀតនៃឯកសារដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ 6.6។

[129] D366/7.1.229 (ឯកសារ 88); D366/7.1.53 (ឯកសារ 89); D366/7.1.132 (ឯកសារ 94); D366/7.1.134 (ឯកសារ 96);D267/3.36 (ឯកសារ 102); IS 9.1 (ឯកសារ 110); D366/7.1.188 (ឯកសារ 111); D366/7.1.61 (ឯកសារ 120); D366/7.1.459 (ឯកសារ 150)។

[130] D366/7.1.229 (ឯកសារ 88); D366/7.1.53 (ឯកសារ 89); D366/7.1.19 (ឯកសារ 92)។

[131] IS 6.4 (ឯកសារ 125); IS 18.23 (ឯកសារ 136); D366/7.1.56 (ឯកសារ 137)។

[132] D366/7.1.188 (ឯកសារ 111); D366/7.1.187 (ឯកសារ 97); IS 9.1 (ឯកសារ 110)។

[133] D366/7.1.229 (ឯកសារ 88); D366/7.1.133 (ឯកសារ 95); D366/7.1.134 (ឯកសារ 96); D267/3.36 (ឯកសារ 102); D366/7.1.61 (ឯកសារ 120); IS 18.23 (ឯកសារ 136); ERN 00079290- 317 *ថ្មី* (ឯកសារ 164)។

[134] D366/7.1.133 (ឯកសារ 95); D366/7.1.134 (ឯកសារ 96); D267/3.36 (ឯកសារ 102)។

[135] IS 6.5 (ឯកសារ 170)។

"បានឮពីអត្ថន័យ និងខ្លឹមសារស្រដៀងគ្នា" និងបានបញ្ជាក់ថា "ពាក្យពេចន៍ទាំងនេះត្រូវបានប្រើនៅក្នុងការប្រកាសទៅកាន់កងទ័ព"[136]។

៥០. នៅក្នុងការផ្តល់សក្ខីកម្មដែលរៀបចំដោយ ក.ស.ច.ស លោក ឆាំង យុ ជានាយក DC-Cam បានបង្ហាញអត្តសញ្ញាឯកសារចំនួន ៤ និងបានពណ៌នាពីស្ថានភាពដែលរកឃើញឯកសារទាំងនេះ[137]។ គាត់បានបំភ្លឺថា ឯកសារចំនួនពីរក្នុងចំណោមឯកសារទាំងនេះត្រូវបានរកឃើញនៅ ទួលស្លែង[138] ហើយឯកសារចំនួន ២ ទៀត Ben Kiernan បានផ្តល់ឱ្យ DC-Cam[139]។ មូលដ្ឋានទិន្នន័យរបស់ DC-Cam បង្ហាញថាមានឯកសារចំនួន ១៤ ដទៃទៀត នៅក្នុងឯកសារប្រភេទរងនេះត្រូវបាន DC-Cam ប្រមូលពីបណ្ណសារទួលស្លែង (TSL) នៅឆ្នាំ១៩៩៩[140] ហើយឯកសារមួយទៀតត្រូវបានប្រមូលពីក្រសួងមហាផ្ទៃនៅឆ្នាំ១៩៩៩[141]។ ដំណើរការគ្រប់គ្រងឯកសារដែលប្រមូលពី TSL និងពីក្រសួងមហាផ្ទៃ ត្រូវបានរៀបរាប់ដូចខាងលើស្រាប់[142]។ ព័ត៌មាននៅក្នុងសំណុំរឿងបង្ហាញថា ឯកសារមួយទៀតត្រូវបាន Ben Kiernan រកឃើញ និងចម្លងដោយ Ben Kiernan នៅវិទ្យាស្ថានវិទ្យាសាស្ត្រនៅភ្នំពេញ[143]។ ឈ្មោះ "Ben Kiernan" ត្រូវបានសរសេរដោយដៃនៅផ្នែកខាងលើជ្រុងខាងស្តាំទំព័រទី១ នៃឯកសារនេះ។

---

[136] សូមមើល D234/9 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី [redacted] ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៩ ទំព័រ៥។

[137] D311/2 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី (ឆាំង យុ), ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៩ ត្រង់ទំព័រ២-៤, ៦ ទាក់ ទង នឹងឯកសារ IS 6.5 (ឯកសារ 170); IS 6.4 (ឯកសារ 125); IS 6.2 (ឯកសារ 104); IS 9.1 (ឯកសារ 110)។

[138] IS 6.5 (ឯកសារ 170) និង IS 9.1 (ឯកសារ 110)។ សូមមើលផងដែរ មូលដ្ឋានទិន្នន័យ DC-Cam មាននៅ http://www.d.dccam.org/Database/Lod/index.php (អាចស្វែងរកបានតាមរយៈលេខយោងរបស់ DC-Cam)។

[139] IS 6.4 (ឯកសារ 125); IS 6.2 (ឯកសារ 104)។ សូមមើលផងដែរ មូលដ្ឋានទិន្នន័យ DC-Cam មាននៅ http://www.d.dccam.org/Database/Lod/index.php (អាចស្វែងរកបានតាមរយៈលេខយោងរបស់ DC-Cam)។

[140] D366/7.1.134 (ឯកសារ 96); D366/7.1.132 (ឯកសារ 94); D366/7.1.188 (ឯកសារ 111); D366/7.1.187 (ឯកសារ 97) ; D366/7.1.459 (ឯកសារ 150; D366/7.1.54 (ឯកសារ 91); D366/7.1.229 (ឯកសារ 88); D366/7.1.53 (ឯកសារ 89) ; D366/7.1.56 (ឯកសារ 137); D366/7.1.133 (ឯកសារ 95) ; D366/7.1.60 (ឯកសារ 118); D366/7.1.61 (ឯកសារ 120); D366/7.1.57 (ឯកសារ 103); D267/3.36 (ឯកសារ 102)។

[141] ERN 00079290- 317 ថ្មី (ឯកសារ 164)។ សូមមើល មូលដ្ឋានទិន្នន័យ DC-Cam មាននៅ http://www.d.dccam.org/Database/Lod/details.php?keyword=d02180&numRecords=100&lang=eng&page=1&idnum=D02180 ។

[142] សូមមើលផ្នែក I ខាងលើ។

[143] IS 18.23 (ឯកសារ 136)។ សូមមើលឯកសារជាភាសាអង់គ្លេសត្រង់ ERN 00103994 រៀបរាប់ពីប្រភពឯកសារ។

៥១. ជាចុងក្រោយ ប្រការដែលគួរឲ្យកត់សម្គាល់គឺថា ឯកសារចំនួន ៣ ក្នុងចំណោមឯកសារស្ថិតក្នុងអនុប្រភេទនេះត្រូវបានទទួលយកជាភស្តុតាងក្នុងសំណុំរឿង ០០១[144]។

## ៦. ប្រវត្តិរូបនៅសម័យកម្ពុជាប្រជាធិបតេយ្យ

៥២. មានឯកសារចំនួន ៩ នៅក្នុងបញ្ជីឯកសារដែលត្រូវបានចាត់ចូលក្នុងប្រភេទឯកសារស្តីពី "ប្រវត្តិរូបនៅសម័យកម្ពុជាប្រជាធិបតេយ្យ"[145]។ ឯកសារប្រភេទនេះ រួមមានជាគោល គឺឯកសារប្រវត្តិរូបអ្នកទោសនៅ ស-២១ និងប្រវត្តិរូបស្ម័យទិទៀន (ឬជីវទស្សន៍) របស់កម្មាភិបាលក្រសួងការបរទេស។ នៅក្នុងចំណោមឯកសារទាំងនេះ ក៏មានប្រវត្តិរូបរបស់ ឡេង ម៉ាលីស លេខាធិការគណៈកម្មាធិការពាណិជ្ជកម្មផងដែរ[146]។

៥៣. គ្រប់ប្រវត្តិរូបអ្នកទោសនៅ ស-២១ ចំនួន៤[147] សុទ្ធតែបានកត់ត្រាអំពីព័ត៌មាននានាស្តីពីប្រវត្តិរូបរបស់អ្នកទោស ដែលត្រូវបានកំណត់រួចមកហើយ ថាជាគោលដៅនៃការកម្ទេច។ ការធ្វើដូចនេះគឺស្របទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនីសកម្ពុជា ដែលគេបានស្គាល់ថាជាគោលនយោបាយដែលមានលក្ខណៈជាប្រព័ន្ធ ដើម្បីកំណត់អត្តសញ្ញាណ និងបោសសម្អាត "ខ្មាំង" ឬសមាសភាពមិនល្អ។

៥៤. ប្រវត្តិរូបរបស់អ្នកទោសនៅ ស-២១ ទាំងនេះ សុទ្ធតែមានទម្រង់ដូចៗគ្នា។ គ្រប់ឯកសារទាំងអស់នេះ សុទ្ធតែប្រើទម្រង់ដែលមានស្រាប់មួយ ដែលតែងតែដាក់ចំណងជើងឯកសារថា "ប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំង" នៅត្រង់ចំណុចកណ្តាលខាងលើនៃទំព័រ ហើយមានរូបថតអ្នកទោសមួយសន្លឹងបិទនៅត្រង់ចុងខាងស្តាំផ្នែកខាងលើនៃទំព័រនោះផងដែរ។ ខ្លឹមសារនៃឯកសារប្រវត្តិរូបទាំងនេះមានដូចជា៖ ឈ្មោះដើម ឈ្មោះហៅក្រៅ អាយុ ភេទ សញ្ជាតិ ទីកន្លែងកំណើត (ភូមិ សង្កាត់ ស្រុក តំបន់) ក្រសួង និងមុខតំណែងចាប់ពីថ្ងៃចូលបដិវត្តន៍ រហូតមកទល់ពេលបច្ចុប្បន្ន ឬក្រសួង និងមុខតំណែងមុនពេលរំដោះក្រុងភ្នំពេញ និងក្រសួង និងមុខតំណែងនាពេលបច្ចុប្បន្ន ឈ្មោះឪពុក

---

[144] IS 6.5 (ឯកសារ 170) ត្រូវបានទទួលយកជាឯកសារ E3/103; IS 18.23 (ឯកសារ 136) ត្រូវបានទទួលយកជាឯកសារ E3/67; IS 9.1 (ឯកសារ 110) ត្រូវបានទទួលយកជាឯកសារ E3/28។

[145] ឯកសារ 171-179 នៅក្នុងបញ្ជីឯកសារ។

[146] IS 3.3 (ឯកសារ 172)។

[147] មានប្រវត្តិរូបអ្នកទោស ស-២១ ចំនួនបួន នៅក្នុងបញ្ជីឯកសារ៖ IS 3.6 (ឯកសារ 176); IS 3.5 (ឯកសារ179); D288/5.464/2 (ឯកសារ177); IS 3.1, D279/7.8 (ឯកសារ178)។

និងមានពេលខ្លះ មុខរបររបស់គាត់ ឈ្មោះម្ដាយ និងទីកន្លែងកំណើតរបស់គាត់ ទីលំនៅបច្ចុប្បន្ន ចំនួនកូនប្រុស និងកូនស្រី ទីកន្លែងចាប់ខ្លួន (ជាទូទៅ) កាលបរិច្ឆេទនៃការចាប់ខ្លួន លេខផ្ទះ និង ទំហំបន្ទប់ (បន្ទប់ដែលអ្នកទោសត្រូវបានឃុំខ្លួន)។ ចុងបញ្ចប់ នៅខាងចុងទំព័រនៃឯកសារប្រវត្តិរូប ទាំងនេះ មានព័ត៌មានដើម្បីសម្គាល់ [អ្នកទោសនោះ] (ដូចជា កម្ពស់ មាឌ ជាដើម)។

៩៥. ខ្លឹមសារនៃប្រវត្តិរូបរបស់កម្មាភិបាលក្រសួងការបរទេស[148] មានភាពស៊ីសង្វាក់គ្នាជាច្រើន។ បើ ទោះជាមានប្រវត្តិរូបខ្លះមានព័ត៌មានលម្អិតជាងប្រវត្តិរូបផ្សេងទៀតក៏ដោយ ក៏ប្រវត្តិរូបស្ទើរតែទាំង អស់ សុទ្ធតែមានព័ត៌មានស្ដីពីទស្សនៈ និងគោលជំហរនយោបាយ ក៏ដូចជាការចូលរួមនៅក្នុង ស្ថាប័នណាមួយ មុនពេលចូលបដិវត្តន៍ផងដែរ។ ប្រវត្តិរូបទាំងនោះរៀបរាប់លម្អិតអំពីតួនាទីរបស់ ម្ចាស់ប្រវត្តិរូប និងការចូលរួមចំណែកនៅក្នុងបដិវត្តន៍មុននឹងធ្វើការពិនិត្យលើចំណុចខ្លាំង និង ចំណុចខ្សោយនៃអាកប្បកិរិយារបស់បុគ្គលនោះ ព្រមទាំងថាតើអាកប្បកិរិយាដែលប្រឆាំងបដិវត្តន៍ នោះ បានកែប្រែ ឬក៏នឹងត្រូវបានកែប្រែដោយរបៀបណាផងដែរ។

៩៦. ការិយាល័យសហព្រះរាជអាជ្ញា ទទួលបានប្រវត្តិរូបចំនួនបីក្នុងចំណោមប្រវត្តិរូបចំនួនបួន និង ប្រវត្តិរូបរបស់ ឡេង ម៉ាលីស ពីមជ្ឈមណ្ឌលឯកសារកម្ពុជា នៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ បឋម ហើយបានភ្ជាប់ប្រវត្តិរូបទាំងនេះទៅនឹងដីកាបញ្ជូនរឿងឱ្យស៊ើបសួរ។ មជ្ឈមណ្ឌលឯកសារ កម្ពុជារកបានប្រវត្តិរូបអ្នកទោស ស-២១ ម្នាក់ នៅក្រសួងមហាផ្ទៃ នៅក្នុងឆ្នាំ១៩៩៥[149] និងប្រវត្តិ រូបអ្នកទោស ស-២១ ពីរនាក់ទៀត[150] និងប្រវត្តិរូបរបស់ ឡេង ម៉ាលីស[151] នៅទួលស្លែងនៅក្នុង ឆ្នាំ១៩៩៨។

---

[148] មានឯកសារស្វ័យតិះទាន (ជីវទស្សន៍) ចំនួនបួន របស់កម្មាភិបាលនៃក្រសួងការបរទេស នៅក្នុងបញ្ជីឯកសារ៖ D366/7.1.830 (ឯកសារ174); D366/7.1.829 (ឯកសារ173); D366/7.1.831 (ឯកសារ175) និងប្រវត្តិរូប ឡុង នរិន្ទ (ឯកសារ171)។ ឯកសារក្រោយនេះ មិនមាននៅក្នុងសំណុំរឿងនៅឡើយទេ តែមាននៅក្នុងឃ្លាំងផ្ទុកឯកសាររួមហើយ។

[149] IS 3.6 (ឯកសារ 176)។ សូមមើល ទិន្នន័យមជ្ឈមណ្ឌលឯកសារកម្ពុជា នៅ http://www.d.dccam.org/Database/Lod/details.php?keyword=I09004&numRecords=100&lang=eng&page=1&idnum=I09004 ។

[150] IS 3.5 (ឯកសារ 179); IS 3.1, D279/7.8 (ឯកសារ 178)។ សូមមើល ទិន្នន័យមជ្ឈមណ្ឌលឯកសារកម្ពុជា នៅ http://www.d.dccam.org/Database/Lod/index.php (អាចស្រាវជ្រាវតាមលេខឯកសារ DC-Cam ឬចំណងជើង)

[151] IS 3.3 (ឯកសារ 172). សូមមើល ទិន្នន័យមជ្ឈមណ្ឌលឯកសារកម្ពុជា នៅ http://www.d.dccam.org/Database/Lod/details.php?keyword=K07887&numRecords=100&lang=eng&page=1&idnum=K07887 ។

៩៧. ប្រវត្តិរូប ស-២១ ដែលនៅសល់មួយទៀត[152] ត្រូវបានដាក់ដោយអង្គភាពជនរងគ្រោះភ្ជាប់មកជាមួយនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ យោងតាមទិន្នន័យឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ឯកសារមួយនេះក៏ត្រូវមជ្ឈមណ្ឌលរកបានមកពីក្រសួងមហាផ្ទៃ នៅក្នុងឆ្នាំ១៩៩៥ ផងដែរ[153]។ ខ្សែសង្វាក់ក្នុងការគ្រប់គ្រងឯកសារដែលប្រមូលបានពីក្រសួងមហាផ្ទៃនេះ ត្រូវបានលើកឡើងពីដំបូងរួចហើយ[154]។

៩៨. ប្រវត្តិរូបទាំងបួន ដែលបានមកពីកម្មាភិបាលរបស់ក្រសួងការបរទេស ត្រូវប្រមូលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយការិយាល័យសហព្រះរាជអាជ្ញា ហើយបានដាក់ចូលទៅក្នុងសំណុំរឿង ឬឃ្លាំងផ្ទុកឯកសាររួម (“SMD”) បន្ទាប់ពីកិច្ចស៊ើបសួរបឋម។ យោងតាមទិន្នន័យឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ប្រវត្តិរូបទាំងនេះត្រូវប្រមូលបាននៅក្រសួងមហាផ្ទៃ[155]។

៩៩. ប្រវត្តិរូបរបស់ ឆ្កោក លួន ហៅ យ៉ាន ដែលជាកម្មាភិបាលមួយរូបនៅក្រសួងការបរទេស ត្រូវបានទទួលយកធ្វើជាភ័ស្តុតាងនៅក្នុងសំណុំរឿង០០១[156]។ បន្ថែមលើនេះ ប្រវត្តិរូបនៅសម័យកម្ពុជាប្រជាធិបតេយ្យចំនួន១២ទៀតក៏ត្រូវបានទទួលយកធ្វើជាភ័ស្តុតាងក្នុងសំណុំរឿង ០០១ ផងដែរ[157]។

## ៧. កំណត់ហេតុពាណិជ្ជកម្មរបស់កម្ពុជាប្រជាធិបតេយ្យ

[152] ឯកសារ D288/5.464/2 (ឯកសារ 177)។

[153]សូមមើលទិន្នន័យមជ្ឈមណ្ឌលឯកសារកម្ពុជា៖ http://www.d.dccam.org/Database/Lod/details.php?keyword=I08990&numRecords=100&lang=eng&page=1&idnum=I08990 ។

[154] សូមអាន ផ្នែក I ខាងលើ ។

[155] សូមមើល ទិន្នន័យមជ្ឈមណ្ឌលឯកសារកម្ពុជា នៅ http://www.d.dccam.org/Database/Lod/index.php (អាចស្វែងរកតាមរយៈលេខឯកសារ ឬ ចំណងជើង មជ្ឈមណ្ឌលឯកសារកម្ពុជា)។

[156] ឯកសារ D288/5.464/2 (ឯកសារ 177) ទទួលយកជាឯកសារ E3/464/2។

[157] ឯកសារ D22/175.3, D 22/174.5 (ទទួលយកជាឯកសារ E3/476/2); D288/5.470/2 (ទទួលយកជាឯកសារ E3/470/2); D288/5.469/2 (ទទួលយកជាឯកសារ E3/469/2); D2-15.37 (ទទួលយកជាឯកសារ E3/77); D2-15.33 (ទទួលយកជាឯកសារ E3/76); D288/5.471/2 (ទទួលយកជាឯកសារ E3/471/2);D2-15.36 (ទទួលយកជាឯកសារ E3/074);D108/26.58 (ទទួលយកជាឯកសារ E3/075);D22/22/3 (ទទួលយកជាឯកសារ E3/468/3);D22/17/2 (ទទួលយកជាឯកសារ E3/503/2);D22/15/2 (ទទួលយកជាឯកសារ E3/478/2);D2-15.34 (ទទួលយកជាឯកសារ E3/78)។ ឯកសារទាំងនេះមាននៅក្នុងឯកសារ E9/31 បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា ស្របតាមវិធាន៨០(៣), ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១១។

៦០. បញ្ជីឈ្មោះឯកសារនេះមានឯកសារចំនួន១៦៩ ដែលត្រូវចាត់ចូលក្នុងប្រភេទជា "កំណត់ហេតុពាណិជ្ជកម្មរបស់កម្ពុជាប្រជាធិបតេយ្យ"[១៥៨]។ ឯកសារទាំងនេះមានដូចជារបាយការណ៍ ការប្រាស្រ័យទាក់ទង, បញ្ជីតម្លៃទំនិញ និងបញ្ជីកត់ត្រាចេញ-ចូលទំនិញទាក់ទងនឹងពាណិជ្ជកម្មធម្មតា និងបញ្ហាពាណិជ្ជកម្មផ្សេងៗ។

៦១. សាក្សី ស គឹមល្មុត[១៥៩], ដែលបានធ្វើការនៅក្នុងធនាគារពាណិជ្ជកម្មក្រៅប្រទេសកម្ពុជាស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងពាណិជ្ជកម្មបានបញ្ជាក់ និងពិភាក្សាលើឯកសារពាណិជ្ជកម្មចំនួន១៤ ក្នុងអំឡុងនៃកិច្ចសម្ភាសន៍ជាមួយគាត់ដែលធ្វើឡើង ដោយការិយាល័យសហចៅក្រមស៊ើបអង្កេត[១៦០]។ គាត់បានពិនិត្យឯកសារទាំងនេះ និងបានបញ្ជាក់ថា អក្សរសរសេរដៃ និងហត្ថលេខាលើឯកសារចំនួន ១១នេះ[១៦១] គឺជាអក្សរ និងហត្ថលេខារបស់ វ៉ាន់ រិទ្ធ ដែលជាលេខាពាណិជ្ជកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ អក្សរសរសេរដៃ និងហត្ថលេខាដែលបានធ្វើយថាភូតដោយ ស គឹមល្មុត ត្រូវបានប្រទះឃើញនៅលើឯកសារចំនួន១០៧ឯកសារ នៅក្នុងកម្រងឯកសារនេះ[១៦២]។

---

[១៥៨] កត់សម្គាល់ថា ឯកសារ D161/1.32 (ឯកសារ 298) និង D366/7.1.213 (ឯកសារ 299) គឺជាឯកសារថតចម្លងខុសគ្នាពីឯកសារតែមួយដូចគ្នា ដែលឯកសារទីមួយ ក.ស.ច.ស បានមកពីបណ្ណសារដ្ឋានជាតិ ហើយឯកសារទីពីរ ក.ស.ព បានមកពី DC-Cam។

[១៥៩] TCW 583 (ត្រូវបានបញ្ជាក់អត្តសញ្ញាណជា ស គឹមល្មុត នៅក្នុងឯកសារ E131/17 ដីកាកោះហៅសាក្សី, ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១១)។

[១៦០] D161/1.28 (ឯកសារ 319);D161/1.30, D279/6.5 (ឯកសារ 180); D161/1.31, D279/6.2 (ឯកសារ 334); D279/6.3 (ឯកសារ 341); D161/1.7, D279/6.4 (ឯកសារ 332); D161/1.9, D279/6.13 (ឯកសារ 263); D161/1.25, D279/6.10 (ឯកសារ 303); IS 21.142, D279/7.7 (ឯកសារ 323); D161/1.21, D279/6.9 (ឯកសារ 276); D161/1.27 (ឯកសារ 328); D161/1.20, D279/6.8 (ឯកសារ 272); D161/1.13, D279/6.7 (ឯកសារ 257); D279/7.4 (ឯកសារ 345) D161/1.14, D279/6.6 (ឯកសារ 246)។ សូមមើល D279/6 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ស គឹមល្មុត ហៅ មី, ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩ ត្រង់កថាខ័ណ្ឌ៩-១០; D279/7 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី, ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៩ ត្រង់កថាខ័ណ្ឌ៥,៧។

[១៦១] D161/1.28 (ឯកសារ 319); D161/1.30, D279/6.5 (ឯកសារ 180); D161/1.31, D279/6.2 (ឯកសារ 334); D279/6.3 (ឯកសារ 341); D161/1.7, D279/6.4 (ឯកសារ 332); D161/1.25, D279/6.10 (ឯកសារ 303); D161/1.21, D279/6.9 (ឯកសារ 276); D161/1.27 (ឯកសារ 328); D161/1.20, D279/6.8 (ឯកសារ 272); D161/1.13, D279/6.7 (ឯកសារ 257); D161/1.14, D279/6.6 (ឯកសារ 246)។

[១៦២] D366/7.1.823 (ឯកសារ 181); IS 10.3 (ឯកសារ 182); IS 18.16 (ឯកសារ 191); IS 18.51 (ឯកសារ 201); D366/7.1.487 (ឯកសារ 202); (ឯកសារ 203) ថ្មី; D366/7.1.148 (ឯកសារ 206); (ឯកសារ 207) ថ្មី; IS 21.25

៦២. ឯកសារទាំងនេះមានទម្រង់ផ្នែកខាងក្នុងជាច្រើនដែលអាចជឿទុកចិត្តបាន។ បញ្ជីកំណត់ហេតុពាណិជ្ជកម្មនេះ មានរបាយការណ៍ចំនួន៣៥ ដែលធ្វើឡើងដោយកម្មាភិបាលក្រសួងពាណិជ្ជកម្មពីកិច្ចប្រជុំចរចាពាណិជ្ជកម្មជាមួយគណៈប្រតិភូបរទេស[១៦៣]។ ឯកសារទាំងនេះមានទម្រង់ទូទៅ

---

(ឯកសារ 209); D161/1.18 (ឯកសារ 214); IS 21.30 (ឯកសារ 213); IS 21.34 (ឯកសារ 215); D366/7.1.160 (ឯកសារ 217); IS 10.7 (ឯកសារ 216); IS 18.50 (ឯកសារ 219); IS 21.38 (ឯកសារ 220); IS 18.53 (ឯកសារ 222); IS 21.49 (ឯកសារ 224); D161/1.17 (ឯកសារ 223); D366/7.1.806 (ឯកសារ 225); D366/7.1.509 (ឯកសារ 226); D366/7.1.510 (ឯកសារ 227); D366/7.1.511 (ឯកសារ 228); D161/1.48 (ឯកសារ 229); IS 21.72 (ឯកសារ 230); IS 21.75 (ឯកសារ 231); IS 18.57 (ឯកសារ 234); D161/1.11 (ឯកសារ 235); IS 21.82 (ឯកសារ 239); D161/1.52 (ឯកសារ 240); IS 21.85 (ឯកសារ 242); IS 21.89 (ឯកសារ 243); D161/1.15 (ឯកសារ 245); IS 21.88 (ឯកសារ 244); IS 21.90 (ឯកសារ 247); IS 21.92 (ឯកសារ 250); IS 21.93 (ឯកសារ 249); D161/1.12 (ឯកសារ 251); D366/7.1.514 (ឯកសារ 253); IS 21.95 (ឯកសារ 254); IS 21.97 (ឯកសារ 256); D161/1.10 (ឯកសារ 258); IS 21.98 (ឯកសារ 255); D366/7.1.813 (ឯកសារ 260); D366/7.1.517 (ឯកសារ 261); D161/1.9, D279/6.13 (ឯកសារ 263); IS 21.103 (ឯកសារ 264); D161/1.8 (ឯកសារ 267); D161/1.19 (ឯកសារ 266); IS 21.104 (ឯកសារ 268); IS 21.110 (ឯកសារ 270); D119.1 (ឯកសារ 271); IS 21.114 (ឯកសារ 273); IS 21.119 (ឯកសារ 275); D161/1.23 (ឯកសារ 277); IS 21.120 (ឯកសារ 278); D366/7.1.519 (ឯកសារ 279); IS 21.128 (ឯកសារ 280); D366/7.1.520 (ឯកសារ 281); D161/1.22 (ឯកសារ 282); IS 21.129 (ឯកសារ 283); D366/7.1.521 (ឯកសារ 284); D161/1.47 (ឯកសារ 286); D366/7.1.523 (ឯកសារ 287); IS 21.132 (ឯកសារ 289); IS 21.131 (ឯកសារ 288); D161/1.24 (ឯកសារ 290); D366/7.1.524 (ឯកសារ 292); D366/7.1.818 (ឯកសារ 293); D161/1.3 (ឯកសារ 296); IS 21.135 (ឯកសារ 294); D161/1.4, D200/3.3, D279/7.5 (ឯកសារ 295); D366/7.1.525 (ឯកសារ 297); D366/7.1.213 (ឯកសារ 299); D161/1.32 (ឯកសារ 298); D366/7.1.526 (ឯកសារ 300); D366/7.1.819 (ឯកសារ 301); IS 21.136 (ឯកសារ 302); D161/1.46 (ឯកសារ 304); D366/7.1.527 (ឯកសារ 305); D161/1.43 (ឯកសារ 306); D366/7.1.528 (ឯកសារ 307); D161/1.45 (ឯកសារ 308); D366/7.1.530 (ឯកសារ 309); D366/7.1.531 (ឯកសារ 310); IS 21.137 (ឯកសារ 311); D161/1.16 (ឯកសារ 312); D366/7.1.532 (ឯកសារ 313); IS 18.68 (ឯកសារ 314); IS 21.139 (ឯកសារ 317); IS 10.15 (ឯកសារ 318); D161/1.34 (ឯកសារ 320); IS 21.143 (ឯកសារ 324); D161/1.26 (ឯកសារ 330); New (ឯកសារ 327); IS 21.145 (ឯកសារ 331); D366/7.1.533 (ឯកសារ 333); D161/1.33 (ឯកសារ 336); D366/7.1.534 (ឯកសារ 337); D366/7.1.535 (ឯកសារ 338); D161/1.37 (ឯកសារ 339); New (ឯកសារ 340); D161/1.29 (ឯកសារ 342); D161/1.36 (ឯកសារ 343); D366/7.1.537 (ឯកសារ 344); D161/1.35 (ឯកសារ 346); D366/7.1.541 (ឯកសារ 348)។

[១៦៣] D248/6.1.12 (ឯកសារ 238); D366/7.1.806 (ឯកសារ 225); D366/7.1.345 (ឯកសារ 248); IS 18.21 (ឯកសារ 195); D366/7.1.353 (ឯកសារ 259); D366/7.1.782 (ឯកសារ 196); D366/7.1.347 (ឯកសារ 262); D366/7.1.350 (ឯកសារ 269); IS 18.51 (ឯកសារ 201); D366/7.1.341 (ឯកសារ 233); D366/7.1.339 (ឯកសារ

ស្រដៀងៗគ្នា, មានសរសេរពេលវេលានៃការធ្វើកំណត់ត្រា, កាលបរិច្ឆេទនៃកិច្ចប្រជុំ, អ្នកចូលរួមក្នុងកិច្ចប្រជុំពីភាគីកម្ពុជាប្រជាធិបតេយ្យ និងពីក្រុមគណៈប្រតិភូបរទេស និងមានអមដោយសេចក្តីសង្ខេបនៃចំណុចសំខាន់ដែលបានពិភាក្សា ក្នុងនោះរួមទាំង “មតិ” និង/ឬ “សំណូមពរ” ពីភាគីនីមួយៗ។ របាយការណ៍ទាំងនេះបានផ្ញើជូនបុគ្គលផ្សេងៗ ក្នុងនោះមាន ខៀវ សំផន (ដោយប្រើឈ្មោះបដិវត្តរបស់គាត់ថា “ហែម”, ឌឿន(ស្វួស វ៉ាស៊ី ហៅ ជឿ ឌឿន) ឬគណៈកម្មាធិការពាណិជ្ជកម្ម និងមានព័ត៌មានលម្អិតទាក់ទងនឹងកិច្ចប្រជុំនានា ដែលអាចដឹងបានតែមន្ត្រីមួយចំនួននៅក្នុងក្រសួងនេះប៉ុណ្ណោះ។ ឯកសារទាំងនេះជារឿយៗមានប្រើឃ្លា និងពាក្យពេចន៍ច្បាស់ៗដែលមានទំនាក់ទំនងជាមួយនឹងបក្សកុម្មុយនីស្តកម្ពុជា។ ឧទាហរណ៍ ឃ្លាថា “គោរព និងស្រឡាញ់” ត្រូវបានប្រើជាញឹកញាប់ នៅផ្នែកខាងលើនៃឯកសារ ហើយឯកសារភាគច្រើនត្រូវបានបញ្ចប់ដោយឃ្លាបង្ហាញពីការគោរពថា “ដោយភាតរភាពបដិវត្តយ៉ាងកក់ក្តៅ” (ឬក៏មានការសំដែងការគោរពផ្សេងៗទៀត)។ វ៉ាន់ រិទ្ធ ត្រូវបានកត់ត្រាថាបានចូលរួមកិច្ចប្រជុំចំនួន១៧ ក្នុងចំណោមកិច្ចប្រជុំនានា[១៦៤] ហើយ ស គឹមល្នុត ត្រូវបានកត់ត្រាថាបានចូលរួមក្នុងកិច្ចប្រជុំនានាចំនួន៧ ក្នុងចំណោមកិច្ចប្រជុំទាំងនោះ[១៦៥]។ ស គឹមល្នុត បានផ្តល់សក្ខីកម្មថា គាត់ត្រូវបានគេហៅឲ្យចូលរួមក្នុងកិច្ចប្រជុំទាំងឡាយណាដែលនិយាយអំពីបញ្ហា “សេដ្ឋកិច្ច និងហិរញ្ញវត្ថុ”[១៦៦]។

198); D366/7.1.351 (ឯកសារ 236); IS 18.11 (ឯកសារ 187); IS 18.19 (ឯកសារ 193); IS 18.20 (ឯកសារ 194); D366/7.1.160 (ឯកសារ 217); D366/7.1.344 (ឯកសារ 326);; IS 18.50 (ឯកសារ 219); D366/7.1.823 (ឯកសារ 181); D366/7.1.789 (ឯកសារ 204); D366/7.1.348 (ឯកសារ 265); D366/7.1.342 (ឯកសារ 237); D366/7.1.784 (ឯកសារ 197); D366/7.1.486 (ឯកសារ 200); D366/7.1.511 (ឯកសារ 228); IS 18.12 (ឯកសារ 188); D248/6.1.11 (ឯកសារ 212); D366/7.1.349 (ឯកសារ 274); IS 18.53 (ឯកសារ 222); D279/7.4 (ឯកសារ 345); D248/6.1.10 (ឯកសារ 205); D366/7.1.346 (ឯកសារ 252); D366/7.1.343 (ឯកសារ 241); D366/7.1.509 (ឯកសារ 226); D366/7.1.510 (ឯកសារ 227)។

[១៦៤] D248/6.1.12 (ឯកសារ 238); D366/7.1.806(ឯកសារ 225); D366/7.1.345 (ឯកសារ 248); D366/7.1.347 (ឯកសារ 262); D366/7.1.160 (ឯកសារ 217);; D366/7.1.344 (ឯកសារ 326);; IS 18.50 (ឯកសារ 219); D366/7.1.348 (ឯកសារ 265); D366/7.1.342 (ឯកសារ 237); D366/7.1.486 (ឯកសារ 200); D366/7.1.511 (ឯកសារ 228); D248/6.1.11 (ឯកសារ 212); D366/7.1.349 (ឯកសារ 274); IS 18.53 (ឯកសារ 222); D279/7.4 (ឯកសារ 345); D366/7.1.346 (ឯកសារ 252); D366/7.1.343 (ឯកសារ 241); D366/7.1.510 (ឯកសារ 227)។

[១៦៥] D366/7.1.160; IS 18.50; D366/7.1.348; D248/6.1.11; IS 18.53; D366/7.1.509; D366/7.1.510។

[១៦៦] D297/7 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី (ស គឹមល្នុត), ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៩ ត្រង់ទំព័រ៥។

៦៣. មានកំណត់ត្រានៃការចុះបញ្ជីចេញ-ចូលទំនិញចំនួន៥៤ ទាក់ទងនឹងការប្រើប្រាស់ឥណទានដែលមានទឹកប្រាក់ចំនួន "១៤០លានយ៉ាន់"។ បញ្ជីនេះមានទម្រង់ស្ទើរតែប្រហាក់ប្រហែលគ្នាក្នុងការកត់ត្រាតម្លៃសរុបទំនិញដែលបាននាំចេញ និងការទូទាត់ប្រាក់ បន្ទាប់ពីការបំបែកបញ្ជីលម្អិតនៃទំនិញពាក់ព័ន្ធ។ សាក្សី ស គឹមល្អុត បានឆ្លើយថាភូតបញ្ជីមួយក្នុងចំណោមបញ្ជីចេញ-ចូលទំនិញទាំងនេះ[១៦៧]។ គាត់បានបញ្ជាក់បន្ថែមទៀតថា ប្រទេសចិនបានផ្តល់ឥណទានដល់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ សម្រាប់បង្កើតធនាគារពាណិជ្ជកម្មក្រៅប្រទេស និងបានពន្យល់ថា ធនាគារនេះចាំបាច់ត្រូវរៀបចំរបាយការណ៍ទៀតទាត់ដោយធ្វើការកត់ត្រាពីទំនិញដែលបាននាំចេញ ឬនាំចូលដោយប្រើប្រាស់ឥណទាននេះ[១៦៨]។

៦៤. គណៈកម្មាធិការពាណិជ្ជកម្ម ឬ FORTRA (ក្រុមហ៊ុនពាណិជ្ជកម្មក្រៅប្រទេសរបស់កម្ពុជាប្រជាធិបតេយ្យ) ធ្វើការប្រាស្រ័យទាក់ទងជាប្រចាំជាមួយនឹងក្រុមហ៊ុន រ៉ែន ហ្វុង នៅក្នុងទីក្រុងហុង កុង។ ឯកសារទាំងនេះមានទម្រង់ និងរចនាបទដូចគ្នា[១៦៩]។ ឯកសារទាំងនេះមានបង្ហាញលេខសម្គាល់ដើម្បីបញ្ជាក់ពីលេខរៀងនៃការប្រាស្រ័យទាក់ទង រួមទាំងការកំណត់អក្សរដើម្បីបញ្ជាក់ពីទីក្រុងហុង កុង និងឆ្នាំនៃការទំនាក់ទំនង។ ឯកសារទាំងនេះបានសរសេរផ្ញើជូនសមមិត្ត សុក (អ៊ុំង សុក ហៅ សាន សុក) ដែលទទួលខុសត្រូវការិយាល័យនេះ ឬក៏សមមិត្ត គ្រិន (ធុច គ្រិន ហៅ គ្រិន) ដែលឡើងជំនួសសមមិត្ត សុក បន្ទាប់ពីត្រូវបានចាប់ខ្លួន និងសម្លាប់ នៅចុងឆ្នាំ១៩៧៨។

៦៥. ឯកសារយ៉ាងច្រើន (ចំនួន១០១) ត្រូវបានសរសេរដោយប្រើម៉ាស៊ីនអង្គុលីលេខលើផ្នែកខាងក្រោយ និងបញ្ច្រាសក្រដាសសម្គាល់ក្រុមហ៊ុនដែលបានប្រើក្នុងប្រទេសកម្ពុជា នៅមុនសម័យកម្ពុជាប្រជាធិបតេយ្យ។ ក្រដាសដែលបានយកមកប្រើញឹកញាប់មានដូចជា Societe Nationale d'Assurances[១៧០], Chrun You Hats & Family S.A.[១៧១], Societe Khmere De

---

[១៦៧] សូមមើល D279/6 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី (ស គឹមល្អុត ហៅ មី), ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩ ត្រង់ទំព័រ៨-៩ និយាយថា ឯកសារ D161/1.9 គឺ "ធ្វើនៅក្រសួង"។

[១៦៨] ដូចជើងទំព័រខាងលើ។

[១៦៩] IS 21.26 (ឯកសារ 210); IS 21.27 (ឯកសារ 211); IS 21.39 (ឯកសារ 221); IS 21.147, D279/7.9 (ឯកសារ 347) D161/1.3 (ឯកសារ 296); D161/1.45 (ឯកសារ 308); D161/1.37 (ឯកសារ 339); IS 21.72 (ឯកសារ 230); D161/1.35 (ឯកសារ 346); D161/1.43 (ឯកសារ 306); D161/1.4, D200/3.3, D279/7.5 (ឯកសារ 295); D161/1.47 (ឯកសារ 286); D161/1.36 (ឯកសារ 343); D161/1.46 (ឯកសារ 304); D161/1.48 (ឯកសារ 229).។

[១៧០] ឧទាហរណ៍ សូមមើល D161/1.28 (ឯកសារ 319)។

[១៧១] ឧទាហរណ៍ សូមមើល D366/7.1.341 (ឯកសារ 233)។

Transports,[១៧២] និង Henry Wiengartner & Co Inc[១៧៣]។ ឯកសារចំនួន១០ ក្នុងចំណោមឯកសារទាំងនេះដែលត្រូវបានសរសេរលើផ្នែកខាងក្រោយ និងបញ្ជាសក្រដាសសម្គាល់ក្រុមហ៊ុនត្រូវបានបញ្ជាក់ដោយ ស គឹមល្មុត[១៧៤] ហើយនៅក្នុងឯកសារទាំងនេះឯកសារចំនួនពីរ[១៧៥] មានអក្សរសរសេរដៃ និងហត្ថលេខារបស់ វ៉ាន់ រិទ្ធ។ ឯកសារចំនួន៧១ ក្នុងចំណោមឯកសារចំនួន ១០១ នេះត្រូវបានសរសេរផ្នែកខាងក្រោយ និងបញ្ជាសក្រដាសសម្គាល់ក្រុមហ៊ុនដោយប្រើម៉ាស៊ីនអង្គុលីលេខក៏មានចំណារ និង/ឬហត្ថលេខារបស់ វ៉ាន់ រិទ្ធ ដែរ[១៧៦]។

---

[១៧២] ឧទាហរណ៍ សូមមើល IS 21.134 (ឯកសារ 291)។

[១៧៣] ឧទាហរណ៍ សូមមើល IS 21.98 (ឯកសារ 255)។

[១៧៤] D161/1.28 (ឯកសារ 319); D161/1.31, D279/6.2 (ឯកសារ 334); D161/1.9, D279/6.13 (ឯកសារ 263); D161/1.25, D279/6.10 (ឯកសារ 303); IS 21.142, D279/7.7 (ឯកសារ 323); D161/1.21, D279/6.9 (ឯកសារ 276); D161/1.27 (ឯកសារ 328); D161/1.20, D279/6.8 (ឯកសារ 272); D161/1.13, D279/6.7 (ឯកសារ 257); D161/1.14, D279/6.6 (ឯកសារ 246)។

[១៧៥] D161/1.9, D279/6.13 (ឯកសារ 263); IS 21.142, D279/7.7 (ឯកសារ 323)។

[១៧៦] D161/1.48 (ឯកសារ 229); IS 21.129 (ឯកសារ 283); D366/7.1.819 (ឯកសារ 301); D366/7.1.806 (ឯកសារ 225); IS 21.132 (ឯកសារ 289); D161/1.32 (ឯកសារ 298); IS 21.89 (ឯកសារ 243); IS 21.104 (ឯកសារ 268); D161/1.16 (ឯកសារ 312); IS 21.98 (ឯកសារ 255); D161/1.46 (ឯកសារ 304); D161/1.17 (ឯកសារ 223); IS 21.82 (ឯកសារ 239); IS 21.131 (ឯកសារ 288); IS 21.38 (ឯកសារ 220); IS 21.49 (ឯកសារ 224); D161/1.29 (ឯកសារ 342); D161/1.36 (ឯកសារ 343); IS 21.103 (ឯកសារ 264); D161/1.11 (ឯកសារ 235); D161/1.19 (ឯកសារ 266); D119.1 (ឯកសារ 271); D161/1.24 (ឯកសារ 290); IS 21.92 (ឯកសារ 250); D161/1.12 (ឯកសារ 251); IS 21.95 (ឯកសារ 254); D161/1.8 (ឯកសារ 267); D366/7.1.813 (ឯកសារ 260); D366/7.1.534 (ឯកសារ 337); D161/1.47 (ឯកសារ 286); D161/1.18 (ឯកសារ 214); IS 21.135 (ឯកសារ 294); IS 10.7 (ឯកសារ 216); D161/1.26 (ឯកសារ 330); D161/1.4, D200/3.3, D279/7.5 (ឯកសារ 295); D161/1.23 (ឯកសារ 277); IS 21.30 (ឯកសារ 213); IS 21.136 (ឯកសារ 302); IS 21.85 (ឯកសារ 242); D366/7.1.818 (ឯកសារ 293); D161/1.15 (ឯកសារ 245); D366/7.1.537 (ឯកសារ 344); IS 21.137 (ឯកសារ 311); IS 21.34 (ឯកសារ 215); IS 21.114 (ឯកសារ 273); IS 21.93 (ឯកសារ 249); IS 21.128 (ឯកសារ 280); D366/7.1.160 (ឯកសារ 217); IS 21.97 (ឯកសារ 256); IS 18.50 (ឯកសារ 219); D161/1.43 (ឯកសារ 306); IS 21.110 (ឯកសារ 270); IS 21.90 (ឯកសារ 247); D161/1.35 (ឯកសារ 346); D366/7.1.511 (ឯកសារ 228); IS 21.120 (ឯកសារ 278); D366/7.1.510 (ឯកសារ 227); IS 18.53 (ឯកសារ 222); D366/7.1.213 (ឯកសារ 299); IS 21.72 (ឯកសារ 230); IS 21.144 (ឯកសារ 329); D366/7.1.509 (ឯកសារ 226); D161/1.10 (ឯកសារ 258); IS 21.119

៦៦. ការិយាល័យសហចៅក្រមស៊ើបអង្កេតបានទទួលឯកសារចំនួន៤៦ ក្នុងចំណោមឯកសារពាណិជ្ជកម្មទាំងអស់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងបានដាក់ចូលទៅក្នុងសំណុំរឿងក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ[១៧៧]។ ឯកសារចំនួន៣៩ ក្នុងចំណោមឯកសារដែលទទួលបាននេះ ត្រូវបានទទួលពីបណ្ណសារដ្ឋានជាតិ យោងតាមដីកាចាត់ឲ្យស៊ើបសួរជំនួស[១៧៨]។

៦៧. ការិយាល័យសហព្រះរាជអាជ្ញាបានទទួលឯកសារពាណិជ្ជកម្មផ្សេងៗទៀត ក្នុងរបបកម្ពុជាប្រជាធិតេយ្យពីមជ្ឈមណ្ឌលឯកសារកម្ពុជា។ ជាពិសេស ឯកសារចំនួន៦៥ ក្នុងចំណោមឯកសារទាំងនេះ បានទទួលពីមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរបឋម ហើយបានប្រើជាឧបសម្ព័ន្ធភ្ជាប់នឹងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ[១៧៩]។ ឯកសារមួយចំនួនទៀតបានទទួលបន្ទាប់ពីបានចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ ឯកសារចំនួន៥១ ក្នុងចំណោមឯកសារទាំងនេះត្រូវបានដាក់ចូលទៅក្នុងសំណុំរឿង តាមសំណើរបស់ការិយាល័យសហព្រះរាជអាជ្ញា នៅ

(ឯកសារ 275); D161/1.37 (ឯកសារ 339); IS 21.75 (ឯកសារ 231); IS 21.88 (ឯកសារ 244); D161/1.22 (ឯកសារ 282); D161/1.52 (ឯកសារ 240); D161/1.45 (ឯកសារ 308); D161/1.34 (ឯកសារ 320)។

[១៧៧] D119.1 (ឯកសារ 271); D248/6.1.10 (ឯកសារ 205); D248/6.1.11 (ឯកសារ 212); D248/6.1.12 (ឯកសារ 238); D279/6.12 (ឯកសារ 325); D279/6.3 (ឯកសារ 341); D279/7.4 (ឯកសារ 345); D161/1.30, D279/6.5 (ឯកសារ 180); D161/1.18 (ឯកសារ 214); D161/1.17 (ឯកសារ 223); D161/1.48 (ឯកសារ 229); D161/1.11 (ឯកសារ 235); D161/1.52 (ឯកសារ 240); D161/1.14, D279/6.6 (ឯកសារ 246); D161/1.15 (ឯកសារ 245); D161/1.12 (ឯកសារ 251); D161/1.10 (ឯកសារ 258); D161/1.13, D279/6.7 (ឯកសារ 257); D161/1.9, D279/6.13 (ឯកសារ 263); D161/1.19 (ឯកសារ 266); D161/1.8 (ឯកសារ 267); D161/1.20, D279/6.8 (ឯកសារ 272); D161/1.21, D279/6.9 (ឯកសារ 276); D161/1.23 (ឯកសារ 277); D161/1.22 (ឯកសារ 282); D161/1.47 (ឯកសារ 286); D161/1.24 (ឯកសារ 290); D161/1.4, D200/3.3, D279/7.5 (ឯកសារ 295); D161/1.3 (ឯកសារ 296); D161/1.32 (ឯកសារ 298); D161/1.25, D279/6.10 (ឯកសារ 303); D161/1.46 (ឯកសារ 304); D161/1.43 (ឯកសារ 306); D161/1.45 (ឯកសារ 308); D161/1.16 (ឯកសារ 312); D161/1.28 (ឯកសារ 319); D161/1.34 (ឯកសារ 320); D161/1.26 (ឯកសារ 330); D161/1.27 (ឯកសារ 328); D161/1.7, D279/6.4 (ឯកសារ 332); D161/1.31, D279/6.2 (ឯកសារ 334); D161/1.33 (ឯកសារ 336); D161/1.37 (ឯកសារ 339); D161/1.29 (ឯកសារ 342); D161/1.36 (ឯកសារ 343); D161/1.35 (ឯកសារ 346)។

[១៧៨] ឯកសារ ដែលមានលេខយោងផ្តើមដោយ "D161"។ សូមមើល D161 ដីកាចាត់ឲ្យស៊ើបសួរជំនួស, ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩។

[១៧៩] ឯកសារ ដែលមានលេខយោងផ្តើមដោយ "IS"។

ខែកុម្ភៈ ឆ្នាំ២០១០[១៨០]។ ការិយាល័យសហព្រះរាជអាជ្ញាបានទទួលឯកសារ "ថ្មី" ចំនួន៧ទៀត ពីមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយឯកសារទាំងនេះមិនទាន់ត្រូវបានដាក់ទៅក្នុងសំណុំរឿងនៅឡើយ ប៉ុន្តែភាគីអាចចូលមើលឯកសារទាំងនេះនៅក្នុងឃ្លាំងផ្ទុកឯកសាររួម (SMD)[១៨១]។

## ៨. សេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ

៦៨. មានឯកសារចំនួនប្រាំពីរនៅក្នុងបញ្ជីឯកសារដែលត្រូវបានគេចាត់ទុកថាជា "សេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ"[182]។ ឯកសារប្រភេទនេះរួមមានសេចក្តីថ្លែងការណ៍ ឬឯកសារផ្លូវការចេញដោយរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ។

៦៩. ឯកសារទាំងនេះជាកំណត់ហេតុដែលត្រូវបានបង្កើតនាសម័យកាលនោះ ស្តីពីព្រឹត្តិការណ៍នានាដែលបានកត់ត្រាទុក ចាប់ទាំងថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦ រហូតដល់ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ១៩៧៩។ ឯកសារទាំងនេះមានទម្រង់ដូចៗគ្នា ដែលលក្ខណៈខាងក្រៅបង្ហាញពីយថាភូតរបស់វា។ នៅទំព័រទី១ នៃឯកសារនីមួយៗមានបង្ហាញពីអង្គភាពរបស់កម្ពុជាប្រជាធិបតេយ្យ ដែលទទួលខុសត្រូវក្នុងការបញ្ជូនឯកសារនេះ។ មានបោះត្រាផ្លូវការនៅលើទំព័រទី១ នៃឯកសារចំនួនបី[183] ក្នុងចំណោមឯកសារទាំងប្រាំពីរ។ ឯកសារចំនួនពីរ[184] បានបង្ហាញច្បាស់ថាបានផ្ញើចេញពីក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ឯកសារមួយទៀត[185] មានអក្សរចារឹកថា "Mission du Gouvernement du Kampuchea Démocratique en France" រួមទាំងព័ត៌មានសម្រាប់ទំនាក់ទំនងនៅខាងក្រោមទំព័រទី១ផងដែរ។ ទំព័រនីមួយៗត្រូវបានដាក់លេខស្ទើរតែដូចគ្នាបេះបិទ ពោលគឺ

---

[១៨០] ឯកសារ ដែលមានលេខយោងផ្តើមដោយ "D366"។ សូមមើល D366 សំណើរបស់សហព្រះរាជអាជ្ញាសុំដាក់បញ្ចូលឯកសារភ័ស្តុតាងបន្ថែមទៅក្នុងសំណុំរឿង, ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១០។

[១៨១] (ឯកសារ 183) ថ្មី; (ឯកសារ 186) ថ្មី; (ឯកសារ 199) ថ្មី; (ឯកសារ 203) ថ្មី; (ឯកសារ 207) ថ្មី; (ឯកសារ 327) ថ្មី; (ឯកសារ 340) ថ្មី។

[182] ឯកសារ 345-355 នៅក្នុងបញ្ជីឈ្មោះឯកសាររបស់សហព្រះរាជអាជ្ញា។ សេចក្តីថ្លែងការរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យមាន៖ D313/1.2.319 (ឯកសារ 351); IS 12.16 (ឯកសារ 350); D115/2.2, D313/1.2.361 (ឯកសារ 353); D56-Doc. 187 (ឯកសារ 355); D366/7.1.821 (ឯកសារ 354); IS 19.38 (ឯកសារ 352); IS 9.2 (ឯកសារ 349)។

[183] D56-Doc. 187 (ឯកសារ 355); IS 9.2 (ឯកសារ 349); IS 12.16 (ឯកសារ 350)។

[184] D313/1.2.319 (ឯកសារ 351); IS 19.38 (ឯកសារ 352)។

[185] IS 12.16 (ឯកសារ 350)។

នៅចំកណ្តាលឯកសារនីមួយៗ ហើយអាសយដ្ឋាននៃប្រភពឯកសារនោះ (ពោលគឺ ភ្នំពេញ) ត្រូវបានបោះពុម្ពនៅផ្នែកខាងក្រោមនៃឯកសារចំនួនបួន[186] ក្នុងចំណោមឯកសារចំនួនប្រាំពីរនោះ។

៧០. មានភាពស៊ីសង្វាក់គ្នាដែលនៅក្នុងឯកសារទាំងអស់ ដែលមានប្រើពាក្យពេចន៍ជាក់លាក់មួយចំនួនរបស់ ប.ក.ក ដូចជា "ចក្រពត្តិអាមេរិក"[187] "ពួកទេសានុព័ន្ធនិយម"[188] និង "ការឈ្លានពាន"[189]។

៧១. ឯកសារចំនួនប្រាំក្នុងចំណោមឯកសារទាំងប្រាំពីរបានទទួលពី DC-Cam និងដែលបានបញ្ចូលក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងចុងក្រោយបានបញ្ចូលទៅក្នុងសំណុំរឿងទៅតាមសំណើរបស់ ក.ស.ព[190]។ លោក ឆាំង យុ ជានាយក DC-Cam បានបង្ហាញឯកសារមួយក្នុងចំណោមឯកសារទាំងនេះ[191] ក្នុងអំឡុងពេលសាកសួររបស់ ក.ស.ច.ស ហើយបានបញ្ជាក់ថា DC-Cam ជាអ្នករក្សាទុកសំណៅដើមនៃឯកសារនេះ[192]។ ឯកសារមួយទៀត[193] ត្រូវបានផ្តល់យថាភូតដោយសាក្សីឈ្មោះ [redacted] ក្នុងអំឡុងពេលសាកសួរដោយ ក.ស.ច.ស[194]។ ឯកសារទាំងពីរនេះត្រូវបានទទួលយកជាភស្តុតាងក្នុងសំណុំរឿង ០០១[195]។

៧២. ឯកសារចំនួនពីរដែលនៅសេសសល់[196] ក៏ត្រូវបានបញ្ចូលទៅក្នុងសំណុំរឿងដោយ ក.ស.ព និងអាចស្វែងរកត្រឡប់ទៅក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម អ.ស.ប វិញបាន ដែលមានឈ្មោះ រូបសញ្ញាសម្គាល់ និងព័ត៌មានសម្រាប់ទំនាក់ទំនងមាននៅផ្នែកខាងលើនៃទំព័រទី១។

## ៩. របាយការណ៍សារព័ត៌មានពាក់ព័ន្ធនឹងកម្ពុជាប្រជាធិបតេយ្យ

---

[186] D313/1.2.319 (ឯកសារ 351); IS 12.16 (ឯកសារ 350); D115/2.2, D313/1.2.361 (ឯកសារ 353); IS 19.38 (ឯកសារ 352)។

[187] D313/1.2.319 (ឯកសារ 351); IS 12.16 (ឯកសារ 350); D115/2.2, D313/1.2.361 (ឯកសារ 353); D366/7.1.821 (ឯកសារ 354)។

[188] D115/2.2, D313/1.2.361 (ឯកសារ 353)។

[189] D313/1.2.319 (ឯកសារ 351); IS 12.16 (ឯកសារ 350); D115/2.2, D313/1.2.361 (ឯកសារ 353); D56-Doc. 187 (ឯកសារ 355); IS 19.38 (ឯកសារ 352); IS 9.2 (ឯកសារ 349)។

[190] D313/1.2.319 (ឯកសារ 351); IS 12.16 (ឯកសារ 350); D115/2.2, D313/1.2.361 (ឯកសារ 353); D56-Doc. 187 (ឯកសារ 355); IS 9.2 (ឯកសារ 349)។

[191] IS 9.2 (ឯកសារ 349)។

[192] D311/2 កំណត់ហេតុស្តាប់ចម្លើយសាក្សី (ឆាំង យុ) ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៩ ទំព័រ៣។

[193] IS 19.38 (ឯកសារ 352)។

[194] សូមមើល D233/2 កំណត់ហេតុស្តាប់ចម្លើយសាក្សី, ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩។

[195] ត្រូវបានទទួលស្គាល់ជាឯកសារ E3/756 និង E3/027 តាមលំដាប់។

[196] D366/7.1.821 (ឯកសារ 354); D115/2.2, D313/1.2.361 (ឯកសារ 353)។

៧៣. មានឯកសារចំនួន៣០ នៅក្នុងបញ្ជីឯកសារដែលត្រូវបានចាត់ទុកជា "របាយការណ៍សារព័ត៌មានពាក់ព័ន្ធនឹងកម្ពុជាប្រជាធិបតេយ្យ"[197]។ ឯកសារប្រភេទនេះរួមមានព្រឹត្តិប័ត្រព័ត៌មានដែលត្រូវបានបោះពុម្ពផ្សាយដោយរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ និងការបោះពុម្ពផ្សាយរបស់អន្តរជាតិចំពោះព័ត៌មាននានាដែលពាក់ព័ន្ធនឹងរបបកម្ពុជាប្រជាធិបតេយ្យ។

## ព្រឹត្តិប័ត្រព័ត៌មានដែលត្រូវបានបោះពុម្ពផ្សាយដោយរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ

៧៤. មានរបាយការណ៍ចំនួនប្រាំបី[198] នៅក្នុងឯកសារប្រភេទនេះដែលផ្ញើចេញពីអង្គភាពនានារបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ (ពោលគឺ ស្ថានទូតកម្ពុជាប្រជាធិបតេយ្យនៅក្រុងប៉េកាំង ក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យ បេសកកម្មអចិន្ត្រៃយ៍កម្ពុជាប្រជាធិបតេយ្យប្រចាំទីក្រុងហ្សឺណែវ និងទីភ្នាក់ងារសារព័ត៌មានកម្ពុជាប្រជាធិបតេយ្យ)។ ឯកសារទាំងនេះមានចាប់ពីថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ១៩៧៨ រហូតដល់ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៨០ និងកំណត់ហេតុទាំងអស់ស្តីពីព្រឹត្តិការណ៍នានាដែលបានកត់ត្រានាសម័យកាលនោះ។

៧៥. របាយការណ៍ចំនួនបី[199] ក្នុងចំណោមរបាយការណ៍ទាំងនោះមានចំណងជើងថា 'Nouvelles du Kampuchea'។ ឯកសារទាំងនេះមានទម្រង់ដូចគ្នាសម្រាប់ប្រើប្រាស់ផ្ទៃក្នុង។ ចំណងជើងនៅលើទំព័រទី១ ត្រូវបានឆ្លាក់ជាអក្សរធំៗនៅចំកណ្តាលផ្នែកខាងលើ អមដោយពាក្យថា ឯកសារនេះត្រូវបានផ្សព្វផ្សាយដោយ 'La Voix du Kampuchea Democratique' និងមានពាក្យថា វាជារបាយការណ៍ព័ត៌មានដែលត្រូវបានបោះពុម្ពផ្សាយដោយនាយកដ្ឋានសារព័ត៌មាន និងព័ត៌មាននៃក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យ។ នៅផ្នែកខាងក្រោមនៃទំព័រទី១ ក៏មានលេខ កាលបរិច្ឆេទ និងអត្ថបទសង្ខេប។

៧៦. របាយការណ៍ចំនួនពីរ[200] ក្នុងចំណោមរបាយការណ៍ទាំងនេះដែលមានចំណងជើងថា ព្រឹត្តប័ត្រព័ត៌មាន 'Bulletin D'information'។ របាយការណ៍ទាំងនេះមានទម្រង់ដូចៗគ្នាសម្រាប់ប្រើប្រាស់ផ្ទៃក្នុង។ ទំព័រទី១ រួមមានត្រាផ្លូវការរបស់កម្ពុជាប្រជាធិបតេយ្យដែលអមដោយពាក្យថា ព្រឹត្តប័ត្រ

---

[197] ឯកសារ 356-385 នៅលើបញ្ជីឯកសារ។

[198] D56-Doc. 190 (ឯកសារ 384); D56-Doc. 146 (ឯកសារ 380); D56-Doc. 197, D56-Doc. 197/Corr-1 (ឯកសារ 385); D366/7.1.538 (ឯកសារ 381); D56-Doc. 186 (ឯកសារ 383); D56-Doc. 173 (ឯកសារ 382); D56-Doc. 142 (ឯកសារ 378); D56-Doc. 128 (ឯកសារ 377)។

[199] D56-Doc. 146 (ឯកសារ 380); D56-Doc. 142 (ឯកសារ 378); D56-Doc. 128 (ឯកសារ 377)។

[200] D56-Doc. 190 (ឯកសារ 384); D56-Doc. 186 (ឯកសារ 383)។

ព័ត៌មានកម្ពុជាប្រជាធិបតេយ្យ "Kampuchea Democratique, Bulletin d'information" ជាអក្សរពុម្ពធំ និងព័ត៌មានស្តីពីការបោះពុម្ពផ្សាយនៅផ្នែកខាងក្រោមដែលដាក់ថា បោះផ្សាយដោយស្ថានទូតនៃកម្ពុជាប្រជាធិបតេយ្យ ប្រចាំទីក្រុងប៉េកាំង "Publie par L'Ambassade du Kampuchea Democratique - Beijing"។ លេខ កាលបរិច្ឆេទ និងតារាងមាតិកាមាននៅលើទំព័រទី១។ របាយការណ៍មួយទៀត[201] ក៏ស្របគ្នាជាមួយនឹងឯកសារទាំងពីរនេះដែរ។ ពោលគឺ ព្រឹត្តប័ត្រព័ត៌មាន 'News Bulletin' មាននៅលើទំព័រទី១ ដែលស្ថិតនៅខាងក្រោមត្រាផ្លូវការរបស់កម្ពុជាប្រជាធិបតេយ្យ និងពាក្យថា "កម្ពុជាប្រជាធិបតេយ្យ"។ នៅខាងក្រោមនេះ គេកត់សម្គាល់ថា ឯកសារនេះ "ត្រូវបានចេញផ្សាយដោយស្ថានទូតកម្ពុជាប្រជាធិបតេយ្យនៅទីក្រុងប៉េកាំង"។ ចុងក្រោយ លេខ កាលបរិច្ឆេទ និងតារាងមាតិកាក៏មាននៅលើទំព័រទី១ នេះដែរ។

៧៧. ឯកសារពីរចុងក្រោយនៅក្នុងឯកសារប្រភេទដូចគ្នានេះដែរ សុទ្ធតែបង្ហាញពីលក្ខណៈផ្ទៃក្នុងដែលអាចជឿជាក់បាន។ ឯកសារមួយមានបោះត្រាផ្លូវការនៅផ្នែកខាងលើកណ្តាលទំព័រទី១ ដោយមានឈ្មោះកន្លែងបោះពុម្ពផ្សាយ និងព័ត៌មានសម្រាប់ទំនាក់ទំនងនៅផ្នែកខាងឆ្វេង[202]។ តារាងមាតិកាដែលមានលក្ខណៈដូចគ្នានឹងព័ត៌មាន/ព្រឹត្តិប័ត្រព័ត៌មានកម្ពុជាប្រជាធិបតេយ្យដទៃទៀតដែរ មាននៅលើទំព័រទី២។ ស្រដៀងគ្នានេះដែរ ឯកសារទីពីរមានឈ្មោះកន្លែងបោះពុម្ពផ្សាយនៅខាងក្រោមចំណងជើង "ព្រឹត្តិប័ត្រព័ត៌មាន" ដែលស្ថិតនៅផ្នែកខាងលើកណ្តាលទំព័រទី១[203]។ លេខ កាលបរិច្ឆេទ និងតារាងមាតិកាក៏មាននៅលើទំព័រទី១ដែរ ដោយស៊ីសង្វាក់គ្នាជាមួយនឹងព័ត៌មាន/ព្រឹត្តិប័ត្រព័ត៌មានកម្ពុជាប្រជាធិបតេយ្យផ្សេងៗទៀត។

៧៨. ព្រឹត្តិប័ត្រព័ត៌មានទាំងអស់ដែលត្រូវបានបោះពុម្ពផ្សាយដោយរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ត្រូវបានដាក់ក្នុងសំណុំរឿង ដោយ ក.ស.ព។ ឯកសារទាំងនេះត្រូវបានផ្តល់ឲ្យ ក.ស.ព បន្ទាប់ពី DC-Cam បានប្រមូលផ្តុំចងក្រងមកពីបណ្ណាំឯកសារដែលគេហៅថាកម្រងឯកសាររបស់ប្រទេសស៊ុយអែត (Swedish Collection) កាលពីក្នុងខែកុម្ភៈ ឆ្នាំ២០០៧[204]។

---

[201] D56-Doc. 173 (ឯកសារ 382)។

[202] D56-Doc. 197, D56-Doc. 197/Corr-1 (ឯកសារ 385)។

[203] D366/7.1.538 (ឯកសារ 381)។

[204] សូមមើល មូលដ្ឋានទិន្នន័យ DC-Cam មាននៅ៖ http://www.d.dccam.org/Database/Lod/index.php។

*ការបោះពុម្ពផ្សាយជាអន្តរជាតិនៃរបាយការណ៍ព័ត៌មានរបស់កម្ពុជាប្រជាធិបតេយ្យ*

៧៩. មានរបាយការណ៍ចំនួន២២ នៅក្នុងឯកសារប្រភេទនេះ ដែលបានមកពីសេចក្ដីសង្ខេបព័ត៌មាននៃការផ្សាយទូទាំងពិភពលោក (SWB) របស់វិទ្យុ BBC ឬសេវាផ្សព្វផ្សាយព័ត៌មានបរទេស (FBIS) របស់សេអ៊ីអា។ របាយការណ៍ទាំងអស់នេះ គឺជាកំណត់ហេតុដែលអ្នកកាសែតកត់ត្រាអំពីព្រឹត្តិការណ៍នានាដែលបានកើតឡើងនាពេលនោះ ដែលពួកគេបានអះអាងថា ចាប់តាំងពីថ្ងៃទី១ ខែសីហា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៧៨។

៨០. មានរបាយការណ៍ SWB ចំនួនបួន[205] ដែលក្នុងចំណោមនេះ មានរបាយការណ៍ចំនួនបីមានទម្រង់ដូចគ្នាបេះបិទ។ លក្ខណៈអក្សរ និងសណ្ឋាននៅក្នុងឯកសារនេះទាំងមូល គឺសុទ្ធតែមានលក្ខណៈស្តង់ដាដូចៗគ្នា។ អក្សរកាត់ "SWS" ត្រូវបានបោះពុម្ពនៅជ្រុងខាងលើនៃផ្នែកខាងឆ្វេងនៃទំព័រនីមួយៗ ហើយកាលបរិច្ឆេទ គឺស្ថិតនៅជ្រុងខាងលើនៃផ្នែកខាងស្តាំ។ នៅចន្លោះសូចនាពីរនេះ បង្ហាញលេខមួយជួរ ដែលចាប់ផ្ដើមដោយអក្សរ "FE" ហើយបន្ទាប់មកមានលេខបួនខ្ទង់ និងអក្សរ "A3" និងលេខរាយ ដែលញែកចេញពីគ្នាដោយសញ្ញា "/"។ មានឯកសារមួយ ដែលមានទម្រង់ខុសពីនេះបន្តិច ក្នុងនោះវាមានអត្ថបទពេញមួយដែលសរសេរថា "សេចក្ដីសង្ខេបព័ត៌មាននៃការផ្សាយទូទាំងពិភពលោក" ដែលបានបោះពុម្ពនៅជ្រុងខាងលើនៃផ្នែកខាងឆ្វេង[206]។ លក្ខណៈអក្សរ និងសណ្ឋាន គឺនៅតែមានលក្ខណៈដូចគ្នាទៅនឹងឯកសារផ្សេងៗទៀតដែលនៅក្នុងប្រភេទដូចគ្នានេះ។

៨១. មានរបាយការណ៍ FBIS ចំនួន ១៨[207] ដែលឯកសារទាំងអស់នោះសុទ្ធតែមានទម្រង់ លក្ខណៈអក្សរ និងសណ្ឋានស្រដៀងៗគ្នា។ របាយការណ៍នីមួយៗសុទ្ធតែមានលេខរ៉ូម៉ាំង "IV" និងកាលបរិច្ឆេទដែលបានបោះពុម្ពនៅជ្រុងខាងលើនៃផ្នែកខាងឆ្វេងក្នុងទំព័រនីមួយៗ។ ពាក្យ "Cambodia" និងលេខទំព័រ (ត្រូវបានដាក់នៅពីក្រោយអក្សរ H) ក៏ត្រូវបានបោះពុម្ពនៅផ្នែកខាងលើនៃទំព័រនីមួយៗដែរ។

---

[205] IS 12.24 (ឯកសារ 369); D56-Doc. 069 (ឯកសារ 364); D313/1.2.336 (ឯកសារ 370); D56-Doc. 143 (ឯកសារ 379)។

[206] D313/1.2.336 (ឯកសារ 370)។

[207] D262.29 (ឯកសារ 365); New (D262.36 សម្រង់) (ឯកសារ 372); D262.16 (ឯកសារ 357); D262.16 (ឯកសារ 357); D262.34 (ឯកសារ 368); D262.19 (ឯកសារ 359); D262.26 (ឯកសារ 362); D262.36, D262.36/ច្បាប់កែតម្រូវ -1 (ឯកសារ 371); D262.42 (ឯកសារ 375); D262.21 (ឯកសារ 361); D262.44 (ឯកសារ 361); D262.27 (ឯកសារ 363); New (D196.12 សម្រង់) (ឯកសារ 374); D262.32 (ឯកសារ 367); D262.9 (ឯកសារ 356); D262.30 (ឯកសារ 366); D262.17 (ឯកសារ 358); D196.12 (ឯកសារ 373); D262.20 (ឯកសារ 360)។

៨២. ទាក់ទងអំពីប្រភពដើម របាយការណ៍ទាំងអស់នៅក្នុងប្រភេទនេះ ត្រូវបានដាក់នៅក្នុងសំណុំរឿង ដោយ កសព។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្ដល់របាយការណ៍ SWBទាំងនេះ មកឲ្យ កសព។ របាយការណ៍ទាំងអស់ លើកលែងតែរបាយការណ៍មួយ[208] ក្នុងចំណោមឯកសារទាំងនេះចេញ ដែលត្រូវបានកត់ត្រាទុកនៅក្នុងមូលដ្ឋានទិន្នន័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដោយសារតែ របាយការណ៍នេះទទួលបានមកពី Swedish collection ក្នុងខែកុម្ភៈ ឆ្នាំ២០០៧[209]។ ការិយាល័យ សហចៅក្រមស៊ើបអង្កេតបានទទួលរបាយការណ៍របស់ FBIS ពីបណ្ណាល័យនៃសាកលវិទ្យាល័យ Harvard ក្នុងអំឡុងពេលនៃការស៊ើបសួរ ហើយបានដាក់ចូលទៅក្នុងឃ្លាំងផ្ទុកឯកសាររួម (Shared Material Drive) ក្នុងខែមិថុនា ឆ្នាំ២០០៨។ បន្ទាប់មក របាយការណ៍ទាំងនេះ ត្រូវបាន ដាក់បញ្ចូលនៅក្នុងសំណុំរឿងតាមសំណើរបស់ កសព[210]។

## ១០. សំណេរដែលពាក់ព័ន្ធនឹងកម្ពុជាប្រជាធិបតេយ្យ

៨៣. មានឯកសារចំនួនបីនៅក្នុងបញ្ជីឯកសារ ដែលត្រូវចាត់ថ្នាក់ជា "សំណេរដែលពាក់ព័ន្ធនឹងកម្ពុជាប្រជាធិបតេយ្យ"[211]។ បណ្ដុំសំណេរដែទីមួយត្រូវបានកត់ត្រាដោយអ្នកកាសែតឈ្មោះ Elizabeth Becker ក្នុងអំឡុងពេលនៃដំណើរទស្សនកិច្ចរបស់គាត់ទៅកាន់កម្ពុជាប្រជាធិបតេយ្យ ក្នុងពាក់ កណ្ដាលខែធ្នូ ឆ្នាំ ១៩៧៨[212]។ បណ្ដុំសំណេរដែទីពីរ ត្រូវបានកត់ត្រាដោយកម្មាភិបាលបក្ស កុម្មុយនីស្តកម្ពុជាម្នាក់ ក្នុងអំឡុងពេលនៃវគ្គបំពាក់បំប៉ននយោបាយនៅថ្ងៃទី២៦ ខែមេសា ឆ្នាំ ១៩៧៨[213]។ បណ្ដុំសំណេរដែទីបី ត្រូវបានកត់ត្រាដោយកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាម្នាក់ និង រួមមានសំណេរដែនានាស្ដីពីសុន្ទរកថា ឯកសារ និងកិច្ចប្រជុំនានា នៅក្រសួងការបរទេសរបស់

[208] D313/1.2.336 (ឯកសារ 370)។

[209] សូមមើល មូលដ្ឋានទិន្នន័យ DC-Cam មាននៅ៖ http://www.d.dccam.org/Database/Lod/index.php ។

[210] សេចក្ដីរាយការណ៍ចំនួន១៦ (*គឺ* សេចក្ដីរាយការណ៍ដែលមានលេខយោងចាប់ផ្ដើមដោយ D262) ត្រូវបានដាក់ អនុលោមតាម ឯកសារ D262 នៃសំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យដាក់របាយការណ៍ ស្ដីពីសេវាផ្សព្វផ្សាយព័ត៌មានបរទេស បញ្ចូលក្នុងសំណុំរឿង, ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩។ សេចក្ដីរាយការណ៍សំខាន់ពីរត្រូវបានភ្ជាប់ទៅនឹងសេចក្ដីសន្និដ្ឋានបន្ថែមរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៩។

[211] ឯកសារ 386-388 នៅក្នុងបញ្ជីឈ្មោះឯកសាររបស់សហព្រះរាជអាជ្ញា។

[212] D366/7.1.408 (ឯកសារ 388)។

[213] ថ្មី (ឯកសារ 387)។

កម្ពុជាប្រជាធិបតេយ្យ រវាងឆ្នាំ១៩៧៦ និងឆ្នាំ១៩៧៩[214]។ មានមតិយោបល់ជាច្រើននៅក្នុងឯកសារនេះ មានការជាប់ពាក់ព័ន្ធជាមួយនឹង "វ៉ាន់" ដែលជាឈ្មោះបដិវត្តរបស់ អៀង សារី។

៨៤. បណ្តុំសំណេរដៃចំនួនពីរដែលរៀបចំឡើងដោយកម្មាភិបាលទាំងពីរនាក់របស់បក្សកុម្មុយនីស្តកម្ពុជា សុទ្ធតែប្រើពាក្យពេចន៍ខុសប្លែកពីគ្នា ដូចជា "គោលជំហរសមូហភាព" "ការសម្លាប់ គឺជាមូលដ្ឋានដ៏ចម្បង" "មានជនក្បត់ពី១% ទៅ ៥%" "ស៊ើបប្រវត្តិ" "បីគោនក្នុងមួយហិចតា" និង "ការប្រុងប្រយ័ត្នបដិវត្តន៍" ដែលមានការពាក់ព័ន្ធជាទូទៅជាមួយនឹងបក្សកុម្មុយនីស្តកម្ពុជា និងការរក្សាមនោគមន៍វិជ្ជារបស់ខ្លួន។ សំណេរដៃដែលអ្នកកាសែតបានកត់ត្រា គឺស្ថិតនៅក្នុងដៃរបស់គាត់ ដោយមានសរសេរជាអក្សរកាត់តាមទម្រង់របស់គាត់ ហើយសំណេរដៃទាំងនោះ កត់ត្រានូវកន្លែងកើតហេតុ និងព្រឹត្តិការណ៍នានា ដែលគាត់បានពិពណ៌នានៅពេលបន្ទាប់មកទៀត នៅក្នុងសៀវភៅរបស់គាត់ស្តីពីកម្ពុជាប្រជាធិបតេយ្យ[215]។

៨៥. ព័ត៌មាននៅក្នុងសំណុំរឿង បង្ហាញថាសំណេរដៃនានាពីក្រសួងការបរទេសរបស់កម្ពុជាប្រជាធិបតេយ្យ ពីដើមដំបូង ត្រូវបានរកឃើញក្នុងឆ្នាំ១៩៧៩ នៅផ្ទះមួយដែលគេជឿជាក់ថា ត្រូវបានប្រើប្រាស់ដោយជនជាប់ចោទ អៀង សារី[216]។ បុគ្គលដែលបានរកឃើញឯកសារនេះ បានផ្តល់ឯកសារនេះមួយច្បាប់ ទៅឲ្យអ្នកស្រាវជ្រាវឈ្មោះ Ben Kiernan ក្នុងឆ្នាំ១៩៨៦ ជាអ្នកផ្តល់ឯកសារមួយច្បាប់មកឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងឆ្នាំ១៩៩៥[217]។ កសព បានទទួលឯកសារនោះជាលើកដំបូងពីមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងអំឡុងពេលនៃការស៊ើបអង្កេតបឋមរបស់ខ្លួន និងបានភ្ជាប់ឯកសារនោះជាមួយនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ[218]។ អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត បានទទួលឯកសារនេះមួយច្បាប់ពីមជ្ឈមណ្ឌលឯកសារកម្ពុជា នៅពេលបន្ទាប់ ក្នុងអំឡុងពេលនៃការស៊ើបសួរតាមផ្លូវតុលាការ ស្របតាមដីកាចាត់ឲ្យស៊ើបសួរជំនួស[219]។

---

[214] IS 14.1, D267/5/1.1.25 (ឯកសារ 386)។

[215] សៀវភៅនិពន្ធដោយ Elizabeth Becker, *នៅពេលដែលសង្គ្រាមរលត់ទៅ* (នៅក្នុងសំណុំរឿង ដាក់ជាឯកសារ IS 4.1)។

[216] សូមមើល ផ្នែកបន្តទៅបកប្រែជាភាសាអង់គ្លេសនៃសៀវភៅកត់ត្រា៖ D267/5/1.1.25 ត្រង់ ERN 00003239។

[217] *ដូចជើងទំព័រខាងលើ*។

[218] IS 14.1 (ឯកសារ 386)។

[219] D267/5/1.1.25 (ឯកសារ 386)។ សូមមើល D267 ដីកាចាត់ឲ្យស៊ើបសួរជំនួស, ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៩ និង D267/5 របាយការណ៍អនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស, ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៩។

៨៦. មជ្ឈមណ្ឌលឯកសារកម្ពុជា ទទួលបានសំណោរដៃរបស់កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាម្នាក់ពីវគ្គបំពាក់បំប៉ននយោបាយ នៅពេលដែលមជ្ឈមណ្ឌលនេះប្រមូលឯកសារទាំងនោះ ពីបណ្ណសារទួលស្លែង ក្នុងឆ្នាំ ១៩៩៩[220]។ សំណោរដៃរបស់អ្នកកាសែតឈ្មោះ Elizabeth Becker ដែលបានកត់ត្រាពីដំណើរទស្សនកិច្ចរបស់គាត់មកកាន់កម្ពុជាប្រជាធិបតេយ្យ ក្នុងខែធ្នូ ឆ្នាំ១៩៧៨ គឺបានទទួលមកពីអ្នកនិពន្ធ ដោយការិយាល័យសហព្រះរាជអាជ្ញា។ កំណត់ត្រាទាំងនោះត្រូវបានដាក់បញ្ចូលនៅក្នុងសំណុំរឿងតាមសំណើរបស់ កសព ក្នុងឆ្នាំ២០១០។ សំណោរដៃទាំងនេះ គឺស្ថិតក្នុងដៃរបស់អ្នកនិពន្ធរហូតទល់ពេលគាត់បានផ្តល់ឲ្យទៅ កសព។ លោកស្រី Becker ត្រូវបានដាក់ធ្វើជាសាក្សីសម្រាប់សវនាការជំណាក់កាលដំបូងក្នុងសំណុំរឿង០០២ ដូច្នេះហើយ ខ្លួនគាត់ផ្ទាល់អាចធ្វើការបញ្ជាក់យថាភូតចំពោះសំណោរដៃទាំងនេះក្នុងតុលាការបាន ប្រសិនបើចាំបាច់។

## ១១. បទបញ្ជារបស់កម្ពុជាប្រជាធិបតេយ្យ

៨៧. មានឯកសារចំនួន២ នៅក្នុងបញ្ជីឯកសារដែលត្រូវបានចាត់ថ្នាក់ជា "បទបញ្ជារបស់កម្ពុជាប្រជាធិបតេយ្យ"[221]។ បទបញ្ជាទាំងពីរនេះត្រូវបានកំណត់ថាជារបស់ "អង្គការ" ដែលក្នុងបរិបទនេះ គឺសំដៅដល់ ប៉ុល ពត ឬ នួន ជា។ បទបញ្ជាទី១ ពាក់ព័ន្ធនឹងបញ្ហាសន្តិសុខ នៅត្រឹមចុងឆ្នាំ ១៩៧៥[222]។ បទបញ្ជាទី២ ពាក់ព័ន្ធនឹងបញ្ហាសេដ្ឋកិច្ច នៅត្រឹមខែមករា ឆ្នាំ១៩៧៧[223]។

៨៨. បទបញ្ជាទី១ គឺចេញពីអង្គការផ្ញើទៅ "យ៉ា" ជាឈ្មោះហៅក្រៅរបស់ ម៉ែន សាន ដែលជាលេខាភូមិភាគឦសាននាពេលនោះ[224]។ ឯកសារនេះមានព័ត៌មានអំពីស្ថានភាពនៅមូលដ្ឋាន រួមទាំងការណែនាំផ្សេងៗស្តីពីការប្រមូលផ្តុំ និងការពង្រាយកម្លាំងប្រយុទ្ធដើម្បីវាយប្រហារទៅលើអង្គភាពនានារបស់ពួកវៀតណាមដែលជ្រៀតចូលទឹកដីកម្ពុជា។ បទបញ្ជានេះបានប្រើប្រាស់នូវវោហារស័ព្ទខុសៗគ្នាដែលទាក់ទិននឹង ប.ក.ក និងការរក្សាមនោគមន៍វិជ្ជារបស់ បកក។ ឯកសារនេះចាប់ផ្តើមដោយប្រើពាក្យស្វាគមន៍ថា "ជូនចំពោះមិត្ត យ៉ា ជាទីស្រឡាញ់ និងនឹករឭក" បញ្ចប់ដោយប្រើឃ្លាថា "ដោយភាតរៈបដិវត្តន៍ដ៏កក់ក្តៅបំផុត" និងប្រើវោហារស័ព្ទដទៃទៀតដូចជា "ក្តាប់សភាព

[220] សូមមើល មូលដ្ឋានទិន្នន័យ DC-Cam មាននៅ៖ http://www.d.dccam.org/Database/Lod/details.php?keyword=D13676&numRecords=100&lang=eng&page=1&idnum=D13676។

[221] ឯកសារ 389 និង 390 នៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា។

[222] D366/7.1.136 (ឯកសារ 389)។

[223] IS 18.25 (ឯកសារ 390)។

[224] D366/7.1.136 (ឯកសារ 389)។

ការណ៍ខ្មាំង" "ត្រូវរក្សាការសម្ងាត់" និង "ចលនាកម្លាំងក្នុងចំណោមប្រជាជនតាមភូមិ"។ ភ្ជាប់បន្ថែមទៅនឹងចុងនៃបទបញ្ហានេះគឺជាយោបល់ដែលកត់សម្គាល់ថា អង្គការក៏បានទទួលទូរលេខមួយពី យ៉ា ដែរ ពាក់ព័ន្ធនឹង "ប្រជាជនថ្មី" ដែលជាពាក្យមួយ ប.ក.ក និយមយកមកប្រើដែរ។

៨៩. ក.ស.ព បានទទួលឯកសារនេះពី DC-Cam និងបានដាក់បញ្ចូលនៅក្នុងសំណុំរឿងក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរតាមសំណើសុំរបស់ ក.ស.ព[225]។ បើតាមមូលដ្ឋានទិន្នន័យរបស់ DC-Cam ឯកសារនេះត្រូវបានប្រមូលដោយ DC-Cam ពីក្រសួងមហាផ្ទៃ ក្នុងឆ្នាំ១៩៩៧[226]។ ឯកសារនេះមានលេខសម្គាល់របស់ក្រសួងមហាផ្ទៃ[227]។ ដំណើរការគ្រប់គ្រងឯកសារដែលត្រូវបានប្រមូលពីក្រសួងមហាផ្ទៃ ត្រូវបានលើកឡើងខាងលើរួចមកហើយ[228]។

៩០. បទបញ្ជាទីពីរ ជាបទបញ្ជាដែលអង្គការផ្ញើជូនទៅក្រសួងពាណិជ្ជកម្ម ដោយបានផ្ដល់ការណែនាំពិស្ដារឆ្លើយតបទៅនឹងផែនការមួយដែលបានស្នើឡើងសម្រាប់ការនាំចូល និងនាំចេញ[229]។ ក.ស.ព បានទទួលឯកសារនេះពី DC-Cam នៅពេលស៊ើបអង្កេតបឋម និងបានភ្ជាប់ជាមួយនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ មូលដ្ឋានទិន្ន័យនៃ DC-Cam បង្ហាញថា ឯកសារនេះត្រូវបានប្រមូលពីបណ្ណសារជាតិកម្ពុជា នៅឆ្នាំ២០០២[230]។ ឯកសារនេះមានលេខសម្គាល់របស់បណ្ណសារជាតិ[231]។

## ១២. របាយការណ៍កម្ពុជាប្រជាធិបតេយ្យ

៩១. មានឯកសារចំនួន៣២ នៅក្នុងបញ្ជីឯកសារដែលត្រូវបានចាត់ថ្នាក់ជា "របាយការណ៍ DK"[232]។ ឯកសារចំនួន៣២នេះ ត្រូវបានបែងចែកជាអនុប្រភេទចំនួន៤ រួមមាន៖ របាយការណ៍ចំនួន៧ពីភូមិភាគផ្ញើជូនថ្នាក់មជ្ឈិម របាយការណ៍យោធាចំនួន៥ របាយការណ៍របស់មន្ទីរ ស២១ ចំនួន៥

---

[225] D366 សំណើរបស់សហព្រះរាជអាជ្ញា សុំដាក់បញ្ចូលភ័ស្តុតាងបន្ថែមនៅក្នុងសំណុំរឿង, ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១០។

[226] សូមមើល មូលដ្ឋានទិន្នន័យ DC-Cam មាននៅ: http://www.d.dccam.org/Database/Lod/details.php?keyword=01043&numRecords=100&lang=eng&page=1&idnum=L01043។

[227] លេខសរសេរដោយដៃមាននៅក្នុងរង្វង់ក្រចកខាងលើនៃជ្រុងខាងស្ដាំ។

[228] សូមមើលផ្នែក I ខាងលើ។

[229] IS 18.25 (ឯកសារ 390)។

[230] សូមមើល មូលដ្ឋានទិន្នន័យ DC-Cam មាននៅ: http://www.d.dccam.org/Database/Lod/details.php?keyword=D20615&numRecords=100&lang=eng&page=1&idnum=D20615 ។

[231] លេខយោងមាននៅក្នុងរង្វង់ក្រចក និងផ្ដើមដោយ "ANC" នៅខាងលើជ្រុងខាងស្ដាំទំព័រ។

[232] ឯកសារ 391-422 នៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា។

និងរបាយការណ៍ពីក្រសួងចំនួន១៥។ របាយការណ៍ទាំងនេះទទួលមកពី DC-Cam ដែល DC-Cam បានទទួលរបាយការណ៍ទាំងនេះពីប្រភពចំនួនបួន ដែលរួមមាន មកពីក្រសួងមហាផ្ទៃ បណ្ណសារទួលស្លែង (TSL) បណ្ណសារជាតិកម្ពុជា និងប្រវត្តិវិទូ Ben Kiernan។ ដំណើរការគ្រប់គ្រងឯកសារដែលប្រមូលពី TSL និងពីក្រសួងមហាផ្ទៃ ត្រូវបានរៀបរាប់ដូចខាងលើស្រាប់[233]។

៩២. ឯកសារទាំងអស់លើកលែងតែឯកសារចំនួន៤ ប្រមូលបានពីដំបូងដោយ ក.ស.ព និងបានភ្ជាប់ជាមួយនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរផង ឬបានបញ្ចូលទៅក្នុងសំណុំរឿង តាមសំណើរបស់ ក.ស.ព នៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរផង។ ឯកសារចំនួន៤ទៀត ត្រូវបានប្រមូល និងបញ្ចូលក្នុងសំណុំរឿងដោយ ក.ស.ច.ស នៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ[234]។

*របាយការណ៍ពីភូមិភាគ ទៅមជ្ឈិម*

---

233 សូមមើល ផ្នែក I ខាងលើ។

234 D175/3.17 (ឯកសារ 409); D175/3.93 (ឯកសារ 410); D175/3.92 (ឯកសារ 411), D248/6.1.9 (ឯកសារ 398)។ ឯកសារបីដំបូងទទួលបានស្របតាមដីកាចាត់ឱ្យស៊ើបសួរជំនួស ចុះថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០០៨ (D175)។ ឯកសារទីបួនទទួលបានស្របតាមដីកាចាត់ឱ្យស៊ើបសួរជំនួស ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ (D248)។ គួរកត់សម្គាល់ថាឯកសារ IS 21.1 (ឯកសារ 391) ក៏ត្រូវបាន ក.ស.ច.ស ប្រមូលមកពី DC-Cam ស្របតាមដីកាចាត់ឱ្យស៊ើបសួរជំនួសចុះថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០០៨ ផងដែរ (D175) និងត្រូវបានដាក់ក្នុងសំណុំរឿងជាឯកសារលេខ D175/6.8។

៩៣. ឯកសារចំនួន៧[235] នៅក្នុងអនុប្រភេទនេះ គឺជាឧទាហរណ៍ស្ដីពីរបបនៃការរាយការណ៍ប្រចាំសប្ដាហ៍ ពីថ្នាក់ភូមិភាគជូនមជ្ឈិមបក្ស ឧទាហរណ៍ដូចជា ពីភូមិភាគពាយ័ព្យ ភូមិភាគឦសាន ភូមិភាគកណ្ដាល ភូមិភាគបូព៌ា និងភូមិភាគនិរតី។

៩៤. ឯកសារទាំងអស់នេះសុទ្ធតែធ្វើតាមទម្រង់ស្ដង់ដារបស់ ប.ក.ក ដោយប្រើប្រាស់វោហារស័ព្ទរបស់ ប.ក.ក និងឃ្លាប្រយោគមនោគមន៍វិជ្ជាដូចជា "ខ្មាំងខាងក្នុង" "គណៈ៨៧០ ជាទីនឹករឭក" "បោសសំអាតខ្មាំងឲ្យអស់" ជាដើម។ ឯកសារទាំងនោះរួមមានឈ្មោះជាលេខកូដផ្សេងៗទៅតាមបទដ្ឋានរបស់ DK ដូចជា ក-៥១ សំដៅដល់ក្រសួងពាណិជ្ជកម្ម ឬ ៥៦០ សម្រាប់ភូមិភាគនិរតី និងការយោងទៅលើមេដឹកនាំ ប.ក.ក/DK ដែលគេធ្លាប់ស្គាល់ មកពីតាមបណ្ដាអង្គភាពនានារបស់អង្គការ ដូចជា កែ ពក, សុន សេន, យ៉ា, ឌុច, នួន ជា និង អៀង សារី ជាដើម។

៩៥. លើកលែងតែរបាយការណ៍មួយចេញ[236] ក្រៅពីនេះ ខ្លឹមសារនៃឯកសារទាំងនេះពាក់ព័ន្ធជាចំបងទៅនឹងប្រធានបទនានាដែលត្រូវបានគេស្គាល់ថា ជាបញ្ហាដោយឡែករបស់ថ្នាក់ដឹកនាំ ប.ក.ក ដែលរួមមាន "ខ្មាំងខាងក្នុង" "ខ្មាំងខាងក្រៅ" ការបង្កបង្កើនផលកសិកម្ម និងការអភិវឌ្ឍន៍របស់អង្គការជាដើម។ ឧទាហរណ៍ មានឯកសារមួយដែលពាក់ព័ន្ធនឹង "គិញ" ដែលជានារីម្នាក់អាយុ ២៥ឆ្នាំ និងដែលមានភ្ជាប់ចម្លើយសារភាពរបស់នារីនោះមកជាមួយផងដែរ[237]។ ឯកសារមួយទៀត ពណ៌នាពីរបៀបដែលអាជ្ញាធរភូមិភាគនិរតី "បំផ្លាញ" "ខ្មាំងខាងក្នុង" ចំនួន៣២នាក់ នៅក្នុងអំឡុងសប្ដាហ៍មុន ហើយនឹងអំពីតើការខ្វះខាតស្បៀងអាហារដែលបានរីករាលដាល នៅក្នុងទូទាំងភូមិភាគទាំងមូល មានសភាពយ៉ាងដូចម្ដេច?[238]។

---

235

236 ERN 00187831-00187837 ថ្មី(ឯកសារ 396)។ ឯកសារនេះ និយាយអំពីពាណិជ្ជកម្មជាមួយថៃ។

237 IS 21.1, D175/6.8 (ឯកសារ 391)។

238 IS 21.124, D288/5.909 (ឯកសារ 422)។

៩៦. ឯកសារដែលនៅក្នុងអនុប្រភេទ ជារបាយការណ៍នានាពីភូមិភាគផ្ញើជូនទៅមជ្ឈិមបក្សនៃរបាយការណ៍ DK ត្រូវបាន DC-Cam ទទួលបានពីប្រភពជាច្រើន។ មានឯកសារមួយត្រូវបានប្រមូលមកពីបណ្ណសារជាតិកម្ពុជា នៅក្នុងឆ្នាំ២០០២[239]។ ឯកសារចំនួន៣ ក្នុងចំណោមឯកសារទាំងនេះត្រូវបានប្រមូលពីទួលស្លែង នៅចន្លោះពីឆ្នាំ១៩៩៦ ដល់ឆ្នាំ១៩៩៩[240]។ មានអក្សរយោង "TS" ឬ "TSL" នៅផ្នែកខាងលើជ្រុងខាងស្ដាំនៃឯកសារទាំងពីរនេះ[241]។ ឯកសារចំនួន៣ចុងក្រោយ[242] ត្រូវបានប្រមូលពីក្រសួងមហាផ្ទៃ ហើយឯកសារទាំង៣នេះមានលេខសម្គាល់របស់ក្រសួងមហាផ្ទៃផងដែរ[243]។

៩៧. ចុងក្រោយ ប្រការគួរឲ្យកត់សម្គាល់គឺថា ឯកសារចំនួន៣ ក្នុងចំណោមឯកសារទាំង៧ នៅក្នុងអនុប្រភេទនេះ ត្រូវបានអង្គជំនុំជម្រះសាលាដំបូងទទួលយកជាភ័ស្តុតាងក្នុងសំណុំរឿង០០១[244]។

### *របាយការណ៍យោធា*

៩៨. ឯកសារចំនួន៥[245] នៅក្នុងអនុប្រភេទទីពីរគឺ របាយការណ៍យោធាពាក់ព័ន្ធជាបឋមទៅនឹងរបាយការណ៍ស្ដីពីការប្រយុទ្ធជាមួយកងកម្លាំងវៀតណាម និង/ឬ ការចាប់ខ្លួន និងការសម្លាប់ជនជាតិវៀតណាម។ របាយការណ៍ជាច្រើន ក៏បានពិភាក្សាផងដែរ ពីការវិវត្តក្នុងស្រាវជ្រាវរកខ្មាំងខាងក្នុង។ ឧទាហរណ៍ របាយការណ៍មួយពី មាស មុត ដែលចម្លងជូន នួន ជា (អ៊ុំ នួន) និង អៀង សារី (បង វ៉ាន់) ពណ៌នាពីការសម្លាប់ជនជាតិវៀតណាមចំនួន១២០នាក់[246]។ ឯកសារមួយទៀតក៏បានចម្លងជូន នួន ជា និង អៀង សារី ផងដែរ ពណ៌នាពីជម្លោះផ្នែកយោធានៅភូមិភាគបូព៌ា[247]។ ឯកសារទីបី ពីលេខាកងពល៨០១ ផ្ញើជូន សុន សេន ពណ៌នាពីបញ្ហាខ្មាំងខាងក្នុង នៅភូមិភាគ

---

239 ERN 00187831-00187837 ថ្មី (ឯកសារ 396)។

240 IS 21.1, D175/6.8 (ឯកសារ 391), D366/7.1.845 (ឯកសារ 405), and D175/3.17 (ឯកសារ 409)។

241 IS 21.1, D175/6.8 (ឯកសារ 391) និង D175/3.17 (ឯកសារ 409)។

242 IS 21.7 (ឯកសារ 392), IS 18.42 (ឯកសារ 413), និង IS 21.124, D288/5.909 (ឯកសារ 422)។

243 លេខយោងសរសេរដោយដៃមាននៅក្នុងវង់ក្រចកខាងលើជ្រុងខាងស្ដាំ។

244 IS 21.7 (ឯកសារ 392) ត្រូវបានទទួលយកជាឯកសារ E3/808; IS 18.42 (ឯកសារ 413) ត្រូវបានទទួលយកជាឯកសារ E3/769; និង IS 21.124, D288/5.909 (ឯកសារ 422) ត្រូវបានទទួលយកជាឯកសារ E3/909។

245 D366/7.1.483 (ឯកសារ 406), D175/3.93 (ឯកសារ 410), D175/3.92 (ឯកសារ 411), IS 18.59, D2-15.15 (ឯកសារ 420) និង IS 18.61 (ឯកសារ 421)។

246 D2-15.15 (ឯកសារ 420)។

247 IS 18.61 (ឯកសារ 421)។

ព្លិសាន រួមទាំងការចាប់ខ្លួនជនជាតិវៀតណាមចំនួន៧នាក់[248] ផងដែរ។ ករណីលើកលែងមួយគឺរបាយការណ៍មួយដែលពណ៌នាពីការចាប់ខ្លួនបុគ្គល៥រូប ពីកងពល៤៥០ និងក្រសួងពាណិជ្ជកម្មដែលបានធ្វើដំណើរដោយគ្មាន*លិខិតដើរផ្លូវ*[249]។

៩៩. ឯកសារទាំងនេះបានបង្ហាញពីសញ្ញាណដែលគួរឲ្យជឿជាក់បានជាច្រើនប្រការ ដូចជា ទម្រង់ និងពុម្ពអក្សរជាស្តង់ដារ DK រួមទាំង វោហារស័ព្ទ និងឈ្មោះជាលេខកូដរបស់ ប.ក.ក។ ឯកសារទាំងនេះត្រូវបានសរសេរ ផ្ញើជូន ឬយោងទៅដល់ កម្មាភិបាល ប.ក.ក/DK ដែលគេស្គាល់ ដូចជា សូ សារឿន, ឌី ធិន, សុន សេន, ប៉ុល ពត, វន វ៉េត, នួន ជា និង អៀង សារី។ ឯកសារចំនួន២ទៀត ផ្ញើជូន សុន សេន (ហៅ អ៊ំ "៨៩") មានចំណារដែលសរសេរដោយ សុន សេន[250] ទៀតផង។

១០០. ឯកសារទាំង៥ ត្រូវបានប្រមូលដោយ DC-Cam ពីក្រសួងមហាផ្ទៃ នៅចន្លោះពីឆ្នាំ១៩៩៧ រហូតដល់ឆ្នាំ១៩៩៩[251]។ ឯកសារទាំង៥ មានសញ្ញាសម្គាល់របស់ក្រសួងមហាផ្ទៃ[252] រួមទាំងលេខសម្គាល់របស់ DC-Cam[253] ដែរ។

១០១. ឯកសារចំនួន២ ក្នុងចំណោមឯកសារនៅក្នុងអនុប្រភេទនេះ ត្រូវបានអង្គជំនុំជម្រះសាលាដំបូងទទួលយកជាភ័ស្តុតាង ក្នុងសំណុំរឿង០០១[254]។

### *របាយការណ៍មន្ទីរ-ស២១*

១០២. ឯកសារចំនួន៥[255] នៅក្នុងអនុប្រភេទទីបី គឺជារបាយការណ៍មន្ទីរស-២១ ដែលមានខ្លឹមសារស្រដៀងគ្នា ហើយឯកសារនេះភាគច្រើន គឺជាបញ្ជីឈ្មោះរបស់បុគ្គលនានា ដែលស្ថិតក្រោមការស៊ើបអង្កេតរបស់មន្ទីរស-២១។ ឯកសារទាំងបីនេះមានការពាក់ព័ន្ធទៅនឹងខ្មាំងដែលត្រូវគេសង្ស័យ

---

[248] D175/3.93 (ឯកសារ 410)។

[249] D366/7.1.483 (ឯកសារ 406)។

[250] ឯកសារ D175/3.93 (ឯកសារ 410), និង D175/3.92 (ឯកសារ 411) មានសក្សរសរសេរដោយដៃដែលស្រដៀងគ្នានឹងអក្សរសរសេរដោយដៃ ដែល ឌុច ថាជាអក្សររបស់ សុន សេន។ សូមមើល ឧទាហរណ៍ ប្រតិចារឹកចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ ត្រង់ទំព័រ៥៧-៥៨ យោងទៅអក្សរសរសេរដោយដៃនៅលើឯកសារ E3/20 (ERN 00172999)។

[251] សូមមើល មូលដ្ឋានទិន្នន័យ DC-Cam មាននៅ :http://www.d.dccam.org/Database/Lod/index.php (អាចស្វែងរកបានតាមរយៈលេខយោង DC-Cam)។

[252] លេខយោងសរសេរដោយដៃមាននៅក្នុងរង់ក្រចកខាងលើជ្រុងខាងស្តាំ។

[253] លេខយោងសរសេរដោយដៃមាននៅក្នុងរង់ក្រចកខាងលើជ្រុងខាងស្តាំ និងនាំមុខដោយអក្សរ "D" ឬ "L"។

[254] D2-15.15 (ឯកសារ 420) ត្រូវបានទទួលយកជាឯកសារ E3/91 និង E3/779, និង IS 18.61 (ឯកសារ 421) ត្រូវបានទទួលយកជាឯកសារ E3/780។

[255] IS 16.2 (ឯកសារ 399), IS 16.23 (ឯកសារ 400), IS 16.18 (ឯកសារ 408), IS 16.56 (ឯកសារ 412) and IS 18.56 (ឯកសារ 418)។

នៅក្នុងអង្គភាពមួយចំនួននៃក្រសួងពាណិជ្ជកម្ម[256] ហើយឯកសារមួយមានការពាក់ព័ន្ធទៅនឹងខ្មាំងដែលត្រូវគេសង្ស័យនៅក្នុងអង្គភាពមួយចំនួនរបស់អង្គការ រួមទាំង ក្រសួងពាណិជ្ជកម្ម ភូមិភាគឧត្តរ និងភូមិភាគបស្ចិម[257] និងឯកសារមួយទៀតពាក់ព័ន្ធនឹងខ្មាំងដែលត្រូវបានសង្ស័យនៅមន្ទីរ "ក-១" និងអង្គភាព "ក" ផ្សេងៗទៀត ក្រោមការគ្រប់គ្រងរបស់មន្ទីរ៨៧០[258]។

១០៣. គោលបំណង និងខ្លឹមសារនៃឯកសារទាំងនេះ គឺស្របជាមួយនឹងព័ត៌មានផ្សេងៗទៀត នៅក្នុងសំណុំរឿងទាក់ទិនទៅនឹងការបោសសម្អាតអង្គភាពនានារបស់អង្គការ។ ឯកសារចំនួន៤ ក្នុងចំណោមឯកសារទាំងនេះ ជាប់ពាក់ព័ន្ធទៅនឹងការបោសសម្អាតក្រសួងពាណិជ្ជកម្ម បន្ទាប់ពីការចាប់ខ្លួន កុយ ធួន និងអ្នកជាប់ទាក់ទងជាមួយគាត់[259]។ ព្រឹត្តិការណ៍ជាបន្តបន្ទាប់ទាំងនេះត្រូវបាន ឌុច ធ្វើការពិភាក្សាដោយប្រើពេលយ៉ាងយូរមួយ នៅក្នុងសំណុំរឿង០០១។ ឯកសារទាំងនេះត្រូវបានចុះកាលបរិច្ឆេទដូចគ្នានឹងព្រឹត្តិការណ៍ទាំងនោះ ហើយឯកសារទាំងនោះ មានរចនាបទ ទម្រង់ ពុម្ពអក្សរ និងលក្ខណៈផ្សេងៗទៀតស្រដៀងគ្នាទៅនឹងឯកសារមួយចំនួនទៀតដែលត្រូវបានបញ្ចូលទៅក្នុងឯកសារភ័ស្តុតាងនៃសំណុំរឿង០០១ និងជាឯកសារដែល ឌុច បានផ្តល់យថាភូត[260]។ ឯកសារទីប្រាំ[261]ទាក់ទិននឹងការបោសសម្អាតនៅពេលបន្ទាប់។ ឈ្មោះ និងតួនាទីរបស់បុគ្គលមួយចំនួនធំ នៅក្នុងឯកសារនេះ ត្រូវបានបញ្ជាក់អះអាងដោយសាក្សីឈ្មោះ [redacted] នៅក្នុងពេលសាកសួរដោយ ក.ស.ច.ស[262]។ ឯកសារនេះត្រូវបានអង្គជំនុំជម្រះសាលាដំបូងទទួលយកជាឯកសារភ័ស្តុតាង ក្នុងសំណុំរឿង០០១[263]។

១០៤. ឯកសារទាំងប្រាំនៅក្នុងអនុប្រភេទនេះ[264] ត្រូវបានមជ្ឈមណ្ឌលឯកសារកម្ពុជាប្រមូលពីបណ្ណសារទួលស្លែង (TSL)។ ឯកសារនីមួយៗនៃឯកសារទាំងនេះ មានលេខសម្គាល់របស់ DC-Cam និង TSL ផងដែរ។

[256] IS 16.2 (ឯកសារ 399), IS 16.23 (ឯកសារ 400), និង IS 16.18 (ឯកសារ 408)។

[257] IS 16.56 (ឯកសារ 412)។

[258] IS 18.56 (ឯកសារ 418)។

[259] IS 16.2 (ឯកសារ 399), IS 16.23 (ឯកសារ 400), IS 16.18 (ឯកសារ 408) និង IS 16.56 (ឯកសារ 412)។

[260] សូមមើល ឧទាហរណ៍ E3/20, E3/86 និង E3/416។

[261] IS 18.56 (ឯកសារ 418)។

[262] D91/9 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០៧ ត្រង់ទំព័រ ៧-៩។

[263] ជាឯកសារ E3/52។

[264] IS 16.2 (ឯកសារ 399), IS 16.23 (ឯកសារ 400), IS 16.18 (ឯកសារ 408), IS 16.56 (ឯកសារ 412) និង IS 18.56 (ឯកសារ 418)។

## *របាយការណ៍ក្រសួង*

១០៥. ឯកសារចំនួន១៥[265] នៅក្នុងអនុប្រភេទទីបួន និងចុងក្រោយ គឺជារបាយការណ៍របស់ក្រសួង ដែលទាក់ទងនឹងបញ្ហានៃកិច្ចប្រតិបត្តិការរបស់ក្រសួងពាណិជ្ជកម្ម ក្រសួងការបរទេស និងក្រសួងសង្គមកិច្ច។ របាយការណ៍នេះភាគច្រើន គឺមកពីក្រសួងពាណិជ្ជកម្ម[266] ឯកសារមួយមកពីក្រសួងការបរទេស[267] និងមួយទៀតពីក្រសួងសង្គមកិច្ច[268]។

១០៦. របាយការណ៍ពាណិជ្ជកម្មបានបែងចែកជាពីរប្រភេទ រួមទាំងរបាយការណ៍ចំនួន៤ ពាក់ព័ន្ធទៅនឹងបញ្ហាបច្ចេកទេស ដូចជាការគ្រប់គ្រង និងរចនាសម្ព័ន្ធចាត់តាំងជាដើម និងឯកសារចំនួន៩ ទាក់ទិនទៅនឹងបញ្ហានយោបាយ ជាពិសេសការស្រាវជ្រាវរកខ្មាំងខាងក្នុងក្រសួង និងអ្នកដែលត្រូវបានបញ្ជូនទៅមន្ទីរស-២១។ របាយការណ៍របស់ក្រសួងការបរទេសពិពណ៌នាអំពីសន្និបាតមួយរបស់ក្រសួងការបរទេស ដែលទទួលបានជោគជ័យក្នុង "ការកម្ទេច និងការបោសសម្អាតខ្មាំង" នៅក្នុងក្រសួង តាមរយៈការជំរុញឲ្យមានការប្រុងប្រយ័ត្ន ក្នុងការស្រាវជ្រាវរកខ្មាំងបន្ថែមទៀតនៅក្នុងជួរបក្ស។

១០៧. ឯកសារទាំងនេះសុទ្ធតែប្រើទម្រង់ និងពុម្ពអក្សរ និងមានពាក្យពេចន៍មនោគមន៍វិជ្ជាជាបទដ្ឋានរបស់បក្សកុម្មុយនីស្តកម្ពុជា ដូចជា "ខ្មាំងខាងក្នុង" "វិធានការ" សម្រាប់ដោះស្រាយជាមួយនឹង "សមាសភាពមិនល្អ" ជាដើម ហើយឈ្មោះជាលេខកូដរបស់ ប.ក.ក ដូចជា ក-១៥ សម្រាប់ក្រសួងពាណិជ្ជកម្ម និង "ភា" ជាឈ្មោះហៅក្រៅរបស់ អៀង ធីរិទ្ធ ជាដើម។

១០៨. ឯកសារទាំងនេះ ស្របជាមួយនឹងការទទួលខុសត្រូវរបស់អង្គការដែលជាប្រភពរបស់វា។ ឯកសារខ្លះទៀតត្រូវបានគេផ្ញើ ជាពិសេសទៅកាន់ ឬចុះហត្ថលេខាដោយកម្មាភិបាល ប.ក.ក ដែលត្រូវ

---

[265] IS 18.10 (ឯកសារ 393), ERN 00187813-00187817 ថ្មី (ឯកសារ 394), D366/7.1.330 (ឯកសារ 395), D366/7.1.332 (ឯកសារ 397), D248/6.1.9 (ឯកសារ 398), D366/7.1.844 (ឯកសារ 401), D108/26.27 (ឯកសារ 402), D366/7.1.159 (ឯកសារ 403), IS 18.17 (ឯកសារ 404), ERN 00187878-00187879 ថ្មី (ឯកសារ 407), ERN 00187883-00187885 ថ្មី (ឯកសារ 414), ERN 00187895-00187897 ថ្មី (ឯកសារ 415), ERN 00187898-00187900 ថ្មី (ឯកសារ 416), IS 18.49 (ឯកសារ 417) និង IS 21.102 (ឯកសារ 419)។

[266] IS 18.10 (ឯកសារ 393), ERN 00187813-00187817 ថ្មី (ឯកសារ 394), D366/7.1.330 (ឯកសារ 395), D366/7.1.332 (ឯកសារ 397), D248/6.1.9 (ឯកសារ 398), D366/7.1.844 (ឯកសារ 401), D108/26.27 (ឯកសារ 402), D366/7.1.159 (ឯកសារ 403), IS 18.17 (ឯកសារ 404), ERN 00187878-00187879 ថ្មី (ឯកសារ 407), ERN 00187883-00187885 ថ្មី (ឯកសារ 414), ERN 00187895-00187897 ថ្មី (ឯកសារ 415) និងERN 00187898-00187900 ថ្មី (ឯកសារ 416)។

[267] IS 18.49 (ឯកសារ 417)។

[268] IS 21.102 (ឯកសារ 419)។ ឯកសារនេះគឺជាសំណើរទៅកាន់ក្រសួងពាណិជ្ជកម្ម។

បានគេដឹងថាជាអ្នកទទួលខុសត្រូវចំពោះការចាត់ចែងដែលបានលើកឡើង រួមមាន វ៉ាន រិទ្ធ ហៅ រិទ្ធ នៅក្រសួងពាណិជ្ជកម្ម និង អៀង ធីរិទ្ធ នៅក្រសួងសង្គមកិច្ច[269] ជាដើម។ ឯកសាររបស់ក្រសួងពាណិជ្ជកម្មចំនួន៣[270] ដែលពិភាក្សាអំពីការបោសសម្អាតបុគ្គលិកក្រសួងពាណិជ្ជកម្មមួយក្រុម ត្រូវបានបញ្ជាក់ដោយអង្គហេតុថា ឈ្មោះទាំងនោះពិតមាននៅក្នុងបញ្ជីឈ្មោះអ្នកទោសនៅមន្ទីរស-២១របស់ កសព មែន[271]។ ឯកសារមួយក្នុងចំណោមឯកសារទាំងនេះ ត្រូវបានអង្គជំនុំជម្រះសាលាដំបូងទទួលយកជាឯកសារភស្តុតាងនៅក្នុងសំណុំរឿង០០១[272]។

១០៩. ឯកសារនៅក្នុងអនុប្រភេទរបាយការណ៍របស់ក្រសួងនៃរបាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យ ត្រូវបានរកឃើញនៅតាមទីតាំងផ្សេងៗ។ ឯកសារចំនួន១១ ក្នុងចំណោមឯកសារទាំងនេះ[273] ត្រូវបានមជ្ឈមណ្ឌលឯកសារកម្ពុជាប្រមូលមកពីបណ្ណសារជាតិ ក្នុងឆ្នាំ១៩៩៩ និងឆ្នាំ ២០០២[274]។ ឯកសារទាំងនេះ សុទ្ធតែមានលេខសម្គាល់របស់បណ្ណសារជាតិកម្ពុជា[275]។ ឯកសារចំនួនពីរនៃឯកសារទាំងនេះ ត្រូវបានមជ្ឈមណ្ឌលឯកសារកម្ពុជាបានមកពីបណ្ណសារទួលស្លែង[276] និងមានលេខសម្គាល់របស់បណ្ណសារទួលស្លែង។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានរកឃើញឯកសារមួយនៅក្រសួងមហាផ្ទៃ ក្នុងឆ្នាំ១៩៩៩[277]។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលឯកសារចុងក្រោយនៅក្នុងអនុប្រភេទនេះពីប្រវត្តិវិទូឈ្មោះ Ben Kiernan ក្នុងឆ្នាំ១៩៩៦[278]។

---

269 ឧទាហរណ៍ IS 21.102 (ឯកសារ 419)។

270 D108/26.27 (ឯកសារ 402), D366/7.1.159 (ឯកសារ 403), និង IS 18.17 (ឯកសារ 404)។

271 សូមអាន D288/6.68.1។

272 IS 18.49 (ឯកសារ 417) ជាឯកសារ E3/176។

273 ERN 00187813-00187817 ថ្មី (ឯកសារ 394), D366/7.1.330 (ឯកសារ 395), D366/7.1.332 (ឯកសារ 397), D248/6.1.9 (ឯកសារ 398), D366/7.1.844 (ឯកសារ 401), IS 18.17 (ឯកសារ 404), ERN 00187878-00187879 ថ្មី (ឯកសារ 407), ERN 00187883-00187885 ថ្មី (ឯកសារ 414), ERN 00187895-00187897 ថ្មី (ឯកសារ 415), ERN 00187898-00187900 ថ្មី (ឯកសារ 416) និង IS 21.102 (ឯកសារ 419)។

274 សូមមើល មូលដ្ឋានទិន្នន័យ DC-Cam មាននៅ: http://www.d.dccam.org/Database/Index.htm (អាចស្វែងរកតាមរយៈលេខចុះដោយ DC-Cam)។

275 លេខឃោងមាននៅក្នុងរង់ក្រចក និងផ្ដើមដោយ "ANC" នៅខាងលើជ្រុងខាងស្តាំទំព័រ។

276 D108/26.27 (ឯកសារ 402), និង D366/7.1.159 (ឯកសារ 403)។

277 IS 18.49 (ឯកសារ 417)។ សូមមើល មូលដ្ឋានទិន្នន័យ DC-Cam មាននៅ: http://www.d.dccam.org/Database/Lod/details.php?keyword=D01791&numRecords=100&lang=eng&page=1&idnum=D01791 ។

278 IS 18.10 (ឯកសារ 393)។ សូមមើល មូលដ្ឋានទិន្នន័យ DC-Cam មាននៅ: http://www.d.dccam.org/Database/Lod/details.php?keyword=D00698&numRecords=100&lang=eng&page=1&idnum=D00698 ។

## ១៣. សារទូរលេខកម្ពុជាប្រជាធិបតេយ្យ

១១០. មានឯកសារចំនួន៦២ នៅក្នុងបញ្ជីឯកសារត្រូវបានចាត់ថ្នាក់ជាទូរលេខ DK[279]។ ទូរលេខទាំងអស់មានរចនាសម្ព័ន្ធមួយដែលគេកំណត់ច្បាស់លាស់ និងមានការទទួលស្គាល់ផងដែរ។ ទូរលេខនីមួយៗត្រូវដាក់លេខពីលេខ១ ដល់លេខ១០០ ទៅតាមទម្លាប់អនុវត្តរបស់ ប.ក.ក[280] និងដាក់ឈ្មោះមន្ទីរ ឬបុគ្គលដែលត្រូវទទួលទូរលេខនោះ។ ទូរលេខនីមួយៗមានកថាខណ្ឌដាច់ៗពីគ្នាដែលរាយការណ៍ពីបញ្ហាជាក់លាក់នានា (ឧទាហរណ៍ បទល្មើសរបស់បុគ្គល ឬការប្រុងប្រយ័ត្ន[281] និងសកម្មភាពខ្មាំង[282])។ ទូរលេខត្រូវបានដាក់ដោយឃ្លាគោរពដែលមានលក្ខណៈផ្នែក ជូនទៅ ប.ក.ក និងស្របតាមមនោគមន៍វិជ្ជា ប.ក.ក ឧទាហរណ៍ "ជូនពរសុខសប្បាយ និងជ័យជម្នះ"[283] ឬ "ដោយភាតរៈបដិវត្តន៍ដ៏ជ្រាលជ្រៅ [ឬកក់ក្ដៅបំផុត]"[284]។ បន្ទាប់មក ក្នុងទូរលេខនីមួយៗមានរៀបរាប់ឈ្មោះអ្នកដែលត្រូវទទួលឯកសារចម្លងទូរលេខនោះ។ ទូរលេខភាគច្រើនត្រូវបានចម្លងជូន បង/អ៊ំ ប៉ុល, បង/អ៊ំ នួន, បង វ៉ាន់ និង បង ខៀវ។

១១១. ទូរលេខមួយចំនួនត្រូវបានសាក្សីផ្ដល់យថាភាព ឬបញ្ជាក់ខ្លឹមសាររបស់វាក្នុងពេលស្ដាប់ចម្លើយដែលរៀបចំដោយ ក.ស.ច.ស។ សាក្សីឈ្មោះ សៅ សារុន ដែលជាអតីតលេខាតំបន់១០៥ បានបញ្ជាក់ថា គាត់ជាអ្នកសរសេរ*ទូរលេខ៥៥*[285] ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៧៨ ដែលពាក់ព័ន្ធទៅនឹងការចាប់ខ្លួន និងការឃុំឃាំងមិត្ត សុទ[286]។ គាត់បានបញ្ជាក់ផងដែរថា ការពិត អ្នកទទួលទូរលេខនោះ (ដែលត្រូវបានកំណត់អត្តសញ្ញាណថា "បង") គឺ ប៉ុល ពត[287]។ តាមរយៈចំណារសរសេរដែលបង្ហាញថា

---

[279] ឯកសារ 423-484 នៅក្នុងបញ្ជីឯកសារ។ មួយក្នុងចំណោមឯកសារទាំងនេះ (D366/7.1.824 – ឯកសារ 484) គឺជាកម្រងឯកសារសារទូរលេខបកប្រែជាភាសាអង់គ្លេសចំនួន៩ ដែលមានចំនួនមាន នៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា។

[280] សាក្សី សៅ សារុន បានពន្យល់ពីប្រព័ន្ធចុះលេខ។ *សូមមើល* **D201/5** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សៅ សារុន កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ត្រង់ទំព័រ៣។

[281] សូមមើល ឧទាហរណ៍ IS 21.113 ទូរលេខ ៥៥ (ឯកសារលេខ 477)។

[282] សូមមើល ឧទាហរណ៍ ទូរលេខ ៣២៥ (D200/2.11, ឯកសារ 472); ៦០ (D312.2.21, ឯកសារ 444) និង ៦៨ (IS 21.33, ឯកសារ 443)។

[283] **IS 21.33** ទូរលេខ ៦៨ ពី ឈាន ទៅកាន់ ម៨១, ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ១៩៧៧ (ឯកសារ 443) និង IS 21.13 ទូរលេខ ០៤ ពី កែ ពក ទៅកាន់ ប៉ុល ពត ចុះថ្ងៃទី២ ខែមេសា ឆ្នាំ១៩៧៦ (ឯកសារ 433)។

[284] **D161/1.2** សេចក្ដីព្រៀងទូរលេខ ពីគណៈកម្មាធិការពាណិជ្ជកម្ម ទៅកាន់សមមិត្ត សុខ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ១៩៧៧ (ឯកសារ 441)។

[285] IS 21.113 (ឯកសារ 477)។

[286] សូមមើល D201/5 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី (សៅ សារុន), ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ត្រង់ទំព័រ៦ និង D201/6 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី (សៅ សារុន), ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៩ ត្រង់ទំព័រ៣។

[287] D201/6 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី (សៅ សារុន), ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៩ ត្រង់ទំព័រ៤។

ទូរលេខនោះក៏បានផ្ញើទៅឲ្យ នួន ជា ដែរ។ មានមតិលើបញ្ហានេះ សាក្សី [redacted] បានអះអាងថា ទូរលេខនោះបានផ្ញើទៅឲ្យ នួន ជា ដោយសារវាពាក់ព័ន្ធនឹង "កិច្ចការផ្ទៃក្នុង"[288]។

១១២. [redacted] អតីតអ្នករៀបចំផ្ញើទូរលេខនៅក្នុងភូមិភាគឧត្តរថ្មី បានបញ្ជាក់ថា *ទូរលេខ៣២*[289] ពាក់ព័ន្ធនឹងយុទ្ធជនពីរនាក់ដែលបានធ្វើដំណើរដោយគ្មានលិខិតអនុញ្ញាតត្រឹមត្រូវ ត្រូវបានចុះហត្ថលេខាដោយ កែ ពក ហើយសាក្សីរូបនេះក៏បានបញ្ជាក់ពីខ្លឹមសារនៅក្នុងទូរលេខនោះដែរ[290]។ គាត់ក៏បានផ្ដល់យថាភាពផងដែរដល់ *ទូរលេខ០២*និង *ទូរលេខ១០*ពី កែ ពក ផ្ញើទៅគណៈ៨៧០ ដោយពណ៌នាថា ទូរលេខទាំងនោះជា "ទូរលេខពិត"[291]។

១១៣. សាក្សី [redacted] ក៏បានពិនិត្យ និងកំណត់ពីកាលបរិច្ឆេទ សំណេរដៃ និងឈ្មោះអ្នកផ្ញើទូរលេខជាច្រើនរួមមាន *ទូរលេខ១០ ទូរលេខ១១ ទូរលេខ១៣* និង *ទូរលេខ៩* ពីលេខាភូមិភាគកណ្ដាល កែ ពក[292] *ទូរលេខ០៨* ពីលេខាភូមិភាគពាយ័ព្យ សាន រី[293] និង*ទូរលេខ០២* ពីតាម៉ុក[294]។ លោក ឆាំង យុ នាយក DC-Cam ក៏បានកំណត់អត្តសញ្ញាណទូរលេខចំនួន៤ ក្នុងចំណោមទូរលេខទាំងនោះ បានពិភាក្សាពីស្ថានភាពក្នុងការរកឃើញទូរលេខទាំងនោះ ហើយគាត់បានបញ្ជាក់ថា DC-Cam ជាអ្នករក្សាទុកសំណៅដើមនៃឯកសារទាំងនេះ[295]។

១១៤. ខ្លឹមសាររបស់ទូរលេខជាច្រើនស្របទៅនឹងកំណត់ហេតុប្រវត្តិឯករាជ្យនានា ដែលបញ្ជាក់បន្ថែមនូវភាពដែលអាចជឿជាក់បានរបស់វា។ ឧទាហរណ៍ *ទូរលេខ៧៨* ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៧៦[296]

---

[288] D200/2 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី [redacted], ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៩ ត្រង់ទំព័រ១៧។

[289] D248/2.3 (ឯកសារ 468)។

[290] D232/8 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី [redacted] ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ត្រង់ទំព័រ ៩-១០។

[291] D232/11 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី [redacted] ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៩ ត្រង់ទំព័រ៣-៤ ទាក់ទងនឹងឯកសារ D175/5.7 (ឯកសារ 480) និង IS 21.109 (ឯកសារ 473)។

[292] D200/2 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ([redacted]), ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៩ ត្រង់ទំព័រ១៦ ទាក់ទងនឹងឯកសារ D175/5.7 (ឯកសារ 480), D175/5.8 (ឯកសារ 481), D200/2.3 (ឯកសារ 482), និង IS 21.118 (ឯកសារ 479)។

[293] D200/2 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ([redacted]), ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៩ ត្រង់ទំព័រ១៥ ទាក់ទងនឹងឯកសារ IS 21.112 (ឯកសារ 476)។

[294] D200/2 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ([redacted]), ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៩ ត្រង់ទំព័រ១១-១២ ទាក់ទងនឹងឯកសារ D175/5.4 (ឯកសារ 471)។

[295] D311/2 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឆាំង យុ ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៩ ទំព័រ៨-៩ ទាក់ទងនឹងឯកសារ IS 21.29 (ឯកសារ 442), IS 21.33 (ឯកសារ 443), IS 21.112 (ឯកសារ 476), និង IS 21.116 (ឯកសារ 478)។

[296] IS 21.5 (ឯកសារ 425)។

និង *ទូរលេខ៧៩* ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៧៦[297] ត្រូវបានរៀបចំដោយ យាង ស៊ីម ជាកម្មាភិបាល DK មួយរូបដែលគេស្គាល់ និងរបាយការណ៍ស្តីពីជម្លោះនៅក្នុងភូមិភាគឦសាន ដែលបានកើតឡើងនាពេលនោះ។ ទូរលេខ៨១ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៧៦[298] ដែលត្រូវបានរៀបចំដោយ យាង ស៊ីម ដែរនោះ ស្របទៅនឹងគោលនយោបាយ ប.ក.ក ក្នុងការជម្លៀសជនជាតិភាគតិចចេញពីតំបន់ព្រំដែន។ *ទូរលេខ៣២*[299] ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៧៨ បង្ហាញថាមិត្ត ម៉េត ជាលេខកងពល៥១២។ ព័ត៌មាននេះមានតែកម្មាភិបាលជាន់ខ្ពស់ ប.ក.ក ទេទើបដឹង និងជាការបង្ហាញថាឯកសារនេះមានយថាភូតត្រឹមត្រូវ។

១១៥. ទូរលេខទាំងអស់ត្រូវបាន ក.ស.ព ឬ ក.ស.ច.ស ប្រមូលពី DC-Cam ក្នុងអំឡុងពេលស៊ើបអង្កេតបឋម និងពេលបើកកិច្ចស៊ើបសួរ។ បើតាមមូលដ្ឋានទិន្នន័យរបស់ DC-Cam និងការបំភ្លឺរបស់លោក ឆាំង យុ មានទូរលេខចំនួន៥៩ ស្ថិតនៅក្នុងបញ្ជីឯកសារ ដែល DC-Cam បានប្រមូលពីក្រសួងមហាផ្ទៃ នៅឆ្នាំ១៩៩៦[300]។ ដំណើរការគ្រប់គ្រងឯកសារនានាដែលប្រមូលពីក្រសួងមហាផ្ទៃត្រូវបានលើកឡើងខាងលើស្រាប់[301]។ DC-Cam បានទទួលទូរលេខចំនួន២ ពីបណ្ណសារជាតិ[302] ឯកសារមួយបានទទួលពី Ben Kiernan[303]។ ឯកសារទាំងនេះមានលេខ៤២៣ ៤៨៣ និង៤២៤ នៅក្នុងបញ្ជីឯកសារ។

១១៦. ទូរលេខចំនួន៣៧ ក្នុងចំណោមទូរលេខទាំងនោះដែលមាននៅក្នុងបញ្ជីឯកសារ ត្រូវបានទទួលយកជាភ័ស្តុតាងក្នុងសំណុំរឿង០០១[304]។

[297] D108/28.36 (ឯកសារ 426)។

[298] D366/7.1.667 (ឯកសារ 427)។

[299] D248/2.3 (ឯកសារ 468)។

[300] D311/2 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆាំង យុ ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៩ ទំព័រ៨-៩ និង មូលដ្ឋានទិន្នន័យ DC-Cam មាននៅ៖ http://www.d.dccam.org/Database/Lod/index.php (អាចស្វែងរកបានតាមរយៈលេខយោង DC-Cam)។

[301] សូមមើល ផ្នែក I ខាងលើ។

[302] D119.2 (ឯកសារ 423) និង IS 21.146 (ឯកសារ 483)។ សូមមើល មូលដ្ឋានទិន្នន័យ DC-Cam មាននៅ៖ http://www.d.dccam.org/Database/Index.htm (អាចស្វែងរកបានតាមរយៈលេខយោង DC-Cam)។

[303] IS 21.2 (ឯកសារ 424) សូមមើល មូលដ្ឋានទិន្នន័យ DC-Cam មាននៅ៖ http://www.d.dccam.org/Database/Lod/details.php?keyword=D00679&numRecords=100&lang=eng&page=1&idnum=D00679។

[304] IS 21.2 ត្រូវបានទទួលយកជាឯកសារ E3/789 (ឯកសារ 424); IS 21.5 ត្រូវបានទទួលយកជាឯកសារ E3/786 (ឯកសារ 425); D108/28.36 ត្រូវបានទទួលយកជាឯកសារ E3/807 (ឯកសារ 426); IS 21.9 ត្រូវបានទទួលយកជាឯកសារ E3/811 (ឯកសារ 429); D108/28.36 ត្រូវបានទទួលយកជាឯកសារ E3/810 (ឯកសារ 428); IS 21.10 ត្រូវបានទទួលយកជាឯកសារ E3/791 (ឯកសារ 430); D108/28.1 ត្រូវបានទទួលយកជាឯកសារ E3/805 (ឯកសារ 431); IS 21.11 ត្រូវបានទទួលយកជាឯកសារ E3/114 (ឯកសារ 432); IS

## ១៤. ការបោះពុម្ពផ្សាយរបស់ FUNK/GRUNK

១១៧. មានឯកសារចំនួន២៣ នៅក្នុងបញ្ជីឯកសារដែលត្រូវបានចាត់ថ្នាក់ជា "ការបោះពុម្ពផ្សាយរបស់ FUNK/GRUNK"។ ឯកសារប្រភេទនេះកើតឡើងដោយឯកសារ៤ប្រភេទ រួមមាន៖ ព្រឹត្តិប័ត្រព័ត៌មាន *Nouvelles du Cambodge* ការបោះពុម្ពផ្សាយផ្លូវការរបស់ក្រសួងការបរទេសដែលមានមូលដ្ឋាននៅប្រទេសបារាំង ការបោះពុម្ពផ្សាយរបស់ FBIS និងការបោះពុម្ពផ្សាយផ្លូវការដទៃទៀតពី FUNK/GRUNK។

១១៨. ឯកសារទាំង២៣ ត្រូវបានបង្កើតឡើងក្នុងសម័យកាលនោះ ក្នុងគោលបំណងកត់ត្រានូវព្រឹត្តិការណ៍នាពេលនោះ។ ខ្លឹមសារនៃឯកសារទាំងនេះរួមមានរបាយការណ៍ស្តីពីសកម្មភាពរបស់សមាជិកផ្លូវការនៃ FUNK/GRUNK និងគោលនយោបាយ និងអំពាវនាវឲ្យគាំទ្រដល់ FUNK/GRUNK។

### *ព្រឹត្តិប័ត្រព័ត៌មាន Nouvelles du Cambodge*

១១៩. មានការបោះពុម្ពផ្សាយចំនួន១៣ របស់ព្រឹត្តិប័ត្រព័ត៌មាន *Nouvelles du Cambodge* ដែលត្រូវបានបោះពុម្ពផ្សាយដោយទីភ្នាក់ងារព័ត៌មានកម្ពុជា[305]។ ឯកសារនីមួយៗចេញពីប្រភពនេះមានលក្ខណៈ

---

21.13 ត្រូវបានទទួលយកជាឯកសារ E3/111 (ឯកសារ 433); IS 21.13 ត្រូវបានទទួលយកជាឯកសារ E3/068 (ឯកសារ 434); D2-15.23 ត្រូវបានទទួលយកជាឯកសារ E3/085 and E3/124 (ឯកសារ 436); IS 21.20 ត្រូវបានទទួលយកជាឯកសារ E3/819 (ឯកសារ 437); IS 21.19 ត្រូវបានទទួលយកជាឯកសារ E3/818 (ឯកសារ 438); IS 21.24 ត្រូវបានទទួលយកជាឯកសារ E3/823 (ឯកសារ 440); IS 21.29 ត្រូវបានទទួលយកជាឯកសារ E3/824 (ឯកសារ 442); IS 21.33 ត្រូវបានទទួលយកជាឯកសារ E3/828 (ឯកសារ 443); IS 21.48 ត្រូវបានទទួលយកជាឯកសារ E3/840 (ឯកសារ 446); D108/28.107 ត្រូវបានទទួលយកជាឯកសារ E3/796 (ឯកសារ 447); IS 21.52 ត្រូវបានទទួលយកជាឯកសារ E3/844 (ឯកសារ 450); D108/28.114 ត្រូវបានទទួលយកជាឯកសារ E3/844 (ឯកសារ 451); IS 21.68 ត្រូវបានទទួលយកជាឯកសារ E3/140 (ឯកសារ 545); IS 21.67 ត្រូវបានទទួលយកជាឯកសារ E3/863 (ឯកសារ 455); IS 21.66 ត្រូវបានទទួលយកជាឯកសារ E3/862 (ឯកសារ 453); IS 21.70 ត្រូវបានទទួលយកជាឯកសារ E3/861 (ឯកសារ 456) IS 21.74 ត្រូវបានទទួលយកជាឯកសារ E3/867 (ឯកសារ 457); IS 21.78 ត្រូវបានទទួលយកជាឯកសារ E3/871 (ឯកសារ 458); IS 21.79 ត្រូវបានទទួលយកជាឯកសារ E3/872 (ឯកសារ 460); IS 21.81ត្រូវបានទទួលយកជាឯកសារ E3/874 (ឯកសារ 461); D108/28.193 ត្រូវបានទទួលយកជាឯកសារ E3/874 (ឯកសារ 462); D108/28.214 ត្រូវបានទទួលយកជាឯកសារ E3/890 (ឯកសារ 465); IS 21.101 ត្រូវបានទទួលយកជាឯកសារ E3/891 (ឯកសារ 466); D108/28.297 ត្រូវបានទទួលយកជាឯកសារ E3/911 (ឯកសារ 467); D 108/28.225 ត្រូវបានទទួលយកជាឯកសារ E3/895 (ឯកសារ 470); IS 21.109 ត្រូវបានទទួលយកជាឯកសារ E3/900 (ឯកសារ 473) D108/28.245 ត្រូវបានទទួលយកជាឯកសារ E3/901 (ឯកសារ 475); IS 21.116 ត្រូវបានទទួលយកជាឯកសារ E3/904 (ឯកសារ 478); IS 21.118 ត្រូវបានទទួលយកជាឯកសារ E3/906 (ឯកសារ 179)។

[305] D108/43/4 (ឯកសារ 503), IS 12.9 (ឯកសារ 495), IS 12.1 (ឯកសារ 487), IS 12.2 (ឯកសារ 488), IS 12.4 (ឯកសារ 490), IS 12.10 (ឯកសារ 499) IS 12.8 (ឯកសារ 494), IS 12.3 (ឯកសារ 489), IS 12.6(ឯកសារ 492), IS 12.5 (ឯកសារ

ដូចគ្នាទាំងទម្រង់ និងសណ្ឋាន។ ចំណងជើង (*Nouvelles du Cambodge*) និងឈ្មោះកន្លែងបោះពុម្ពផ្សាយ (*Agence Kampuchea d'Information*) មាននៅផ្នែកខាងលើកណ្ដាលទំព័រទី១ ដែលមានទម្រង់អក្សរផ្ដាក់ផង។ ខាងក្រោមនោះជាពាក្យពេចន៍ដែលបញ្ជាក់ថាវាជាព័ត៌មានដែលចេញផ្សាយដោយទីភ្នាក់ងារព័ត៌មាន FUNK។ មានតារាងមាតិកាមួយស្ថិតលើទំព័រទី១ នេះដែរ។ ឯកសារអស់ទាំងនេះបានទទួលពី DC-Cam ដែលបានប្រមូលពី Swedish collection នៅខែកុម្ភៈ ឆ្នាំ២០០៧[306]។ ក.ស.ព បានទទួលឯកសារចំនួន១១ ក្នុងចំណោមឯកសារទាំងនោះក្នុងពេលស៊ើបអង្កេតបឋម និងបានភ្ជាប់មកជាមួយនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរផងដែរ[307]។ក.ស.ច.ស បានផ្ទេរឯកសារមួយពីសំណុំរឿង០០១ មកសំណុំរឿងនេះ ក្នុងអំឡុងពេលបើកកិច្ចស៊ើបសួរ[308]។ ឯកសារមួយចុងក្រោយដែល ក.ស.ព បានទទួលដែរនោះ មិនទាន់បានបញ្ចូលក្នុងសំណុំរឿងនៅឡើយទេ តែគេអាចរកបាននៅក្នុងថតដាក់សម្ភារៈរួម[309]។

### *ក្រសួងការបរទេសកម្ពុជា*

១២០. មានឯកសារចំនួន៤ ដែលបានចេញដោយក្រសួងការបរទេសកម្ពុជានៅប្រទេសបារាំង[310]។ ឯកសារទាំងអស់នោះមានសណ្ឋាន ទំព័រ ទម្រង់ និងពុម្ពអក្សរដូចៗគ្នា។ ឯកសារនីមួយៗមានពាក្យថា "*Mission du Government Royal D'Union Nationale du Cambodge*" នៅផ្នែកខាងលើជ្រុងខាងឆ្វេង អមដោយអាសយដ្ឋាន និងទូរស័ព្ទសម្រាប់ទំនាក់ទំនងរបស់ស្ថានទូត និងមានលេខយោងឯកសារផងដែរ។ ឯកសារទាំងនោះក៏មានបោះត្រាផ្លូវការដែរអមជាមួយពាក្យថា "Mission du Government Royal d'Union Nationale du Cambodge (PARIS)" នៅផ្នែកខាងក្រោមជ្រុងខាងស្ដាំឯកសារ។ ឯកសារ១ ក្នុងចំណោមឯកសារទាំងនេះត្រូវបាន ក.ស.ព ប្រមូលពី DC-Cam

491) , IS 12.7 (ឯកសារ 493), IS 12.13 (ឯកសារ 507), ERN S 00002195 ថ្មី (ឯកសារ 501)។

306 សូមមើលមូលដ្ឋានទិន្នន័យ DC-Cam មាននៅ http://www.d.dccam.org/Database/Lod/index.php (អាចស្វែងរកបានតាមរយៈលេខយោង DC-Cam)។

307 IS 12.9 (ឯកសារ 495), IS 12.1 (ឯកសារ 487), IS 12.2 (ឯកសារ 488), IS 12.4 (ឯកសារ 490), IS 12.10 (ឯកសារ 499) , IS 12.8 (ឯកសារ 494), IS 12.3 (ឯកសារ 489), IS 12.6(ឯកសារ 492), IS 12.5 (ឯកសារ 491) , IS 12.7 (ឯកសារ 493), IS 12.13 (ឯកសារ 507)។

308 D108/43/4 (ឯកសារ 503). សូមមើល D108 ដីកាសម្រេច, ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨។

309 ERN S 00002195 (ឯកសារ 501) ថ្មី។

310 D199/26.2.116 (ឯកសារ 505), D199/26.2.94 (ឯកសារ 502), D199/26.2.115 (ឯកសារ 504), IS 17.1 (ឯកសារ 506)។

ក្នុងពេលស៊ើបអង្កេតបឋម និងបានភ្ជាប់ជាមួយនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរផងដែរ[311]។ DC-Cam បានឯកសារនេះពី Swedish collection នៅខែកុម្ភៈ ឆ្នាំ២០០៧[312]។ ឯកសារចំនួន៣ ផ្សេងទៀត ត្រូវបាន ក.ស.ច.ស ទទួលបាន និងបញ្ចូលក្នុងសំណុំរឿងក្នុងពេលបើកកិច្ចស៊ើបសួរ អនុលោមតាមដីកាចាត់ឲ្យស៊ើបសួរជំនួសខាងអន្តរជាតិ[313]។

*ការបោះពុម្ពផ្សាយឡើងវិញរបស់ FBIS*

១២១. បានការបោះពុម្ពផ្សាយ FBIS ចំនួន២ ដែលពាក់ព័ន្ធនឹងការផ្សាយតាមវិទ្យុ និងការបោះពុម្ពផ្សាយរបស់ FUNK/GRUNK[314]។ ឯកសារមួយជាការផ្សាយសម្លេង "ដោយលួចលាក់" របស់វិទ្យុផ្សាយសម្លេង FUNK នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៧៥ និងឯកសារមួយទៀតជាការបោះពុម្ពផ្សាយ "ដោយលួចលាក់" ដោយទីភ្នាក់ងារព័ត៌មានកម្ពុជា នៅថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៧៥។ ឯកសារទាំង២ នេះមានសណ្ឋាន និងទម្រង់ជាបទដ្ឋានរបស់ FBIS និងមានលេខរ៉ូម៉ាំង "IV" នៅផ្នែកខាងលើជ្រុងខាងឆ្វេង ដែលអមដោយកាលបរិច្ឆេទ និងអក្សរ "H" លេខទំព័រនៅផ្នែកខាងលើជ្រុងខាងស្តាំផងដែរ[315]។ មានចុះកាលបរិច្ឆេទរបស់ឯកសារផងដែរនៅផ្នែកខាងលើជ្រុងខាងឆ្វេង ហើយពាក្យថា "**កម្ពុជា**" នៅផ្នែកកណ្តាលខាងលើស្តាំ។

*ការបោះពុម្ពផ្សាយដទៃទៀតពី FUNK/GRUNK*

១២២. មានឯកសារចំនួន៤ ពីការបោះពុម្ពផ្សាយដទៃទៀតរបស់ FUNK/GRUNK។ ក.ស.ព បានទទួលឯកសារទាំង៤ នោះពី DC-Cam[316]។ ឯកសារចំនួន៣ ក្នុងចំណោមឯកសារទាំងនេះ ត្រូវបាន DC-Cam ប្រមូលពី Swedish collection នៅខែកុម្ភៈ ឆ្នាំ២០០៧[317]។

---

[311] IS 17.1 (ឯកសារ 506)។

[312] សូមមើលមូលដ្ឋានទិន្នន័យ DC-Cam មាននៅ http://www.d.dccam.org/Database/Lod/details.php?keyword=D29041&numRecords=100&lang=eng&page=1&idnum=D29041។

[313] D199/26.2.116(ឯកសារ 505), D199/26.2.94(ឯកសារ 502), D199/26.2.115(ឯកសារ 504). សូមអាន D199 ដីកាចាត់ឲ្យស៊ើបសួរជំនួសអន្តរជាតិ, ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៩។

[314] D108/43/1 (ឯកសារ 500), ERN 00166706 (ឯកសារ 498) ថ្មី។

[315] សូមមើលបន្ថែម ផ្នែកទី៩ ខាងលើ ទាក់ទងនឹងសេចក្តីរាយការណ៍ FBIS។

[316] IS 19.129 (ឯកសារ 496); IS 18.1(ឯកសារ 486); D366/7.1.455 (ឯកសារ 485) D56-doc. 016 (ឯកសារ 497)។

[317] IS 19.129 (ឯកសារ 496); D366/7.1.455 (ឯកសារ 485) D56-doc. 016 (ឯកសារ 497)។ សូមមើលមូលដ្ឋានទិន្នន័យ DC-Cam មាននៅ http://www.d.dccam.org/Database/Lod/index.php (អាចស្វែងរកបានតាមរយៈលេខយោង DC-Cam)។

## ១៥. ការប្រាស្រ័យទាក់ទងជាមួយអន្តរជាតិ

១២៣. មានឯកសារចំនួន១០ នៅក្នុងបញ្ជីឯកសារ ដែលចាត់ប្រភេទថាជាឯកសារស្តីពីទំនាក់ទំនងអន្តរជាតិ[318]។ ឯកសារទាំងនេះមានជាគោលគឺ សារទូរលេខរវាងស្ថានទូតសហរដ្ឋអាមេរិក និងស្ថានទូតប្រទេសបារាំង និងរដ្ឋាភិបាលរបស់ប្រទេសទាំងពីរនេះ[319]។ នៅក្នុងចំណោមឯកសារប្រភេទនេះ ក៏មានរបាយការណ៍មួយ ដែលមានចំណងជើងថា "ប្រទេសចិន និងប្រទេសកម្ពុជា" សរសេរដោយ Leon Trivière នៃ Missions Étrangeres de Paris ផ្ញើជូនទៅអង្គភាពប្រទេសចិននៃការិយាល័យទំនាក់ទំនងបារាំង-អាស៊ី[320]។

### *សារទូរលេខរបស់សហរដ្ឋអាមេរិក*

១២៤. សារមានទូរលេខសហរដ្ឋអាមេរិកចំនួន៤ នៅក្នុងបញ្ជីឯកសារ។ គ្រប់សារទូរលេខទាំងអស់តំណាងឱ្យទំនាក់ទំនងផ្ទៃក្នុង រវាងរដ្ឋាភិបាលសហរដ្ឋអាមេរិក និងស្ថានទូតនានារបស់ខ្លួន។ សារទូរលេខទាំងនោះ មានចាប់ពីថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ហើយសុទ្ធតែពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍នៅក្នុងបរិបទនយោបាយប្រទេសកម្ពុជា។ ហេតុដូច្នេះ សារទូរលេខទាំងនេះ គឺជាកំណត់ហេតុដែលកើតឡើងក្នុងអំឡុងពេលតែមួយ នៃព្រឹត្តិការណ៍នានា ដែលសារទូរលេខទាំងនេះបានកត់ត្រា។

១២៥. សារទូរលេខទាំងនេះមានទម្រង់ដូចៗគ្នា។ ឯកសារទាំងអស់មានការចាត់ប្រភេទរបស់វា ដូចជា "ស្លាកឯកសារ" និងកម្មវត្ថុ មុននឹងចូលដល់តួរសេចក្តីនៃសារទូរលេខនោះ។ នៅក្នុងសារទូរលេខទាំងនោះ ក៏មានរៀបរាប់អំពីអ្នកផ្ញើ អ្នកទទួល ជាគោល និងអ្នកទទួលដទៃទៀតដែលនឹងទទួលបានសារទូរលេខនោះជាច្បាប់ចម្លងផងដែរ (មានដូចជា ស្ថានទូតសហរដ្ឋអាមេរិក ឬក្រសួងរដ្ឋាភិបាលសហរដ្ឋអាមេរិក ជាដើម)។ សារទូរលេខទាំងនេះ ក៏បញ្ជាក់បន្ថែមទៀតផងដែរនូវលេខ "ដីកាបញ្ជារបស់ប្រធានាធិបតី" (*'Executive Order'*) ដែលជាទូទៅ គឺលេខ ១១៦៥២ ស្តីអំពី "ការចាត់

---

[318] ឯកសារ 508-517 នៅក្នុងបញ្ជីឯកសារ។ កត់សម្គាល់ថា ឯកសារ D2-15.1, D83-Annex-00011 (ឯកសារ 517), គឺជាបទសម្ភាសន៍មានចំណងជើងថា "ប្រវត្តិរបស់ កែ ពក", មាននៅក្នុងឯកសារនេះ ចាត់ថ្នាក់ខុស។

[319] មានទូរលេខ៨ នៅក្នុងបញ្ជីឯកសារ: D313/1.2.92 (ឯកសារ 515); D313/1.2.74 (ឯកសារ 513); D199/26.2.212 (ឯកសារ 512); D199/26.2.153 (ឯកសារ 516); D199/26.2.201 (ឯកសារ 511); D313/1.2.52 (ឯកសារ 508); D199/26.2.199 (ឯកសារ 510); D313/1.2.56 (ឯកសារ509)។

[320] ឯកសារ D199/26.2.28 (ឯកសារ 514)។

ប្រភេទឯកសារ និងការដកចំណាត់ប្រភេទឯកសារស្តីពីព័ត៌មាន និងសម្ភារៈខាងសន្តិសុខជាតិ”។ ជាចុងក្រោយ ប្រតិចារឹកនៃអត្ថបទសារទូរលេខទាំងនេះ (ដែលមិនមែនជាច្បាប់ចម្លងនៃសារទូរលេខដើម) សុទ្ធតែមានទំព័រចុងក្រោយមួយសន្លឹកភ្ជាប់មកជាមួយ ដែលមានចំណងជើងថា លក្ខណៈនានារបស់សារលិខិត ដែលរៀបរាប់នូវព័ត៌មានលម្អិតទាំងអស់របស់សារទូរលេខនីមួយៗ (ដែលមានដូចជា អ្នកផ្ញើ អ្នកទទួល ចំណាត់ប្រភេទឯកសារសម្ងាត់ ជាដើម)។

១២៦. គ្រប់សារទូរលេខរបស់សហរដ្ឋអាមេរិកទាំងអស់ត្រូវបានដាក់ចូលទៅក្នុងសំណុំរឿងដោយ កសព នៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ។ កសព បានទទួលឯកសារទាំងនេះពីសំណុំឯកសារកំណត់ហេតុដ៏ធំមួយ ដែលមានចាប់ពីថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៧៣ ដល់ថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៧៥ ដែលត្រូវបានផ្សាយជាសាធារណៈដោយរដ្ឋបាលគ្រប់គ្រងកំណត់ហេតុ និងបណ្ណសារជាតិរបស់សហរដ្ឋអាមេរិក[321]។ ហេតុដូច្នេះ សារទូរលេខទាំងអស់នេះ សុទ្ធតែចេញមកពីប្រភពដើមតែមួយ គឺបណ្ណសារកំណត់ហេតុផ្លូវការរបស់រដ្ឋាភិបាល ហើយដូច្នេះ ដំណើរនៃការរក្សាភ័ស្តុតាងអាចត្រូវបានបង្កើតរួចជាស្រេច។

*សារទូរលេខ និងរបាយការណ៍របស់បារាំង*

១២៧. សារទូរលេខរបស់បារាំងចំនួន៤ នៅក្នុងបញ្ជីឯកសារ។ គ្រប់សារទូរលេខទាំងអស់ តំណាងឱ្យការទាក់ទងផ្ទៃក្នុងរបស់រដ្ឋាភិបាលបារាំង។ សារទូរលេខទាំងនេះមានចាប់ពីថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៧៨ ហើយសុទ្ធតែពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ថ្មីៗ នៅក្នុងបរិបទនយោបាយប្រទេសកម្ពុជាទាំងអស់។ ហេតុដូច្នេះ សារទូរលេខទាំងនេះ គឺជាកំណត់ហេតុដែលកើតឡើងក្នុងអំឡុងពេលតែមួយ នៃព្រឹត្តិការណ៍នានាដែលសារទូរលេខទាំងនេះ បានកត់ត្រា។

១២៨. សារទូរលេខទាំងនេះមានទម្រង់ដូចៗគ្នា ដែលសុទ្ធតែត្រូវបានបោះពុម្ពនៅលើទំព័រដែលមានក្បាលទំព័រផ្លូវការដូចគ្នា គឺ Ministère des Affaires Etrangères (ក្រសួងការបរទេស) និងចំណងជើងរង Télégramme A L'Arrivée (សារទូរលេខមកដល់ថ្មី)។ ជាទូទៅ នៅចុងខាងស្តាំផ្នែកខាងលើនៃទំព័រ មានពាក្យថា “Déchiffrement” ហើយនៅចុងខាងស្តាំផ្នែកខាងលើវិញ មានបង្ហាញអំពីអ្នកទទួលសារទូរលេខនោះ។ ស្ទើរតែគ្រប់ពេលទាំងអស់ នៅក្នុងផ្នែកបន្ទាប់ទៀតនៃអត្ថបទ

---

[321] ឯកសារ D313 សំណើរបស់សហព្រះរាជអាជ្ញា សុំដាក់បញ្ចូលឯកសារភ័ស្តុតាងបន្ថែមទៅក្នុងសំណុំរឿង,ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩, ត្រង់កថាខណ្ឌ ១១។

សារទូរលេខនោះសុទ្ធតែមានបង្ហាញអំពីកាលបរិច្ឆេទ និងចំណាត់ប្រភេទឯកសារ និងមធ្យោបាយនៃការបញ្ជូនសារទូរលេខនោះ ហើយប្រយោគបន្ទាប់មកទៀត បញ្ជាក់អំពីកម្មវត្ថុ។ បន្ទាប់ពីនោះមក គឺជាតួរសេចក្ដីនៃសារទូរលេខ។

១២៩. ភាពស៊ីសង្វាក់គ្នានៅក្នុងអត្ថបទសារទូរលេខចំនួនពីរ ក៏បង្ហាញឱ្យឃើញផងដែរអំពីភាពអាចជឿជាក់បាននៃឯកសារនោះ។ ជាឧទាហរណ៍ នៅក្នុងបន្ទាត់ទីមួយនៃតួរសេចក្ដីនៃអត្ថបទឯកសារ D199/26.2.212 (ឯកសារ ៥១២) យោងទៅលើលេខសារទូរលេខ ៥៩៥ ដែលជាឯកសារ D199/26.2.199 (ឯកសារ ៥១០)។

១៣០. សារទូរលេខរបស់បារាំង និងរបាយការណ៍របស់ Leon Triviere ត្រូវបានប្រគល់ជូន កសចស ដោយក្រសួងការបរទេសបារាំង ដែលជាការឆ្លើយតបទៅនឹងដីកាចាត់ឱ្យស៊ើបសួរជំនួសរបស់ ក.ស.ច.ស[322]។ ហេតុដូច្នេះ សារទូរលេខទាំងនេះ គឺជាកំណត់ហេតុផ្លូវការរបស់រដ្ឋាភិបាល [បារាំង] ដែលចេញមកពីប្រភពតែមួយដូចគ្នា ដោយមានដំណើរនៃការរក្សាភស្តុតាងរួចជាស្រេច។

## ១៦. សេចក្ដីរាយការណ៍របស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានអន្តរជាតិ

១៣១. មានឯកសារចំនួនម្ភៃបួន (២៤) ច្បាប់នៅក្នុងបញ្ជីឯកសារ ដែលត្រូវបានចាត់ប្រភេទថាជា "សេចក្ដីរាយការណ៍របស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានអន្តរជាតិ"[323]។ ឯកសារប្រភេទនេះ គឺពិតជាត្រូវបានចងក្រងពីសេចក្ដីរាយការណ៍របស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដែលបានមកពីអ្នកបោះពុម្ពផ្សាយអន្តរជាតិនានា ជាពិសេស បានមកពីប្រព័ន្ធផ្សព្វផ្សាយសារព័ត៌មានផ្សេងៗ នៅក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ និងនៅក្នុងអំឡុងពេលភ្លាមៗ ទាំងមុន និងក្រោយ របបកម្ពុជាប្រជាធិបតេយ្យ។

១៣២. សេចក្ដីរាយការណ៍របស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានទាំងអស់នេះ រៀបរាប់អំពីចំណាត់ការលើកិច្ចការទូត រួមមាន ដំណើរទស្សនកិច្ចផ្លូវរដ្ឋ និងសុន្ទរកថានានា ដែលថ្លែងដោយមេដឹកនាំ បកកព្រឹត្តិការណ៍ដែលកើតឡើងនៅក្នុងប្រទេសកម្ពុជា ព្រមទាំងការជម្លៀសប្រជាជនចេញពីទីក្រុង

---

322 ឯកសារ D199/26 ដីកាសម្រេច, ថ្ងៃទី៨ ខែមករា ឆ្នាំ២០១០។

323 ឯកសារលេខ ៥១៨-៥៤១ នៅក្នុងបញ្ជីឯកសារ។

ភ្នំពេញ ការប្រហារជីវិត "ជនក្បត់" និងកិច្ចសម្ភាសន៍ដែលធ្វើឡើងវិញជាមួយមេដឹកនាំជាន់ខ្ពស់នានា រួមមាន អៀង សារី ផងដែរ។

១៣៣. សេចក្តីរាយការណ៍ព័ត៌មានទាំងអស់ ធ្វើតាមបែបបទពិសេសនៃអត្ថបទសារព័ត៌មាន ឬសេចក្តីរាយការណ៍អំពីសេវាផ្សាយព័ត៌មានអន្តរជាតិ (FBIS)[324] ដែលបានកំណត់អត្តសញ្ញាណរបស់អ្នកបោះពុម្ពផ្សាយនៅលើឯកសារទាំង២៤ច្បាប់នេះ ហើយអ្នកនិពន្ធអត្ថបទសារព័ត៌មានម្នាក់ៗ ត្រូវបានកំណត់អត្តសញ្ញាណចំពោះឯកសារភាគច្រើន។ កាលបរិច្ឆេទត្រូវបានសរសេរនៅលើឯកសារទាំងអស់នេះផងដែរ។ ក្នុងចំណោមឯកសារទាំងនេះ មានឯកសារចំនួន១៣ច្បាប់ ស្ថិតនៅក្នុងទម្រង់បោះពុម្ពផ្សាយដើម ក្រដាសបោះពុម្ពផ្សាយពិសេស និងការរៀបចំតាក់តែងរបស់វា[325]។ ឯកសារទាំងឡាយដែលមិនស្ថិតក្នុងទម្រង់បោះពុម្ពផ្សាយដើមរបស់វា គឺដោយសារតែឯកសារទាំងនោះបានទទួលមកពីបណ្ណសាររបស់អ្នកបោះពុម្ពផ្សាយ ដែលឯកសារទាំងអស់នេះមានឃីហោស្លាកសញ្ញា ឬសេចក្តីលម្អិតនៃគេហទំព័របណ្ណសារ[326] ។

១៣៤. អត្ថបទសារព័ត៌មានចំនួនប្រាំបួន(៩)ច្បាប់ដោយដែលមានសំណេរដៃ ចាប់ផ្តើមជាមួយនឹងអក្សរ "D" នៅជ្រុងទំព័រខាងលើផ្នែកខាងស្តាំ និងចំណារដោយដៃដែលទាក់ទងនឹងកាលបរិច្ឆេទ ឬអ្នកបោះពុម្ពផ្សាយ ត្រូវបានប្រមូលចងក្រងដោយ DC-Cam[327]។ ភាគច្រើននៃឯកសារទាំងនេះ អាច

---

[324] មានសេចក្តីរាយការណ៍របស់សេវាផ្សព្វផ្សាយព័ត៌មានបរទេសបី (FBIS) នៅក្នុងបញ្ជីឯកសារ។ D262.3 (ឯកសារ521); D262.4 (ឯកសារ 522); D376.3 (ឯកសារ 532)។ សេចក្តីរាយការណ៍របស់ FBIS ត្រូវបានបង្កើតឡើងដោយទីភ្នាក់ងារស៊ើបអង្កេតកណ្តាលរបស់អាមេរិក និងមានការបកប្រែជាភាសាអង់គ្លេសនៃសេចក្តីរាយការណ៍ទាំងនេះ មកពីប្រភពព័ត៌មានសាធារណៈផ្សេងទៀត។ របាយការណ៍នេះត្រូវបានធ្វើជាប្រចាំថ្ងៃតាំងពីសង្គ្រាមលោកលើកទីពីរ។

[325] សូមមើល D29/I ឯកសារភ្ជាប់ 15, D29- ឯកសារភ្ជាប់ 36 (ឯកសារ541); D262.3 (ឯកសារ521); (ឯកសារ 525) ថ្មី; D56-Doc 006 (ឯកសារ 519 ); D262.4 (ឯកសារ 522); D366/7.1.278 (ឯកសារ 527); D376.3 (ឯកសារ 532); D313/1.2.370 (ឯកសារ 535); D56-Doc 119 (ឯកសារ 536); D56-Doc 019 (ឯកសារ 523); D56-Doc 020, D108/43/2 (ឯកសារ 524); (ឯកសារ 528) ថ្មី; D313/1.2.371 (ឯកសារ 526)។

[326] ឯកសារ D56-Doc 18 (ឯកសាសរ 538)។ IS 19.52 (ឯកសារ 540)។ IS 19.230 (ឯកសារ 520)។ ឯកសារ D56-Doc 062 (ឯកសារ 530)។ ឯកសារ D56-Doc 118 (ឯកសារ 534)។ ឯកសារ D56-Doc 432, D29- ឯកសារភ្ជាប់ 48 (ឯកសារ 539)។ ឯកសារ D365/1.1.11 (ឯកសារ 526)។ ឯកសារ D56-Doc 005 (ឯកសារ 518)។ ឯកសារ D56-Doc 078 (ឯកសារ 531)។ ឯកសារ D56-Doc 109 (ឯកសារ 533)។ ឯកសារ D56-Doc 041 (ឯកសារ 529)។

[327] ឯកសារ D366/7.1.278 (ឯកសារ 527, មជ្ឈមណ្ឌលឯកសារកម្ពុជា លេខ D28598)។ ឯកសារ D313/1.2.370 (ឯកសារ 535, មជ្ឈមណ្ឌលឯកសារកម្ពុជា លេខ D42102)។ ឯកសារ D56-Doc 019 (ឯកសារ 523 , មជ្ឈមណ្ឌលឯកសារកម្ពុជា លេខ D27874)។ ឯកសារ D56-Doc 020, D108/43/2 (ឯកសារ 524, មជ្ឈមណ្ឌលឯកសារកម្ពុជា លេខ D27881)។ ថ្មី (ឯកសារ 528, មជ្ឈមណ្ឌលឯកសារកម្ពុជា លេខ D28604)។ D313/1.2.371 (ឯកសារ 526, មជ្ឈមណ្ឌលឯកសារកម្ពុជា លេខ D42104)។ ឯកសារ D56-Doc 119 (ឯកសារ 537, មជ្ឈមណ្ឌលឯកសារកម្ពុជា លេខ D30745)។ ឯកសារ D56-Doc 006 (ឯកសារ 519 មជ្ឈមណ្ឌល

រកបានពីប្រភពដើមដែលត្រូវបានគេហៅថា “ការប្រមូលចងក្រងដោយប្រទេសស៊ុយអែត”[328]។ ក.ស.ច.ស បានទទួលសេចក្ដីរាយការណ៍របស់ FBIS ចំនួនបី មកពីបណ្ណាល័យសាកលវិទ្យាល័យហារីត (Harvard University) នៅក្នុងអំឡុងនៃកិច្ចស៊ើបសួរ និងបានដាក់បញ្ចូលទៅក្នុងឃ្លាំងផ្ទុកឯកសាររួមក្នុងកុំព្យូទ័រ(SMD) ក្នុងខែមិថុនា ឆ្នាំ២០០៨។ ជាបន្ទាប់មកទៀត ឯកសារចំនួនពីរត្រូវបានដាក់បញ្ចូលនៅក្នុងសំណុំរឿងតាមសំណើរបស់ ក.ស.ព[329]។ របាយការណ៍របស់ FBIS មួយផ្សេងទៀត ត្រូវបានដាក់ទៅក្នុងសំណុំរឿងតាមការផ្ដួចផ្ដើមផ្ទាល់របស់ ក.ស.ច.ស[330]។ អត្ថបទសារព័ត៌មានពីរ ក្នុងចំណោមអត្ថបទសារព័ត៌មានទាំងនេះ ត្រូវបាន ក.ស.ព ប្រមូលក្នុងអំឡុងកិច្ចស៊ើបអង្កេតបឋម និងបានភ្ជាប់ជាឧសម្ព័ន្ធទៅនឹងដីកាបញ្ជូនរឿងឱ្យស៊ើបសួរ[331]។ ក.ស.ព បានទទួលឯកសារដប់ (១០) ច្បាប់ផ្សេងទៀតមកពីព្រភពសាធារណៈ បន្ទាប់ពីការចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររួចមក[332]។

១៣៩. អត្ថបទសារព័ត៌មានមួយច្បាប់ ក្នុងចំណោមអត្ថបទសារព័ត៌មានទាំងអស់ នៅក្នុងបញ្ជីឯកសារ ត្រូវបានទទួលយកជាភ័ស្តុតាងនៅក្នុងសំណុំរឿង០០១[333]។ ក្រៅពីនេះ អត្ថបទសារព័ត៌មានអន្តរជាតិជាង ២០០ ច្បាប់ទៀត ដែលមានប្រភព និងចរិតលក្ខណៈស្រដៀងគ្នាទៅនឹងអត្ថបទសារព័ត៌មាននៅក្នុងបញ្ជីឯកសារ ត្រូវបានទទួលស្គាល់ក្នុងសំណុំរឿង០០១ ថាមានតម្លៃជាភ័ស្តុតាងភរនីយភាព

---

ឯកសារកម្ពុជា លេខ D25911)។ ថ្មី (ឯកសារ 525, មជ្ឈមណ្ឌលឯកសារកម្ពុជា លេខ D28399)។

[328] ឯកសារ D366/7.1.278 (ឯកសារ 527, មជ្ឈមណ្ឌលឯកសារកម្ពុជា លេខ D28598)។ ឯកសារ D56-Doc 019 (ឯកសារ 523, មជ្ឈមណ្ឌលឯកសារកម្ពុជា លេខ D27874)។ ឯកសារ D56-Doc 020, D108/43/2 (ឯកសារ 524, មជ្ឈមណ្ឌលឯកសារកម្ពុជា លេខ D27881)។ ថ្មី (ឯកសារ 528, មជ្ឈមណ្ឌលឯកសារកម្ពុជា លេខ D28604)។ ឯកសារ D56-Doc 119 (ឯកសារ 537, មជ្ឈមណ្ឌលឯកសារកម្ពុជា លេខ D30745)។ ឯកសារ D56-Doc 006 (ឯកសារ 519។ មជ្ឈមណ្ឌលឯកសារកម្ពុជា លេខ D25911)។ ថ្មី (ឯកសារ 525, មជ្ឈមណ្ឌលឯកសារកម្ពុជា លេខ D28399)។ សូមមើល ទិន្នន័យមជ្ឈមណ្ឌលឯកសារកម្ពុជា មាននៅ http://www.d.dccam.org/Database/ Lod/index.php. (អាចស្រាវជ្រាវរកបានតាមរយៈលេខ DC-Cam)។

[329] ឯកសារ D262.3 (ឯកសារ 521), D262.4 (ឯកសារ 522), D376.3 (ឯកសារ 532)។ សូមមើល ឯកសារ D262 សំណើសុំដាក់របាយការណ៍ ស្ដីពីសេវាផ្សព្វផ្សាយព័ត៌មានបរទេស បញ្ចូលក្នុងសំណុំរឿង, ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩។

[330] ឯកសារ D376.3 (ឯកសារ 532)។ សូមមើល ឯកសារ D376 ដីកាសម្រេច, ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១០។

[331] IS 19.52 (ឯកសារ 540)។ IS 19.230 (ឯកសារ 520)។

[332] សូមមើល ឯកសារ D56 សំណើរបស់សហព្រះរាជអាជ្ញា ស្ដីពីការសុំឱ្យដាក់បញ្ចូលឯកសារទៅក្នុងសំណុំរឿង, ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩ ត្រង់កថាខណ្ឌ ១ និង ឯកសារ D56-ឧបសម្ព័ន្ធ ក និង តារាងសំអាងផ្លូវច្បាប់សម្រាប់គាំទ្រដល់ការឃុំខ្លួនជនសង្ស័យបណ្ដោះអាសន្ន ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៧។

[333] IS 19.52 (ឯកសារ 540; ទទួលយកជាឯកសារ E3/180)។

នៃអត្ថិភាពជម្លោះប្រដាប់អាវុធអន្តរជាតិរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម[334]។

## ១៧. ផែនទី

១៣៦. មានផែនទី១នៅក្នុងបញ្ជីឯកសារ[335]។ ឯកសារនេះមានប្រភពមកពីបណ្ណសារទូរនិមិត្តវៀតណាម (Virtual Vietnam Archive) ដែលបានដំណើរការដោយ *មជ្ឈមណ្ឌលវៀតណាម (The Vietnam Center)* ហើយសាធារណជនទូទៅក៏អាចចូលមើលបានដែរ[336]។ ក.ស.ច.ស បានផ្ទេរផែនទីនេះពីសំណុំរឿង០០១ ទៅក្នុងសំណុំរឿងនេះ ក្នុងអំឡុងពេលបើកកិច្ចស៊ើបសួរ[337]។ ឯកសារនេះត្រូវបានទទួលយកជាភ័ស្តុតាងក្នុងសំណុំរឿង[338]។

## ១៨. កំណត់ហេតុប្រជុំ

១៣៧. មានឯកសារចំនួន២៧ច្បាប់នៅក្នុងបញ្ជីឯកសារ ត្រូវបានចាត់ថ្នាក់ជា "កំណត់ហេតុអង្គប្រជុំ"[339]។ ឯកសារប្រភេទនេះរួមមាន កំណត់ហេតុអង្គប្រជុំគណៈអចិន្ត្រៃយ៍នៃបកក ចំនួន២២ច្បាប់[340] កំណត់ហេតុអង្គប្រជុំរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យចំនួន២ច្បាប់[341] កំណត់ហេតុអង្គប្រជុំរវាងតំណាងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ និងប្រតិភូពាណិជ្ជកម្មអន្តរជាតិរបស់ប្រទេសចិន

---

[334] សូមមើល ឯកសារ E176 សេចក្តីសម្រេចលើសំណើរបស់ភាគីនានា សុំដាក់សម្ភារៈមួយចំនួនទៅចំពោះមុខអង្គជំនុំជម្រះ អនុលោមតាមវិធានផ្ទៃក្នុង ៨៧(២), ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៩ ត្រង់កថាខណ្ឌ ៦ រួមជាមួយឯកសារ E61.1 (បន្ទាត់ ២៤-២៤៨)។

[335] D108/50/1.2 (ឯកសារ 542)។

[336] លេខយោង៖ MAP12090305. មាននៅ http://www.virtualarchive.vietnam.ttu.edu/starweb/virtual/vva/servlet.starweb?path=virtual/vva/virtual.web។

[337] *សូមមើល* D108 ដីកាសម្រេច ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨។

[338] ត្រូវបានទទួលយកជាឯកសារ E3/344។

[339] ឯកសារ 543 -569 on នៅក្នុងបញ្ជីឯកសារ។

[340] IS 13.1 (ឯកសារ 543)។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ 13.2, ឯកសារD323/8.3, D200/9.7, D279/6.1 (ឯកសារ 544)។ IS 13.3 (ឯកសារ 545)។ IS 13.4 (ឯកសារ 546)។ IS 13.6 (ឯកសារ 547)។ IS 13.5 (ឯកសារ 548)។ ឯកសារ D251/1 (ឯកសារ 549)។ IS 13.8 (ឯកសារ 550)។ IS 13.7 (ឯកសារ 551)។ IS 13.10 (ឯកសារ 552)។ IS 13.9 (ឯកសារ 553)។ IS 13.11, ឯកសារ D279/7.2 (ឯកសារ 554)។ IS 13.12 (ឯកសារ 556)។ IS 13.14, ឯកសារD279/7.1 (ឯកសារ 558)។ IS 13.15 (ឯកសារ 559)។ IS 13.16, IS 13.16/Corr-1 (ឯកសារ 560)។ IS 13.18 (ឯកសារ 561)។ IS 13.19 (ឯកសារ 562)។ IS 13.20 (ឯកសារ 563)។ IS 13.21 (ឯកសារ 564)។ IS 13.23 (ឯកសារ 565)។ IS 13.24 (ឯកសារ 566)។

[341] IS 13.43 (ឯកសារ 567) និង D56-Doc. 148 (ឯកសារ 568)។

ចំនួនមួយច្បាប់[342] និងកំណត់ហេតុអង្គប្រជុំរបស់គណៈកម្មាធិការទទួលបន្ទុកទិញ-លក់ទំនិញរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យមួយច្បាប់[343] និងកំណត់ហេតុអង្គប្រជុំសភាតំណាងប្រជាជននៃកម្ពុជាប្រជាធិបតេយ្យមួយច្បាប់[344]។

## *កំណត់ហេតុអង្គប្រជុំរបស់គណៈអចិន្ត្រៃយ៍ បកក*

១៣៨. កំណត់ហេតុអង្គប្រជុំគណៈអចិន្ត្រៃយ៍នៃ បកក មានលក្ខណៈស្រដៀងគ្នា និងយកតាមទម្រង់ដែលស៊ីសង្វាក់គ្នាជាទូទៅមួយ។ ភាគច្រើននៃឯកសារនេះ ត្រូវបានវាយអង្គុលីលេខនៅលើក្រដាសទំហំ A4 ដោយមានទ្រង់ទ្រាយអក្សរដូចគ្នា ឬស្រដៀងគ្នា។ កំណត់ហេតុអង្គប្រជុំចំនួនដប់ប្រាំបី(១៨) ច្បាប់ ក្នុងចំណោមកំណត់ហេតុអង្គប្រជុំដែលបានដាក់បញ្ចូលចំនួនម្ភៃពីរ(២២)ច្បាប់ នៅក្នុងបញ្ជីឯកសារ រួមមាន កំណត់ត្រាវត្តមានរបស់អ្នកចូលរួម[345]។ កំណត់ហេតុអង្គប្រជុំកត់ត្រាការចូលរួមជាប្រចាំរបស់សមាជិកដែលគេស្គាល់ (ឬសមាជិក*ដែលមានអំណាចតាមព្រឹត្តិហេតុ* "*de facto* members") នៃគណៈអចិន្ត្រៃយ៍ បកក រួមមាន នួន ជា ត្រូវបានកត់ត្រាថាមានវត្តមានក្នុងអង្គប្រជុំទាំងនោះចំនួន១៨លើក ប៉ុល ពត ត្រូវបានកត់ត្រាថាមានវត្តមានក្នុងអង្គប្រជុំទាំងនោះចំនួន១៧លើក[346] ខៀវ សំផន ត្រូវបានកត់ត្រាថាមានវត្តមានក្នុងអង្គប្រជុំទាំងនោះចំនួន១៥លើក[347] អៀង សារី ត្រូវបានកត់ត្រាថាមានវត្តមានក្នុងអង្គប្រជុំទាំងនោះចំនួន១០លើក[348]។ ខៀវ សំផន បានបញ្ជាក់ថា រូបគាត់ ប៉ុល ពត នួន ជា បានចូលរួមក្នុងកិច្ចប្រជុំខ្លះ នៅក្នុងចំណោមកិច្ចប្រជុំទាំងអស់នោះ។ ក្នុងសៀវភៅរបស់គាត់ដែលបានសរសេរ ក្នុងឆ្នាំ២០០៧ ខៀវ សំផន បានបញ្ជាក់ថា រូបគាត់ ប៉ុល ពត និង នួន ជា មានវត្តមាននៅក្នុងកិច្ចប្រជុំថ្ងៃទី១៤ ខែមិថុនា ឆ្នាំ ១៩៧៦[349] និង

---

[342] ឯកសារ D56-Doc. 149, D279/7.10 (ឯកសារ 569)។

[343] ឯកសារ D248/6.1.3 (ឯកសារ 555)។

[344] IS 13.13 (ឯកសារ 557)។

[345] ឯកសារបួនខាងក្រោម មិនមានឈ្មោះអ្នកចូលរួមទេ៖ IS 13.1(ឯកសារ543); D251/1 (ឯកសារ549); IS 13.2, D232/8.3, D200/9.7(ឯកសារ544); IS 13.14, D279/7.1 (ឯកសារ558)។

[346] មិនមានឈ្មោះ ប៉ុល ពត នៅក្នុង IS 13.12 (ឯកសារ556) ទេ។

[347] ខៀវ សំផន មិនមានសរសេរថាមានវត្តមាននៅក្នុងឯកសារ IS 13.4 (ឯកសារ 546); IS 13.16 (ឯកសារ 560); or IS 13.23 (ឯកសារ 565)។

[348] អៀង សារី មិនមានសរសេរថាមានវត្តមាននៅក្នុងឯកសារ IS 13.4 (ឯកសារ 546); IS 13.8 (ឯកសារ 550); IS 13.9 (ឯកសារ 553); IS 13.12 (ឯកសារ556); IS 13.19 (ឯកសារ562); IS 13.21 (ឯកសារ 564); IS 13.23 (ឯកសារ 565); IS 13.24 (ឯកសារ566)។

[349] D213.2 ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា ពីដើមរហូតសម័យកម្ពុជាប្រជាធិបតេយ្យ ដោយ ខៀវ សំផន, ត្រង់ទំព័រ ERN 00498263-4

បានលើកឡើងថា កំណត់ហេតុកិច្ចប្រជុំមួយផ្សេងទៀត ក្នុងឆ្នាំ១៩៧៦ បានកត់ត្រា "គំនិតដែលបានលើកឡើងដោយ ប៉ុល ពត"[350]។ នៅក្នុងការសួរចម្លើយមួយចំពោះមុខ កសចស ក្នុងឆ្នាំ២០០៧ ខៀវ សំផន បានផ្តល់សក្ខីកម្មថា គាត់បានចូលរួមក្នុងកិច្ចប្រជុំខ្លះរបស់គណៈអចិន្ត្រៃយ៍[351]។

១៣៩. កម្មវត្ថុនៃកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ បកក គឺអាចពាក់ព័ន្ធនឹងថ្នាក់លើបំផុតរបស់រដ្ឋាភិបាល និងស្របគ្នាទៅនឹងគោលនយោបាយរបស់ បកក ដែលបានដឹងរួចមកហើយ។ គោលនយោបាយការបរទេស និងការការពារជាតិ គឺជាប្រធានបទដែលត្រូវបានលើកឡើងយ៉ាងញឹកញាប់បំផុតនៅក្នុងកិច្ចប្រជុំ។ ក្នុងចំណោមកំណត់ហេតុនៃកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ បកក ទាំង២២ នៅក្នុងបញ្ជីឯកសារ មានតែកំណត់ហេតុចំនួន៧ប៉ុណ្ណោះ ដែលមិនផ្តោតការយកចិត្តទុកដាក់ទៅលើប្រធានបទពីរនេះ[352]។ ការពិតនៃខ្លឹមសារនៅក្នុងកំណត់ហេតុនៃកិច្ចប្រជុំពីរនៃកិច្ចប្រជុំទាំងឡាយដែលបានកត់ត្រាកិច្ចប្រជុំ ផ្តោតការយកចិត្តទុកដាក់ទៅលើពាណិជ្ជកម្ម[353] ព្រមទាំងការផ្ទេរមុខងារ និងការទទួលខុសត្រូវ នៅក្នុងគណៈកម្មាធិការផ្សេងៗរបស់ បកក[354] ត្រូវបានបញ្ជាក់ទាំងស្រុង ឬដោយផ្នែកខ្លះ ដោយ ស គឹមល្មុត នៅក្នុងកិច្ចសម្ភាសន៍ស្តាប់ចម្លើយមួយដែលបានធ្វើឡើងដោយ ក.ស.ច.ស[355]។ បន្ថែមលើនេះទៀត ការពិតនៃខ្លឹមសារនៅក្នុងកំណត់ហេតុនៃកិច្ចប្រជុំថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៧៦ ត្រូវបានបញ្ជាក់អះអាង និងអត្ថាធិប្បាយដោយ ខៀវ សំផន ផ្ទាល់[356]។

១៤០. នៅក្នុងកិច្ចសម្ភាសន៍ស្តាប់ចម្លើយមួយដែល ក.ស.ច.ស បានធ្វើកាលពីថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៩ លោក ឆាំង យុ ដែលជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បានកំណត់អត្តសញ្ញាណទៅលើកំណត់ហេតុនៃកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ បកក ចំនួន៤ច្បាប់ នៅក្នុងបញ្ជីឯកសារ ហើយបាន

---

ទាក់ទងនឹងឯកសារ IS 13.18 (ឯកសារ561)។

[350] *ដូចជើងទំព័រខាងលើ*។ ត្រង់លេខ ERN 00498285។

[351] ឯកសារ C25 កំណត់នៃកិច្ចពិភាក្សាដេញដោល, ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ ត្រង់ទំព័រ ៥។

[352] ឯកសារខាងក្រោមមិនពិនិត្យផ្ទៀងផ្ទាត់គោលនយោបាយបរទេស ឬយោធា/ការការពារជាតិទេ៖ IS 13.14, D279/7.1 (ឯកសារ 558); IS 13.23(ឯកសារ 565); IS 13.2, D232/8.3, D200/9.7(ឯកសារ 544)។

[353] IS 13.11, D279/7.2(ឯកសារ 554)។

[354] IS 13.14, D279/7.1 (ឯកសារ 558)។

[355] សូមមើល D279/7 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី (សគឹម ល្មុត), ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៩ ត្រង់ទំព័រ ៣ (ទាក់ទងនឹងឯកសារ IS 13.11 គាត់បានអះអាងថា វាជាឯកសារកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ និងថាខ្លឹមសារត្រឹមត្រូវ។ ទាក់ទងនឹងឯកសារ IS 13.14 គាត់បានបញ្ជាក់ពីការរៀបចំគណៈកម្មាធិការពាណិជ្ជកម្ម និងការកត់ត្រាសមាជិកនៃគណៈកម្មាធិការមួយចំនួនផ្សេងទៀត)។

[356] ឯកសារ D213.2 ពិចារណាអំពី ប្រវត្តិសាស្ត្រកម្ពុជាពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ, ខៀវ សំផន, ត្រង់ទំព័រ៤៤-៦ ទាក់ទងទៅនឹងIS 13.18 (ឯកសារ 561)។

អះអាងថា មជ្ឈមណ្ឌលឯកសារកម្ពុជារក្សាទុកនូវច្បាប់ដើមនៃឯកសារទាំងនេះ[357]។ ឯកសារផ្សេងទៀតទាំងអស់ នៅក្នុងបញ្ជីឯកសារ គឺមានទម្រង់ និងលក្ខណៈស្រដៀងគ្នាទៅនឹងឯកសារដែលបានកំណត់អត្តសញ្ញាណ ដោយលោក ឆាំង យុ។ លើសពីនេះទៅទៀត ឯកសារចំនួនពី (២) ច្បាប់ក្នុងចំណោមឯកសារដែលគាត់បានកំណត់អត្តសញ្ញាណ បង្ហាញពីទម្រង់ត្រីកោណនៃតួអក្សរខ្មែរ ដែលត្រូវបានប្រើប្រាស់ជាទូទៅ សម្រាប់ការខ័ណ្ឌចែកនៅក្នុងឯកសារ បកក[358]។ រូបសញ្ញានេះក៏មាននៅលើកំណត់ហេតុកិច្ចប្រជុំចំនួនប្រាំ(៥)ផ្សេងទៀតរបស់គណៈអចិន្ត្រៃយ៍ រួមទាំងឯកសារដែលបញ្ជាក់យថាភូតដោយ ខៀវ សំផន ផងដែរ[359]។

១៤១. ក្នុងចំណោមកំណត់ហេតុនៃកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ បកក ចំនួនម្ភៃពីរ (២២) ច្បាប់ នៅក្នុងបញ្ជីឯកសារ មានកំណត់ហេតុចំនួនម្ភៃ (២០) ច្បាប់ ដែលត្រូវបានកត់ត្រានៅក្នុងទិន្នន័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលលោក Ben Kiernen បានផ្តល់ជូនមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងឆ្នាំ១៩៩៦[360]។ លោក ឆាំង យុ បានបញ្ជាក់ថា លោក Ben Kiernen បានទទួលឯកសារទាំងនេះពីលោក ខៀវ កាញ៉ារិទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មាន ដែលបានទទួលឯកសារដើមពី *មន្ទីរគណៈសិរ្ស* នៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា បន្ទាប់ពីការកាត់ទោសរបស់តុលាការប្រជាជនបដិវត្តន៍កម្ពុជា ក្រោយពីឆ្នាំ១៩៧៩[361]។ យ៉ាងហោចណាស់ ខៀវ សំផន បានបញ្ជាក់អំពីយថាភូតទៅលើកំណត់មួយ ក្នុងចំណោមកំណត់ហេតុនៃកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ ដែលទទួលបានមកពីការប្រមូលចងក្រងរបស់លោក Ben Kiernan[362]។ ឯកសារពីរ (២) ច្បាប់ទៀត ត្រូវបានមជ្ឈមណ្ឌលឯកសារកម្ពុជាប្រមូលមកពីក្រសួងមហាផ្ទៃ ក្នុងឆ្នាំ១៩៩៦[363]។ គេបានធ្វើការលើកឡើងពីមុនរួច

[357] ឯកសារ D311/2 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆាំង យុ, ថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០០៩, ត្រង់ទំព័រ ៤ ពាក់ព័ន្ធទៅនឹងឯកសារ IS 13.1(ឯកសារ 543)។ IS 13.24 (ឯកសារ 566)។ IS 13.5 (ឯកសារ 548)។ IS 13.2 (ឯកសារ 544)។

[358] IS 13.1 (ឯកសារ 543) និង 13.5 (ឯកសារ 548)។

[359] IS 13.20 (ឯកសារ 563)។ IS 13.3(ឯកសារ 545); 13.18 (ឯកសារ 561); D251/1(ឯកសារ 549); 13.19(ឯកសារ 562)។

[360] សូមមើល មជ្ឈមណ្ឌលឯកសារកម្ពុជា, ទិន្នន័យ, មាននៅhttp://www.d.dccam.org/Database/Index.htm

[361] សូមមើល ឯកសារ D311/2 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆាំង យុ, ថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៩ ទំព័រ១០ និង D155.3 មានចំណងជើងថា ការចងក្រងទុកជាឯកសារនូវឧក្រិដ្ឋកម្មរបស់កម្ពុជាប្រជាធិបតេយ្យ (Documenting the Crimes of Democratic Kampuchea), ដោយ John D. Ciorciari និង ឆាំង យុ, ទំព័រ២២៨។

[362] ឯកសារ D213.2 ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា ពីដើមរហូតសម័យកម្ពុជាប្រជាធិបតេយ្យ, ខៀវ សំផន, ត្រង់ទំព័រ ៤៤ បញ្ជាក់ថា កំណត់ហេតុ ថ្ងៃទី១៤ ខែ ឧសភា ឆ្នាំ ១៩៧៦ (ត្រូវបាន "បោះពុម្ពទាំងស្រុងក្នុង" សៀវភៅរបស់ Ben Kiernan ក្រោមចំណងជើងថា "របប ប៉ុល ពត"។ កំណត់ហេតុនៅក្នុងឯកសារ IS 13.18 (ឯកសារ 561) ស្របគ្នាជាមួយនឹងកំណត់ហេតុដែលត្រូវបានយោងក្នុងសៀវភៅរបស់ Ben Kiernan។

[363] IS 13.1 (ឯកសារ 543) និង 13.12 (ឯកសារ 556)។ ទាក់ទងនឹងប្រភពនៃ ឯកសារ IS 13.1 សូមមើល ឯកសារ D311/2

ហើយពីការកាន់កាប់ឯកសារនានា ដែលបានប្រមូលមកពីក្រសួងមហាផ្ទៃ[364]។ ក្នុងចំណោមឯកសារទាំងអស់ ត្រូវបានសហព្រះរាជអាជ្ញាទទួលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជា នៅក្នុងអំឡុងពេលស៊ើបអង្កេតបឋម និងត្រូវបានដាក់ភ្ជាប់ទៅនឹងដីកាបញ្ជូនរឿងឱ្យស៊ើបសួរ លើកលែងតែឯកសារមួយប៉ុណ្ណោះ។ ឯកសារមួយនេះត្រូវបាន ក.ស.ច.ស ដាក់ចូលទៅក្នុងសំណុំរឿង នៅក្នុងអំឡុងនៃកិច្ចស៊ើបសួររបស់ខ្លួន[365]។

១៤២. ចុងបញ្ចប់ គួរកត់សម្គាល់ថា កំណត់ហេតុចំនួនដប់ប្រាំពីរ(១៧) ក្នុងចំណោមកំណត់ហេតុប្រជុំគណៈអចិន្ត្រៃយ៍ បកក ចំនួន២២ ក្នុងបញ្ជីឯកសារ ត្រូវបានទទួលយកជាភស្តុតាងក្នុងសំណុំរឿង ០០១[366]។

## *កំណត់ហេតុអង្គប្រជុំរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ*

១៤៣. កំណត់ហេតុមួយនៃកំណត់ហេតុអង្គប្រជុំរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ កត់ត្រាពីខ្លឹមសារនៃកិច្ចប្រជុំរវាងគណៈប្រតិភូកម្ពុជាដែលដឹកនាំដោយ អៀង សារី និងគណៈប្រតិភូពាណិជ្ជកម្មបរទេសចិន[367]។ ខ្លឹមសារជាក់ស្តែងនៃកំណត់ហេតុនេះ ត្រូវបានបញ្ជាក់ដោយ ស គឹមល្មុត[368]។ ការិយាល័យសហព្រះរាជអាជ្ញាបានទទួលកំណត់ហេតុនេះពីមជ្ឈមណ្ឌលឯកសារកម្ពុជា និងបានដាក់កំណត់ហេតុនេះក្នុងសំណុំរឿង បន្ទាប់ពីដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ យោងតាម

---

កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ាំង យុ, ថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៩ ត្រង់ទំព័រ ៥។ ទាក់ទងនឹងប្រភពឯកសារ IS 13.12, សូមមើលទិន្នន័យមជ្ឈមណ្ឌលឯកសារកម្ពុជា នៅ http://www.d.dccam.org/Database/Lod/detailsphp?keyword=L01174&numRecords=100&lang=eng&page=1&idnum=L01174

[364] សូមមើលវាក្យខ័ណ្ឌ I ខាងលើ។

[365]ឯកសារ D251/1 (ឯសារ 549)។ សូមមើល ឯកសារ D251 ដីកាសម្រេច, ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ បញ្ជាក់ថា ឯកសារនេះត្រូវបានយកចេញពីឃ្លាំងផ្ទុកឯកសាររួម (ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា)។

[366] ឯកសារ IS 13.16, 13.16/Corr-1 (ទទួលយកជាឯកសារ E3/175); IS 13.15 (ទទួលយកជាឯកសារ E3/186); E13.1 (ទទួលយកជាឯកសារ E3/081); IS13.6 (ទទួលយកជាឯកសារ E3/084); IS 13.12 (ទទួលយកជាឯកសារ E3/751); IS 13.4 (ទទួលយកជាឯកសារ E3/749); IS 13.10 (ទទួលយកជាឯកសារ E3/089); IS 13.7 (ទទួលយកជាឯកសារ E3/100); IS 13.3 (ទទួលយកជាឯកសារ E3/748); IS 13.18 (ទទួលយកជាឯកសារ E3/752); IS 13.24 (ទទួលយកជាឯកសារ E3/178); IS 13.5 (ទទួលយកជាឯកសារ E3/750); IS 13.19 (ទទួលយកជាឯកសារ E3/088); IS 13.8 (ទទួលយកជាឯកសារ E3/044); IS 13.2, D232/8.3, D200/9.7, D279/6.1 (ទទួលយកជាឯកសារ E3/014); IS 13.23 (ទទួលយកជាឯកសារ E3/101); IS 13.14, D279/7.1 (ទទួលយកជាឯកសារ E3/055)។

[367] ឯកសារ D56-Doc. 148 (ឯកសារ ៥៦៨)។

[368] មើល កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សគឹម ល្មុត, ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៩ (ឯកសារលេខ D279/7), ទំព័រ ៥។

មូលដ្ឋានទិន្នន័យនៃមជ្ឈមណ្ឌលឯកសារកម្ពុជា, កំណត់ហេតុនេះបានទទួលដំបូងពីលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅខែកញ្ញា ឆ្នាំ១៩៩៥[369]។

១៤៤. កំណត់ហេតុផ្សេងទៀត កត់ត្រាពីកិច្ចប្រជុំមួយរវាងគណៈប្រតិភូកម្ពុជាដែលដឹកនាំដោយ អៀង សារី និងគណៈប្រតិភូគមនាគមន៍ចិន[370]។ កំណត់ហេតុនេះមានទម្រង់ និងរចនាបទដែលមានលក្ខណៈដូចគ្នានឹងកំណត់ហេតុនៃកិច្ចប្រជុំនៃគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលត្រូវបានធ្វើយថាភូតដោយលោក ឆាំង យុ[371] និង ខៀវ សំផន[372]។ ការិយាល័យសហព្រះរាជអាជ្ញាបានទទួលកំណត់ហេតុនេះពីមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងអំឡុងពេលនៃការស៊ើបអង្កេតបឋម និងបានភ្ជាប់ជាឧបសម្ព័ន្ធនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ យោងតាមមូលដ្ឋានទិន្នន័យនៃមជ្ឈមណ្ឌលឯកសារកម្ពុជា, មជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលកំណត់ហេតុនេះពីបណ្ណសារដ្ឋានជាតិកម្ពុជា នៅឆ្នាំ២០០២[373]។

### *កំណត់ហេតុនៃកិច្ចប្រជុំរបស់សភាតំណាងប្រជាជននៃកម្ពុជាប្រជាធិបតេយ្យ*

១៤៥. ឯកសារលេខ IS 13.13 គឺជាកំណត់ហេតុអង្គប្រជុំសន្និបាតលើកទី១ នៃនីតិកាលទីមួយ របស់សភាតំណាងប្រជាជនកម្ពុជា ពីថ្ងៃទី១១ ដល់ថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៧៦។ ខ្លឹមសារនៃឯកសារនេះស៊ីសង្វាក់គ្នានឹងគោលនយោបាយ និងមនោគមវិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា និងបានប្រើប្រាស់ឃ្លាមួយចំនួន ដូចជា "ពួកចក្រពត្តិអាមេរិក" ដែលជាចំណុចពិសេសរបស់បក្សកុម្មុយនីស្តកម្ពុជា។ ឯកសារនេះមានទម្រង់ និងរចនាបទដូចសៀវភៅខ្នាតតូច ហើយមានពុម្ពអក្សរ និងរចនាបទដូចគ្នាយ៉ាងខ្លាំងទៅនឹងទស្សនាវដ្តីទង់បដិវត្ត និងទស្សនាវដ្តីយុវជន និងយុវនារីបដិវត្ត។

---

[369] មើលមូលដ្ឋានទិន្នន័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅឯ ៖ http://www.d.dccam.org/Database/Lod/details.php?keyword=D00127&numRecords=100&lang=eng&page=1&idnum=D00127

[370] ឯកសារ IS 13.43 (ឯកសារ ៥៦៧)

[371] D311/2 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆាំង យុ, ថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៩, ទំព័រ ៤ ទាក់ទងនឹងឯកសារ IS 13.1, IS 13.24, IS 13.5, IS 13.2។

[372] D213.2 ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា ពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ, ខៀវ សំផន, ទំព័រ ៥៥ បញ្ជាក់ថា កំណត់ហេតុអង្គប្រជុំ នៅថ្ងៃទី១៤ ឧសភា ឆ្នាំ១៩៧៦ (ត្រូវបាន "បោះពុម្ពផ្សាយទាំងស្រុង" នៅក្នុងសៀវភៅ Ben Kiernan ដែលមានចំណងជើងថា "របបប៉ុលពត"។ កំណត់ហេតុអង្គប្រជុំទាំងនេះ IS 13.18 (ឯកសារ ៥៦១) គឺជាសំណៅដូចគ្នាបេះបិទមួយទៅនឹងកំណត់ហេតុអង្គប្រជុំដែលបានបោះពុម្ពផ្សាយនៅក្នុងសៀវភៅរបស់ Ben Kiernan។

[373] មើលមូលដ្ឋានទិន្នន័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅឯ ៖ http://www.d.dccam.org/Database/Lod/details.php?keyword=D20448&numRecords=100&lang=eng&page=1&idnum=D20448

លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បានបញ្ជាក់បន្ថែមថា មជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលឯកសារនេះពីឡូលស្តែង នៅឆ្នាំ១៩៩៩[374]។ ខ្លឹមសារនៃឯកសារនេះគឺមានភាពស៊ីសង្វាក់គ្នាជាមួយនឹងអត្ថបទមួយរបស់ FBIS, ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ១៩៧៦ ដែលមានចំណងជើងថា៖ “ហ៊ូ នឹម បានប្រកាសនូវសេចក្តីប្រកាសព័ត៌មាន ស្តីពីសភាតំណាងប្រជាជនបដិវត្តន៍” ដែលសរសេរជាងដែលឡើងវិញ នូវសេចក្តីដកស្រង់ពីឯកសារដដែល ដូចដែលផ្សាយដោយសេវាកម្មក្នុងស្រុកនៃទីក្រុងភ្នំពេញ (Phnom Penh Domestic Services)[375]។ ឯកសារនេះត្រូវបានគេប្រគល់ឲ្យសហព្រះរាជអាជ្ញា ក្នុងអំឡុងពេលនៃការស៊ើបអង្កេតបឋម និងបានដាក់ភ្ជាប់ជាមួយនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ ឯកសារនេះត្រូវបានទទួលស្គាល់ជាឯកសារភ័ស្តុតាងក្នុងសំណុំរឿង ០០១[376]។

## *កំណត់ហេតុនៃកិច្ចប្រជុំផ្សេងៗទៀត*

១៤៦. ឯកសារលេខ D248/6.1.3 គឺជាសំណុំនៃកំណត់ហេតុអង្គប្រជុំគណៈកម្មាធិការរៀបចំទំនិញដែលត្រូវទិញ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៦។ កំណត់ហេតុនេះមានទម្រង់ និងរចនាបទដែលមានលក្ខណៈដូចគ្នាយ៉ាងខ្លាំងទៅនឹងកំណត់ហេតុអង្គប្រជុំនៃគណៈកម្មាធិការអចិន្ត្រៃយ៍ដទៃទៀត ដែលត្រូវបានផ្តល់យថាភូតដោយលោក ឆាំង យុ ឬ ខៀវ សំផន។ យោងតាមមូលដ្ឋានទិន្នន័យនៃមជ្ឈមណ្ឌលឯកសារកម្ពុជា, មជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលកំណត់ហេតុនេះពីលោក Ben Kiernan នៅឆ្នាំ១៩៩០[377]។ ការិយាល័យសហចៅក្រមស៊ើបអង្កេតបានដាក់បញ្ចូលកំណត់ហេតុនោះ ទៅក្នុងសំណុំរឿង ក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ បន្ទាប់ពីទទួលបានដីកាចាត់ឲ្យស៊ើបសួរជំនួស[378]។

១៤៧. ឯកសារលេខ “D56-Doc.149, D279/7.10” គឺជាកំណត់ហេតុអង្គប្រជុំគណៈប្រតិភូពាណិជ្ជកម្មកម្ពុជាប្រជាធិបតេយ្យ និងគណៈប្រតិភូពាណិជ្ជកម្មនៃសាធារណរដ្ឋប្រជាមានិតចិន។ កំណត់ហេតុនេះ មានទម្រង់ដូចគ្នាយ៉ាងខ្លាំងទៅនឹងកំណត់ហេតុអង្គប្រជុំផ្សេងៗរបស់បក្សកុម្មុយនីស្តកម្ពុជា

---

[374] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆាំង យុ ថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៩ (ឯកសារលេខ D311/2), ទំព័រ ៩។

[375] ឯកសារលេខ D262.17 (ឯកសារ ៣៥៨), ចុះថ្ងៃទី១៤ មេសា១៩៧៦, ត្រង់លេខ ERN 00167623-626 ។

[376] ទទួលស្គាល់ដោយមានលេខសម្គាល់ E3/043។

[377] មើលមូលដ្ឋានទិន្នន័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅឯ ៖ http://www.d.dccam.org/Database/Lod/details.php?keyword=D00692&numRecords=100&lang=eng&page=1&idnum=D00692

[378] មើលឯកសារ D248 ដីកាចាត់ឱ្យស៊ើបសួរជំនួស, ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩។

និងបង្ហាញពីរចនាអក្សរខ្មែររាងត្រីកោណ ដែលត្រូវបានប្រើប្រាស់ជាញ្ញើកញ្ញាប់សម្រាប់បង្ហាញពីការបែងចែកតាមផ្នែក នៅក្នុងឯកសាររបស់បក្សកុម្មុយនីស្តកម្ពុជា[379]។ ការរៀបចំកិច្ចប្រជុំនេះត្រូវបានបញ្ជាក់ដោយ ស គីមល្អុត[380] ហើយមានចុះឈ្មោះ អៀង សារី និង ខៀវ សំផន ជាអ្នកទទួលកំណត់ហេតុអង្គប្រជុំនេះ។ ការិយាល័យសហព្រះរាជអាជ្ញាបានទទួលកំណត់ហេតុនេះពីមជ្ឈមណ្ឌលឯកសារកម្ពុជា និងបានដាក់នៅក្នុងសំណុំរឿង បន្ទាប់ពីដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ យោងតាមមូលដ្ឋានទិន្នន័យនៃមជ្ឈមណ្ឌលឯកសារកម្ពុជា, កំណត់ហេតុនេះបានទទួលដំបូងពី ហ៊ុន សែន នៅខែកញ្ញា ឆ្នាំ១៩៩៥[381]។

## ១៩. រូបថត

១៤៨. មានរូបថតចំនួន៦៣សន្លឹក នៅក្នុងបញ្ជីឯកសារ[382]។ រូបថតចំនួន៥៧សន្លឹក ក្នុងចំណោមរូបថតទាំងនោះត្រូវបានប្រមូលដោយ ក.ស.ព ហើយរូបថតទាំងអស់ត្រូវបានថតក្នុងសម័យ DK។ ដោយសាររូបថតទាំងនេះ បង្ហាញពីព្រឹត្តិការណ៍ដែលកើតឡើងនាសម័យនោះ រូបថតទាំងនោះក៏ចាត់ទុកជាឯកសារកំណត់ហេតុមួយបែបដែរ។

១៤៩. រូបថតចំនួន៤៥សន្លឹក បានពីការប្រមូលរបស់ជាងថតរូបម្នាក់នៅមន្ទីរស-២១ ឈ្មោះ ញ៉ែម អេន ហើយលោក Stephen Heder បានផ្តល់រូបថតទាំងនេះ ដល់ ក.ស.ព ក្នុងពេលស៊ើបអង្កេតបឋម[383]

[379] សញ្ញានេះក៏មានឃើញនៅលើកំណត់ហេតុនៃកិច្ចប្រជុំដទៃទៀតដែរ ៖ IS 13.1, 13.5, 13.3, 13.18, D251/1, និង 13.19។

[380] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សគីម ល្អុត, ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៩ (ឯកសារលេខ D279/7)។

[381] មើលមូលដ្ឋានទិន្នន័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅឯ ៖ http://www.d.dccam.org/Database/Lod/details.php?keyword=D00132&numRecords=100&lang=eng&page=1&idnum=D00132

[382] ឯកសារ 570-632។

[383] D313/1.2.196 (ឯកសារ 585); D313/1.2.233 (ឯកសារ 613); D313/1.2.214 (ឯកសារ 610); D313/1.2.200 (ឯកសារ 601); D313/1.2.234 (ឯកសារ 573); D313/1.2.231 (ឯកសារ 584); D313/1.2.235 (ឯកសារ 571); D313/1.2.206 (ឯកសារ 609); D313/1.2.221 (ឯកសារ 597); D313/1.2.226 (ឯកសារ 612); D313/1.2.232 (ឯកសារ 592); D313/1.2.197 (ឯកសារ 589); D313/1.2.212 (ឯកសារ 581); D313/1.2.216 (ឯកសារ 596); D313/1.2.192 (ឯកសារ 615); D313/1.2.222 (ឯកសារ 598); D313/1.2.236 (ឯកសារ 574); D313/1.2.195 (ឯកសារ 587); D313/1.2.228 (ឯកសារ 621); D313/1.2.201 (ឯកសារ 604); D313/1.2.230 (ឯកសារ 600); D313/1.2.204 (ឯកសារ 599); D313/1.2.229 (ឯកសារ 622); D313/1.2.199 (ឯកសារ 611); D313/1.2.186 (ឯកសារ 594); D313/1.2.190 (ឯកសារ 580); D313/1.2.237(ឯកសារ 572); D313/1.2.187 (ឯកសារ 595); D313/1.2.193 (ឯកសារ 603); D313/1.2.225 (ឯកសារ 602); D313/1.2.202 (ឯកសារ 607); D313/1.2.191 (ឯកសារ 614); D313/1.2.185 (ឯកសារ 591); D313/1.2.207 (ឯកសារ 608); D313/1.2.227 (ឯកសារ 620) ; D313/1.2.158 (ឯកសារ 590); D313/1.2.171 (ឯកសារ 605); D313/1.2.157 (ឯកសារ 588); D313/1.2.168 (ឯកសារ 586); D313/1.2.170 (ឯកសារ 606); D313/1.2.169 (ឯកសារ 617); D313/1.2.160 (ឯកសារ 616); D313/1.2.173 (ឯកសារ 593); D313/1.2.163 (ឯកសារ 582)។

ឬដោយ DC-Cam[384]។ កាសែតភ្នំពេញប៉ុស្តិ៍បានប្រមូលទិញរូបថតទាំងនេះមួយភាគធំពី ញ៉ែម អេន។ មានរូបថតចំនួន៩សន្លឹកបន្ថែមទៀតមានប្រភពពី DC-Cam[385] ដែលរូបថតចំនួន២សន្លឹកក្នុងចំណោមនោះត្រូវបានប្រមូលដំបូងពីបណ្ណសារទួលស្លែង[386]។ រូបថតចំនួន ៣ សន្លឹកចុងក្រោយនេះ ក.ស.ព ទើបតែបានទទួលនាពេលថ្មីៗនេះ ហើយបានដាក់ទៅក្នុងថតផ្ទុកសម្ភារៈរួមរួចហើយ[387]។ រូបថតចំនួន២សន្លឹកក្នុងចំណោមរូបថតទាំងនោះ បានមកពីបណ្ណសាររូបថតទីភ្នាក់ងារព័ត៌មានឡាវ (Lao News Agency Photo Archive) តាមរយៈ Martin Rathie។

១៥០. រូបថតចំនួន៦សន្លឹកដែលនៅសល់ ត្រូវបានដាក់ដោយ ក.ស.ច.ស និងបានទទួលអនុលោមតាមដីកាចាត់ឲ្យស៊ើបសួរជំនួស[388]។

## ២០. របាយការណ៍បញ្ចប់ការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស

១៥១. មានឯកសារមួយនៅក្នុងបញ្ជីឯកសារ ដែលត្រូវបានចាត់ថ្នាក់ថាជា "របាយការណ៍បញ្ចប់ការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស"[389]។ ឯកសារនេះជាកំណត់ហេតុផ្លូវការ ដែលបានរៀបចំដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលរាយការណ៍ពីការបញ្ចប់ការអនុវត្ត តាមដីកាចាត់ឲ្យស៊ើបសួរជំនួស។

១៥២. ឯកសារនេះស្របគ្នាទៅនឹងឯកសារដទៃទៀត ដែលមានប្រភពសម្រាប់ប្រើប្រាស់ផ្ទៃក្នុងនៃឯកសារបែបនេះដែរ។ ពោលគឺវាមានទម្រង់ជាបទដ្ឋាន រួមមាន ការបោះត្រាផ្លូវការនៅផ្នែកខាងលើនៃទំព័រទី១ ដោយមានពាក្យថា "ព្រះរាជាណាចក្រកម្ពុជា" នៅផ្នែកខាងស្តាំ។ លេខសំណុំរឿង ការិយាល័យ

---

សូមមើល D313 សំណើរបស់សហព្រះរាជអាជ្ញា សុំដាក់ឯកសារបន្ថែមទៅក្នុងសំណុំរឿង ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩ កថាខណ្ឌ២០។

[384] D366/7.1.415 (ឯកសារ 578)។

[385] D366/7.1.420 (ឯកសារ 579); D366/7.1.422 (ឯកសារ 619); D366/7.1.442 (ឯកសារ 625); D366/7.1.429 (ឯកសារ 618); D366/7.1.449 (ឯកសារ 624); D366/7.1.443 (ឯកសារ 626); D366/7.1.438 (ឯកសារ 623) ; D313/1.2.166 (ឯកសារ 575); D313/1.2.164 (ឯកសារ 583)។

[386] D313/1.2.166 (ឯកសារ 575); D313/1.2.164 (ឯកសារ 583)។ សូមមើល D313 សំណើរបស់សហព្រះរាជអាជ្ញា សុំដាក់ឯកសារបន្ថែមទៅក្នុងសំណុំរឿង ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩។

[387] *រូបថត ខៀវ សំផន, អៀង សារី និង អៀង ធីរិទ្ធ* (ឯកសារ 577)។ *រូបថត ខៀវ សំផន, អៀង សារី និង អៀង ធីរិទ្ធ* (ឯកសារ 576)។ *រូបថតពីរ មួយជារូបរបស់ អៀង សារី និងមួយជារូបរបស់ នួន ជា ធ្វើសុន្ទរកថា នៅក្នុងពិធីទទួលភ្ញៀវ* (ឯកសារ 570)។

[388] D200/3.10 (ឯកសារ 627); D200/9.8 (ឯកសារ 631); D200/3.9 (ឯកសារ 628); D200/9.9 (ឯកសារ 632); D200/9.12 (ឯកសារ 630); D200/9.11 (ឯកសារ 629) (សូមមើល D200 ដីកាចាត់ឲ្យស៊ើបសួរជំនួស ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩)។

[389] D208/2 (ឯកសារ 633)។

សហចៅក្រមស៊ើបអង្កេត និងកាលបរិច្ឆេទ ឯកសារយោង កាលបរិច្ឆេទផុតកំណត់ និងឈ្មោះមន្ត្រីស៊ើបអង្កេតត្រូវបានបោះពុម្ពនៅខាងក្រោមត្រា។ ចំណងជើងឯកសារ "របាយការណ៍បញ្ចប់ការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស" នៅផ្នែកខាងស្តាំ និងអាសយដ្ឋានពិស្តារសម្រាប់ទំនាក់ទំនងស្ថិតនៅផ្នែកខាងក្រោមបង្អស់នៃទំព័រនីមួយៗ។

## ២១. ចម្លើយសារភាពនៅមន្ទីរស-២១

១៩៣. មានឯកសារចំនួន១០៣ នៅក្នុងបញ្ជីឯកសារដែលត្រូវបានចាត់ថ្នាក់ជា "ចម្លើយសារភាពនៅមន្ទីរស-២១"[390]។ ចម្លើយសារភាពទាំងនោះត្រូវបានសរសេរដោយអ្នកទោសនៅមន្ទីរស-២១ ដោយខ្លួនឯង ឬត្រូវបានធ្វើប្រតិចារឹកដោយអ្នកសួរចម្លើយ ប្រសិនបើអ្នកទោសនោះមិនអាចសរសេរបាន។ អង្គភាពវាយអង្គុលីលេខមន្ទីរស-២១ ក៏បានចម្លងដោយវាយអង្គុលីលេខដែរ។ ដូចបានកត់សម្គាល់នៅក្នុងសាលក្រមលើសំណុំរឿង ០០១ រួចមកហើយ គឺថាចម្លើយសារភាពត្រូវបានស្រង់យកដើម្បីបញ្ជាក់ពីការសង្ស័យរបស់ ប.ក.ក ចំពោះអំពើក្បត់ និងដើម្បីឱ្យចេញឈ្មោះខ្មាំងដទៃទៀត ហេតុនេះចម្លើយសារភាពធ្វើជាលេសដើម្បីឱ្យមានការចាប់ខ្លួនបន្ថែមទៀត[391]។ បើតាមសំដីរបស់ ឌុច ទាំងនេះជា "ការងារស្នូល" របស់មន្ទីរស-២១[392]។

១៩៤. ភាពអាចជឿជាក់បាននៃឯកសារទាំងនេះត្រូវបានស្តែងឡើងដោយកត្តានានាជាច្រើន នៅក្នុងចម្លើយសារភាពផ្ទាល់តែម្តង។ ក្នុងចម្លើយសារភាពភាគច្រើនមានប្រើវោហារស័ព្ទថា "អង្គការ" "សន្តិបាល" និង "វិធីក្តៅ" ដែលស្របគ្នាជាទូទៅនៅមន្ទីរស-២១ និង ប.ក.ក ដែលរក្សាបាននូវមនោគមន៍វិជ្ជារបស់ខ្លួន[393]។ ដូចបានលើកឡើងខាងរួចមកហើយ គឺថា ទោះបីចម្លើយសារភាពសរសេរដោយដៃក្តី និងវាយអង្គុលីលេខក្តី ក៏វាមានទម្រង់ និងខ្លឹមសារស្របគ្នាដែរ។ ដោយឡែក ដូចបានពិភាក្សាខាងលើរួចមកហើយ គឺថាចម្លើយសារភាពតែងមានបញ្ជីឈ្មោះកម្មាភិបាលដែលត្រូវ

---

[390]ឯកសារ 634-736 នៅក្នុងបញ្ជីឯកសារ។ មានឯកសារចំនួនប្រាំនៃឯកសារទាំងនេះ មិនមែនជាចម្លើយសារភាពទេ តែជាសេចក្តីសង្ខេបចម្លើយសារភាពរបស់ DC-Cam ឬ លោកបណ្ឌិត Stephen Heder។ ឯកសារ D108/31.20 (ឯកសារ 646); លេខ ERN 00223111 *ថ្មី* (ឯកសារ 667); លេខ ERN 00223125 *ថ្មី* (ឯកសារ 669); លេខ ERN 00294991-92 *ថ្មី* (ឯកសារ 678); លេខ ERN 00223122-23 *ថ្មី* (ឯកសារ 686)។

[391] E188 សាលក្រម, ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ១៧៧-១៧៩។

[392] D121/6.2 សេចក្តីអត្ថាធិប្បាយ និងចម្លើយជាលាយលក្ខណ៍អក្សររបស់ ឌុច, ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩ ត្រង់ទំព័រ២៥។

[393] ឧទាហរណ៍ សូមមើល, IS 5.65 (ឯកសារ 638), ត្រង់ ERN 00290113-14។

ឆ្លើយដាក់ សម្រួលឲ្យមានការចាប់ខ្លួនជាទ្រង់ទ្រាយធំបន្ថែមទៀតដោយថ្នាក់មជ្ឈិម[394]។ ឌុច បានទទួលស្គាល់ថា ការបញ្ចូលបញ្ជីឈ្មោះទាំងនេះជាទម្លាប់អនុវត្តជាបទដ្ឋានទៅហើយ[395]។

១៥៥. មានលក្ខណៈសម្គាល់ដោយឡែកមួយចំនួនដែរ នៅក្នុងចម្លើយសារភាពនៅមន្ទីរស-២១ទាំងនោះ។ ជាធម្មតា នៅក្របមុខមានសរសេរចំណងជើងនៅក្នុងប្រអប់បន្ទាត់ជាប់ ឬបន្ទាត់ដាច់ៗ មានចុះកាលបរិច្ឆេទនៅផ្នែកខាងក្រោមជ្រុងខាងស្តាំ។ ទំព័រខ្លះក៏មានលក្ខណៈសម្គាល់ដោយឡែកដែរ រួមមានអក្សរ "ស" ដែលសរសេរក្នុងរង្វង់[396]។ ឌុច បានអះអាងថា នោះជាអក្សរកាត់មានន័យថា "សម្ងាត់" ហើយគាត់ជាអ្នកសរសេរចំពោះចម្លើយសារភាពដោយឡែកមួយចំនួន[397]។ ចំណុចនេះវាស្របទៅនឹងគោលនយោបាយរក្សាការសម្ងាត់ជុំវិញមន្ទីរស-២១[398]។ គេអាចរកឃើញសញ្ញាសម្គាល់បន្ថែមទៀតនៅក្នុងផ្នែកតួនៃចម្លើយសារភាពដែរ ដោយឡែក៖ (១).កាលបរិច្ឆេទ និងហត្ថលេខានៅជ្រុងខាងឆ្វេងនៃអត្ថបទ និង (២).កាលបរិច្ឆេទ និងហត្ថលេខានៅពេលបញ្ចប់ចម្លើយសារភាព។ ដោយឡែក ជាញឹកញយមានកាលបរិច្ឆេទ និងហត្ថលេខាពីរនៅចុងអត្ថបទ ដែលនៅខាងឆ្វេងជាកាលបរិច្ឆេទ និងហត្ថលេខារបស់អ្នកសួរចម្លើយ និងនៅខាងស្តាំជាកាលបរិច្ឆេទ និងហត្ថលេខារបស់អ្នកទោស ហើយជាញឹកញយអមដោយស្នាមមេដៃផង[399]។

១៥៦. ចម្លើយសារភាពជាច្រើនក៏មានការសង្ខេបរបស់អ្នកសួរចម្លើយផងដែរ និងចំណារ និងសញ្ញានានាធ្វើឡើងដោយ ឌុច[400] សុន សេន ហៅ ខៀវ[401] និង នួន ជា[402]។ ឌុច បានផ្តល់យថាភូតចំពោះសំណេរដៃរបស់បុគ្គលទាំងនេះ[403]។ ចំណារទាំងនោះរួមមាន ការណែនាំលើប្រធានបទឲ្យបន្ត ឬ

---

[394] ឧទាហរណ៍ សុំមើល, IS 5.28 (ឯកសារ 698), ត្រង់ ERN 00005185-91, 00746209-12។

[395] D120 កំណត់ហេតុនៃការសួរចម្លើយ ឌុច ដោយ ស.ច.ស, ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៨ ត្រង់ទំព័រ៥, ៩។ D121/6.2 សេចក្តីអត្ថាធិប្បាយ និងចម្លើយជាលាយលក្ខណ៍អក្សររបស់ ឌុច, ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩ ត្រង់ទំព័រ១២-១៣។

[396] ឧទាហរណ៍ សុំមើល D43/IV-Annex 21 (ឯកសារ 697), ត្រង់ ERN 00173973។

[397] D227 កំណត់ហេតុនៃការសួរចម្លើយ ឌុច ដោយ ស.ច.ស, ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៩ ERN 000398204-11, ត្រង់ ទំព័រ៧។

[398] សូមមើល D121/6.2 សេចក្តីអត្ថាធិប្បាយ និងចម្លើយជាលាយលក្ខណ៍អក្សររបស់ ឌុច, ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩ ត្រង់ទំព័រ១៣។

[399] ឧទាហរណ៍ សូមមើល IS 5.28 (ឯកសារ 698), ត្រង់ ERN 00005160, 00746208។

[400] ឧទាហរណ៍ សូមមើល, D108/31.42 (ឯកសារ 692), ត្រង់ ERN 00174502 ។

[401] ឧទាហរណ៍ សូមមើល, D43/IV- ឧបសម្ព័ន្ធ 80 (ឯកសារ 663) ត្រង់ ERN 00174862។

[402] ឧទាហរណ៍ សូមមើល, D43/IV- ឧបសម្ព័ន្ធ 41 (ឯកសារ 707), ត្រង់ ERN 00174100។

[403] ឧទាហរណ៍ សូមមើល, ប្រតិចារឹកចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ ត្រង់ទំព័រ៥៧-៥៨ ការបញ្ជាក់អក្សររបស់ សុន សេន នៅក្នុងឯកសារ D43/IV ឧបសម្ព័ន្ធ 18 (ឯកសារ 649) ទទួលយកក្នុងសំណុំរឿង០០១ ជាឯកសារ E3/20; D260 កំណត់ហេតុសួរចម្លើយ ឌុច ដោយ សចស, ៣ ធ្នូ ២០០៩, ត្រង់ទំព័រទី២-៣, កំណត់អត្តសញ្ញាណអក្សរសរសេរដោយដៃរបស់គាត់ផ្ទាល់, របស់ សុន សេន និងរបស់ នួន ជា នៅលើឯកសារ D108/31.42 (ឯកសារ 692), ត្រង់ ERN 00174502។

ចៀសវាង ក្នុងការសួរចម្លើយបន្ថែមទៀត ការប្រើទារុណកម្ម និងការបញ្ជូនចម្លើយសារភាពទាំងនេះទៅឲ្យ ប៉ុល ពត និងប្រធានអង្គភាព។ ទម្លាប់អនុវត្តនេះស្របទៅនឹងគោលនយោបាយដ៏ទូលំទូលាយរបស់ ប.ក.ក នៃការបញ្ជូនព័ត៌មានសន្តិសុខទៅថ្នាក់មជ្ឈិម ដែលក្នុងបរិបទនេះ មន្ទីរស-២១ មានតួនាទីពិសេស ជាគុកដែលត្រូវរាយការណ៍ផ្ទាល់ទៅសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍[404]។ ក្នុងករណីខ្លះ ឈ្មោះ ឬផ្នែកខ្លះនៃអត្ថបទត្រូវបានគូសលុបចោល។ ឌុច បាននិយាយថា ការណ៍នេះបានធ្វើឡើង ដើម្បីចៀសវាងការឆ្លើយដាក់បុគ្គលមួយចំនួន[405]។ ការអនុវត្តនេះសម្រាប់ឲ្យថ្នាក់មជ្ឈិមប្រើចម្លើយសារភាពជាមូលដ្ឋាន ក្នុងការចាប់ខ្លួននៅពេលយកជាមធ្យោបាយផ្នែកនយោបាយ។

១៩៧. មានការបញ្ជាក់ពីភ័ស្តុតាងដទៃទៀតដែរ គឺថាអ្នកទោសត្រូវបានឃុំឃាំង និងសួរចម្លើយនៅមន្ទីរស-២១។ ឧទាហរណ៍ ឌុច បានផ្តល់នូវបញ្ជីឈ្មោះកម្មាភិបាលផ្នែកសន្តិសុខដែលត្រូវបានបញ្ជូនទៅមន្ទីរស-២១ ក្នុងចំណោមនោះ រួមមាន ញឹម ឆុន *ហៅ* ហាង់ ដែលជាអ្នកសរសេរចម្លើយសារភាពនៅក្នុងបញ្ជីឯកសារ[406]។ មានចម្លើយសារភាពជាច្រើនដែល ឌុច បានបញ្ចេញយោបល់ដែលបង្ហាញថាឯកសារនោះជាឯកសារពិត។ ឧទាហរណ៍ ឌុច មានមតិទៅលើចម្លើយសារភាពរបស់ លាន សិរីវុធ និងបានអះអាងថា វាជា "ឯកសារចម្លង" ដែលបង្ហាញថា ចម្លើយសារភាពបែបនោះត្រូវបានគេយក ហើយថាគាត់យល់ថាវាជាឯកសារចម្លងពីចម្លើយសារភាពនោះប្រាកដមែន[407]។

១៩៨. ចម្លើយសារភាព ក៏អាចត្រូវបានបញ្ជាក់ផងដែរ ដោយសារហត្ថលេខារបស់អ្នកសួរចម្លើយនៅមន្ទីរស-២១ ដែលគេស្គាល់ នៅពេលដែលហត្ថលេខានោះដូចគ្នានឹងហត្ថលេខានៅលើឯកសារដែល ឌុច បញ្ជាក់ថាជាឯកសារពិតនោះ។ ឧទាហរណ៍ ចម្លើយសារភាពរបស់ លាន សិរីវុធ ដូចបានយោងខាងលើ ត្រូវបានចុះហត្ថលេខាដោយអ្នកសួរចម្លើយមន្ទីរស-២១ ឈ្មោះ អឿន[408]។ ហត្ថលេខានេះក៏គេបានរកឃើញនៅក្នុងចម្លើយសារភាពរបស់ ឡុង មុយ *ហៅ* ជួន ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៧៧ ផងដែរ[409]។ ការបង្ហាញទ្រង់ទ្រាយនៃសញ្ញាសម្គាល់ដូចគ្នានេះនៅក្នុងឯកសារនិមួយៗ ដែលនៅក្នុង

---

[404] D1 ដីកាដំណោះស្រាយ, ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ កថាខណ្ឌ៤២២, ៤៥៦។

[405] សូមមើល D121/6.2 សេចក្តីអត្ថាធិប្បាយ និងចម្លើយជាលាយលក្ខណ៍អក្សររបស់ ឌុច, ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩ ត្រង់កថាខណ្ឌ២៧, ៣១ និងទំព័រ១៣, ១៥។ សូមមើលផងដែរ D86/24 កំណត់ហេតុនៃការសួរចម្លើយ ឌុច ដោយ ស.ច.ស, ចុះថ្ងៃទី២ ខែមេសា ឆ្នាំ២០០៨, ត្រង់ទំព័រទី៥-៦។ D119 កំណត់ហេតុនៃការសួរចម្លើយ ឌុច ដោយ ស.ច.ស, ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៨, ត្រង់ទំព័រទី៥។

[406] D86/28 កំណត់ហេតុនៃការសួរចម្លើយ ឌុច, ចុះថ្ងៃទី៦ ខែឧសភា ឆ្នាំ២០០៨, ERN 00209168-83; D159/5.53 (ឯកសារ 681)។

[407] D121/6.2 សេចក្តីអត្ថាធិប្បាយ និងចម្លើយជាលាយលក្ខណ៍អក្សររបស់ ឌុច, ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩, ERN 00434334-49, ត្រង់ទំព័រ៥, យោងឯកសារ IS 5.46 (ឯកសារ 706)។

[408] IS 5.46 (ឯកសារ 706), ត្រង់ ERN 00024551។

[409] D43/IV-Annex 74 (ឯកសារ 691), ត្រង់ ERN 00174753។

ឯកសារមួយ ត្រូវបានធ្វើយថាភូតដោយ ឌុច បញ្ជាក់អះអាងបន្ថែមទៀតថា ឯកសារទាំងពីរគឺជាចម្លើយសារភាពរបស់មន្ទីរស-២១ សុទ្ធសាធ។

១៥៩. ចម្លើយសារភាពនៅក្នុងបញ្ជីឯកសារ ត្រូវបាន DC-Cam ប្រមូលពីមន្ទីរស-២១ផង ក្រសួងមហាផ្ទៃផង។ ដំណើរការគ្រប់គ្រងឯកសារដែលប្រមូលពី TSL ត្រូវបានរៀបរាប់ដូចខាងលើស្រាប់[410]។ ក.ស.ព បានទទួលចម្លើយសារភាពចំនួន៣៦ ក្នុងចំណោមចម្លើយសារភាពទាំងនោះ ក្នុងអំឡុងពេលស៊ើបអង្កេតបឋម និងបានភ្ជាប់ជាមួយដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ[411]។ ក្នុងចំណោមចម្លើយសារភាពដទៃទៀត មានចម្លើយសារភាពចំនួន២ ត្រូវបានភ្ជាប់ជាមួយដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ដោយ ក.ស.ព[412] ចម្លើយសារភាពចំនួន១០ ត្រូវបានបញ្ចូលក្នុងសំណុំរឿង ទៅតាមសំណើរបស់ ក.ស.ព[413] ចម្លើយសារភាពចំនួន៤២ ត្រូវបានដាក់ក្នុងសណុំរឿង អនុលោមទៅតាមដីការបស់ ស.ច.ស[414] និងចម្លើយសារភាពចំនួន១១ទៀតជាឯកសារថ្មី មិនទាន់បានបញ្ចូលក្នុងសំណុំ

---

410 សូមមើលវាក្យខ័ណ្ឌ I ខាងលើ។

411 IS 5.115 (ឯកសារ 704); IS 5.65 (ឯកសារ 638); IS 5.100 (ឯកសារ 730); IS D2-15.45, D196.15; IS 5.74 (ឯកសារ 722); IS D2-15.39, D288/5.72, D312.2.23 (ឯកសារ 724); IS 5.55 (ឯកសារ 721); IS 5.113 (ឯកសារ 666); IS 5.13 (ឯកសារ 733); IS 5.79 (ឯកសារ 636); IS 5.108 (ឯកសារ 705); IS 5.39 (ឯកសារ 653); IS 5.34 ឯកសារ 732); IS 5.46 (ឯកសារ 5.46); IS 5.61 (ឯកសារ 652); IS 5.2 (ឯកសារ 694); IS 5.10 (ឯកសារ 734); IS 5.88 (ឯកសារ 715); IS 5.104 (ឯកសារ 658); IS 5.112 (ឯកសារ 713); IS 5.97 (ឯកសារ 640); IS 5.50 (ឯកសារ 693); IS 5.96 (ឯកសារ 711); IS 5.109 (ឯកសារ 682); IS 5.92 (ឯកសារ 660); IS 5.1 (ឯកសារ 684); IS 5.31 (ឯកសារ 637); IS 5.25 (ឯកសារ 650); IS 5.86 (ឯកសារ 718); IS 5.28 (ឯកសារ 698); IS 5.71 (ឯកសារ 674); IS 5.117.( ឯកសារ 670) ; D2-15.41, D83- ឯកសារ ឧបសម្ព័ន្ធ -00004 (ឯកសារ 664); D83-ឧបសម្ព័ន្ធ -00004 (ឯកសារ 736); D2-15.44, D2-15.44/ច្បាប់តម្រូវ-1 (ឯកសារ 725)។

412 D83- ឧបសម្ព័ន្ធ -00004 (ឯកសារ 664); D196.13 (ឯកសារ 720)។

413 D366/7.1.78 (ឯកសារ 729); D366/7.1.90 (ឯកសារ 657); D366/7.1.95 (ឯកសារ 688); D366/7.1.93 (ឯកសារ 672); D366/7.1.116 (ឯកសារ 709); D366/7.1.77 (ឯកសារ 635); D366/7.1.119 (ឯកសារ 710); D366/7.1.122 (ឯកសារ 712); D366/7.1.88 (ឯកសារ 647); D366/7.1.85 (ឯកសារ 643)។ ឯកសារទាំងអស់បានដាក់ក្នុងសំណុំរឿង ស្របតាមឯកសារ D366 សំណើរបស់សហព្រះរាជអាជ្ញា សុំដាក់ឯកសារភ័ស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១០។

414 D43/IV- ឧបសម្ព័ន្ធ 58 (ឯកសារ 661); D43/IV- ឧបសម្ព័ន្ធ 41 (ឯកសារ 707); D43/IV- ឧបសម្ព័ន្ធ 18 (ឯកសារ 649); D43/IV- ឧបសម្ព័ន្ធ 21 (ឯកសារ 696); D43/IV- ឧបសម្ព័ន្ធ 80 (ឯកសារ 663); D43/IV- ឧបសម្ព័ន្ធ 86 (ឯកសារ 642); D43/IV- ឧបសម្ព័ន្ធ 74 (ឯកសារ 691); D43/IV- ឧបសម្ព័ន្ធ 63 (ឯកសារ 700); D43/IV- ឧបសម្ព័ន្ធ 47 (ឯកសារ 719); D43/IV- ឧបសម្ព័ន្ធ 69 (ឯកសារ 655); D43/IV- ឧបសម្ព័ន្ធ 50, D43/IV- ឧបសម្ព័ន្ធ 50/ច្បាប់កែតម្រូវ -1 (ឯកសារ 662); D43/IV- ឧបសម្ព័ន្ធ 54 (ឯកសារ 699); D43/IV- ឧបសម្ព័ន្ធ 34 (ឯកសារ 676); D43/IV- ឧបសម្ព័ន្ធ 38 (ឯកសារ 668); D43/IV- ឧបសម្ព័ន្ធ 07 (ឯកសារ 683); D43/IV- ឧបសម្ព័ន្ធ 60 (ឯកសារ 651); D43/IV- ឧបសម្ព័ន្ធ 50, D43/IV- ឧបសម្ព័ន្ធ 50/ច្បាប់កែតម្រូវ -1 (ឯកសារ 662); D82/II- ឧបសម្ព័ន្ធ 14 (ឯកសារ 689); D82/II- ឧបសម្ព័ន្ធ 43 (ឯកសារ 703); D82/II- ឧបសម្ព័ន្ធ 25 (ឯកសារ 665); D82/II- ឧបសម្ព័ន្ធ 42 (ឯកសារ 644); D82/II- ឧបសម្ព័ន្ធ 06 (ឯកសារ 716); D108/31.23 (ឯកសារ 656);

រឿងទេ[415] ប៉ុន្តែអាចរកបាននៅក្នុងឃ្លាំងផ្ទុកឯកសាររួម។ ចម្លើយសារភាពចំនួន១៣ ក្នុងចំណោមចម្លើយសារភាពទាំងនោះ ត្រូវបានទទួលយកជាភ័ស្តុតាងរួចហើយ នៅក្នុងអំឡុងពេលកិច្ចដំណើរការសវនាការក្នុងសំណុំរឿង០០១[416]។

---

D108/31.24 (ឯកសារ 659); D108/31.43 (ឯកសារ 695); D108/31.20 (ឯកសារ 646); D108/31.13 (ឯកសារ 641); D108/31.42 (ឯកសារ 692); D108/31.22 (ឯកសារ 648); D159/5.43 (ឯកសារ 727); D159/5.50 (ឯកសារ 701); D159/5.24 (ឯកសារ 690); D159/5.10 (ឯកសារ 671); D159/5.18 (ឯកសារ 735); D159/5.6 (ឯកសារ 714); D159/5.3 (ឯកសារ 708); D159/5.98 (ឯកសារ 675); D159/5.5 (ឯកសារ 681); D159/5.36 (ឯកសារ 717); D159/5.53 (ឯកសារ 681); D159/5.37 (ឯកសារ 731); D175/3.77, D175/3.77/ ច្បាប់កែតម្រូវ-1 (ឯកសារ 687); D312.2.24 (ឯកសារ 728); D312.1.58 (ឯកសារ 723)។ ឯកសារទាំងអស់បានដាក់ក្នុងសំណុំរឿងស្របតាមឯកសារ D43 ដីកាចាត់ឱ្យស៊ើបសួរជំនួស សម្រាប់ឯកសារនៅ DC-Cam, ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០៧។ ឯកសារ D82 ដីកាចាត់ឱ្យស៊ើបសួរជំនួស សម្រាប់ឯកសារនៅ សារមន្ទីរទួលស្លែង, ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៨។ ដីកាសម្រេចផ្ទេរឯកសារពីសំណុំរឿង០០១ ទៅសំណុំរឿង០០២ ឯកសារ D108 ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨។ ឯកសារ D159 ដីកាចាត់ឱ្យស៊ើបសួរជំនួស សម្រាប់ឯកសារនៅ សារមន្ទីរទួលស្លែង, ចុះថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០០៨។ ឯកសារ D175 ដីកាចាត់ឱ្យស៊ើបសួរជំនួស សម្រាប់ឯកសារនៅ DC-Cam ចុះថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០០៨។ ឯកសារ D312 ដីកាសម្រេចរបស់ ស.ច.ស ស្តីពីការដាក់ឯកសារទៅក្នុងសំណុំរឿង០០២ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០។

[415] ចម្លើយសារភាពរបស់ ញឹម ឈន *ហៅ* ហង់ (NHIM Chhon alias HANG) ដែលស្រង់ដោយ មន្ទីរស២១, មិនដឹងកាលបរិច្ឆេទ, ERN 00694354។ ចម្លើយសារភាពរបស់ ម៉ែន សាន *ហៅ* នៃ សារ៉ន *ហៅ* យ៉ា (MEN San alias NEY Saran alias Ya (ទី៩) ដែលស្រង់ដោយមន្ទីរស២១, ចុះថ្ងៃទី២៦ កញ្ញា១៩៧៦ ។ ចម្លើយសារភាពរបស់ អែម មិន *ហៅ* សេន (EM Min alias SEN) ដែលស្រង់ដោយមន្ទីរស២១, ចុះថ្ងៃទី១១ ឧសភា ១៩៧៧។ ចម្លើយសារភាពរបស់ អែម មិន *ហៅ* សេន (EM Min alias SEN) ដែលស្រង់ដោយមន្ទីរស២១, ចុះថ្ងៃទី៤ ឧសភា១៩៧៧, ERN 00223104-05។ ចម្លើយសារភាពរបស់ តាន់ ទ្រី *ហៅ* ឈឿន (TANN Try alias CHHOEURN) ដែលស្រង់ដោយមន្ទីរស២១, ចុះថ្ងៃទី៨ ឧសភា ១៩៧៧, ERN 00233528-29។ ចម្លើយសារភាពរបស់ គាំ ចាន់ *ហៅ* ជន(KOAM Chan alias CHORN) ដែលស្រង់ដោយមន្ទីរ ស២១, ចុះថ្ងៃទី៣ ធ្នូ ១៩៧៧ , ERN 00658631-33។ ចម្លើយសារភាពរបស់ គាំ ចាន់ *ហៅ* ជន (KOAM Chan alias CHORN) ដែលស្រង់ដោយមន្ទីរស២១, ចុះថ្ងៃទី២១ តុលា ១៩៧៧។ (ឯកសារ ដូចខាងក្រោមនេះគឺជាចម្លើយសារភាព ប៉ុន្តែសេចក្តីសង្ខេបត្រូវបានរៀបចំដោយ DC-Cam) ចម្លើយ សារភាពរបស់ យុង ពៅ *ហៅ* យ៉ាង ប៉ូវ (YUNG Peou alias YANG Pov) ដែលស្រង់ដោយមន្ទីរស២១ , ចុះថ្ងៃទី២៤ មេសា ១៩៧៧, ERN 00223125។ ចម្លើយសារភាពរបស់ អេង ម៉េង ហៀង *ហៅ* ឈន (ENG Meng Heang alias CHHON) ដែលស្រង់ដោយមន្ទីរស២១, (សេចក្តីសង្ខេបនៃចម្លើយសារភាព), ចុះថ្ងៃទី៧ ឧសភា ១៩៧៧, ERN 00294991-92។ ចម្លើយសារភាពរបស់ ឃុន ថុន ថាណារ៉ាក់ *ហៅ* ពេញ (KUN THON Thanarak alias Penh) ដែលស្រង់ដោយមន្ទីរស២១, ចុះថ្ងៃទី២១ មេសា ១៩៧៧, ERN 00223111។ ចម្លើយសារភាពរបស់ ប៊ូ កែវ *ហៅ* ខាវ (BOU Keo alias KHAV)ដែលស្រង់ដោយមន្ទីរស២១, ចុះថ្ងៃទី១២ កក្កដា ១៩៧៧, ERN 00223122។

[416] ឯកសារលេខ D43/IV- ឧបសម្ព័ន្ធទី ៥៨ (ឯកសារ 661, ដែលត្រូវបានទទួលយកថាជាឯកសារលេខ E3/416)។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ 5.115 (ឯកសារ 704, ដែលត្រូវបានទទួលយកជាឯកសារលេខ E3/401)។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ 5.65 (ឯកសារ 638, ដែលត្រូវបានទទួលយកថាជាឯកសារលេខ E3/372, និងលេខ E3/377)។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ 5.100 (ឯកសារ 730, ដែលត្រូវបានទទួលយកថាជាឯកសារលេខ E3/182)។ ឯកសារលេខ D159/5.37 (ឯកសារ 731, ដែលត្រូវបានទទួលយកជាឯកសារលេខ E3/125)។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ D2-15.45 និងលេខ D196.15 (ឯកសារ 722, ដែលត្រូវបានទទួលយកថាជាឯកសារលេខ E3/119)។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ 5.74 (ឯកសារ 726, ដែលត្រូវបានទទួលយកជាឯកសារលេខ E3/080)។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ D2-15.39, លេខ D288/5.72, និងលេខ D312.2.23 (ឯកសារ 724,

## ២២. បញ្ជីឈ្មោះអ្នកទោសកម្ទេចនៅមន្ទីរ ស-២១

១៦០. បញ្ជីឯកសារមានឯកសារចំនួន១០ ដែលត្រូវបានចាត់ចំណាត់ថ្នាក់ជា "បញ្ជីឈ្មោះអ្នកទោសកម្ទេច ស-២១"[417]។ បញ្ជីឈ្មោះអ្នកទោសកម្ទេចទាំងនេះត្រូវបានរក្សាទុកដោយអង្គភាពឯកសារ ស-២១ រួមជាមួយឯកសារដទៃទៀតដូចជា បញ្ជីឈ្មោះអ្នកទោស បញ្ជីសួរចម្លើយអ្នកទោស និងរូបថត ដើម្បីអនុវត្តទៅតាមគោលនយោបាយទូលំទូលាយ នៅស-២១ ក្នុងការកត់ត្រាយ៉ាងហ្មត់ចត់នូវការទទួល ការសួរចម្លើយ និងការកម្ទេចអ្នកទោស។ ទង្វើដូចនេះស៊ីសង្វាក់គ្នានឹងគោលនយោបាយទូលំទូលាយរបស់បក្សកុម្មុយនីស្តកម្ពុជា ទាក់ទងនឹងការបញ្ជូនព័ត៌មានសន្តិសុខទៅកាន់ថ្នាក់មជ្ឈិម ដែលមាន ស-២១ ជាពន្ធនាគារមួយមានតួនាទីពិសេស ក្នុងការរាយការណ៍ផ្ទាល់ទៅសមាជិកគណៈអចិន្ត្រៃយ៍។ ជាពិសេស បញ្ជីឈ្មោះអ្នកទោសកម្ទេចទាំងនេះកត់ត្រាពីការអនុវត្តចុងក្រោយនៃគោលនយោបាយ "កម្ទេច" ខ្លាំងក្នុងរបបនោះ។

១៦១. បញ្ជីឈ្មោះអ្នកទោសកម្ទេចទាំងនេះមានសរសេរពាក្យ/ឃ្លាយ៉ាងច្បាស់លាស់ ដូចជា "យុទ្ធជន", "កម្ទេច", "កម្លាំងសម្ងាត់យួន", "ពលករថ្មី" និង "ពលករចាស់" ដែលមានទំនាក់ទំនងជាសាមញ្ញជាមួយនឹងបក្សកុម្មុយនីស្តកម្ពុជា និងរក្សាមនោគមវិជ្ជារបស់បក្ស។ បញ្ជីឈ្មោះអ្នកទោសកម្ទេចទាំងនេះ ប្រើប្រាស់ទម្រង់មួយដែលស៊ីសង្វាក់គ្នាយ៉ាងខ្លាំងទៅនឹងបញ្ជីទាំងអស់ ក្នុងនោះមានឈ្មោះ, ឈ្មោះហៅក្រៅ/ឈ្មោះបដិវត្តន៍, មកពី និង របររកស៊ីនៃអ្នកត្រូវកម្ទេច។ បញ្ជីខ្លះមានចុះលេខអ្នកទោស, ភេទ, អាយុ, ថ្ងៃខែឆ្នាំចូល, ថ្ងៃខែឆ្នាំកម្ទេច, ក្រុមសួរចម្លើយ និងអ្នកសួរចម្លើយ[418]។

១៦២. មូលដ្ឋានទិន្នន័យនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបង្ហាញថា បញ្ជីឈ្មោះអ្នកទោសកម្ទេចទាំងអស់មានប្រភពដើមពីការប្រមូលទុក នៅបណ្ណសារដ្ឋានទួលស្លែង។ គេបានធ្វើការលើកឡើងពីមុនរួចហើយពីការកាន់កាប់ឯកសារ ដែលបានប្រមូលមកពីបណ្ណសារដ្ឋានទួលស្លែង[419]។ បញ្ជីចំនួន ៨

ដែលត្រូវបានទទួលយកជាឯកសារលេខ E3/72)។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ 5.55 (ឯកសារ 721, ដែលត្រូវបានទទួលយកជាឯកសារលេខ E3/71)។ ឯកសារលេខ D83-ឧបសម្ព័ន្ធទី-00004 (ឯកសារ 736, ដែលត្រូវបានទទួលយកជាឯកសារលេខ E3/65)។ ឯកសារលេខ D2-15.41, លេខ D83-ឧបសម្ព័ន្ធទី-00004 (ឯកសារ 664, ដែលត្រូវបានទទួលយកជាឯកសារលេខ E3/64)។ ឯកសារលេខ D43/IV-ឧបសម្ព័ន្ធទី 41 (ឯកសារ 707, ដែលត្រូវបានទទួលយកថាជា E3/21)។ ឯកសារលេខ D43/IV-ឧបសម្ព័ន្ធទី 18 (ឯកសារ649, ដែលត្រូវបានទទួលយកជាឯកសារលេខ E3/20)។

[417] ឯកសារ 737-746 នៅក្នុងបញ្ជីឈ្មោះឯកសារ។

[418] ឧទាហរណ៍ មើល IS 16.38, ឯកសារលេខ D312.1.7 (ឯកសារ ៩៩)។

[419] សូមមើលវាក្យខ័ណ្ឌ I ខាងលើ។

ក្នុងចំណោមបញ្ជីអ្នកទោសកម្មេចចំនួន១០ ត្រូវបានមជ្ឈមណ្ឌលឯកសារកម្ពុជាប្រគល់ឲ្យការិយាល័យសហព្រះរាជអាជ្ញា ក្នុងអំឡុងពេលនៃការស៊ើបអង្កេតបឋម និងត្រូវបានដាក់ជាឧសម្ព័ន្ធនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ ការិយាល័យសហចៅក្រមស៊ើបអង្កេតបានដាក់ឯកសារពីរផ្សេងទៀត ទៅក្នុងសំណុំរឿងក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ[420]។ បញ្ជីមួយត្រូវបានដាក់ចូលក្នុងសំណុំរឿង តាមសំណើរបស់ការិយាល័យសហព្រះរាជអាជ្ញា បន្ទាប់ពីបានចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ[421] និងបញ្ជីមួយផ្សេងទៀតត្រូវបានបញ្ជូនពីសំណុំរឿង០០១។

១៦៣. ក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០១, ឌុច បានផ្ដល់យថាភូតលើបញ្ជីមួយក្នុងចំណោមបញ្ជីឈ្មោះអ្នកទោសកម្ទេចទាំងនេះ ដែលមាននៅក្នុងបញ្ជីឯកសារ ដោយធ្វើការបញ្ជាក់ថា បញ្ជីនោះមានចំណាររបស់គាត់ និង ម៉ម ណៃ[422]។ បញ្ជីនេះ និងបញ្ជីមួយផ្សេងទៀតនៅក្នុងបញ្ជីឯកសារ ត្រូវបានអង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់ជាភ័ស្ដុតាង ក្នុងសំណុំរឿង ០០១[423]។ អង្គជំនុំជម្រះសាលាដំបូងបានគត់សម្គាល់ក្នុងសាលក្រមរបស់ខ្លួនថា ខ្លួនបានប្រើប្រាស់បញ្ជីអ្នកទោស, បញ្ជីសួរចម្លើយ និងបញ្ជីអ្នកទោសកម្ទេច ដើម្បីកំណត់ចំនួនអ្នកទោសនៅ ស-២១[424]។

១៦៤. ខ្លឹមសារនៃបញ្ជីឈ្មោះអ្នកទោសកម្ទេចនៅ ស-២១ អាចបញ្ជាក់ពីការពិតតាមរយៈការប្រៀបធៀបជាមួយនឹងឯកសារផ្សេងៗទៀត។ ឧទាហរណ៍ បញ្ជីឈ្មោះអ្នកទោសដែលការកម្ទេចកក្នុងបញ្ជីនេះត្រូវបានពន្យាររហូតដល់ខែមករា ឆ្នាំ១៩៧៧ សំដៅដល់ចំនួនអ្នកទោសដែលបានជាប់ឃុំនៅស-២១ នៅពេលនោះ ហើយបញ្ជីនេះត្រូវបានបញ្ជាក់ផ្ទៀងផ្ទាត់តាមរយៈចម្លើយសារភាព ឬបញ្ជីឈ្មោះអ្នកទោសកម្ទេចផ្សេងៗទៀត[425]។ ដូចគ្នានេះដែរ បញ្ជីឈ្មោះអ្នកទោសកម្ទេច នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ

[420] ឯកសារលេខ D108/26.140, ឯកសារលេខ D312.1.13 (ឯកសារ 743) និងឯកសារលេខ D312.1.34, ឯកសារលេខ D366/7.1.146 (ឯកសារ ៧៤១)។ មើលកំណត់សម្គាល់លើឯកសារ D108 ដោយសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨ និងកំណត់សម្គាល់លើឯកសារ D312 ដោយសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០។

[421] ឯកសារលេខ D366, សំណើរបស់សហព្រះរាជអាជ្ញាសុំដាក់បញ្ចូលឯកសារភ័ស្ដុតាងបន្ថែមទៅក្នុងសំណុំរឿង ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ ២០១០។

[422] ឯកសារលេខ E1/35.1, ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី ៖ សវនាការ "ឌុច" ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ លេខឯកសារ ERN 00344105-225, ទំព័រ ២៧។

[423] ឯកសារលេខ IS 16.46, D312.1.25 (ឯកសារ ៧៣៨; ត្រូវបានទទួលស្គាល់ជាឯកសារលេខ E3/370); ឯកសារលេខ IS 16.76 (ឯកសារ ៧៤២; ត្រូវបានទទួលស្គាល់ជាឯកសារលេខ E3/432)។

[424] សាលក្រម ឯកសារលេខ E188, ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០, លេខឯកសារ ERN 00572517-797, កថាខណ្ឌ ១៤០-១៤២។

[425] ឯកសារលេខ IS 16.46, D312.1.25 (ឯកសារ ៧៣៨; ត្រូវបានទទួលស្គាល់ជាឯកសារលេខ E3/370), ទំព័រ ២ (សរសេរក្នុងបញ្ជីថា

១៩៧៨ មានលក្ខណៈស្របគ្នានឹងរូបថតនៃទាហានល្បើយសឹកវៀតណាម ឈ្មោះ LE Van Nam ហើយបញ្ជីនេះក៏មានកត់ត្រាពីការទទួលយកល្បើយសឹកនេះមក ស-២១ នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ ១៩៧៨ និងមានចម្លើយសារភាពនៅមុនមិនយូរប៉ុន្មាន ពីកាលបរិច្ឆេទការសម្លាប់ក្នុងបញ្ជីឈ្មោះអ្នកទោសកម្ទេច[426]។

## ២៣. បញ្ជីសួរចម្លើយអ្នកទោសនៅ ស-២១

១៦៥. មានឯកសារចំនួន៩៩ នៅក្នុងបញ្ជីឯកសារដែលត្រូវបានចាត់ថ្នាក់ថាជា "បញ្ជីសួរចម្លើយអ្នកទោសនៅមន្ទីរស-២១"[427]។ បញ្ជីសួរចម្លើយអ្នកទោសនៅមន្ទីរស-២១ ត្រូវបានរក្សាទុកដោយអង្គភាពឯកសាររបស់មន្ទីរស-២១ ដូចជាបញ្ជីឈ្មោះអ្នកទោស បញ្ជីឈ្មោះអ្នកទោសដែលបានសម្លាប់ និងរូបថត ដែលស្របទៅនឹងគោលនយោបាយយ៉ាងទូលំទូលាយរបស់មន្ទីរស-២១ ក្នុងការកត់ត្រាយ៉ាងយកចិត្តទុកដាក់នូវដំណើរការទទួល សួរចម្លើយ និងសម្លាប់អ្នកទោស។ ដោយឡែក បញ្ជីសួរចម្លើយអ្នកទោស បានកត់ត្រានូវដំណើរការសួរចម្លើយ ដែលមានគោលបំណងប្រមូលចម្លើយសារភាពឲ្យបានពេញលេញពីអ្នកទោស ដែលព័ត៌មាននោះនឹងត្រូវបញ្ជូនទៅឲ្យមជ្ឈិមបក្ស។

១៦៦. បញ្ជីសួរចម្លើយអ្នកទោសបានប្រើប្រាស់វោហារស័ព្ទនានាដូចជា "យុទ្ធជន" "គិញយួន" "កម្មករថ្មី" "កម្មករចាស់" ដែលស្របទៅនឹង ប.ក.ក និងរក្សានូវមនោគមន៍វិជ្ជារបស់ ប.ក.ក ផងដែរ[428]។ បញ្ជីទាំងនេះត្រូវមានទម្រង់មួយស្របគ្នាជាខ្លាំង។ បញ្ជីទាំងនេះ រួមមានព័ត៌មានពិស្តារជាមូលដ្ឋានអំពីអ្នកទោស និងដំណើរការសួរចម្លើយ រួមមាន ឈ្មោះ ឈ្មោះហៅក្រៅ តួនាទី ស្ថានភាពសួរចម្លើយ កាលបរិច្ឆេទចាប់ខ្លួន និងអ្នកសួរចម្លើយ។ ជាធម្មតា អ្នកទោសត្រូវបានបែងចែកដោយអង្គភាពសួរចម្លើយមន្ទីរស-២១ និងបន្ទាប់មកដោយស្ថាប័នចាត់តាំង (ឧ. ភូមិភាគ ឬក្រសួង)។

---

មាស វង់ គឺជាអ្នកទោស), 00185361 (សរសេរក្នុងបញ្ជីថា សឿង គ្រិន គឺជាអ្នកទោស), និង 16 (សរសេរក្នុងបញ្ជីថា ហេង ពេជ ហៅ ឆន គឺជាអ្នកទោស); ឯកសារលេខ cf. IS 16.49 បញ្ជីឈ្មោះអ្នកទោសកម្ទេច ស២១, ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ១៩៧៧, ទំព័រ៤ (បញ្ជាក់ថា មាស វង់ ត្រូវបានសម្លាប់ ក្រោមកមកបន្តិច); ឯកសារលេខ D43/IV-Annex 72 សេចក្តីសង្ខេបនៃចម្លើយសារភាពរបស់ សឿង គ្រិន, ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៧៧, ឯកសារលេខ D108/31.22 ចម្លើយសារភាពរបស់ ហេង ពេជ ហៅ ឆន, ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៧៧, លេខឯកសារ ERN 00178177-78 (Zylab បញ្ជាក់មិនត្រឹមត្រូវថា ចម្លើយសារភាពនេះគឺជារបស់ "ពេជ ពៅ ហៅ ឆន")។

[426] ឯកសារ IS 7.6 (ឯកសារ ៧៤៦), ទំព័រ ១; ឯកសារលេខ cf. D108/32.3 P3949 រូបថតរបស់ LE Van Nam នៅស ២១, ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៧៨, លេខឯកសារ ERN P 00004001; ឯកសារលេខ D108/50/1.48 ចម្លើយសារភាពរបស់ LE Van Nam, ចុះថ្ងៃទី១០ សីហា ឆ្នាំ១៩៧៨, លេខឯកសារ ERN 00168953-55។

[427] ឯកសារ 747-845 នៅក្នុងបញ្ជីឯកសារ។

[428] សូមមើល ឧទាហរណ៍ IS 16.87 (ឯកសារ 752)។

បញ្ជីទាំងនេះក៏បានកត់ត្រាផងដែរនូវព័ត៌មានផ្សេងៗដូចជា អាយុ និងភេទ របស់អ្នកទោស និងតើអ្នកទោសជា "ប្រជាជនចាស់" ("អ្នកមូលដ្ឋាន") ឬ "ប្រជាជនថ្មី" ដែលជាពាក្យគេប្រើសម្រាប់រក្សាគោលនយោបាយរើសអើងរបស់ ប.ក.ក ប្រឆាំងនឹង "ប្រជាជនថ្មី[429]។

១៦៧. ខ្លឹមសារនៅក្នុងចម្លើយសារភាពនៅមន្ទីរស-២១ អាចត្រូវបានបញ្ជាក់ដោយការប្រៀបធៀបរវាងបញ្ជីមួយទៅនឹងបញ្ជីមួយទៀតបាន។ ឧទាហរណ៍ អ្នកទោស សៅ សារុន ហៅ សារ៉ន ឬ រ៉ន ត្រូវបានគេចុះក្នុងបញ្ជីស្របគ្នាថាជា "ប្រជាជនចាស់" ជាលេខាកងវរសេនាតូច ឬជាលេខាវរសេនាធំលេខ១១៦ នៃតំបន់២៣ (ភូមិភាគបូព៌ា) ហើយដែលត្រូវបានចាប់ខ្លួននៅថ្ងៃទី២៦ ខែមីនា ឆ្នាំ១៩៧៨[430]។ អ្នកទោសម្នាក់ទៀតមកពីភូមិភាគបូព៌ាឈ្មោះ ឈូក លឹម *ហៅ* បុល ឬ ប៉ុល ក៏ត្រូវបានចុះក្នុងបញ្ជីថាជា "ប្រជាជនចាស់" ជាសមាជិកកងពលនៃតំបន់២០ ហើយដែលត្រូវបានចាប់ខ្លួននៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៨[431]។ សៀវភៅបញ្ជីសម្រាប់កត់ត្រាអំពីការសួរចម្លើយទាំងឡាយអាចនឹងមានភាពស៊ីសង្វាក់គ្នាជាបន្ថែមទៀត ដោយការប្រៀបធៀបគ្នាទៅនឹងឈ្មោះរបស់ពួកអ្នកទោសដែលមាននៅក្នុងសៀវភៅបញ្ជីសំរាប់កត់ត្រា អំពីការសម្លាប់នានា ក្នុងបញ្ជីឈ្មោះអ្នកទោស ក្នុងចម្លើយសារភាពទាំងឡាយដែលស្រង់ដោយមន្ទីរស២១ ឬក្នុងប្រវត្តិរូបនៅមន្ទីរស២១។

១៦៨. មូលដ្ឋានទិន្នន័យនៃឯកសារនៅ DC-Cam បង្ហាញថា បញ្ជីសួរចម្លើយអ្នកទោសទាំងអស់នោះមានប្រភពពីបណ្ណសារទួលស្លែង (TSL)។ ដំណើរការគ្រប់គ្រងឯកសារដែលប្រមូលពី TSL ត្រូវបានរៀបរាប់ដូចខាងលើស្រាប់[432]។ ក.ស.ព បានទទួលបញ្ជីសួរចម្លើយអ្នកទោសចំនួន៦៦ ក្នុងចំណោមបញ្ជីសួរចម្លើយអ្នកទោសទាំងនោះ ពី DC-Cam ក្នុងពេលស៊ើបអង្កេតបឋម និងបានភ្ជាប់ជាមួយនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ[433]។ បញ្ជីសួរចម្លើយអ្នកទោសចំនួន៣៣ ទៀត បានទទួលពី DC-Cam ក្នុងពេលដំណើរការសំណុំរឿង០០១ ហើយចុងក្រោយត្រូវបាន ក.ស.ច.ស បញ្ចូលក្នុងសំណុំរឿង០០២[434]។

---

[429] សូមមើល ឧទាហរណ៍ IS 16.119 (ឯកសារ 769)។

[430] IS 16.99, ទំព័រ១ (ឯកសារ 764); IS 16.115, ទំព័រ១ (ឯកសារ 784); D108/26.184, ទំព័រ១ (ឯកសារ 782); IS 16.121, ទំព័រ១ (ឯកសារ 788); IS 16.131 ទំព័រ១ (ឯកសារ 803)។

[431] IS 16.115, ទំព័រ១ (ឯកសារ 784); D108/26.184, ទំព័រ១ (ឯកសារ 782); IS 16.121, ទំព័រ១ (ឯកសារ 788); D108/26.199, ទំព័រ១ (ឯកសារ 795); IS 16.131, ទំព័រ១ (ឯកសារ 803)។

[432] សូមមើលវាក្យខ័ណ្ឌ I ខាងលើ។

[433] សូមមើល ឯកសារ ដែលមានលេខយោងផ្តើមដោយ "IS"។

[434] D108 កំណត់សម្គាល់ផ្ទេរឯកសារពីសំណុំរឿង០០១ ទៅសំណុំរឿង០០២ របស់ កសចស, ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨, ERN

១៦៩. ចុងក្រោយ ប្រការដែលគួរឲ្យកត់សម្គាល់ គឺថាបញ្ជីសួរចម្លើយអ្នកទោសចំនួន៣ ក្នុងចំណោមបញ្ជីសួរចម្លើយអ្នកទោសទាំងអស់ដែលស្ថិតនៅក្នុងបញ្ជីឯកសារ ត្រូវបានទទួលយកជាភស្តុតាងក្នុងសំណុំរឿង០០១[435]។ អ.ជ.ស.ដ បានកត់សម្គាល់បន្ថែមទៀត នៅក្នុងសាលក្រមរបស់ខ្លួនថា ក្នុងការសម្រេចពីចំនួនអ្នកទោសនៅមន្ទីរស-២១ អង្គជំនុំជម្រះនេះបានពឹងផ្អែកទៅលើបញ្ជីឈ្មោះអ្នកទោស ការសួរចម្លើយ និងការសម្លាប់[436]។

## ២៤. បញ្ជីឈ្មោះអ្នកទោស ស-២១

១៧០. បញ្ជីឯកសារ មានបញ្ជីទាំងអស់ចំនួន៦៩ ដែលត្រូវបានចាត់ចំណាត់ថ្នាក់ជា "បញ្ជីឈ្មោះអ្នកទោស ស-២១"[437]។ បញ្ជីឈ្មោះអ្នកទោសទាំងនេះត្រូវបានរក្សាទុកដោយអង្គភាពឯកសារ ស-២១ ដើម្បីកត់ត្រាអ្នកទោស ស្របតាមគោលនយោបាយយ៉ាងទូលំទូលាយ ក្នុងការកត់ត្រាយ៉ាងហ្មត់ចត់នូវការទទួល, ការសួរចម្លើយ និងការកម្ទេចអ្នកទោស។ បញ្ជីឈ្មោះអ្នកទោសទាំងនេះត្រូវបានប្រើប្រាស់រួមជាមួយនឹងបញ្ជីសួរចម្លើយអ្នកទោស, និងបញ្ជីឈ្មោះអ្នកទោសកម្ទេច និងរូបថតដែលបានថតនៅពេលទទួល និងកម្ទេចអ្នកទោស[438]។ ទង្វើដូចនេះក៏ស៊ីសង្វាក់គ្នានឹងគោលនយោបាយទូលំទូលាយរបស់បក្សកុម្មុយនីស្តកម្ពុជា ទាក់ទងនឹងការបញ្ជូនព័ត៌មានសន្តិសុខទៅកាន់ថ្នាក់មជ្ឈិម ដែលមាន ស-២១ ជាពន្ធនាគារ មានតួនាទីពិសេសក្នុងការរាយការណ៍ផ្ទាល់ទៅសមាជិកគណៈអចិន្ត្រៃយ៍[439]។

១៧១. បញ្ជីឈ្មោះអ្នកទោសទាំងនេះភាគច្រើនមានសរសេរពាក្យ/ឃ្លាយ៉ាងច្បាស់លាស់ ដូចជា "ចារកម្មយួន", "ពលករថ្មី" "ពលករចាស់" និង "ធីវ គី" ដែលមានទំនាក់ទំនងយ៉ាងសាមញ្ញជាមួយនឹងបក្សកុម្មុយនីស្តកម្ពុជា និងការរក្សាមនោគមវិជ្ជារបស់បក្ស[440]។ បញ្ជីឈ្មោះអ្នកទោសទាំងនេះក៏

---

00236076-77។

[435] IS 8.1, D312.1.30 (ឯកសារ 796, ត្រូវបានទទួលយកជាឯកសារ E3/454); IS 16.77 (ឯកសារ 801, ត្រូវបានទទួលយកជាឯកសារ E3/453); IS 16.119 (ឯកសារ 769, ត្រូវបានទទួលយកជាឯកសារ E3/452)។

[436] E188 សាលក្រម, ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០, ERN 00572517-797, កថាខណ្ឌ១៤០-១៤២។

[437] ឯកសារ ៨៤៦-៩១៤ ក្នុងបញ្ជីឯកសារ។ កំណត់សម្គាល់ ៖ ឯកសារមួយក្នុងចំណោមឯកសារទាំងឡាយ (ឯកសារលេខ D2-15.32, ឯកសារ ៩១២) គឺមិនមែនជាបញ្ជីអ្នកទោសទេ ប៉ុន្តែជាបញ្ជីចម្លើយសារភាព។ បញ្ជីនេះត្រូវបានទទួលស្គាល់ជាឯកសារក្នុងសំណុំរឿង ០០១ ដែលមានលេខសម្គាល់ E3/192។

[438] សាលក្រម ឯកសារលេខ E188, ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០, លេខឯកសារ ERN 00572517-797, កថាខណ្ឌ១៤៥-១៤៩។

[439] *ដូចខាងលើ*, កថាខណ្ឌ ២៣; ដីកាដំណោះស្រាយ លេខ D1, ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០, កថាខណ្ឌ៤២២, កថាខណ្ឌ៤៥៦។

[440] មើល ឧទាហរណ៍ ឯកសារលេខ IS 16.14 (ឯកសារ ៩០៥) ទំព័រ១-៤។

ប្រើប្រាស់ទម្រង់មួយដែលមានលក្ខណៈដូចគ្នាយ៉ាងខ្លាំង។ ទោះបីប្រភេទនៃព័ត៌មានទាំងនេះដែលបានកត់ត្រាទុកមានលក្ខណៈខុសគ្នាក៏ដោយ ក៏បញ្ជីទាំងនេះមានកត់ត្រាឈ្មោះ និងរបររកស៊ីនៃអ្នកត្រូវកម្ទេច។ ប្រភេទព័ត៌មានបន្ថែមផ្សេងៗទៀតមាន ដូចជា លេខអគារ, លេខបន្ទប់ឃុំឃាំង, លេខសម្គាល់អ្នកទោស, ឈ្មោះហៅក្រៅ/ឈ្មោះបដិវត្ត, អាយុ, ភេទ, ប្រភពដើម, ថ្ងៃខែឆ្នាំចូល, និងស្ថានភាពសួរចម្លើយជាដើម ក៏មានចុះបញ្ចូលក្នុងបញ្ជីឈ្មោះអ្នកទោសភាគច្រើនទាំងនេះដែរ[441]។

១៧២. មជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រមូលបញ្ជីឈ្មោះអ្នកទោសទាំងអស់ ពីបណ្ណសារដ្ឋានទួលស្លែង។ គេបានធ្វើការលើកឡើងពីមុនរួចហើយពីការកាន់កាប់ឯកសារដែលបានប្រមូលមកពីបណ្ណសារដ្ឋានទួលស្លែង[442]។ បញ្ជីចំនួន៤ នៅឆ្នាំ១៩៩៦ និងបញ្ជីឈ្មោះអ្នកទោសផ្សេងៗ នៅឆ្នាំ១៩៩៩[443]។ ការិយាល័យសហព្រះរាជអាជ្ញាបានទទួលបញ្ជីឈ្មោះអ្នកទោសចំនួន៣៩ ក្នុងអំឡុងពេលនៃការស៊ើបអង្កេតបឋម និងបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ការិយាល័យសហចៅក្រមស៊ើបអង្កេត បានដាក់បញ្ជីទាំងអស់ដែលនៅសល់ក្នុងចំណោមបញ្ជីឈ្មោះទាំងនេះទៅក្នុងសំណុំរឿង ក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ លើកលែងតែបញ្ជីមួយប៉ុណ្ណោះដែលមិនទាន់បានដាក់។ បញ្ជីឈ្មោះអ្នកទោស ផ្សេងៗទៀតនៅមិនទាន់ត្រូវបានដាក់ចូលក្នុងសំណុំរឿងនៅឡើយទេរហូតដល់ពេលនេះ ប៉ុន្តែនឹងត្រូវដាក់ឱ្យភាគីនានាមើលនៅលើឃ្លាំងផ្ទុកឯកសាររួម[444]។

១៧៣. បញ្ជីឈ្មោះអ្នកទោសទាំងនេះដែលមានប្រភេទដូចគ្នាទៅនឹងបញ្ជីនានានៅក្នុងបញ្ជីឯកសារ ត្រូវបានទទួលស្គាល់ជាឯកសារភ័ស្តុតាងនៅក្នុងសំណុំរឿង០០១[445]។ អង្គជំនុំជម្រះសាលាដំបូងបានគត់

---

[441] មើល ឧទាហរណ៍ ឯកសារលេខ IS 16.88 (ឯកសារ ៨៩៦)។ ឯកសារចំនួន ៣បានកត់ត្រាជាលក្ខណៈមិនធម្មតានូវប្រភេទព័ត៌មានចំនួន ៣ ឬ ៤ ៖ IS 16.6 (ឯកសារ ៨៥១); IS 16.7 (ឯកសារ ៨៥៦); ឯកសារលេខ D108/26.247 (ឯកសារ៩០៤)។

[442] សូមវាក្យខ័ណ្ឌ I ខាងលើ។

[443] មើលមូលដ្ឋានទិន្នន័យរបស់មជ្ឈមណ្ឌលកម្ពុជានៅឯ ៖ http://www.d.dccam.org/Database/Lod/index.php (ឯកសារនេះអាចរកឃើញតាមរយៈលេខឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា)។

[444] ឯកសារលេខ ៨៤៨ ក្នុងបញ្ជីឈ្មោះឯកសាររបស់សហព្រះរាជអាជ្ញា។

[445] ឯកសារលេខ D108/26.59 (ត្រូវបានទទួលស្គាល់ជាឯកសារ E3/504); ឯកសារ IS 18.31, ឯកសារ D108/26.67 (ត្រូវបានទទួលស្គាល់ជាឯកសារ E3/383); D108/26.296, D108/50/1.9 (ត្រូវបានទទួលស្គាល់ជាឯកសារ E3/371); D108/26.186 (ត្រូវបានទទួលស្គាល់ជាឯកសារ E3/435); IS 16.136 (ត្រូវបានទទួលស្គាល់ជាឯកសារ E3/436); ឯកសារលេខ D81-Annex 1 (ឯកសារលេខ E3/038 Annex A,ឯកសារលេខ E3/508)។

សម្គាល់ក្នុងសាលក្រមរបស់ខ្លួនថា ខ្លួនបានប្រើប្រាស់បញ្ជីអ្នកទោស, បញ្ជីសួរចម្លើយ និងបញ្ជីអ្នកទោសកម្ទេច ដើម្បីកំណត់ចំនួនអ្នកទោសនៅ ស-២១[446]។

១៧៤. ជាងនេះទៀត ខ្លឹមសារនៃបញ្ជីឈ្មោះអ្នកទោសនៅ ស-២១ អាចបញ្ជាក់ពីការពិត តាមរយៈការប្រៀបធៀបជាមួយនឹងបញ្ជីផ្សេងទៀត ឬជាមួយនឹងប្រភេទឯកសារផ្សេងៗទៀត។ ឧទាហរណ៍ ព័ត៌មានដែលមាននៅក្នុងបញ្ជីមួយរបស់អ្នកទោសនៅភូមិភាគកណ្តាល ស៊ីសង្វាក់គ្នាទៅនឹងចម្លើយសារភាពមុនមួយដែលបានឆ្លើយដាក់កម្មាភិបាលពេទ្យនៅភូមិភាគកណ្តាល ឈ្មោះ "អាន" ដែលក្រោយមកមានសរសេរនៅក្នុងបញ្ជីមួយមានឈ្មោះថា សំអាត *ហៅ* អាន[447]។ ដូចគ្នានេះដែរ ព័ត៌មាននៅក្នុងបញ្ជីអ្នកទោសនៅភូមិភាគព្រៃសាន ស៊ីសង្វាក់គ្នាជាមួយនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងកំណត់ហេតុស្តាប់ចម្លើយសាក្សី ដែលបង្ហាញថា កម្មាភិបាល ជន យ៉ង់ និង មួយ ប៉យ ត្រូវបានគេហៅឲ្យទៅភ្នំពេញ ហើយបានជាប់ឃុំនៅ ស-២១ នៅចុងឆ្នាំ១៩៧៨[448]។ អ្នកទោសទាំងពីរនេះក៏បានផ្តល់ចម្លើយសារភាពភ្លាម បន្ទាប់ពីពេលចាប់ខ្លួន ដែលការនេះបញ្ជាក់បន្ថែមពីវត្តមានរបស់កម្មាភិបាលទាំងពីរនៅ ស-២១[449]។

## ២៥. ចម្លើយ

១៧៥. មានឯកសារចំនួន១៤ នៅក្នុងបញ្ជីឯកសារដែលត្រូវបានចាត់ថ្នាក់ថាជា "ចម្លើយ"[450]។ ប្រភេទឯកសារនេះភាគច្រើនត្រូវបានដាក់បញ្ចូលនូវចម្លើយនានាដែល DC-Cam បានធ្វើ ដោយរួមបញ្ចូលផងដែរនូវចម្លើយបានធ្វើដោយការិយាល័យសហព្រះរាជអាជ្ញា និងដោយសាលា Oriental and African Studies (SOAS) ព្រមទាំងចម្លើយចំនួនប្រាំផ្សេងទៀត ដែលទទួលបានពីប្រភពខុសៗគ្នា។

---

[446] សាលក្រម ឯកសារលេខ E188, ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០, លេខឯកសារ ERN 00572517-797, កថាខណ្ឌ ១៤០-១៤២។

[447] ឯកសារលេខ D108/26.114 (ឯកសារ ៨៨៧) ទំព័រ ៤, ចម្លើយសារភាពរបស់ ហង់ ប៊ូ, ឯកសារលេខ IS 5.8 ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ ១៩៧៧, លេខឯកសារ ERN 00746208-12, ទំព័រ ៣។

[448] ឯកសារលេខ D108/26.267 (ឯកសារ ៩០៦); ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីលោក ក្លាន ហ្វិត, ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ ២០០៨, លេខ ERN 00346106-12, ទំព័រ ៣; ឯកសារលេខ D208/3 កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី M. ROMAM Yun, ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០៩, ឯកសារលេខ ERN 00350300-08, ទំព័រ៥។

[449] ចម្លើយសារភាព ស២១ របស់ មួយ ប៉យ, ឯកសារលេខ D159/5.43, ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ១៩៧៨; ចម្លើយសារភាពរបស់ ចូន ម៉ុង ហៅ យ៉ង់, ឯកសារលេខ D159/5.18, ចុះថ្ងៃទី៤ ខែមករា ឆ្នាំ១៩៧៩។

[450] ឯកសារ 945-928 នៅក្នុងបញ្ជីឯកសារ។

*ចម្លើយដែលធ្វើដោយ DC-Cam*

១៧៦. មានចម្លើយដែលធ្វើដោយ DC-Cam ចំនួន ៧[451] ដែលការិយាល័យសហព្រះរាជអាជ្ញាបានទទួល។ ចម្លើយដែលធ្វើដោយ DC-Cam ជាទូទៅមានទម្រង់ពីរបែបផ្សេងគ្នា។ ទម្រង់ទីមួយ មានជាសំណួរ និងចម្លើយ។ ទម្រង់ទីពីរ គឺជាជីវប្រវត្តិដែលកត់ត្រាដោយអ្នកសម្ភាសន៍ និងមានលក្ខណៈជាការនិទាន។ ទម្រង់ទាំងពីរ មានចំណងជើងដែលមាន ឈ្មោះ ភេទ អាយុ ទីកន្លែងសម្ភាសន៍ កាលបរិច្ឆេទនៃការផ្តល់សម្ភាសន៍ និងឈ្មោះរបស់អ្នកសម្ភាសន៍។

១៧៧. ឯកសារមួយ[452] មានទម្រង់ប្លែកពីគេបន្តិច ដោយមានអក្សរសរសេរដោយដៃក្នុងសៀវភៅមួយដែលមាន៥៤ទំព័រ ដោយច្បាប់ដើមសរសេរជាភាសាបារាំង។ ខ្លឹមសារនៅលើទំព័រចំនួនពីរ ដែលត្រូវបានបកប្រែជាភាសាអង់គ្លេស គឺស្របគ្នាយ៉ាងខ្លាំងជាមួយនឹងខ្លឹមសារនៃការស្តាប់ចម្លើយ ដែល ក.ស.ច.ស បានធ្វើជាមួយសាក្សីតែមួយ ដែលក្នុងនោះ លោក គាត ឈន់ បានលើកឡើងជាច្រើនដង[453]។

*ចម្លើយដែលធ្វើដោយ ក.ស.ព*

១៧៨. មានចម្លើយចំនួន២ ដែលធ្វើដោយ ក.ស.ព[454] ក្នុងពេលធ្វើការស៊ើបអង្កេតបឋម ស្របតាមវិធាន ៥០។ ឯកសារទាំងពីរនេះមានចំណងជើងដូចគ្នា "កំណត់សម្គាល់នៃកិច្ចសម្ភាសន៍" ដែលមាននៅលើទំព័រនីមួយៗ និង "ការិយាល័យសហព្រះរាជអាជ្ញា" និង "ការស៊ើបអង្កេតបឋម" នៅខាងស្តាំពីក្រោមចំណងជើងនៅទំព័រទីមួយ។ ទំព័រមុខមានបញ្ជីនៅខាងឆ្វេងដែលរួមមាន ឈ្មោះនៃកិច្ចសម្ភាសន៍ ឈ្មោះមន្ត្រីស៊ើបអង្កេត ឈ្មោះមន្ត្រីបកប្រែ កាលបរិច្ឆេទ និងពេលវេលានៃកិច្ចសម្ភាសន៍ ទីកន្លែងសម្ភាសន៍ និងអាសយដ្ឋានរបស់អ្នកផ្តល់សម្ភាសន៍។ លេខទំព័រត្រូវបានដាក់នៅផ្នែកខាងក្រោមទំព័រដូចគ្នា។

*ចម្លើយផ្សេងៗទៀត*

---

[451] IS19.10 (ឯកសារ 918); IS 3.9 (ឯកសារ 916); IS 19.141 (ឯកសារ 921); IS 20.35 (ឯកសារ 919); IS 19.225 (ឯកសារ 920)។ ឯកសារ *ចម្លើយរបស់ សេង សឿន* (ឯកសារ 924) និង *ចម្លើយរបស់របស់ វ៉ោម តុន ហៅ ភី ភួន* (ឯកសារ 928) ជាឯកសារថ្មី។

[452] IS 3.9 (ឯកសារ 916)។

[453] D91/26 (ឯកសារ 936)។

[454] ចម្លើយថ្មីរបស់ [redacted] (ឯកសារ 927); ចម្លើយថ្មី [redacted] (ឯកសារ 926)។

១៧៩. មានចម្លើយចំនួន៥ផ្សេងទៀតបានពីប្រភពខុសៗគ្នា[455]។ ចម្លើយមួយត្រូវបានធ្វើដោយសាលា Oriental and African Studies(SOAS)[456]។ ចម្លើយនេះត្រូវបានកត់ត្រាជាលក្ខណៈជីវប្រវត្តិដោយមនុស្សម្នាក់ដែលមិនមែនជាសាម៉ីខ្លួន និងមានបែបផែនជានិទានតាមបទដ្ឋានជាក់លាក់មួយ។ ចំណងជើងខាងលើនៃផ្នែកខាងឆ្វេងនៃទំព័រទីមួយ មានព័ត៌មានលម្អិតដែលរួមមាន៖ ឈ្មោះរបស់អ្នកផ្ដល់សម្ភាសន៍ អាយុ អាសយដ្ឋាន និងកាលបរិច្ឆេទនៃកិច្ចសម្ភាសន៍។ ចម្លើយនេះ ត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿង ក្នុងពេលធ្វើការស៊ើបសួរតាមផ្លូវតុលាការតាមសំណើសុំរបស់ ក.ស.ព។

១៨០. ឯកសារដែលមានចំណងជើងថា *ចម្លើយរបស់ វ៉ាន់ រិទ្ធ*[457] មានកិច្ចសម្ភាសន៍មួយដែលបានធ្វើឡើងដោយ Steve Heder ដែលជាអ្នកកាសែតមានបទពិសោធន៍ច្រើនឆ្នាំ ជាប្រវត្តិវិទូ និងជាអតីតអ្នកផ្ដល់ប្រឹក្សារបស់ ក.ស.ច.ស[458]។ ការិយាល័យសហព្រះរាជអាជ្ញាបានទទួលឯកសារនេះពីអ្នកនិពន្ធ ហើយឯកសារនេះអាចរកបាននៅក្នុងឃ្លាំងផ្ទុកឯកសាររួម (Shared Material Drive)។ ចម្លើយរបស់សម្ដេចនរោត្ដមសីហនុ គឺជាចម្លើយដែលមានមួយទំព័រ និងត្រូវបានកត់ត្រាជាបុរសទីមួយ[459]។ ច្បាប់ដើមនៃឯកសារជាភាសាបារាំង គឺមានការចុះហត្ថលេខា។ ចម្លើយនេះត្រូវបានទទួលក្នុងពេលធ្វើការស៊ើបអង្កេតបឋមដោយ ក.ស.ព និងត្រូវបានភ្ជាប់ជាមួយនឹងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ។ ឯកសារសំខាន់ចំនួនពីរ រួមមាន ចម្លើយរបស់ ប៉ុល ពត និងសាក្សីឈ្មោះ ឡុង នរិន្ទ[460]។ ឯកសារទាំងពីរនេះត្រូវបានដាក់នៅក្នុងសំណុំរឿងតាមសំណើរបស់ ក.ស.ព ក្នុងពេលធ្វើការស៊ើបសួរតាមផ្លូវតុលាការ។

## ២៦. កំណត់ហេតុបាលាយលក្ខណ៍អក្សរ

[455] D366/7.1.503, D366/7.1.503/Corr-1 (ឯកសារ 915); IS 10.18 (ឯកសារ 925); D366/7.1.584 (ឯកសារ 917); D224.106 (ឯកសារ 923) និង ឯកសារ *ចម្លើយថ្មីរបស់ វ៉ាន់ រិត* (ឯកសារ 922)។

[456] D224.106 (ឯកសារ 923)។

[457] IS 20.35 (ឯកសារ 919)។

[458] IS 20.12 (ឯកសារ 31); IS 20.6, D29/I (ឯកសារ 35); IS 20.7 (ឯកសារ 37); IS 20.7 (ឯកសារ 38)។

[459] IS 10.18 (ឯកសារ 925)។

[460] D366/7.1.584 (ឯកសារ 917) និង D366/7.1.503 (ឯកសារ 915)។

១៨១. មានឯកសារចំនួន៥០ នៅក្នុងបញ្ជីឯកសារដែលត្រូវបានចាត់ទុកថាជា "កំណត់ហេតុជាលាយលក្ខណ៍អក្សរ"[461]។ ឯកសារប្រភេទនេះ ជាកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សីដែលត្រូវបានរៀបចំឡើងដោយ ក.ស.ច.ស និងអាជ្ញាធរនគរបាលបារាំង។

១៨២. លក្ខណៈសម្គាល់សំខាន់ៗផ្នែកខាងក្នុងឯកសារទាំងនេះ ដោយឡែករួមមាន ប្រភព និងលក្ខណៈពិសេសផ្លូវការ ដូចជាស្នាមមេដៃ និង/ឬ អនុលោមទៅតាមវិធានផ្ទៃក្នុង និងមានបោះត្រាផ្លូវការរបស់តុលាការដែលបង្ហាញនូវភ័ស្តុតាងដែលអាចជឿជាក់បានតាំងពីដំបូង។

១៨៣. ក្នុងចំណោមកំណត់ហេតុជាលាយលក្ខណ៍អក្សរចំនួន៥០ មានកំណត់ហេតុផ្លូវការចំនួន៤៦ ត្រូវបានរៀបចំដោយ ក.ស.ច.ស ស្តីពីការផ្តល់ចម្លើយរបស់សាក្សី/ដើមបណ្តឹងរដ្ឋប្បវេណី[462]។ បន្ទាប់ពីចម្លើយត្រូវបានអានឲ្យសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីស្តាប់។ ឯកសារទាំងនោះត្រូវបានផ្តិតមេដៃ ឬចុះហត្ថលេខាដោយសាក្សី/ដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៥៥(៧) នៃវិធានផ្ទៃក្នុង និងមានចុះហត្ថលេខាបន្ថែមទៀតដោយមន្ត្រីស៊ើបអង្កេតនៃ ក.ស.ច.ស។ កំណត់ហេតុទាំងអស់ក៏មានការចុះហត្ថលេខាពីមន្ត្រីបកប្រែដែរ លើកលែងតែកំណត់ហេតុចំនួន៩ ប៉ុណ្ណោះ[463]។ នៅទំព័រទី១ នៃឯកសារទាំងនេះ មានបោះត្រាផ្លូវការរបស់តុលាការ ដែលបង្ហាញថាជាឯកសារសំណៅដើមរបស់តុលាការ។

---

[461] ឯកសារ 929-978 នៅក្នុងបញ្ជីឯកសារ។

[462] D200/9 (ឯកសារ 948); D199/22 (ឯកសារ 953); D143 (ឯកសារ 945); D107/3 (ឯកសារ 140); D166/177 (ឯកសារ 955); D232/9 (ឯកសារ 962); D232/59, D232/59/Corr-1, D232/59/Corr-2 (ឯកសារ 970); D233/9, D233/9/Corr-1 (ឯកសារ 967); D89 (ឯកសារ 938); D91/25 (ឯកសារ 935); D91/10, D91/10/Corr-1 (ឯកសារ 930); D91/3 (ឯកសារ 929); D91/26 (ឯកសារ 936); D166/159 (ឯកសារ 949); D232/8 (ឯកសារ 961); D208/3 (ឯកសារ 956); D246/6 (ឯកសារ 964); D166/176 (ឯកសារ 954); D232/53 (ឯកសារ 968); D247/1, D247/1/Corr-1 (ឯកសារ 969); D234/16 (ឯកសារ 973); D91/15 (ឯកសារ 933); D246/9 (ឯកសារ 965); D369/19 (ឯកសារ 977); D279/3 (ឯកសារ 966); D91/22, D91/22/Corr-1 (ឯកសារ 934); D232/14 (ឯកសារ 963); D200/3 (ឯកសារ 942); D147 (ឯកសារ 947); D234/15 (ឯកសារ 972); D91/21 (ឯកសារ 932); D91/14 (ឯកសារ 931); D279/7, D279/7/Corr-1, D279/7/Corr-2, D279/7/Corr-3 (ឯកសារ 975); D144 (ឯកសារ 946); D200/4 (ឯកសារ 944); D279/6, D279/6/Corr-1, D279/6/Corr-2, D279/6/Corr-3 (ឯកសារ 974) ; D234/8, D234/8/Corr-1 (ឯកសារ 960); D369/36 (ឯកសារ 978); D166/166, D166/166/Corr-1, D166/166/Corr-2 (ឯកសារ 950); D166/183 (ឯកសារ 959); D234/4, D234/4/Corr-1, D234/4/Corr-2 (ឯកសារ 957); D233/2 (ឯកសារ 958); D94/4, D94/4/Corr-1 (ឯកសារ 937); D125/160 (ឯកសារ 941); D369/4 (ឯកសារ 976)។

[463] D234/8, D234/8/Corr-1 (ឯកសារ 960); D369/36 (ឯកសារ 978); D166/166, D166/166/Corr-1, D166/166/Corr-2 (ឯកសារ 950); D166/183 (ឯកសារ 959); D234/4, D234/4/Corr-1, D234/4/Corr-2 (ឯកសារ 957); D233/2 (ឯកសារ 958); D94/4, D94/4/Corr-1 (ឯកសារ 937); D125/160 (ឯកសារ 941); D369/4 (ឯកសារ 976)។

១៨៤. ក៏មានកំណត់ហេតុជាលាយលក្ខណ៍អក្សរចំនួន២ផងដែរ ដែលបានរៀបចំដោយមន្ត្រីនគរបាលបារាំងនៃផ្នែកស៊ើបអង្កេតទីក្រុងប៉ារីស៍ ដែលធ្វើជាកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីដែលបានស្បថរួចហើយ[464]។ ឯកសារទាំងនេះក៏បានចុះហត្ថលេខាផងដែរ ដោយសាក្សីដែលពាក់ព័ន្ធ អនុលោមតាមវិធាន ៥៥(៧) នៃវិធានផ្ទៃក្នុង និងដោយមន្ត្រីនគរបាលដែលពាក់ព័ន្ធផងដែរ ដែលបង្ហាញថាឯកសារទាំងពីរនេះក៏ជាកំណត់ហេតុផ្លូវការដែរ។ ភាពស្របគ្នាដូចជា ពុម្ពអក្សរ និងសណ្ឋានរបស់ឯកសារទាំងនេះ បង្ហាញជាភ័ស្តុតាងបន្ថែមទៀតថា វាជាកំណត់ហេតុផ្លូវការ។ ឯកសារនីមួយមានចំណងជើងថា *ដីកាចាត់ឱ្យស៊ើបសួរជំនួស កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី* ស្ថិតនៅខាងលើផ្នែកខាងស្តាំទំព័រទី១។ នៅផ្នែកខាងឆ្វេង មានប្រអប់មួយដែលបង្ហាញពីព័ត៌មានរបស់មន្ត្រីនគរបាលស៊ើបអង្កេត រួមមាន អាសយដ្ឋាន ទូរស័ព្ទសម្រាប់ទំនាក់ទំនង និងឆ្នាំ រួមទាំង លេខសម្គាល់ដទៃទៀត (ឧ. លេខកូដអង្គភាព)។ ជាការបន្ថែម ទោះបីឯកសារទាំងនេះមិនត្រូវបានរៀបចំដោយ ក.ស.ច.ស ក៏ដោយ ក៏វាបោះមានត្រា ចុះហត្ថលេខា និងចុះកាលបរិច្ឆេទ និងមានការបញ្ជាក់ដោយសំណេរថា "ចម្លងតាមច្បាប់ដើម" ដែរ។

១៨៥. ចុងក្រោយ ឯកសារ D232/59.1 (ឯកសារ 971) គឺជាដ្យាក្រាមមួយ ដែលបានរៀបចំដោយសាក្សីឈ្មោះ [redacted] និងបានផ្តល់ជូន ក.ស.ច.ស។ ឯកសារនេះមានភ្ជាប់ជាមួយនឹងកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សីរូបនេះ[465] និងមានចុះកាលបរិច្ឆេទដដែល និងត្រូវបានចុះហត្ថលេខាដោយសាក្សី និងមន្ត្រីស៊ើបអង្កេតពាក់ព័ន្ធ។ ស្រដៀងគ្នាដែរ ឯកសារ D200/3.8 (ឯកសារ 943) គឺជាតារាងមួយដែលបានផ្តល់ជូន ក.ស.ច.ស ដោយសាក្សីឈ្មោះ [redacted] មានចំនួន២ទំព័រ នៅផ្នែកខាងក្រោយនៃកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សីរូបនេះ[466]។ សាក្សីរូបនេះក៏បានចុះហត្ថលេខាលើឯកសារនេះដែរ៕

## III. **ដំណោះស្រាយដែលបានស្នើសុំ**

១៨៦. សហព្រះរាជអាជ្ញា សូមស្នើឱ្យអង្គជំនុំជម្រះសាលាដំបូង មេត្តា៖

(ក) យកចិត្តទុកដាក់អំពីសូចនាអំពីភាពដែលគួរឱ្យជឿទុកចិត្តបាន នៅពេលធ្វើការពិនិត្យពិចារណាទៅលើការជំទាស់នានារបស់មេធាវីការពារក្តី ទៅនឹងឯកសារចំនួន៩៧៨ ដែលនៅក្នុងបញ្ជីឯកសារ; ហើយ

[464] D199/18 (ឯកសារ 951); D199/20 (ឯកសារ 952)។

[465] D232/59 (ឯកសារ 970)។

[466] D200/9 (ឯកសារ 948)។

(ខ) បន្ទាប់មកទៀត សូមទទួលយកនូវឯកសារទាំង៩៧៨ ដែលមាននៅក្នុងបញ្ជីឯកសារនេះ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១១ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | |